ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- អ្នកដែលមានឥទ្ធិពលធំធេង
- ការពិនិត្យមើលទៅលើគម្រោងនៃការសិក្សាអំពីប្រវត្តិសាស្ត្រ...

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ ៨៨ ខែមេសា ឆ្នាំ២០០៧

ស្វែងរកការពិត
លេខ៨៨ ខែមេសា ឆ្នាំ២០០៧

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ សំបុត្រ ៖ អ្នកដែលមានឥទ្ធិពលធំធេង ..........១

**ផ្នែកឯកសារ**

◆ វិលត្រឡប់ទៅកសាងជីវភាពថ្មី ..........២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ គុកខ្មែរក្រហម ..........៩
◆ មានសំណាងរួចផុតពីសេចក្ដីស្លាប់ ..........១៥
◆ ព្រះតេជគុណ ទុំ អោក ៖ នៅតែចងចាំរឿងខ្មែរក្រហម ..........១៧
◆ បដិវត្តន៍ទៅរកភាពឯកោ ..........១៨
◆ ការទស្សនាសារជាថ្មីនៅទីតាំងប្រល័យពូជសាសន៍ ..........២១
◆ ជនរងគ្រោះនៅតែចងចាំ ..........២៥
◆ អ្នកបើករថយន្តដឹកអង្ករ ..........២៧

**ផ្នែកច្បាប់**

◆ យន្តការសាលាក្ដីខ្មែរក្រហម ៖ វិធាននីតិវិធី និង វិធានភ័ស្តុតាង ..........២៩
◆ វិធានសម្រាប់ការការពារក្ដី ៖ ការបោះមួយជំហានថយក្រោយ ..........៣៩

**វេទិកាពិភាក្សាសាធារណៈ**

◆ ការសិក្សាអំពីទម្រង់ប្រព័ន្ធសន្តិសុខខ្មែរក្រហម ..........៤២
◆ ការពិនិត្យមើលទៅលើគម្រោងនៃការសិក្សាអំពីប្រវត្តិសាស្ត្រ ..........៤៥

**ទំព័រស្រាវជ្រាវរកក្រួសារ**

◆ ប្រវត្តិដ៏សែនកម្សត់របស់ខ្ញុំ ..........៥៣



យុវសិស្សឡើងសួរសំណួរនៅក្នុងអគារសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា



សូ ហ្វារីណា ចែកសៀវភៅកត់ត្រាដល់សិស្សនិងនិស្សិតអ៊ីស្លាម

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ ៖** ផេង ពង្សរ៉ាស៊ី, នង ឧត្តតារា, ហ៊ិន សុផានី, ឆាយ ណារឿន, កែវ ដាស៊ីល, ខេតទ្រីណា អេនឌីសុន, ធារី គ្រលីអ័រ, អ៊ីសាក ថាប៊័រ, ម៉ាក ក្លេមិន, លឹម ស្រីផល្លា **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** ណយ សុផារី, ឌី ខាំបូលី **អ្នកបកប្រែ ៖** បាន់ ចំរើន, ប៉ាន់ ស៊ីម៉ាឡា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក ៖** លី សុផល **ក្រាហ្វិកកុំព្យូទ័រ ៖** គឹម សុវណ្ណដានី **គ្រប់គ្រងការចែកផ្សាយ ៖** រ័ត្ន តារាពិដោរ Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ :*

# អ្នកដែលមានឥទ្ធិពលធំធេង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការ១០ឆ្នាំមកហើយ ក្នុងការនាំយកមេដឹកនាំខ្មែរក្រហមនៃរបបដ៏ឃោរឃៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិឆ្ពោះទៅរកយុត្តិធម៌ ។ មិនដល់៤ឆ្នាំផង ខ្មែរក្រហមបានធ្វើឲ្យប្រទេសជាតិធ្លាក់ចុះដុនដាប ។ មួយភាគបួននៃប្រជាជនសរុបបានបាត់បង់ជីវិត ហើយអ្នករស់រានមានជីវិតភាគច្រើនជាស្ត្រីមេម៉ាយនិងកុមារប្រឹងប្រែងបន្តជីវភាពលើទឹកដីរបស់ប្រទេសដែលត្រូវបំផ្លាញទាំងស្រុងលើវិស័យសេដ្ឋកិច្ចនយោបាយ និងផ្លូវអារម្មណ៍ ។

យ៉ាងណាមិញ នៅពេលដែលខ្មែរក្រហមដួលរលំនៅក្នុងឆ្នាំ១៩៧៩ ប្រទេសកម្ពុជាមិនទាន់បានសុខសន្តិភាពនៅឡើយទេ សូម្បីតែក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ក្រោមជំនួយអង្គការសហប្រជាជាតិក៏ដោយ ។ ខ្មែរក្រហមបន្តសង្គ្រាមវាយឆ្មក់រហូតដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ ។ ការវាយប្រហារនេះរារាំងមិនឲ្យប្រទេសកម្ពុជារីកលូតលាស់ទៅមុខនិងបំភិតបំភ័យប្រជាជននៅតាមជនបទ ។

ហេតុការណ៍នេះបានបន្ថយល្បឿននៃការស្តាបនាជាតិឡើងវិញ ហើយរបួសស្នាមបន្សល់ទុកពីរបបប្រល័យពូជសាសន៍នៅតែដក់ជាប់ជាមួយនឹងប្រជាជនកម្ពុជា ។ អ្វីដែលប្រជាជនកម្ពុជាទន្ទឹងរង់ចាំ គឺឱកាសឃើញមេដឹកនាំខ្មែរក្រហមត្រូវនាំយកទៅកាត់ទោស តាមផ្លូវច្បាប់ឲ្យសមស្របនឹងអំពើសាហាវឃោរឃៅដែលខ្លួនបានប្រព្រឹត្ត ។ ការទន្ទឹងរង់ចាំមួយទៀតគឺឱកាសផ្សះផ្សាជាមួយអ្នកឯទៀតក៏ដូចជាផ្សះផ្សាខ្លួនឯងផ្ទាល់ ។ សព្វថ្ងៃជនដៃដល់នៃរបបខ្មែរក្រហម និងជនរងគ្រោះកំពុងរស់នៅភូមិផងរបងជាមួយគ្នា ខំព្យាយាមសម្របខ្លួនទាំងការទើសទាស់ដើម្បីកុំឲ្យកើតវិវាទ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងធ្វើកិច្ចការមួយដើម្បីផ្តល់ឲ្យជនរងគ្រោះកម្ពុជានូវសេចក្តីថ្លៃថ្នូរ ទំនុកចិត្ត ការគោរព និងដំណឹងទាក់ទិននឹងស្ថានភាពនយោបាយក្នុងប្រទេសតាមរយៈការអប់រំ និងកម្មវិធីចុះផ្សព្វផ្សាយផ្ទាល់តាមភូមិស្រុកនានា ។ ទន្ទឹមនឹងនោះ យើងបានធ្វើកិច្ចការដែលជំរុញឲ្យមានតុលាការមួយដែលលេចចេញជាលទ្ធផលផ្លែផ្កា ។ សវនាការគ្រោងនឹងកើតនៅចុងឆ្នាំនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាលទ្ធផលលេចចេញពីស្នាដៃរបស់បុគ្គលជាច្រើននាក់ ។ ក្នុងចំណោមនោះ អ្នកដែល



រូបថតកុមារកុមារីក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៩

សំខាន់គឺ បុគ្គលិកកូនខ្មែរដ៏ឧស្សាហ៍ព្យាយាម ដែលជាក្មេងជំនាន់ក្រោយនៃរបបវាលពិឃាត ។ បុគ្គលិកវ័យក្មេងទាំងអស់បានអភិវឌ្ឍសមត្ថភាពខ្លួនឯងតាមរយៈបទពិសោធន៍ការងារ និងកំពុងត្រៀមខ្លួនដឹកនាំសង្គមជំនាន់ក្រោយ ។

យើងក៏មានការដឹងគុណចំពោះសប្បុរសជនមកពីប្រទេសនានាជុំវិញពិភពលោក ដែលបានចំណាយពេលវេលា និងកម្លាំងកាយចិត្តជួយយើងដោយក្តីសប្បុរស ។ ប្រការសំខាន់គឺអ្នកទាំងអស់ជឿជាក់លើកិច្ចការដែលយើងកំពុងធ្វើ ។ អស់រយៈកាលជាច្រើនឆ្នាំ សប្បុរសជនទាំងនោះបានជួយយើងក្នុងដំណើរការស្វែងរកយុត្តិធម៌ពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា និងការថែរក្សាការចងចាំនៃប្រវត្តិសាស្ត្រទំនើបរបស់ប្រទេសយើង ។

សប្បុរសជនទាំងនោះរួមមានអគ្គរដ្ឋទូតជាច្រើន និងអ្នកសារព័ត៌មានទាំងឡាយដែលសរសេរអត្ថបទមួយចំនួនជះឥទ្ធិពលខ្លាំងដល់រចនាសម្ព័ន្ធតុលាការ ។ ជាងនេះទៅទៀត យើងមានការដឹងគុណអនេកចំពោះអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ អ្នកជំនាញការផ្នែកច្បាប់ សិល្បករ សិស្សានុសិស្ស និងប្រជាពលរដ្ឋដែលសុទ្ធសឹងតែធ្លាប់បានជួយធ្វើកិច្ចការមជ្ឈមណ្ឌលយើង ។ ទន្ទឹមនឹងនោះយើងក៏សូមសម្តែងការដឹងគុណចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលតែងតែគាំទ្រយើងជានិច្ច ។

យ៉ាងណាមិញនៅទីបំផុត អ្នកដែលមានឥទ្ធិពលធំធេងលើប្រវត្តិសាស្ត្រកម្ពុជាគឺប្រជាជនខ្មែរជិតពីរលាននាក់ដែលបានបាត់បង់ជីវិតក្នុងកណ្តាប់ដៃខ្មែរក្រហម និងអ្នកដែលនៅរស់រានមានជីវិតប្រមាណ៦លាននាក់ទៀតដែលបានឆ្លងកាត់ការឈឺចាប់ក្នុងរបបនោះ ។

ប្រជាជនទូទាំងប្រទេសបានរៀបរាប់រឿងរ៉ាវជីវិតរបស់ខ្លួនប្រាប់យើង និងផ្តល់ជូនមជ្ឈមណ្ឌលនូវរូបថតមនុស្សជាទីស្រឡាញ់ដែលបានបាត់បង់ជីវិតដោយសារខ្មែរក្រហម ។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានតស៊ូពុះពារអស់រយៈកាលជាង៣០ឆ្នាំដើម្បីស្តារឡើងវិញនូវមនុស្សជាតិ ស្វែងរកយុត្តិធម៌ និងផ្សះផ្សាជាមួយជនដៃដល់ក៏ដូចជាខ្លួនឯងផ្ទាល់ដែលជាជនរងគ្រោះ ។ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងជួយឲ្យជនរងគ្រោះក្រឡេកមើលអតីតកាលរបស់ប្រទេសខ្លួនឲ្យបានច្បាស់ និងបញ្ចប់ដំណើរការផ្សះផ្សា ។

**ឆាំង យុ**

# មិលត្រឡប់ទៅកសាងជីវភាពថ្មី

ភូមិមួយ ក្នុងឃុំយុទ្ធសាមគ្គី ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ស្ថិតនៅចម្ងាយប្រហែល២០គីឡូម៉ែត្រពីផ្លូវជាតិលេខ៥ ។ នេះជាភូមិកំណើតរបស់មីង ឈន សម្បត្តិ ដែលជាកសិករប្រកបរបរធ្វើស្រែចម្ការដូចប្រជាជនដទៃនៅក្នុងភូមិដែរ ។ ក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើដំណើរទៅដល់ភូមិកំណើតរបស់មីង ដើម្បីជួបសម្ភាសពីដំណើរជីវិតរបស់មីងតាំងពីតូចរហូតមកដល់បច្ចុប្បន្ន ។ ក៏ប៉ុន្តែពេលក្រុមយើងទៅដល់កូនស្រីរបស់មីងបានប្រាប់ថា មីងបានចេញទៅផ្សារតាំងពីព្រឹកដើម្បីទិញសម្ភារមួយចំនួននិងផ្លែឈើដើម្បីរៀបចំទទួលទេវតាឆ្នាំថ្មី ។ ឆ្លៀតឱកាសនេះយើងបានទៅជួបសម្ភាសមីងម្នាក់ទៀតដែលរស់នៅភូមិក្បែរគ្នា ហើយនៅវេលាម៉ោង៣រសៀលបានត្រឡប់មកជួបមីងម្តងទៀត ។ ហាក់ដូចត្រៀមលក្ខណៈរួចជាស្រេច ពេលរថយន្តរបស់យើងចតនៅមុខផ្ទះ មីងដើរយ៉ាងប្រញាប់ប្រញាល់ពីផ្ទះកូនស្រី ដែលមានចៅប្រុសនៅនឹងចង្កេះផង សំដៅមកស្វាគមន៍យើងនិងរកកន្ទេលអង្គុយដ៏សមរម្យ ។ បន្ទាប់ពីបានជួបសន្ទនាគ្នាអស់ពេលជិតបីម៉ោងទើបយើងដឹងថា មីង សម្បត្តិ បានឆ្លងកាត់នូវឧបសគ្គជាច្រើនទម្រាំបានមកកសាងជីវិតថ្មីនៅលើទឹកដីកំណើតខ្លួនវិញ ។

សម្បត្តិ កើតក្នុងគ្រួសារកសិករមួយដែលមានបងប្អូន៨នាក់ និងជាកូនច្បងនៅក្នុងគ្រួសារ ។ កាលពីក្មេង សម្បត្តិ បានចូលរៀនត្រឹមថ្នាក់ទី១១ (ថ្នាក់ពីសង្គមចាស់) ហើយអាចអាននិងសរសេរបានបន្តិចបន្តួចប៉ុណ្ណោះ ។ សម្បត្តិ បានឈប់រៀនបន្ទាប់

ពីរដ្ឋប្រហារឆ្នាំ១៩៧០ ។ នៅពេលនោះ អ្នកភូមិទាំងអស់រួមទាំងគ្រួសាររបស់គាត់ត្រូវរស់នៅក្នុងសភាពច្របូកច្របល់ដោយសារតែការប្រទាញប្រទង់គ្នារវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម ។ ខ្មែរក្រហមបានបំពាក់បំប៉នគោលនយោបាយដល់ប្រជាជនឲ្យក្រោកឈរប្រឆាំងនឹងរបប លន់ នល់ និងធ្វើការជ្រើសរើសយុវជនមួយចំនួនទៅបម្រើការងារនៅក្នុងតំបន់ដែលកាន់កាប់ដោយខ្មែរក្រហម ។

## ការងារនៅមន្ទីរប-៥

មន្ទីរប-៥ គឺជាឃ្លាំងផ្ទុកស្បៀងអាហារនិងសម្ភារសឹកដ៏ធំរបស់ខ្មែរក្រហម ដែលមានទីតាំងនៅក្នុងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង អ្នកគ្រប់គ្រងទូទៅនៅក្នុងមន្ទីរឈ្មោះ បុល ។ ត្រីសាច់មួយចំនួនដឹកមកពីខេត្តកំពង់ចាម និងតំបន់ក្បែរនោះ គ្រឿងឧបភោគទាំងអស់នេះទុកសម្រាប់ផ្គត់ផ្គង់កម្មាភិបាលធំៗ ដូចជា នួន ជា និង ខៀវ សំផន ដែលរស់នៅនិងចេញចូលធ្វើការងារនៅមន្ទីរនោះ ។


ឈន សម្បត្តិ និងស្វាមី ឈួន ឆិល ឃុំយុទ្ធសាមគ្គី ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ

នៅចុងឆ្នាំ១៩៧៣ សម្បត្តិ ត្រូវបានជ្រើសរើសឲ្យទៅធ្វើការនៅមន្ទីរនេះ ដោយសារតែម្ដាយរបស់គាត់ជាប់សាច់ញាតិជាមួយប្រពន្ធ នួន ជា ។ ក្មេងជំទង់ៗបួនប្រាំនាក់ទៀតដែលប្រជាជនមូលដ្ឋាននៅទីនោះ ក៏ត្រូវបានជ្រើសរើសទៅធ្វើការនៅមន្ទីរប-៥ដែរ ។ ភាគច្រើនអ្នកដែលត្រូវបានជ្រើសរើសឲ្យទៅធ្វើការនៅមន្ទីរនេះគឺមានអាយុពី១៤ឬ១៥ឆ្នាំ ដែលត្រូវបានបង្ហាត់បង្រៀននិងអប់រំមនោគមវិជ្ជា ។ សម្បត្តិ ស្ថិតនៅក្នុងក្រុមមួយដែលមានគ្នា៣០នាក់ និងមាននាទីជាអ្នកដាក់បាយឲ្យជ្រូក យាមឃ្លាំង និងធ្វើស្រែចម្ការ ។ ការហូបចុកនៅទីនោះមានលក្ខណៈប្រសើរដោយសារតែជាកន្លែងមួយផ្គត់ផ្គង់អាហារដ៏ធំរបស់ខ្មែរក្រហម ។ សម្បត្តិ ធ្លាប់បានហូបអាហារល្អៗដូចជាត្រីខកំប៉ុង ត្រីដាត់ និងសាច់ជៀតជាដើម ។ ក្រៅពីការបំពេញការងារនេះ សម្បត្តិ និងក្មេងៗដទៃទៀតបានទទួលការបង្ហាត់បង្រៀនឲ្យចេះអានអក្សររយៈពេលប្រហែលមួយឆ្នាំ ។ សម្បត្តិ អាចអាននិងសរសេរបានប្រសើរជាងមុន ។ ទោះជាយ៉ាងនេះក្ដី មេរៀនមួយចំនួនដែលគាត់បានរៀនគឺជាការអប់រំផ្នែកនយោបាយនៃការតស៊ូបដិវត្តន៍ ។

សម្បត្តិ កម្របានជួបនិងឃើញមេដឹកនាំជាន់ខ្ពស់ទាំងនោះណាស់ ដោយសារអ្នកទាំងនោះមកធ្វើការនិងជួបប្រជុំគ្នាតែពេលយប់ ។

នៅដើមឆ្នាំ១៩៧៥ នៅពេលដែលការវាយលុកចូលទីក្រុងភ្នំពេញកាន់តែមានសភាពខ្លាំងក្លា សម្បត្តិ និងមិត្តភក្តិ១០នាក់ត្រូវបានផ្លាស់ចេញពីមន្ទីរប-៥មកធ្វើការនៅមន្ទីរថ្មីក្បែរភ្នំឧដុង្គ ក្នុងខេត្តកំពង់ស្ពឺ ។ នៅទីនោះ សម្បត្តិ បានឃើញសាកសពហើមស្អុយរលួយនៅពាសពេញផ្លូវ និងឮសូរសំឡេងគ្រាប់ផ្លោងយ៉ាងខ្លាំងនៅមិនឆ្ងាយប៉ុន្មានពីកន្លែងធ្វើការថ្មីនេះ ។ ក្រោយមកនៅមន្ទីរប-៥ ខ្វះអ្នកមើលកូនៗរបស់កម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហម សម្បត្តិ និងមិត្តភក្តិ៣នាក់ទៀតត្រូវបានដកបញ្ជូនត្រឡប់មកនៅមន្ទីរប-៥វិញ ដើម្បីមើលថែក្មេងៗទាំងអស់នោះ ។ សម្បត្តិ និងមិត្តភក្តិបីនាក់ មានតួនាទីមើលថែកូនរបស់ នួន ជា ពីរនាក់ (កូនស្រីឈ្មោះ ឡេង និងកូនប្រុសឈ្មោះ សាយ) និងកូន ខៀវ សំផន ម្នាក់ដែលមានឈ្មោះហៅក្រៅថា “អាក្រូច” ។

សម្បត្តិ ភាគច្រើនមើលថែកូនរបស់ ខៀវ សំផន ពីព្រោះកូននោះតូចជាងគេ ដែលមានអាយុប្រហែលបីខែ ។ យូរៗទើបឃើញប្រពន្ធរបស់ ខៀវ សំផន មកមើលកូនម្ដង ប៉ុន្តែយ៉ាងណាក៏ដោយ សម្បត្តិ មិនដែលមានឱកាសនាំក្មេងៗទៅជួប នួន ជា ឬ

ខៀវ សំផន ទេ ហើយ នួន ជា និង ខៀវ សំផន ក៏មិនដែលយកចិត្តទុកដាក់ពីរឿងកូនដែរ ដោយហេតុថា អ្នកទាំងពីរជាប់រវល់ខ្លាំងក្នុងការងារវាយសម្រុកចូលទីក្រុងភ្នំពេញ ។ ប្រហែលជាមួយឬពីរសប្តាហ៍ សម្បត្តិ បានឃើញអ្នកទាំងពីរមកសម្រាកក្នុងមន្ទីរម្តង ។ ជីវិតរស់នៅក្នុងមន្ទីរប-៥ ទោះជាបានហូបចុកគ្រប់គ្រាន់ក្តី ក៏ សម្បត្តិ មិនធ្លាប់បានទៅលេងឪពុកម្តាយបងប្អូននៅឯភូមិដែរ ។ សម្បត្តិ បានទទួលដំណឹងអំពីឪពុកម្តាយតែតាមរយៈមីងថ្លៃរបស់ខ្លួនដែលជាប្រពន្ធរបស់ នួន ជា ប៉ុណ្ណោះដែលមានសិទ្ធិចេញទៅក្រៅជួបសាច់ញាតិបងប្អូននិងអ្នកភូមិ ។ សម្បត្តិ ធ្លាប់ស្នើសុំប្រធានមន្ទីរមកលេងផ្ទះដែរ ប៉ុន្តែសំណើទាំងនេះត្រូវបានបដិសេធ ហើយគាត់ត្រូវបានប្រាប់ថា «មិនអាចទៅបានទេ ព្រោះជាប់ភារកិច្ច» ។

បន្ទាប់ពីបែកទីក្រុងភ្នំពេញ នៅខែមេសា ឆ្នាំ១៩៧៥ នួន ជា និង ខៀវ សំផន បានទៅយកកូនត្រឡប់ទៅវិញ ចំណែក សម្បត្តិ ត្រូវបានបញ្ជូនឲ្យទៅធ្វើស្រែនៅក្បែរភ្នំខដុក្ក ។ ការរស់នៅកន្លែងថ្មីនេះ សម្បត្តិ មានការលំបាកច្រើនជាងការរស់នៅមន្ទីរប-៥ សូម្បីតែត្រីសាច់ក៏មិនសម្បូរដែរ ពេលគឺមានតែសម្លទឹកដែលមានបន្លែតែស្លឹកបាសនិងផ្លែត្នោត និងស្លឹកឈើព្រៃប៉ុណ្ណោះ ។

## ការងារចិញ្ចឹមត្រីនៅប្រាំងចំរេះ

រស់នៅមន្ទីរក្បែរភ្នំខដុក្កបានជិតមួយឆ្នាំ សម្បត្តិ ត្រូវបានបញ្ជូនតាមរថយន្តឲ្យមកធ្វើការនៅប្រាំងចំរេះ ជាយក្រុងភ្នំពេញ ដែលនៅទីនោះមានស្រះជាច្រើនសម្រាប់ចិញ្ចឹមត្រីប្រភេទផ្សេងៗគ្នា ដូចជា ត្រីឆ្តោ ត្រីប្រា និងត្រីដំរី ។ សម្បត្តិ មានភារកិច្ចចិញ្ចឹមត្រី កន្ត្រប និងអណ្តើក ។ ទិន្នផលត្រីដែលបានមកត្រូវដឹកទៅចែកចាយគ្រប់មន្ទីរក្រសួងទាំងអស់នៅទីក្រុងភ្នំពេញ ។ ក្រៅពីការចិញ្ចឹមត្រី សម្បត្តិ មានភារកិច្ចដាំបន្លែបន្ទាប់បន្សំដូចជា ត្រប់ ល្ហុង ស្ពៃ និងត្រកួនជាដើម ។ ការរស់នៅទីនោះមានភាពងាយស្រួលច្រើន ដោយសារគាត់បានហូបគ្រប់គ្រាន់ ។ ទោះជាយ៉ាងនេះក៏ដោយ ក៏គាត់មិនហ៊ានយកត្រីឬបេះបន្លែមកស្លហូបតាមចិត្តបានដែរ ។ សម្បត្តិ បានជួប នួន ជា និង ខៀវ សំផន ម្តងទៀត ក្នុងខណៈពេលដែលអ្នកទាំងពីរទៅធ្វើទស្សនកិច្ចនិងត្រួតពិនិត្យស្រះចិញ្ចឹមត្រី ។

ក្នុងរយៈពេលនោះដែរ សម្បត្តិ ធ្លាប់បានចូលរួមវគ្គរៀនបំពាក់បំប៉ននយោបាយនៅសាលាបច្ចេកទេសភ្នំពេញ (បច្ចុប្បន្នជាវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាឬសាលាតិចណូ) រយៈពេលបីថ្ងៃ ។ វគ្គសិក្សានេះ លើកកម្ពស់អំពីការរីកចម្រើនរបស់ប្រទេសជាតិចាប់តាំងពីរំដោះបាន និងអប់រំ«ឲ្យបងប្អូនខិតខំធ្វើការ កុំជឿការចាក់រុករបស់ខ្មាំង» ។

## កម្មករសំណង់នៅបុរី១០០ខ្នង

ធ្វើការនៅប្រាំងចំរេះបានមួយរយៈ សម្បត្តិ ត្រូវបានបញ្ជូនឲ្យមកធ្វើកម្មករសំណង់នៅម្តុំបុរី១០០ខ្នង ។ ការងាររបស់ សម្បត្តិ គឺ«ក្រងដែកចាក់ជើងសសរ» ការរស់នៅទីនោះពិតជាមានការលំបាកជាខ្លាំងសម្រាប់ សម្បត្តិ ពីព្រោះគាត់ត្រូវធ្វើការងារធ្ងន់ៗដូចជាមនុស្សប្រុសដែរ ហើយរបបអាហារដែលគាត់ទទួលបានតិចតួច និងគ្មានជីវជាតិសម្រាប់ទ្រទ្រង់រាងកាយទៀតផង ។ ជាងនេះទៅទៀត សម្បត្តិ ធុញទ្រាន់នឹងការរៀនសូត្រនយោបាយនៅទីនោះណាស់ ។ ខ្មែរក្រហមច្រើនតែលើកពាក្យស្លោកមួយថា «គ្រុនញាក់ គ្រុនញ័រ គ្រុនត្រាក់ទ័រ គ្រុនឡាន គ្រុនបាយបាន គ្រុនសតិអារម្មណ៍ត្រូវយកទៅវៃចោល ។ អាណាឈឺអឺបន្តិចបន្តួចអត់បានទេ» ។ ក្នុងរយៈពេលមិនដល់មួយខែផងដោយមិនអាចទ្រាំទ្រនឹងការងារទាំងនេះបាន សម្បត្តិ បានលួចរត់ចេញពីទីនោះ ។

សម្បត្តិ នៅចាំបានថាពេលដែលគាត់លួចរត់នោះគឺនៅដើមឆ្នាំ១៩៧៨ ជាពេលដែលមានទឹកជន់យ៉ាងខ្លាំង ។ ទីក្រុងភ្នំពេញមួយភាគធំត្រូវជន់លេច ។ សម្បត្តិ បានបបួលក្មេងស្រីម្នាក់ដែលធ្វើនៅការដ្ឋានសំណង់ជាមួយហែលទឹកមកជាមួយគ្នានៅវេលាម៉ោងប្រហែល៤រសៀល ។ អ្នកទាំងពីរបានលួចចានដែកធំម្នាក់មួយដាក់ខោអាវក្នុងនោះ ហើយកាច់ស្លឹកឈើគ្របលើ ដោយបន្លំខ្លួនហែលបេះផ្កាកំផ្លោកនិងត្រកួន ។ សម្បត្តិ និងក្មេងស្រីម្នាក់នោះហែលទឹកអស់រយៈពេលជាច្រើនម៉ោង នៅទីបញ្ចប់ សម្បត្តិ មកដល់សាលាបច្ចេកទេសដែលគាត់ធ្លាប់មករៀនសូត្រវគ្គនយោបាយម្តង ។ ជាអកុសល ពេលអ្នកទាំងពីរឡើងពីទឹកអ្នកយាមនៅមន្ទីរក៏បានឃើញ ហើយស្រែកសួរថា «មកពីណាមិត្តនារី?» សម្បត្តិ និងក្មេងស្រី បានទូលចានដែកដើរសំដៅទៅរកអ្នកយាម

ហើយឆ្លើយតបយ៉ាងធម្មតាថា «ខ្ញុំមកពីបេះបន្លែ» ។ អ្នកយាមនោះមិនបានឆែកឆេរអ្វីទាំងអស់ ហើយអនុញ្ញាតឲ្យ សម្បត្តិ និងក្មេងស្រីចូលទៅក្នុងមន្ទីរ ។ សម្បត្តិ បន្តដំណើរទាំងក្នុងចិត្តភ័យរន្ធត់យ៉ាងខ្លាំង ពីព្រោះនឹកឃើញថា «ប្រាកដជាគេយកទៅវៃចោលហើយ មិនរស់ទេ» ។

ពេលចូលទៅដល់ក្នុងមន្ទីរ សម្បត្តិ បានដើរសំដៅទៅផ្ទះបាយ ។ អ្នកដាំស្លនៅចាំមុខ សម្បត្តិ ហើយក៏បានសួរថា «មិត្តឯងមកពីណា មិត្តឯងគេបញ្ជូនឲ្យទៅនៅនឹងហើយ ម៉េចក៏មិននៅប្រយ័ត្នគេថាខ្លាំង គេយកទៅវៃចោល» ។ សម្បត្តិ បានឆ្លើយទាំងក្នុងចិត្តភ័យក្តុកក្តួលថា «វៃចោលក៏វៃទៅ បើខ្ញុំមិនចេះនៅ» ។ ប៉ុន្មាននាទីក្រោយមក កម្មាភិបាលគ្រប់គ្រងមន្ទីរបានមកដល់ ហើយបានដដឹកសួរពីប្រវត្តិរូបរបស់គាត់ ។ ប្រធានមន្ទីរបាននិយាយថា «មិត្តឯងអីក៏ហ៊ានម៉្លេះ ប្រឆាំងនឹងអង្គការ អង្គការបញ្ជូនទៅហើយម៉េចក៏រត់មកវិញ» ។ កម្មាភិបាលមន្ទីរបានស្តីបន្ទោស សម្បត្តិ យ៉ាងច្រើនថា មិនចេះតស៊ូ មិនចេះលត់ដំ ។

ក្រោយពីសាកសួរប្រវត្តិរូបយ៉ាងយូរមក សម្បត្តិ បានប្រាប់ថាគាត់ជាក្មួយរបស់ នួន ជា ដូច្នេះបើឲ្យគាត់រស់នៅកន្លែងលំបាកគាត់មិនចេះរស់នៅទេ ។ ដោយព្រោះថាជាក្មួយរបស់ នួន ជា កម្មាភិបាលគ្រប់គ្រងនៅទីនោះមិនហ៊ានបញ្ជូន សម្បត្តិ ទៅណាទេ គ្រាន់តែយកទៅកសាងអប់រំនិងលត់ដំប៉ុណ្ណោះ ។ ជាងនេះទៅទៀត ប្រធានមន្ទីរបានធ្វើការស្រាវជ្រាវប្រវត្តិរូបយ៉ាងហ្មត់ចត់បំផុត មុននឹងអនុញ្ញាតឲ្យ សម្បត្តិ ស្នាក់នៅនិងធ្វើការនៅទីនោះ ។ សម្បត្តិ ស្នាក់នៅបណ្តោះអាសន្ននៅសាលាបច្ចេកទេសបានរយៈពេលកន្លះខែ គាត់ក៏ត្រូវបានបញ្ជូនទៅមន្ទីរបឹងកេងកង ។

## ការងារដឹកជញ្ជូនបន្លែផ្លែឈើនៅមន្ទីរបឹងកេងកង

សម្បត្តិ មកធ្វើការនៅមន្ទីរបឹងកេងកង ជាជាងកាត់ដេរនិងដឹកជញ្ជូនបន្លែផ្លែឈើដូចជា ដំឡូង ល្ពៅ ខ្នុរ ត្រីសាច់ និងអង្ករដាក់តាមមន្ទីរក្រសួងមួយចំនួននៅក្នុងទីក្រុងភ្នំពេញ ។ បន្លែផ្លែឈើទាំងនេះត្រូវបានដឹកមកតាមកប៉ាល់ធំៗពីខេត្តកំពង់ចាមមកស្តុកទុកនៅមាត់ទន្លេក្បែរព្រះបរមរាជវាំង ។ សម្បត្តិ និងក្រុមរបស់ខ្លួនប្រហែល៣០នាក់ ជាអ្នកទៅទទួលដឹកអីវ៉ាន់ទាំងអស់នេះពីច្រាំងទន្លេមកចែកចាយទៅតាមកន្លែងផ្សេងៗ ។ បន្លែត្រីសាច់និងអង្ករមួយចំនួនត្រូវបានដឹកមកដាក់ក្នុងផ្សារធំថ្មី ដែលជាផ្សារតែមួយគត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ផ្សារនេះត្រូវបានបើកលក់ទំនិញសម្រាប់តែអ្នកការទូតប៉ុណ្ណោះ ។ សម្បត្តិ ធ្លាប់ឃើញអ្នកការទូតមួយចំនួនដើរកំសាន្តក្នុងក្រុងនិងថតរូប ប៉ុន្តែគាត់មិនបានជួបនិយាយលេងទេ ។

ក្រៅពីនេះ សម្បត្តិ ក៏ធ្លាប់ដឹកម្ហូបអាហារនិងផ្លែឈើដាក់នៅព្រះបរមរាជវាំងដើម្បីផ្គត់ផ្គង់ សម្តេចព្រះនរោត្តម សីហនុ និងព្រះរាជវង្សានុវង្ស ដែលកំពុងជាប់ឃុំឃាំងនៅទីនោះ ក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្លែនិងគ្រឿងបរិភោគដែលគាត់បានដឹកនោះមាន អង្ករ ដំឡូងជ្វា និងដំឡូងមី ។ ចំណែកត្រីសាច់និងរបស់របរសំខាន់ៗមានក្រុមកម្មាភិបាលផ្សេងទៀតជាអ្នកទទួលខុសត្រូវ ។ សម្បត្តិ នៅចាំបានថា គាត់មិនដែលបានចូលដល់ខាងក្នុងព្រះបរមរាជវាំងទេ ពីព្រោះពេលគាត់ដឹកស្បៀងចូលដល់ខ្លោងទ្វារមុខម្តងៗមានចុងភៅរង់ចាំទទួលរួចជាស្រេច ។ ថ្ងៃមួយ ពេល សម្បត្តិ កំពុងតែជញ្ជូនបន្លែផ្លែឈើពីច្រាំងទន្លេ គាត់ក្រឡេកឃើញ សម្តេច សីហនុ និងព្រះមហេសី ដែលខ្មែរក្រហមដឹកតាមអូប័រកំពុងលំហែកម្សាន្តព្រះកាយតាមដងទន្លេ ។ អូប័រនោះបើកដល់ត្រឹមស្ពានជ្រោយចង្វារ ហើយក៏ត្រឡប់មកវិញ ។ សម្បត្តិ នៅចងចាំយ៉ាងច្បាស់ពីទិដ្ឋភាពជុំវិញព្រះបរមរាជវាំង ទោះបីជាត្រូវបានបោះបង់ចោលក៏ដោយ ក៏មានកម្មាភិបាលនៅថែសួន កាត់ស្មៅ ស្រោចផ្កា និងដើមឈើនៅជុំវិញនោះបានយ៉ាងល្អ ។

ក្រៅពីបានដឹកបន្លែផ្លែឈើទៅកន្លែងសំខាន់ៗទាំងនេះ សម្បត្តិ ធ្លាប់ដឹកអីវ៉ាន់ទៅដាក់នៅក្រសួងការបរទេស ដែលមាន អៀង សារី ជារដ្ឋមន្ត្រី និងដាក់នៅតាមផ្ទះនៅក្បែរមន្ទីរស-២១ ដែលជាមន្ទីរសន្តិសុខថ្នាក់មជ្ឈិមរបស់ខ្មែរក្រហមដែលបានឃុំឃាំងនិងសម្លាប់អ្នកទោសប្រហែល១.៤០០០នាក់ ។ ទោះជាមន្ទីរស-២១ ជាកន្លែងលាក់ការណ៍សម្ងាត់របស់ខ្មែរក្រហម និងមិនដែលចូលទៅក្នុងបរិវេណគុកនេះក៏ដោយ សម្បត្តិ អះអាងថា គាត់បានដឹងថាកន្លែងនោះជាគុកទទួលស្វែង និងជាកន្លែងធ្វើទារុណកម្មអ្នកទោស ។

ដោយសារការងារលីសែងអង្ករនិងស្អករធ្ងន់ធ្ងរពេក សម្បត្តិ

បានធ្លាក់ខ្លួនឈឺដំងឺរលាកតម្រងនោម ដែលធ្វើឲ្យគាត់បត់ជើងខូចមកសុទ្ធតែឈាម ។ សម្បត្តិ ក្តៅខ្លួនរហូតដល់សន្លប់បាត់ស្មារតី ហើយត្រូវបានដឹកតាមរថយន្តមកសម្រាកព្យាបាលនៅមន្ទីរពេទ្យ ១៧មេសា ។ សម្បត្តិ បានទទួលការព្យាបាលយ៉ាងយកចិត្តទុកដាក់ ដោយត្រូវបានព្យួរសេរ៉ូមតាមដៃផង និងជើងផងអស់ជាច្រើនដប ប្រមាណជាពីរខែទើបបានជាសះស្បើយ ។

## ការងារនៅមន្ទីរពាណិជ្ជកម្មទួលទំពូង

សម្បត្តិ ត្រូវបានបញ្ជូនឲ្យមកធ្វើការនៅមន្ទីរពាណិជ្ជកម្ម នៅទួលទំពូង ទទួលភារកិច្ចជាអ្នកកិនសណ្តែកបាយ សណ្តែកសៀង បកគ និងវះពោះតុកកែហាលថ្ងៃ ។ តុកកែរាប់រយរាប់ពាន់ក្បាលត្រូវបានដឹកមកទាំងរស់ពីតំបន់ជនបទ ពីគ្រប់ភូមិភាគទាំងអស់ដើម្បីយកមកវះជាងៀតនិងដាក់ហាលថ្ងៃឲ្យស្ងួតដើម្បីកុំឲ្យស្អុយ ។ បន្ទាប់មកប្រកបាវ និងដាក់ឡាំង រួចបោះត្រាសម្គាល់សម្រាប់នាំចេញទៅប្រទេសចិន ។


ឈួន ឆិល បង្ហាញស្លាកស្នាមពេលត្រូវគ្រាប់នៅសមរភូមិ

ដោយមាននាទីជាប្រធានកងនៅក្នុងមន្ទីរពាណិជ្ជកម្ម សម្បត្តិ ត្រូវបានបញ្ជូនឲ្យទៅចូលរួមសន្និបាតមួយនៅវិទ្យាល័យចតុមុខ ដែលមានសុទ្ធតែមេដឹកនាំជាន់ខ្ពស់ចូលរួម ។ សម្បត្តិ មានឱកាសបានឃើញ អ៊ឹង ស៊ិន (ប្រពន្ធ នួន ជា) ម្តងទៀត ក្នុងខណៈពេលគាត់កំពុងចុះពីលើឡាន ហើយ សម្បត្តិ បានរត់សំដៅទៅរកដើម្បីសួរសុខទុក្ខ ។ គ្រាន់តែឃើញ ស៊ិន បានស្តីបន្ទោសថា «កុំឲ្យរត់ផ្តេសផ្តាស ប្រយ័ត្នគេយកទៅវៃចោល» ។ ដោយបានឮសម្តីរបស់ ស៊ិន បែបនេះ ទើប សម្បត្តិ បានដឹងថាខ្លួនអាចរួចរស់ជីវិតបានដោយសារ ស៊ិន ជាអ្នកជួយធ្វើអន្តរាគមន៍ ។

សម្បត្តិ បានរំឭកអំពីអត្ថន័យនៃការប្រជុំនៅវិទ្យាល័យចតុមុខនោះថា កម្មាភិបាលជាន់ខ្ពស់ទាំងនោះបានអប់រំអ្នកចូលរួម អំពីកិច្ចសម្ងាត់និងខ្មាំងប្រឆាំងនឹងបដិវត្តន៍ថា កុំឲ្យជឿការឃោសនារបស់គេផ្តេសផ្តាស ។ គណៈអធិបតីនៅក្នុងអង្គប្រជុំនោះរួមមាន ប៉ុល ពត, ខៀវ សំផន និង នួន ជា ។ ក្រៅពីការចូលរួមសន្និបាត សម្បត្តិ ធ្លាប់បានទៅមើលភាពយន្តនៅស្តាតអូឡាំពិកនិងសាលចតុមុខចំនួនបួន-ប្រាំដង ដែលខ្មែរក្រហមបានចាក់បញ្ចាំងសម្រាប់កម្មកររោងចក្រមើលកំសាន្ត ។

## កម្មកររថភ្លើងនៅពេជ្រនិល

នៅចុងឆ្នាំ១៩៧៨ សម្បត្តិ ត្រូវបានបញ្ជូនទៅការដ្ឋានពេជ្រនិលតាមរថយន្តក្រុងធំ ។ សម្បត្តិ បានអះអាងថា មិនមែនមានតែកម្មាភិបាលក្នុងមន្ទីររបស់គាត់ទេដែលត្រូវដកទៅធ្វើការនៅមន្ទីរពេជ្រនិលនោះ បុគ្គលិកមួយចំនួនដែលបម្រើការនៅគ្រប់ក្រសួងមន្ទីរទាំងអស់នៅក្នុងទីក្រុងភ្នំពេញត្រូវបានបញ្ជូនទៅទីនោះដែរ ។ អ្នកទាំងអស់ត្រូវបានតម្រូវឲ្យធ្វើការសាងសង់ផ្លូវរថភ្លើងថ្មីមួយខ្សែ ដែលភ្ជាប់ទីក្រុងភ្នំពេញទៅក្រុងកំពង់សោម ។ ខ្សែរថភ្លើងនេះគឺជាជំនួយរបស់រដ្ឋាភិបាលចិន ។ ពីដំបូង សម្បត្តិ និងមិត្តរួមការងាររាប់ពាន់នាក់ត្រូវកាប់ឆ្ការព្រៃ ។ បន្ទាប់មក គាត់ និងមិត្តភក្តិ១០នាក់ទៀតដើរវាស់វែងផ្លូវនិងបោះបង្គោល និងលាបថ្នាំពណ៌សជាសញ្ញាសម្គាល់ ។ វាស់វែងផ្លូវដល់កន្លែងណាត្រូវសម្រាកនៅកន្លែងនោះ ។ សម្បត្តិ ត្រូវសម្រាកនៅក្រោមដើមឈើនិងនៅតាមផ្លូវដោយមិនមានមុងភួយត្រឹមត្រូវទេ ហើយការហូបចុកទៀតសោតក៏មានការខ្វះខាតយ៉ាងខ្លាំង ព្រោះមិនមានអ្នកណាយកម្ហូបអាហារមកឲ្យបានទាន់ពេលវេលា ។

ក្នុងខណៈពេលដែល សម្បត្តិ វាស់វែងផ្លូវដល់ម្តុំត្រពាំងក្រឡឹង ស្រាប់តែឮសូរសំឡេងគ្រាប់ផ្លោងចូលទីក្រុងភ្នំពេញ ។ មិនយូរប៉ុន្មាន មានប្រជាជន កងទ័ព និងកម្មកររោងចក្រជាច្រើន

រត់ឆ្លងកាត់កន្លែងគាត់ធ្វើការ ដោយមានអ្នកខ្លះត្រូវរបួសនិងខ្លះស្លាប់នៅតាមផ្លូវ ។ កម្មករជាច្រើន ជាពិសេសកម្មករធ្វើផ្លូវរថភ្លើង ត្រូវបានវាយសម្លាប់ចោលហើយយកសាកសពទម្លាក់ចូលជ្រោះពេជ្រនិល ដោយសារអង្គការសង្ស័យថា អ្នកទាំងនោះជាជនក្បត់បដិវត្តន៍ ។ ចំណែក សម្បត្តិ ក៏បានរត់ទៅជាមួយគេដែរ ឆ្លងភ្នំកាត់វាលរហូតដល់ខេត្តបាត់ដំបង ។

## រួចពីស្លាប់នៅបាត់ដំបង

សម្បត្តិ បានជួបនឹងគ្រោះថ្នាក់ស្ទើរដល់ជីវិតម្តងទៀត ។ ខ្មែរក្រហមបានប្រកាសរកកម្មករធ្វើផ្លូវរថភ្លើងដើម្បីសម្លាប់ចោល ដោយកម្មករទាំងនេះត្រូវបានសង្ស័យថា ជាអ្នកបះបោរប្រឆាំងនឹងអង្គការ ។ ប៉ុន្តែ ខ្មែរក្រហមបានបញ្ឆោតថា រកកម្មកររថភ្លើងដែលដាច់ឆ្ងាយដើម្បីចែករបបអង្ករ ។ ខ្មែរក្រហមបានបញ្ជាឲ្យកម្មកររថភ្លើងឈរនៅមួយកន្លែង ហើយកម្មកររោងចក្រដទៃទៀតអាចធ្វើដំណើរបន្តទៅមុខបាន ។ នៅជុំវិញវាលស្រែកន្លែងនោះមានកងទ័ពព័ទ្ធជុំវិញ ។ សម្បត្តិ ងឿងឆ្ងល់ជាខ្លាំងអំពីព្រឹត្តិការណ៍នេះ ហើយបានសួរខ្លួនឯងថា *“ហេតុអ្វីបានជាគេឲ្យតែកម្មកររថភ្លើងទៅដូច្នេះ តិចគេយកទៅវៃចោលទេដឹង?”* សំណួរនេះបានបញ្ឆោចិត្តរបស់គាត់ឲ្យដើរចូលទៅក្រុមកម្មករតម្បាញ ។ សម្បត្តិ និយាយថា *“គ្រាន់តែខ្ញុំចេញផុតតែបន្តិច ស្រាប់តែក្រឡេកមើលក្រោយចាប់ចងស្លាបសេកទាំងអស់ (កម្មកររថភ្លើង ២០នាក់ជាង) រួចតែខ្ញុំមួយ ។ គ្រាន់តែខ្ញុំចេញផុត គេបាញ់ចោលរេលនៅតាមប្រឡាយ”* ។ សម្បត្តិ បានដើរយ៉ាងលឿននៅក្នុងហ្វូងមនុស្សជាច្រើន ដើម្បីគេចខ្លួនចេញឲ្យផុតពីតំបន់នោះ ។

សម្បត្តិ ចេះតែបន្តដំណើរតាមប្រជាជនផ្សេងទៀតទៅមុខដោយគ្មានគោលដៅច្បាស់លាស់ ដើរកាត់ព្រៃជាច្រើនថ្ងៃទើបមកដល់ភូមិលាចក្នុងខេត្តពោធិ៍សាត់ ។ ប្រធានសហករណ៍នៅទីនោះបានកោះហៅប្រជាជនជម្លៀសទាំងអស់មកជួបជុំគ្នា ហើយប្រាប់ថា *“បើគេសួររកកម្មកររថភ្លើងកុំប្រាប់ ប្រយ័ត្នគេយកទៅវៃចោល”* ។ សម្បត្តិ មិនបានទៅទេពីព្រោះគាត់កំពុងតែផ្ទុតទឹកនៅឯផ្ទះ ។ ជួនពេលនោះ មានកងទ័ពខ្មែរក្រហមបួន-ប្រាំនាក់បានមកសួរគាត់រកកម្មកររថភ្លើង *“ឯណាកម្មកររថភ្លើង ខ្ញុំចង់នាំទៅធ្វើការនៅឯណោះស្រួល?”* ហើយគាត់ឆ្លើយថា *“ខ្ញុំកម្មកររថភ្លើងតើ”* ។ ទោះជាយ៉ាងនេះក្តីកងទ័ពខ្មែរក្រហមទាំងនោះមិនបានចាប់ សម្បត្តិ ភ្លាមៗទេ ដោយនិយាយថា *“ចាំគ្នាអ្នកឯងមកចាំទៅទាំងអស់គ្នា”* ។

ពេលប្រជាជនទាំងអស់ត្រឡប់មកពីប្រជុំវិញ សម្បត្តិ បានរៀបរាប់រឿងរ៉ាវដែលទាហានខ្មែរក្រហមមកសួររកកម្មកររថភ្លើងប្រាប់ដល់មិត្តភក្តិដែលស្នាក់ក្នុងផ្ទះជាមួយគ្នា ។ មិត្តភក្តិរបស់គាត់បានក្តិចហើយប្រាប់ថា ខ្មែរក្រហមកំពុងតែតាមចាប់ខ្លួនកម្មកររថភ្លើងដើម្បីយកទៅសម្លាប់ចោល ហេតុដូម្តេចក៏ប្រាប់គេ ។ គ្រាន់តែបានដឹងដំណឹងនេះភ្លាម សម្បត្តិ ភិតភ័យយ៉ាងខ្លាំង ហើយបានរត់ទៅពួននៅផ្ទះអ្នកភូមិផ្សេងទៀត ។ ទាហានខ្មែរក្រហមទាំងនោះ មិនអាចរកគាត់ឃើញទេ ព្រោះមានមនុស្សរាប់ម៉ឺននាក់ដែលរត់មកនៅទីនោះបន្ទាប់ពីវៀតណាមវាយកាន់កាប់បានទីក្រុងភ្នំពេញ ។

ស្អែកឡើងកងទ័ពទាំងនេះបានមកម្តងទៀត ជួនពេលដែលរថក្រោះរបស់វៀតណាមបានសម្រុកចូលមកដល់ខេត្តពោធិ៍សាត់ដែរ ។ ទាំងកងទ័ពខ្មែរក្រហម ទាំងប្រជាជនបាននាំគ្នារត់ឡើងទៅលើភ្នំ ។ សម្បត្តិ ក៏បានរួចរស់ជីវិតជាថ្មីម្តងទៀត ។

## រត់ឡើងលើភ្នំជាមួយខ្មែរក្រហម

នៅតាមផ្លូវឡើងភ្នំមានមនុស្សជាច្រើនស្លាប់ ។ សម្បត្តិ ស្នាក់នៅលើភ្នំអស់រយៈពេលបីខែ ដោយដើរបេះបោចស្លឹកឈើព្រៃធ្វើជាអាហារ ។ សម្បត្តិ បានធ្វើដំណើរជាមួយអ្នកភូមិដទៃទៀតចុះមកដល់ខេត្តពោធិ៍សាត់វិញ ។ នៅតាមផ្លូវ អាហារដែល សម្បត្តិ អាចរកបាននៅពេលនោះគ្មានអ្វីក្រៅពីដើរដកដំឡូង ដើម្បីយកមកស្ងោរហូបនោះទេ ។ កំពុងតែដកដំឡូង កងទ័ពវៀតណាមបានបាញ់រះមកលើពួកគាត់ បណ្តាលឲ្យមនុស្សជាច្រើនស្លាប់នៅក្នុងការវាយប្រហារនេះ ។ ដើម្បីគេចពីការបាញ់ប្រហារនេះ សម្បត្តិ រត់រហូតមកដល់ជំរំទ័ពរបស់ តាម៉ុក ហើយបន្តដំណើរជាមួយកងទ័ពខ្មែរក្រហមរហូតដល់ព្រំដែនថៃ ដែលនៅជាប់នឹងខ្លួនរបស់គាត់មានតែសម្លៀកបំពាក់ និងអង្រឹងមួយប៉ុណ្ណោះ ។

ទៅដល់ទល់ដែនថៃ ខ្មែរក្រហមបានចាប់ផ្តើមប្រមូលទ័ព

ឡើងវិញ ប៉ុន្តែ សម្បត្តិ មិនបានចូលរួមជាមួយខ្មែរក្រហមទេ គាត់បបួលមិត្តភក្តិពីរ-បីនាក់លួចត្រឡប់មកស្រុកកំណើតវិញ ។ នៅតាមផ្លូវអ្នកទាំងអស់គ្នា ត្រូវទាហានខ្មែរក្រហមធ្វើការឆែកឆេរ ទោះជាយ៉ាងនេះក្តី ទាហានទាំងនេះមិនបានធ្វើបាបពួកគាត់ឡើយ ដោយគ្រាន់តែនិយាយថា “ប្រយ័ត្នជួបខ្មាំងយួន កុំចុះទៅក្រោម ទៅលើទៅ” ។ ទីបំផុត អ្នកទាំងអស់គ្នាក៏បានមកដល់ភូមិត្រពាំង ដៅក្នុងស្រុកទិរាំល់ដែលមានស្រូវទុំជាច្រើនសេសសល់ពីរបប ខ្មែរក្រហម ។ សម្បត្តិ ក៏បបួលមិត្តភក្តិបោចស្រូវហើយបុកដាំបាយហូបដើម្បីសន្សំកម្លាំងធ្វើដំណើរ ។

មកដល់ឃុំអមលាំង សម្បត្តិ និងមិត្តរួមដំណើរបានជួបកងទ័ពវៀតណាមវិញម្តង ។ កងទ័ពវៀតណាមបានភ្ជង់កាំភ្លើង និងធ្វើការឆែកឆេរពួកគាត់ ។ ដោយមានអន្តរាគមន៍ពីប្រជាជនរស់នៅទីនោះ កងទ័ពវៀតណាមបានអនុញ្ញាតឲ្យ សម្បត្តិ បន្តដំណើរទៅមុខទៀត ។ សម្បត្តិ បានមកដល់ភូមិកំណើតវិញ ប្រហែលនៅក្នុងខែឧសភា ឆ្នាំ១៩៧៩ ។

### ការជួបជុំគ្រួសារសាជាថ្មី

បន្ទាប់ពីឆ្លងកាត់គ្រោះភ័យដល់អាយុជីវិតជាច្រើនលើកមក វាបានក្លាយជាបទពិសោធន៍មួយដែល សម្បត្តិ មិនអាចបំភ្លេចបាន ។ ឪពុកម្តាយព្រមទាំងបងប្អូនបានឃើញគ្នាយ៉ាងយូរ ។ អ្នកមានគុណទាំងពីរសឹងតែមិនជឿថា កូនរបស់គាត់មានជីវិតត្រឡប់មកវិញទេ ពីព្រោះគាត់ឮថាកម្មកររថភ្លើងត្រូវបានយកទៅសម្លាប់ចោលទាំងអស់ ។ ក្រុមគ្រួសារនេះបានមករស់នៅក្នុងផ្ទះតូចដដែល ។ ក្រោយថ្ងៃបុណ្យភ្ជុំបិណ្ឌបានប៉ុន្មានថ្ងៃ ឪពុកម្តាយបានផ្សំផ្គុំ សម្បត្តិ និង ឈួន ឆិល ដែលរស់នៅភូមិជាមួយជាប្តីប្រពន្ធ ។ សម្បត្តិ និយាយថា នៅពេលនោះ ប្រជាជនចងដៃជាអង្ករ ហើយការហូបចុកគឺអន្តុយផ្ទាល់នឹងកន្ទេល ។

ទោះបីជាបងប្អូនបង្កើតទាំងអស់បានឆ្លងផុតសេចក្តីស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏គ្រួសាររបស់មីងទទួលរងផលប៉ះពាល់យ៉ាងខ្លាំងពីរបបនេះ ។ សម្បត្តិ ប្រកបមុខរបរធ្វើស្រែចម្ការ ចំណែក ឆិល ជាអ្នកឡើងត្នោតនិងធ្វើជាឈ្លបឃុំ ។ ឆិល ដែលជាអតីតកងទ័ពខ្មែរក្រហម ក្រោយមកបានចូលបម្រើកងទ័ពរបស់រដ្ឋាភិបាលកម្ពុជា ហើយបានពើបប្រយុទ្ធជាមួយកងទ័ពខ្មែរក្រហមជាច្រើនដងក្នុងឆ្នាំ១៩៨៣ ។

នៅក្នុងការប្រយុទ្ធគ្នាមួយនៅអមលាំង ឆិល បានត្រូវរបួសធ្ងន់ធ្ងាយស្មងជើង ក្រលៀន និងស្មា គាត់ត្រូវបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យក្រុង ក្រោយមកត្រូវបានបញ្ជូនទៅព្យាបាលនៅប្រទេសវៀតណាម ។ ឆិល ត្រូវសម្រាកព្យាបាលអស់រយៈពេលមួយឆ្នាំទើបជាសះស្បើយ ។ ក្រោយពីជះស្បើយ ឆិល នៅតែបន្តអាជីពជាទាហានរបស់រដ្ឋាភិបាលដដែល ចំណែក សម្បត្តិ ប្រកបរបរធ្វើស្រែចម្ការនិងជាឆ្មបប្រចាំភូមិ ។

**ឌី ខាំបូលី**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ ÷

- វិទ្យុFM១០២MHz របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជារៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧:៣០-៧:៤៥ ល្ងាច ។
- វិទ្យុFM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧:៣០ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។
- វិទ្យុFM៩៩MHz ខេត្តព្រះវិហារ រៀងរាល់ថ្ងៃនៅម៉ោង ៧:០០-៧:៣០ព្រឹក និងម៉ោង៦:៣០-៧:០០ល្ងាច ។
- វិទ្យុFM១០៣.២៥MHz ខេត្តបាត់ដំបងរៀងរាល់ថ្ងៃនៅម៉ោង៩:០០-៩:៣០ព្រឹក និងម៉ោង៣:០០-៣:៣០រសៀល ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**ស៊ិន សុធីតា**

# គុកខ្មែរក្រហម

## ខេត្តក្រចេះ

## ស្រុកឆ្លូង

### ១) មន្ទីរសន្តិសុខតំបន់២១

ផ្ទះឈើដំបូលប្រក់ក្បឿងមួយខ្នងសង់តាំងពីឆ្នាំ១៩៦១ ក្នុងមន្ទីរសន្តិសុខតំបន់២១ ស្ថិតនៅភូមិកញ្ជរ ឃុំកញ្ជរ ស្រុកឆ្លូង ខេត្តក្រចេះ បច្ចុប្បន្នជាកម្មសិទ្ធរបស់លោក ឡុង សារ៉ែម ជាអតីតមន្ទីរសន្តិសុខតំបន់២១របស់ខ្មែរក្រហម ។

ចាប់តាំងពីឆ្នាំ១៩៧០ដល់ឆ្នាំ ១៩៧៥ ផ្ទះនេះត្រូវរដ្ឋអំណាចបដិវត្តន៍យកធ្វើជាមន្ទីរពេទ្យ ហើយនៅឆ្នាំ ១៩៧៦ ខ្មែរក្រហមបានធ្វើរបងព័ទ្ធជុំវិញផ្ទះនេះធ្វើជាមន្ទីរសន្តិសុខវិញ ។



ឃិន ឈិន ឃុំព្រៃកសាម៉ាន់ ស្រុកឆ្លូង ខេត្តក្រចេះ

អនុសេនីយ៍ទោ ក្អេង សារ៉ែន បានឲ្យដឹងថាអ្នកទោសប្រមាណ៨០០ នាក់ ដែលខ្មែរក្រហមចាប់មកឃុំនៅលើផ្ទះនេះ ជាមនុស្សដែលកងសន្តិសុខបញ្ជូនមកពីភូមិភាគបូព៌ានិងភូមិភាគឦសាន ។ អ្នកទោសទាំងអស់ត្រូវបានសម្លាប់និងស្លាប់ដោយសារការបង្អត់អាហារ អត់អនាម័យនិងការធ្វើទារុណកម្ម ។ ឃិន ឈិន អាយុ ៦៦ឆ្នាំ រស់នៅក្នុងឃុំព្រៃកសាម៉ាន់ ស្រុកឆ្លូង ធ្លាប់ជាប់ឃុំឃាំងនៅទីនោះអស់រយៈពេល៦ខែ ១០ថ្ងៃ ។ ឈិន និយាយថា អ្នកទោសដែលជាប់ក្នុងនោះជាមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនិងប្រជាជនដែលត្រូវចោទប្រកាន់ថាជាខ្មាំងបដិវត្តន៍ ។ អ្នកទោសត្រូវកងឈ្លបដាក់ខ្នោះជើងតម្រៀបគ្នាពេញមន្ទីរឃុំឃាំងដែលមានពីរជាន់ ។ ក្នុងមួយជាន់ដាក់អ្នកទោសចំនួន ២០០នាក់ ។ អ្នកទោសដែលនៅសល់ត្រូវយកទៅដាក់នៅតាមសំយាបផ្ទះទៀត ។ សារ៉ែម បានឲ្យដឹងថា អ្នកទោសដែលជាប់ឃុំឃាំងនៅតាមសំយាបផ្ទះមានប្រហែល៤០០នាក់ ហើយក្នុងចំណោមអ្នកទោសទាំងអស់មានតែ៤នាក់ប៉ុណ្ណោះដែលអាចវិលត្រឡប់មកជួបជុំគ្រួសារវិញ ។ ក្នុងចំណោមនោះមានជនជាតិចាមពីរនាក់ផង ។ ឈិន ត្រូវបានដោះលែងមកវិញដោយសារគាត់គ្មានឈ្មោះក្នុងបញ្ជីដែលត្រូវកម្ទេច ។ ឈិន បានរំពឹកថា គាត់នៅរស់រានមានជីវិត ក៏ដោយសារផឹកទឹកនោមខ្លួនឯង ។

ឈិន បន្តថា ក្នុងមួយថ្ងៃមានអ្នកទោសស្លាប់ពី១០ទៅ២០នាក់ ។ អ្នកទោសស្រាលមានភារកិច្ចជញ្ជូនសាកសពយកទៅកប់ ។ ឈិន បានទទួលរងការធ្វើទារុណកម្មយ៉ាងខ្លាំងក្លាពីសំណាក់ខ្មែរក្រហមរហូតដល់បាក់ឆ្អឹងជំនីម្ខាងរហូតមកដល់សព្វថ្ងៃនេះនៅពុំទាន់ជាសះស្បើយនៅឡើយ ។

នៅឆ្នាំ១៩៧៧ អ្នកទោសប្រហែល ២០០នាក់ត្រូវកងឈ្លបនាំយកទៅសម្លាប់នៅព្រៃត្រសេកចម្ងាយ៣៨០ ម៉ែត្រពីមន្ទីរសន្តិសុខ ។ មកដល់ឆ្នាំ ១៩៧៨ ការសម្លាប់បានកើនឡើងពីរដង បើប្រៀបធៀបនឹងឆ្នាំមុនៗ ។ សារ៉ែម បាននិយាយថា ពេលដែលកម្មាភិបាលភូមិភាគនិរតី ឬកម្មាភិបាលមជ្ឈិមមកកាន់កាប់ភូមិភាគបូព៌ា កម្មាភិបាលរបស់ភូមិភាគនេះ ត្រូវបានចាប់ខ្លួននិងសម្លាប់ជាមួយអ្នកទោសផ្សេងទៀតជាច្រើន ។ សារ៉ែម បានឮសូរសំឡេងអ្នកទោសស្រែកចេញពីទីតាំងសម្លាប់ព្រៃត្រសេក ។

នៅលើជញ្ជាំងមន្ទីរសន្តិសុខតំបន់២១ ខ្មែរក្រហមបានយកធ្យូងសរសេរចំណាំពីការសម្លាប់មនុស្សរបស់ខ្លួនថាមានពី៦ទៅ៧ពាន់នាក់ ។ សារ៉ែម សន្និដ្ឋានថា អ្នកសរសេរគឺប្រហែលជាប្រធានសន្តិសុខដែលគ្រប់គ្រងមន្ទីរទាំងមូល ។ ប្រធានសន្តិសុខ

ដំបូងបង្អស់ឈ្មោះ ប៊ុន ហើយបន្ទាប់មក ឈ្មោះ គុប និង លាង ។

នៅក្រោយឆ្នាំ១៩៧៩ ឡុង សាអែម បានវិលត្រឡប់មករស់នៅផ្ទះរបស់គាត់វិញ ។

## ៣) មន្ទីរសន្តិសុខនៅផ្ទះ ឯ សាមីន

នៅក្នុងទឹកដីឃុំឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ មានតែមន្ទីរសន្តិសុខមួយកន្លែងគត់សម្រាប់ឃុំឃាំងអ្នកទោសជាប្រជាជនជម្លៀសមកពីទីក្រុងភ្នំពេញ និងប្រជាជនដែលត្រូវអង្គការចោទថាជាបក្ខពួកខ្មែរ-ស ។ មន្ទីរសន្តិសុខនេះ ស្ថិតនៅក្នុងភូមិជ្រោយថ្មលើឃុំឆ្លូង ស្រុកឆ្លូងកើតឡើងនៅឆ្នាំ១៩៧០ ក្នុងទឹកដីនៃតំបន់រំដោះរបស់ខ្មែរក្រហម ។ ឯ សាមីន គឺជាម្ចាស់ផ្ទះនេះដែលត្រូវខ្មែរក្រហមរឹបអូសយកធ្វើជាមន្ទីរសន្តិសុខ ហើយគាត់ព្រមទាំងគ្រួសារបានផ្លាស់ទីលំនៅទៅរស់នៅទីក្រុងភ្នំពេញតាំងពីពេលនោះមក ។

ការឃុំឃាំងអ្នកទោសមានពីរដំណាក់កាលគឺ ១) ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ការឃុំឃាំងធ្វើឡើងចំពោះតែប្រជាជនមូលដ្ឋានណាដែលត្រូវអង្គការចោទថាជាបក្ខពួករបស់ខ្មែរ-សប៉ុណ្ណោះ ។ អ្នកទោសទាំងនេះត្រូវខ្មែរក្រហមនាំយកទៅសម្លាប់នៅចម្ការម៉ៃសាក់ ។ កាន់ ណារ៉ា ជាប្រធានមន្ទីរសន្តិសុខជំនាន់នោះ ។ ២) ពីឆ្នាំ១៩៧៥ដល់ចុងឆ្នាំ១៩៧៨ ការឃុំឃាំងអ្នកទោស គឺធ្វើឡើងចំពោះប្រជាជន១៧មេសា ដែលមានជាប់ពាក់ព័ន្ធនិន្នាការនយោបាយពីសង្គមចាស់ ។ ប្រធានមន្ទីរសន្តិសុខ ឈ្មោះ ទ្រី ។ ទ្រី បានរៀបចំឲ្យមានមន្ទីរសួរចម្លើយមួយដែលមានកន្លែងកត់ឈ្មោះអ្នកទោសនិងសរសេរចម្លើយសារភាព ។

ហាស់ ប៊ុនថេត អាយុ៥៨ឆ្នាំ ជាសមាជិកក្រុមប្រឹក្សា ឃុំឆ្លូង និយាយថា គាត់ឃើញកងឈ្លបបណ្តើរមនុស្សទាំងខ្សែៗ ចេញពីមន្ទីរសន្តិសុខនេះយកទៅសម្លាប់នៅព្រៃចម្ការម៉ៃសាក់ ដែលមានចម្ងាយប្រហែល១គីឡូម៉ែត្រ ប៉ែកខាងលិចមន្ទីរសន្តិសុខ ។ អ្នកទោសខ្លះបានស្លាប់ដោយសារតែគ្មានថ្នាំសង្កូវព្យាបាលជំងឺ គ្មានការថែរក្សា របបអាហារមិនគ្រប់គ្រាន់ និងការធ្វើទារុណកម្មហួសហេតុ ។ ហែម គឹមអេង អាយុ៣៨ឆ្នាំ ប្រាប់ថា អ្នកទោសរាប់រយនាក់ដែលត្រូវកងឈ្លបបណ្តើរចេញពីមន្ទីរសន្តិសុខឯសាមីន ក៏យកទៅសម្លាប់នៅចម្ការម៉ៃសាក់ដែរ ។

នៅចុងឆ្នាំ១៩៧៨ មន្ទីរសន្តិសុខនៅផ្ទះ ឯ សាមីន ត្រូវបានបោះបង់ចោល ។ ស្លាកស្នាមនិងវត្ថុតាងជាច្រើននៅសេសសល់រាយប៉ាយពាសពេញមន្ទីរឃុំឃាំងនោះ ។ ក្រោយពីរបបនេះដួលរំលំ ឯ សាមីន បាននាំកូនៗត្រឡប់ទៅផ្ទះរបស់គាត់វិញ ហើយបានដុសលាងសម្អាតស្នាមឈាមដែលប្រឡាក់លើរនាប និងរៀបចំតុសម្រាប់កត់ចម្លើយរួមនិងប្រមូលបញ្ជីឯកសារ បញ្ជីឈ្មោះកំណត់ហេតុសួរចម្លើយ និងឯកសារផ្សេងៗទៀតគរទុកមួយកន្លែង ហើយក្រោយមកឯកសារទាំងអស់នោះត្រូវបានដុតចោល ។ សាមីន បានបន្តទៀតថា ពេលដែលគាត់រើប្រមូលឯកសារទាំងនោះទៅគរទុកមួយកន្លែង គាត់បានប្រទះឃើញបញ្ជីឈ្មោះមួយសន្លឹកក្នុងនោះមានឈ្មោះជាច្រើនដែលគាត់អះអាងថាជាមនុស្សធ្លាប់ស្គាល់គ្នាដែលនៅជិតខាងកាលពីជំនាន់មុនរបបខ្មែរក្រហម ។ សាមីន រំឭកថា គាត់ខ្សរាប់ធ្វើពិធីបង្សុកូលអុជទៀនធូបនៅពេលបុណ្យទានម្តងៗ ដើម្បីរំឭកដល់វិញ្ញាណក្ខន្ធឪពុករបស់គាត់ ព្រមទាំងមនុស្សជាច្រើននាក់ទៀតដែលបានស្លាប់នៅលើផ្ទះរបស់គាត់ ។ បច្ចុប្បន្ន សាមីន មិនបានជួសជុលផ្ទះរបស់គាត់វិញឡើយ ។ សាមីន បានបើកគ្លីនិកតូចមួយនៅ



មន្ទីរសន្តិសុខនៅផ្ទះ ឯ សាមីន ឃុំឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ

ដាន់ផ្ទាល់ដី ដោយមានអ្នកជំងឺពីរបីនាក់ដេកសម្រាកដើម្បីទទួលការព្យាបាល ។

## ស្រុកក្រចេះ

### ៣) មន្ទីរសន្តិសុខអូរលង់

មន្ទីរសន្តិសុខប្រចាំស្រុកក្រចេះឈ្មោះអូរលង់ ឬមន្ទីរដ-៨ បង្កើតឡើងដោយខ្មែរក្រហម ។ មន្ទីរនេះ ស្ថិតនៅក្នុងភូមិដា ឃុំដា ស្រុកក្រចេះ ហ៊ុមពទ្ធ័ដោយរបងបន្ទាលួសយ៉ាងញឹក ប្រជាជនទូទៅដែលខ្មែរក្រហមស៊ើបដឹងថាជាខ្សែស្រឡាយអ្នកដែលមាននិន្នាការនយោបាយពីសង្គម រួមទាំងកម្មាភិបាលខ្មែរក្រហមឯទៀតដែលអង្គការត្រូវបោសសម្អាត ត្រូវបានបញ្ជូនមកដាក់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខអូរលង់ ហើយយកទៅសម្លាប់ចោលទាំងអស់ ។ សុខ សៀងម៉េង និយាយថា "គ្មានរឿងកសាងខ្លួនជាថ្មីនៅមន្ទីរសន្តិសុខអូរលង់ទេ " ។ មានអ្នកទោសច្រើននាក់ណាស់ដែលជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខអូរលង់ ។ សុខ សៀងម៉េង បន្តថា អ្នកទោសទាំងអស់ត្រូវខ្មែរក្រហមប្រមូលយកមកពីគ្រប់ឃុំទូទាំងស្រុកក្រចេះ ។ កម្លាំងបង្កប់របស់អង្គការនៅតាមមូលដ្ឋានបានរាយការណ៍មកថ្នាក់លើ ហើយសុំយោបល់ចាប់ខ្លួនប្រជាជនណាដែលប្រព្រឹត្តខុសឆ្គងមាគ៌ាបដិវត្តន៍ ។ គន់ ពៅ បាននិយាយពីឈ្មោះ ដល ថា គាត់ជាប់គុកនៅមន្ទីរសន្តិសុខអូរលង់នេះ ព្រោះតែគាត់ធ្វេសប្រហែសឲ្យក្របីស៊ីស្រូវអ្នកដទៃ ។ ស សយ អាយុ៦២ឆ្នាំ សព្វថ្ងៃរស់នៅឃុំដាក៏ត្រូវឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខអូរលង់ដែរ ព្រោះប្តីគាត់ជាអតីតទាហាន ។ អ៊ុក ច្រឹង អាយុ៥០ឆ្នាំ រស់នៅភូមិក្រគរ ជាអ្នកទោសម្នាក់នៅក្នុងមន្ទីរសន្តិសុខអូរលង់នេះ គាត់ត្រូវខ្មែរក្រហមចោទប្រកាន់ថាជាភ្នាក់ងារ សេ.អ៊ី.អា ឬ កា.ហ្សេ.បេ បម្រើខ្មាំង ហើយនិយាយទិតៀនគណៈសហករណ៍ថាដឹកនាំប្រជាជនមិនបានល្អ ។

អ្នកមានទោសធ្ងន់ត្រូវជាប់ខ្នោះរហូតដល់ថ្ងៃស្លាប់ ។ ចំណែកអ្នកទោសស្រាលត្រូវកងឈ្លបដោះលែងឲ្យធ្វើការងារផ្សេងៗ ដូចជាធ្វើស្រែចម្ការ ជីកប្រឡាយ លើកទំនប់ជាដើម ។ ប៉ុន្តែនៅពេលយប់អ្នកទោសទាំងនោះត្រូវជាប់ខ្នោះជើងទាំងពីរ ហើយដេកជាជួរៗតាមការកំណត់របស់កងសន្តិសុខប្រចាំមន្ទីរ ។ អ្នកទោសភាគច្រើនបានស្លាប់ដោយសារបម្រើអង្គការមិនបានជិតដល់ការបង្អត់អាហារ និងការធ្វើទារុណកម្ម ។ ចំណែកអ្នកទោសស្ត្រីខ្លះទៀត ត្រូវស្លាប់ដោយសារតែកងឈ្លបចាប់រំលោភ ។ អ្នកទោសដែលនៅរស់ត្រូវដឹកជញ្ជូនសាកសពអ្នកស្លាប់ទាំងអស់យកទៅកប់ចោល ។

នៅចុងឆ្នាំ១៩៧៨ ការគ្រប់គ្រងនៅមន្ទីរសន្តិសុខអូរលង់បានប្រែប្រួល ។ អ្នកទោសទាំងប៉ុន្មានដែលរួចផុតពីការស្លាប់ត្រូវកងឈ្លបបញ្ជូនទៅកាន់ទីតាំងអូរសម្ភោចបន្តទៀត ។ ក្នុងពេលនោះអ្នកទោសមួយចំនួនបានរត់រួចខ្លួន ហើយមួយចំនួន



សា សែ ឃុំដា ស្រុកក្រចេះ ខេត្តក្រចេះ

ទៀតបានទៅដល់ការដ្ឋានអូរសម្ភោច ។

នៅក្រោយថ្ងៃជ័យជម្នះបន្តិច ប្រធានមន្ទីរសន្តិសុខអូរលង់ឈ្មោះ នីន ត្រូវប្រជាជនធ្វើឃាត ។ ចំណែកឈ្មោះ អូ យីខុន ហៅ ជាតិ, ឈឹម ច្រិល និង ង៉ាន់ ដែលជាកម្មាភិបាលនៅក្នុងមន្ទីរសន្តិសុខអូរលង់បានគេចខ្លួនបាត់ ។

### ៤) មន្ទីរសន្តិសុខវិទ្យាល័យព្រះកុសុមៈ

វិទ្យាល័យព្រះកុសុមៈជាគ្រឹះស្ថានសិក្សាធំជាងគេនៅក្នុងស្រុកក្រចេះ មានទីតាំងនៅភូមិក្រចេះ ឃុំក្រចេះ ស្រុកក្រចេះ ។ កាលពីជំនាន់បដិវត្តន៍ វិទ្យាល័យនេះត្រូវបានប្រើប្រាស់ជាមន្ទីរសន្តិសុខ ។ អគារថ្មពីរជាន់ មាន១០បន្ទប់ ត្រូវបានប្រើប្រាស់ធ្វើ

ជាមន្ទីរឃុំឃាំងអ្នកទោស ចំណែកអគារផ្សេងទៀត ប្រើជាកន្លែងដាក់គ្រឿង សព្វាវុធ ឃ្លាំងដាក់ឱសថ និងមន្ទីរពេទ្យ ។

ចាប់ពីឆ្នាំ១៩៧០រហូតដល់ឆ្នាំ១៩៧៥ អ្នកទោសភាគច្រើនជាប្រភេទមនុស្សដែលជាប់និន្នាការនយោបាយពីសង្គម និងមន្ត្រីរដ្ឋការត្រូវកងឈ្លបចម្រាញ់យកមកពីភូមិឃុំនានាក្នុងស្រុកក្រចេះ ។ ចាប់ពីឆ្នាំ១៩៧៥មក អ្នកទោសដែលចាប់មកត្រូវអង្គការចោទប្រកាន់ថាជាភ្នាក់ងារ សេ.អ៊ី.អា កា.ហ្សេ.បេ និងជាអ្នកបំផ្លាញបដិវត្តន៍ ។ សៅ ឃុិច និយាយថា គាត់បានឃើញខ្មែរក្រហមនាំអ្នកទោសមកកាន់មន្ទីរឃុំឃាំងជាញឹកញយ ព្រោះផ្ទះរបស់គាត់ស្ថិតនៅក្បែរគ្នា ។ អ្នកទោសភាគច្រើនត្រូវកងឈ្លបនាំយកទៅសម្លាប់នៅពេលយប់ តាមមាត់បឹង និងក្នុងព្រៃនាមប៉ែកខាងក្រោយមន្ទីរសន្តិសុខ ។


មន្ទីរសន្តិសុខវិទ្យាល័យព្រះកុសុមៈ ភូមិក្រចេះ ឃុំក្រចេះ ស្រុកក្រចេះ

ក្នុងអំឡុងឆ្នាំ១៩៧៧-៧៨ នៅមន្ទីរសន្តិសុខវិទ្យាល័យព្រះកុសុមៈបានចាប់ផ្តើមរង្គោះរង្គើដោយសារការមិនទុកចិត្តគ្នា ។ ឃ្លាំងសម្ភារទាំងប៉ុន្មានដែលបង្កើតឡើងនៅក្នុងទីតាំងសន្តិសុខនេះត្រូវបានដុតបំផ្លាញចោល ។ នៅឆ្នាំ១៩៧៩ វិទ្យាល័យព្រះកុសុមៈទាំងមូលត្រូវប្រជាជនដួសដុលឡើងវិញ ។

## ស្រុកព្រែកប្រសព្វ

### ២៥) មន្ទីរសន្តិសុខវត្តជ្រោយអម្ពិល

វត្តជ្រោយអម្ពិលស្ថិតនៅជាប់នឹងជើងភ្នំសុពណ៌កាឡី គឺនៅក្នុងភូមិជ្រោយអម្ពិល ឃុំចំបក់ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ។ ព្រះសង្ឃ និងឧបាសកឧបាសិកាត្រូវខ្មែរក្រហមបណ្តេញចេញពីវត្តទាំងអស់ ។ បរិវេណវត្តទាំងមូលត្រូវហាមឃាត់មិនឲ្យប្រជាជនដើរឆ្លងកាត់ ។ កុដិថ្មធំមួយ និងព្រះវិហារត្រូវបានជ្រើសរើសយកធ្វើជាមន្ទីរឃុំឃាំងអ្នកទោស ។ ចំណែកកុដិតូចៗនិងកន្លែងដទៃទៀត នៅក្នុងវត្តជាកន្លែងសម្រាប់ដាក់សម្ភារប្រើប្រាស់ និងមន្ទីរសេដ្ឋកិច្ច ។ មន្ទីរពេទ្យមួយត្រូវបានបង្កើតឡើងនៅក្នុងបរិវេណវត្តនេះ សម្រាប់ព្យាបាលអ្នកទោសដែលរបួសនិងឈឺធ្ងន់ ។ ក្រោយមកមន្ទីរពេទ្យនេះបានត្រូវរុះរើនិងផ្ទេរពីវត្តជ្រោយអម្ពិលទៅកាន់កន្លែងមួយទៀត ព្រោះទីតាំងវត្តទាំងមូល ត្រូវយកធ្វើជាមន្ទីរសន្តិសុខនិងទីតាំងសម្លាប់មនុស្សវិញ ។

គៀម ឃាន អាយុ៧៣ឆ្នាំរស់នៅភូមិជ្រោយអម្ពិល ឃុំចំបក់ ស្រុកព្រែកប្រសព្វ បាននិយាយថា ជនរងគ្រោះដែលជាប់នៅក្នុងមន្ទីរសន្តិសុខវត្តជ្រោយអម្ពិល ភាគច្រើនជាប្រជាជន១៧មេសា និងប្រជាជនមូលដ្ឋានមួយ


ព្រះតេជគុណ គៀម ឃាន ឃុំចំបក់ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ

ចំនួន ។ អ្នកទោសជាប្រជាជន១៧មេសាទាំងអស់ ត្រូវខ្មែរក្រហមប្រមូលមកពីឃុំនានា ហើយខ្លះទៀតដឹកតាមកាណូតពីស្រុកស្ទឹងត្រង់មក ។ អ្នកទោសប្រភេទនេះ ខ្មែរក្រហមមិនសម្លាប់ភ្លាមៗទេ ព្រោះទុកសួរចម្លើយ ធ្វើប្រវត្តិរូប និងធ្វើកំណត់ហេតុផ្សេងៗជាមុនសិន ។ ការសម្លាប់បានប្រព្រឹត្តទៅក្បែរអណ្តូងទឹកខាងជើងព្រះវិហារ ដែលជាទីតាំងកប់សាកសពអ្នកជំងឺរាប់សិបនាក់កាលពីមន្ទីរពេទ្យនេះមិនទាន់ផ្លាស់ប្តូរកន្លែង ។ នៅពេលសម្លាប់ម្តងៗ ខ្មែរក្រហមបានចាក់មីក្រូបំពងសំឡេងលាន់ឮទ្រហឹងអឺងកង ហើយជូនកាលឮមកដល់ខាងក្រៅទៀតផង ។

មន្ទីរសន្តិសុខនៅវត្តជ្រោយអម្ពិល ត្រូវរលំរលាយ បន្ទាប់ពីថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩ ។ កងសន្តិសុខនិងកម្មាភិបាលផ្សេងទៀតដែលធ្វើការនៅក្នុងមន្ទីរសន្តិសុខនៅវត្តជ្រោយ-អម្ពិល ត្រូវអ្នកស្រុកសម្លាប់ ដើម្បីសងសឹកឲ្យបងប្អូនរបស់ខ្លួន ។ រហូតមកដល់សព្វថ្ងៃ នៅតែមានការអះអាងថា កងសន្តិសុខទាំងនោះពុំមាននរណាម្នាក់នៅមានជីវិតឡើយ ។


អ៊ុក អៀម ឃុំសំបូរ ស្រុកសំបូរ ខេត្តក្រចេះ

វត្តជ្រោយអម្ពិលទាំងមូលត្រូវបានរៀបចំនិងជួសជុលឡើងវិញ ហើយរណ្តៅមួយចំនួនត្រូវប្រជាជនគាស់យកអដ្ឋិធាតុមកតម្កល់ក្នុងបូជនីយដ្ឋានមួយស្ថិតនៅក្នុងបរិវេណទីតាំងសម្លាប់ក្រោយវត្តជ្រោយអម្ពិល ។

## ៦) មន្ទីរសន្តិសុខគោកក្តួច

ប្រជាជនមូលដ្ឋាននិងប្រជាជនជម្លៀសដែលជាប់ពាក់ព័ន្ធរឿងនយោបាយចំនួនប្រមាណពី៨០ ទៅ១០០នាក់ ត្រូវខ្មែរក្រហមចាប់បញ្ជូនមកដាក់នៅក្នុងមន្ទីរសន្តិសុខមួយឈ្មោះថាគោកក្តួច ។ មន្ទីរសន្តិសុខនេះស្ថិតនៅក្នុងភូមិកែងប្រាសាទ ឃុំសំបូរ ស្រុកសំបូរ ខេត្តក្រចេះ ។ ក្នុងចំណោមអ្នកទោសទាំងអស់មានមួយចំនួនត្រូវបានសម្លាប់និងស្លាប់ដោយសារការធ្វើទារុណកម្ម និងមួយចំនួនទៀតត្រូវបញ្ជូនបន្តទៅកាន់ការដ្ឋានលត់ដំអូរសម្ពោចនិងប្រស្រាល ។ នរ សារ៉េត ដែលជាអតីតអ្នកទោសនៅមន្ទីរសន្តិសុខគោកក្តួច ត្រូវបានបញ្ជូនទៅកាន់ការដ្ឋានប្រស្រាលដើម្បីយាមខ្មោចអ្នកទោសដែលខ្មែរក្រហមសម្លាប់ ។ អ្នកទោសដែលសេសសល់ពីការសម្លាប់ត្រូវកងសន្តិសុខដាក់ខ្នោះជាប់រង់ចាំការសួរចម្លើយនិងសម្លាប់ ។ គាំ អ៊ុក អាយុ៧៣ឆ្នាំ និង អ៊ុក សៀម រស់នៅឃុំកំពង់ចាម ស្រុកសំបូរបានបំភ្លឺថា អ្នកទោសទាំងអស់សុទ្ធតែជាប់ខ្នោះជើងនិងដៃ ហើយនៅពេលបរិភោគអាហារម្តងៗអ្នកទាំងនោះមិនត្រូវកងសន្តិសុខដោះខ្នោះចេញឡើយ ។ អ៊ុក និង សៀម បានរៀបរាប់ឈ្មោះកម្មាភិបាលនិងកងសន្តិសុខនៅក្នុងមន្ទីរសន្តិសុខនេះថា អ៊ុត សារឿន មានមុខនាទីជាប្រធានមន្ទីរសន្តិសុខគោកក្តួច ចំណែកឈ្មោះ មឿ កែ, យ៉ាបែល, ង៉ុយ និង គន់ សារឿន ព្រមទាំងប្រពន្ធឈ្មោះ គាង សព្វថ្ងៃរស់នៅភូមិកែងប្រាសាទ ឃុំសំបូរ ស្រុកសំបូរ គឺជាជនដៃដល់ ។ ម៉ុន និង អុល ដែលជាកងសន្តិសុខបានបាត់ខ្លួនក្រោយពេលប្រទេសត្រូវបានរំដោះ ។ ឌុក សួរ, អ៊ួង ឃឿន, ម៉ន សាមាន, គន់ ស្រីន និង ម៉ៅ សៃ សព្វថ្ងៃរស់នៅឃុំសំបូរ ស្រុកសំបូរ និង ហ ម៉េង អាន សព្វថ្ងៃរស់នៅទីក្រុងភ្នំពេញ អ្នកទាំងអស់នេះសុទ្ធតែជាអតីតកងសន្តិ-សុខប្រចាំនៅមន្ទីរសន្តិសុខគោកក្តួច ។

## ៧) មន្ទីរសន្តិសុខនៅកោះសំតូច

កោះសំ ជាឈ្មោះកោះចំនួនពីរ នៅចំកណ្តាលទន្លេមេគង្គ ដែលស្ថិតនៅក្នុងទឹកដីស្រុកសំបូរ ខេត្តក្រចេះ ។ ក្នុងចំណោមកោះទាំងពីរនេះកោះតូចមួយត្រូវបានហៅថា “កោះសំតូច” ។ កោះសំតូច ស្ថិតនៅកណ្តាលទន្លេមានចម្ងាយប្រហែល២គីឡូ-ម៉ែត្រពីមាត់ច្រាំង គឺនៅក្នុងភូមិយ៉ាវ ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ ។ ក្នុងសម័យសង្គមរាស្ត្រនិយម ក្រុមគ្រួសាររបស់ វៃ ប្រណី បានចូលទៅកាន់កាប់កោះសំតូចនេះ ដើម្បីធ្វើស្រែ

ចម្ការនៅទីនោះ ។ នៅឆ្នាំ១៩៧០ “កោះសំតូច” ត្រូវខ្មែររំដោះរឹបអូសយកជាកម្មសិទ្ធិ ដោយចាប់ម្ចាស់កោះនេះយកទៅសម្លាប់ចោល ។ បន្ទាប់មក ខ្មែររំដោះបានបង្កើតមន្ទីរអប់រំកែប្រែមួយប្រចាំស្រុកសំបូរនៅលើកោះសំតូចនេះ ។ ប្រជាជនជាច្រើននៅក្នុងស្រុកសំបូរត្រូវខ្មែរក្រហមបញ្ជូនមកកាន់កោះនេះ ដោយសារមានពាក់ព័ន្ធនឹងខ្សែរយៈខ្មាំង ។ ចំណែកអ្នកផ្សេងទៀតដែលជម្លៀសមកពីឃុំតាមូង ស្រុកជីបែ ខេត្តកំពង់ចាម ក៏ត្រូវបញ្ជូនមកឃុំឃាំងនៅលើកោះសំតូចនេះដែរ ។

តែ គឹប៊ិន អាយុ៥១ឆ្នាំ ជាមន្ត្រីសាលាស្រុកសំបូរបាន ត្អូញត្អែរថាសាច់ញាតិរបស់គាត់ជាច្រើននាក់បានស្លាប់ ព្រោះតែមានជាប់ពាក់ព័ន្ធនឹងនិន្នាការនយោបាយពីសង្គមចាស់ បងប្អូន និងឪពុករបស់ វៃ ប្រណី ត្រូវកងឈ្លបសម្លាប់នៅលើកោះសំតូច ដោយសារតែអ្នកទាំងនោះមានបុណ្យស័ក្តិតូចតាចនៅក្នុងរបបលន់នល់ ។ ពុត រៀម ពុំដឹងពីមូលហេតុក្នុងការចាប់ខ្លួនគាត់យកមកដាក់នៅលើកោះសំតូចឡើយ ។ រៀម នៅតែមន្ទិលសង្ស័យចំពោះការចាប់ខ្លួនគាត់ជានិច្ច ។ រៀម ជាប់ឃុំនៅលើកោះសំតូចតែរយៈពេល៤ខែប៉ុណ្ណោះ ក៏ត្រូវដោះលែងមកវិញ ។ ក្នុងរយៈពេលនោះ រៀម ប្រឹងប្រែងធ្វើការជាខ្លាំង ដូចជាកាប់ឆ្ការព្រៃ ភ្ជួរដីធ្វើចម្ការ ដាំពោត សណ្តែកជាដើម ។ នៅពេលយប់ រៀម ត្រូវសម្រាកជាមួយអ្នកទោសដទៃទៀតនៅលើគ្រែវែងមួយក្នុងរោងប្រក់ស្បូវគ្មានជញ្ជាំងមួយចំកណ្តាលកោះ ដែលមានកម្ពស់ប្រមាណ២០សង់ទីម៉ែត្រពីដី ។ អ្នកទោសទាំងនេះមិនត្រូវបានផ្តល់សម្លៀកបំពាក់និងមុងឡើយឡើយ ។


តេ គឿប៊ុន ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ

នៅដើមឆ្នាំ១៩៧៥ មានអ្នកទោសជាប្រជាជនជម្លៀសពីភ្នំពេញជាច្រើននាក់ ត្រូវខ្មែរក្រហមបញ្ជូនតាមទូកជាច្រើនគ្រឿងមកកាន់មន្ទីរសន្តិសុខកោះសំតូចនេះ រួចក្រោយមកអ្នកទាំងនោះត្រូវកងឈ្លបសម្លាប់ទាំងអស់ ។ អ៊ុង សាម៉ុន ជាអ្នកគ្រប់គ្រងមន្ទីរសន្តិសុខនេះតាំងពីឆ្នាំ១៩៧៧ ហើយពាក់កណ្តាលឆ្នាំ១៩៧៥ អ៊ុង សាម៉ុន ត្រូវអង្គការចាប់ខ្លួនដោយចោទថាមានជាប់ខ្សែរយៈក្បត់ជាមួយបក្ខពួកឈ្មោះ ឈុន យោម និង ចែត ជាសមាជិកក្រុម សេ.អ៊ី.អា, ខ្មែរ-ស និងជាគណៈនិងអនុគណៈស្រុកសំបូរកាលពីអំឡុងឆ្នាំ១៩៧០-៧៥ ។ សាម៉ុន និងបក្ខពួកត្រូវបានបញ្ជូនទៅកាន់ឃុំដែលមានជនជាតិរស់នៅច្រើនដែលស្ថិតនៅក្នុងស្រុកសំបូរ ដើម្បីឃុំខ្លួនបណ្តោះអាសន្ននិងសួរចម្លើយ ហើយសម្លាប់ចោល ។

បន្ទាប់ពីចាប់ខ្លួន អ៊ុង សាម៉ុន មន្ទីរឃុំឃាំងលើកោះសំតូច ត្រូវអង្គការរំលាយចោល ដោយប្រគល់ទៅឲ្យខាងមន្ទីរពេទ្យស្រុកមើលការខុសត្រូវវិញ ។ ក្រោយឆ្នាំ១៩៧៩ កោះសំតូច ត្រូវបានប្រគល់ទៅឲ្យម្ចាស់ដើមឈ្មោះ វៃ ប្រណី វិញ ។ ប្រណី លែងហ៊ានទៅប្រកបរបរធ្វើស្រែចម្ការនៅលើកោះសំតូចទៀតហើយ ព្រោះជាកោះដែលឪពុករបស់គាត់ត្រូវខ្មែរក្រហមសម្លាប់នៅទីនោះ ។ នៅពេលរំដោះភ្លាម គឹប៊ិន បានទៅកោះនេះ ដើម្បីស្វែងរកបងប្រុសរបស់គាត់ម្នាក់ដែលខ្មែរក្រហមចាប់ខ្លួន ដោយសារមូលហេតុមានជាប់និន្នាការនយោបាយពីសង្គម ប៉ុន្តែគាត់រកមិនឃើញ ហើយរហូតមកដល់សព្វថ្ងៃនៅតែរកមិនឃើញដដែល ។ នៅលើកោះសំតូច គឹប៊ិន សង្កេតឃើញមានខ្ទោះឈើ និងចម្រូងជាច្រើននៅរាយប៉ាយពាសពេញទីនោះ និងស្លាមឈាមនៅលើដីនិងប្រឡាក់ទង់ស្មៅនៅឡើយ ។

**ផេង ពង្សរ៉ាស៊ី**

# មានសំណាងរួចផុតពីសេចក្តីស្លាប់

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមនុស្សជាច្រើន បានបាត់បង់ជីវិតដោយ ការសម្លាប់ ការធ្វើទារុណកម្ម និងការប្រព្រឹត្តកំហុសបន្តិចបន្តួចក្រៅពីការស្លាប់ដោយអត់អាហារបរិភោគ និងជំងឺ ។ ទុយ ឌុច ជាអតីតកងសន្តិសុខនៅគុកក្រាំងតាចាន់ ដែលក្រោយមកគាត់ត្រូវអង្គការតាមដានរកកំហុសដើម្បីចាប់យកទៅសម្លាប់ ។ ឌុច មានសំណាងផ្ទួនៗ ដោយបានរួចផុតពីការចោទប្រកាន់ ។ ខាងក្រោមនេះ គឺជាការរៀបរាប់ របស់ ទុយ ឌុច ៖

ដើមឡើយ ខ្ញុំរៀននៅវិទ្យាល័យ“សម្តេចឪ” បច្ចុប្បន្នហៅថាវិទ្យាល័យ“១ឧសភា” ។ នៅឆ្នាំ១៩៧០ ខ្ញុំរៀនដល់ថ្នាក់ទី៦ “ចាស់” បើតាមអាយុពិត ខ្ញុំមិនអាចប្រលងយកសញ្ញាប័ត្រមធ្យមសិក្សាកម្រិត១ បានទេ ពីព្រោះ ខ្ញុំអាយុតិច ។ ដូចនេះ ខ្ញុំត្រូវដំឡើងអាយុដាក់១៨ឆ្នាំ ដើម្បីឲ្យបានចូលប្រឡងនឹងគេ ។


ទុយ ឌុច

ជាអកុសលនៅឆ្នាំ១៩៧០ ស្ថានភាពនៅក្នុងភូមិមានភាពច្របូកច្របល់ដោយសារព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ ។ កងទ័ពវាយបែកបន្ទាយអង្គតាសោមនៅក្នុងឆ្នាំ១៩៧៣ ហើយទាហានខ្មែរក្រហមបានចូលក្តោបក្តាប់ភូមិទាំងមូល ។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមធ្វើការជម្លៀសប្រជាជនចេញពីឃុំលាយបូរឲ្យមករស់នៅឃុំពពេល ដែលជាតំបន់រំដោះឬហៅថា “តំបន់ស” ដែលខ្មាំងកាន់កាប់ ។ បន្ទាប់ពីជម្លៀសភ្លាម អង្គការចាត់តាំងឲ្យខ្ញុំធ្វើការងារក្នុងកងកុមារ ។ មិនយូរប៉ុន្មានអង្គការបញ្ជូនខ្ញុំទៅធ្វើការក្នុងកងយុវជនធ្វើទំនប់ប្រឡាយរហូតដល់ចុងឆ្នាំ១៩៧៦ ។ ក្រោយមក សភាពការណ៍នៅក្នុងភូមិបានផ្លាស់ប្តូរ ។ អង្គការចាប់ផ្តើមកែនទ័ពដោយព្យាយាមបញ្ចុះបញ្ចូលឲ្យយើងចូលបម្រើកងទ័ព តែទោះជាយ៉ាងណាវាស្ថិតក្នុងន័យបង្ខិតបង្ខំដូចតែគ្នា ព្រោះថាខ្ញុំនិងឪពុកម្តាយខ្ញុំមិនអាចប្រកែកបានឡើយ មានតែបង្ខំចិត្តធ្វើតែប៉ុណ្ណោះ ម្យ៉ាងទៀត ខ្ញុំមិនអាចបដិសេធថាមិនទៅបម្រើកងទ័ពបានទេ បើពុំនោះសោតខ្ញុំក៏គ្មានបាយហូបដែរ ។

ខ្ញុំធ្វើការបានឡើងឋានៈជាបន្តបន្ទាប់ ។ ដំបូង ខ្ញុំធ្វើជាឈ្លបឃុំនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ ប៉ុន ដែលជាប្រធានឈ្លប ។ បន្ទាប់មក ខ្ញុំធ្វើជាកងទ័ពស្រុកបានប្រហែលជាពីរបីខែ អង្គការក៏បញ្ជូនខ្ញុំទៅធ្វើជាកងទ័ពតំបន់ ។ ប្រមាណជាបីខែក្រោយ អង្គការបញ្ជូនខ្ញុំឲ្យទៅធ្វើជាកងទ័ពភូមិភាគនៅកងពលលេខ៨វិញ ។ តាមការប៉ាន់ស្មានរបស់ខ្ញុំ ប្រធានកងពលលេខ៨នៅពេលនោះគឺ តាម៉ុក ។ អង្គការបញ្ជូនខ្ញុំទៅធ្វើជាកងទ័ពនៅន្លែងផ្សេងៗដើម្បីបង្ហាត់បង្រៀនខ្ញុំឲ្យស្គាល់ពីទីតាំងភូមិសាស្ត្រ និងស្ថានភាពនៅសមរភូមិជាមុនសិន មុននឹងខ្ញុំអាចបំពេញការងារជាបន្តទៀត ។

នៅឆ្នាំ១៩៧៨ អង្គការបញ្ជូនខ្ញុំទៅធ្វើជាកងទ័ពពិសេសឋិតនៅក្នុងកងពលតូច២១០ វរសេនាធំ១៣ អនុសេនាធំ២៣ ឬ២៤ នៅសមរភូមិក្រោយ ។ ការងារចម្បងរបស់ខ្ញុំនៅក្នុងវរសេនាធំ១៣ គឺរែកបាយ រែកទឹក ឲ្យកងទ័ពនៅសមរភូមិមុខ ។ ការងារនេះមានភាពស្រណុកសុខស្រួលច្រើនពីព្រោះខ្ញុំមិនចាំបាច់ឡើងច្បាំងក្នុងសមរភូមិឡើយ ។ ប្រធានវរសេនាធំរបស់ខ្ញុំនៅពេលនោះមានឈ្មោះ មាន និង ថា ។ សព្វថ្ងៃនេះ ខ្ញុំមិនដឹងថាអ្នកទាំងពីរស្លាប់ឬក៏នៅរស់ទេ ។

នៅក្នុងឆ្នាំដដែលនេះ អង្គការបញ្ជូនខ្ញុំទៅធ្វើជាកងការពារនៅគុកក្រាំងតាចាន់ ។ ទ័ពដូចរូបខ្ញុំនេះជួនកាលក៏ត្រូវចុះដកស្ទូងដូចប្រជាជនទូទៅដែរ ។ អួក គឺជាប្រធានកងការពារនៅទីនោះ ។ ក្នុងអំឡុងពេលដែលខ្ញុំធ្វើទ័ព ខ្ញុំធ្លាប់ចុះទៅធ្វើស្រែប្រាំងនៅស្រុកក្រោម ។ ខ្ញុំយល់ថា ការបញ្ជូនរូបខ្ញុំទៅធ្វើការនៅគុកក្រាំងតាចាន់ ប្រៀបដូចជាយកខ្ញុំទៅ“ដាក់មាត់ជុច” ពីព្រោះសាច់ញាតិបងប្អូនខ្ញុំសុទ្ធតែធ្លាប់មានប្រវត្តិមិនល្អ ។ ខ្ញុំមានបងប្អូនជីដូនមួយម្នាក់ត្រូវអង្គការសម្លាប់ ព្រោះគាត់ធ្លាប់ធ្វើទាហាននៅទីក្រុងភ្នំពេញ ។ រីឯមារបស់ខ្ញុំឈ្មោះ ឃឿន និងសាច់ញាតិបងប្អូនរបស់ម្តាយខ្ញុំ ព្រមទាំងឪពុកម្តាយខ្ញុំសុទ្ធតែជាប់ពាក់ព័ន្ធខ្សែរយៈទាំងអស់ ។

ទោះបីជាខ្ញុំប្រឹងប្រែងធ្វើការដោយមិនដែលប្រព្រឹត្តអ្វីខុសនឹងបទបញ្ជាអង្គការក៏ដោយ ក៏អង្គការមិនដំឡើងឋានៈឲ្យខ្ញុំទៀតដែរ

ដោយសារថាខ្ញុំចេះអក្សរនិងជាប់ខ្សែរយៈសាច់ញាតិបងប្អូនដែលមានប្រវត្តិរូបមិនល្អ ។ អង្គការមិនចាត់ទុកខ្ញុំជាប្រជាជនពេញសិទ្ធ ឡើយ ។ មានពេលមួយ ខ្ញុំបាននិយាយទៅកាន់កងទ័ពខ្មែរក្រហមផ្សេងទៀតថា "អី ឯងកុំប្រើវាខ្លាំងពេកព្រោះវានៅក្មេង" ។ មួយរំពេចនោះ កងទ័ពខ្មែរក្រហមទាំងនោះសម្លឹងមើលខ្ញុំតាំងពីក្បាលដល់ចុងជើង ។ បូកបញ្ចូលនឹងកត្តាទាំងអស់នេះ វាជាមូលហេតុដែលធ្វើឲ្យខ្ញុំមិនអាចឡើងឋានៈធំនឹងគេបាន ហើយនៅត្រឹមតែឋានៈជាប្រជាជនត្រៀមប៉ុណ្ណោះ ។

រយៈពេលដែលខ្ញុំធ្វើការនៅគុកក្រាំងតាចាន់ ខ្ញុំឃើញឈ្លបបណ្ដើរអ្នកទោសទាំងខ្សែៗ ។ អ្នកទាំងនោះតែងមានទោសកំហុសជាប់ខ្លួនជានិច្ច គឺគ្មានអ្វីក្រៅពីទាក់ទិននឹងការអត់ឃ្លានឡើយ ។

ជាទូទៅ មនុស្សបើកាលណាឃ្លានច្បាស់ជាលួចត្រួញត្អែរ ។ ប្រសិនបើអង្គការឮពាក្យត្រួញត្អែរនេះច្បាស់ជាបញ្ជាឲ្យឈ្លបយកទៅសម្លាប់ជាមិនខាន ។ ការសម្លាប់មនុស្សនៅទីនោះមានច្រើនបែបច្រើនសណ្ឋានណាស់ ។ ខ្ញុំគឺជាកងការពារនៅបរិវេណខាងក្រៅ ។ ដូច្នេះខ្ញុំមិនដែលឃើញទិដ្ឋភាពនៅខាងក្នុងដូចជាការសម្លាប់មនុស្សនិងការធ្វើទារុណកម្មទេ ។ គ្រាន់តែពេលស្ងាត់ ខ្ញុំឮស្នូរកាំភ្លើងបាញ់ផ្ទង ហើយក៏ស្ងប់ស្ងាត់បាត់ទៅវិញទៅ ។ ក្នុងមួយថ្ងៃ មានការសម្លាប់យ៉ាងហោចណាស់ពី៣ទៅ៤នាក់ ហើយថ្ងៃខ្លះអាចមានការសម្លាប់ពី១០ទៅ២០នាក់ក៏មាន ។ នៅពេលទៅដល់គុកក្រាំងតាចាន់ ភាគច្រើនគឺអង្គការសម្លាប់ទាំងអស់មិនថាអ្នកទោសធ្ងន់ឬស្រាលឡើយ ។ ខ្ញុំមិនដែលឃើញអ្នកទោសណាម្នាក់អាចរត់គេចខ្លួនរួចនោះទេ ប្រសិនបើអ្នកទោសរត់ចេញរួច ខ្ញុំហ៊ានធានាថាយ៉ាងយូរក្នុងរយៈពេលមួយសប្ដាហ៍ អ្នកទោសនោះនឹងត្រូវចាប់មកវិញ ហើយប្រាកដជាត្រូវដេកស្លាប់ដោយសារដាច់ពោះជាមិនខាន ។

នៅអំឡុងពេលដែលខ្ញុំធ្វើការនៅទីនោះ ខ្ញុំមានអារម្មណ៍ថាអង្គការកំពុងតែតាមដានពីសកម្មភាពរបស់ខ្ញុំគ្រប់ពេលវេលា ។ ពួកគេរកលេសចាប់ទោសកំហុសខ្ញុំ តែខ្ញុំមិនហ៊ានប្រព្រឹត្តអ្វីផ្ដេសផ្ដាសឡើយ ។ ក្នុងរយៈពេលប្រហែល៧ខែក្រោយ ខ្ញុំក៏ផ្លាស់ទីកន្លែងធ្វើការទៅនៅស្រុកកោះអណ្ដែតវិញ ។ មិនយូរប៉ុន្មានកងទ័ពរំដោះបានចូលវាយលុកកងទ័ពខ្មែរក្រហម ។ របបខ្មែរក្រហមត្រូវបានផ្ដួលរលំ ។ ខ្ញុំរត់គេចខ្លួនតាមផ្លូវជាតិលេខ២៨ ហើយក៏វិលត្រឡប់មករស់នៅក្នុងភូមិរបស់ខ្ញុំវិញ ។

ចូលមកដល់ភូមិភ្លាម ខ្ញុំហៀបនឹងត្រូវកងទ័ពវៀតណាមចាប់ដាក់គុកញ៉ាបាង ដោយសារតែខ្ញុំមានឈ្មោះដូច ឌុច "កាំង ហ្កិចអៀវ" ប្រធានមន្ទីរគុកទួលស្លែង ។ ជំនាញការវៀតណាមសួរចម្លើយខ្ញុំថា ឯងគឺ ឌុច ជាមេខ្មែរក្រហមដែលរស់នៅឃុំលាយបូរមែនទេ? ខ្ញុំឆ្លើយថា មិនមែនខ្ញុំទេ ឌុច ហៅ"កាំង ហ្កិចអៀវ" មានសម្បុរសហើយជាមនុស្សចាស់ ។ ខ្ញុំអង្វរករគេឲ្យដោះលែងខ្ញុំ ព្រោះនេះគ្រាន់តែជាការភ័ន្តច្រឡំប៉ុណ្ណោះ ។ សំណាងល្អមានប្រជាជនខ្មែរម្នាក់ទៀតប្រាប់ជំនាញការវៀតណាមថា : ខ្ញុំមិនមែនជា ឌុច ដែលពួកគេកំពុងតាមចាប់ខ្លួននោះទេ ។ ខ្ញុំក៏ត្រូវដោះលែងមកវិញ ហើយរៀបការជាមួយប្រពន្ធខ្ញុំឈ្មោះ គល់ វុន នៅក្នុងឆ្នាំ១៩៧៩ ។ សព្វថ្ងៃនេះខ្ញុំមានកូនចំនួន៥នាក់ ។

"ដើម្បីរស់នៅក្នុងប្រទេសមួយឬរស់នៅក្រោមដំបូលផ្ទះមួយបានសុខ ខ្មែរត្រូវចេះអត់ឱនគ្នា ។ ជាពិសេសប្រទេសត្រូវតែមានច្បាប់សម្រាប់ឲ្យមនុស្សទាំងអស់ប្រតិបត្តិតាម ។ យើងមិនត្រូវលើកលែងទោសឲ្យមេដឹកនាំខ្មែរក្រហមឡើយ ។ យើងត្រូវតែកាត់ទោសអ្នកទាំងនោះ ដើម្បីកុំឲ្យអ្នកដទៃយកគម្រាប់តាម" ។ ខ្ញុំមិនទុកចិត្តតុលាការកម្ពុជាទេ ប៉ុន្តែបើមានការចូលរួមកាត់ទោសពីអង្គការសហប្រជាជាតិគឺជាការប្រសើរបំផុត ។ ខ្ញុំយល់ថាជាការសំខាន់ណាស់ក្នុងការចងក្រងឯកសារឲ្យក្មេងៗជំនាន់ក្រោយបានសិក្សាដឹងឮពីរបបកម្ពុជាប្រជាធិបតេយ្យ ។ សិស្សានុសិស្សគួរយល់ដឹងថា ពិតជាមានអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ពិតមែនទោះបីយ៉ាងណា យើងមិនគួរបង្ហាញពីឯក-សារទារុណកម្ម ការសម្លាប់ដែលមានលក្ខណៈព្រៃផ្សៃហួសហេតុដែលជាកត្តាធ្វើឲ្យក្មេងមួយចំនួនយល់ផ្សេងទៅវិញ ។ ក៏ប៉ុន្តែចំពោះរូបខ្ញុំ ខ្ញុំមិនបាននិយាយប្រាប់រឿងរ៉ាវទាំងអស់នោះទៅកូនចៅរបស់ខ្ញុំឡើយ ព្រោះទី១ ខ្ញុំមិនចង់ឲ្យប៉ះពាល់អារម្មណ៍កូនខ្ញុំជាហេតុនាំឲ្យរំខានដល់ការសិក្សារបស់វា និងទី២ កូនរបស់ខ្ញុំមិនជឿថារឿង ដែលកើតឡើងនៅសម័យនោះជាការពិតឡើយ ។ ខ្ញុំទុកឲ្យវាសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រនេះដោយខ្លួនឯងតាមរយៈសៀវភៅសិក្សារបស់សាលា ។ **នង ឧត្តតារា**

# ព្រះតេជគុណ ទុំ អោក : នៅតែចងចាំរឿងខ្មែរក្រហម

ព្រះតេជគុណ ទុំ អោក ជាកូនកសិករក្រីក្រម្នាក់ រស់នៅភូមិចក ឃុំសន្សើយ ស្រុកជីក្រែង ខេត្តសៀមរាប ។ កាលពីក្មេង ព្រះតេជគុណ ធ្លាប់ប្រកបរបរស៊ីឈ្នួលភ្ជួររាស់ដីឲ្យអ្នកជិតខាង ដើម្បីប្តូរយកស្រូវអង្ករមកផ្គត់ផ្គង់ជីវភាពគ្រួសារ ។ ក្នុងអំឡុងសង្គ្រាមស៊ីវិលក្នុងដើមទសវត្សរ៍ឆ្នាំ១៩៧០ ព្រះតេជគុណ បានចូលបម្រើក្នុងជួរកងទ័ពខ្មែរក្រហម ហើយធ្លាប់បានចូលរួមក្នុងសង្គ្រាមប្រឆាំងនឹងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរជាច្រើនលើក ។ ក្រោយថ្ងៃជ័យជម្នះឆ្នាំ១៩៧៥ ព្រះតេជគុណ សប្បាយរីករាយជាខ្លាំងដោយរំពឹងថា ខ្លួនក៏ដូចជាប្រជាជនទូទៅដែរច្បាស់ជាបានរស់ក្នុងសុខសន្តិភាពមិនខាន ។ ផ្ទុយពីការរំពឹងទុក ព្រះតេជគុណ ត្រូវទទួលរងការធ្វើទុក្ខបុកម្នេញយ៉ាងលំបាកវេទនានៅក្នុងរយៈកាលនៃរបបខ្មែរក្រហម ។ ព្រះតេជគុណ តែងតែចងចាំជានិច្ចនូវរឿងរ៉ាវទាំងឡាយដែលបានកើតឡើងក្នុងរបបនោះ ។

នៅឆ្នាំ១៩៧៣ ព្រះតេជគុណ ត្រូវបានចាត់តាំងឲ្យចូលធ្វើការក្នុងជួរកងទ័ពខ្មែរក្រហម ។ ព្រះតេជគុណ ត្រូវបានបញ្ជូនឲ្យទៅរៀនសូត្រក្បួនយុទ្ធសាស្ត្ររយៈពេលមួយខែនៅស្រុកមាត់ខ្លា ដែលស្ថិតក្រោមការក្តោបក្តាប់របស់ សឿន និង ព្រឿន ។ បន្ទាប់មក ព្រះតេជគុណ ត្រូវបានបញ្ជូនឲ្យមកហាត់រៀនលូនក្រាបនៅរលួសរយៈពេល១០ថ្ងៃទៀត ។ បន្ទាប់ពីបញ្ចប់វគ្គហ្វឹកហ្វឺននេះ ព្រះតេជគុណ ត្រូវបានបញ្ជូនឲ្យមកប្រយុទ្ធវាយចូលក្រុងភ្នំពេញនៅឃុំសាន់គរ ខេត្តកំពង់ធំ ។ ដំណើររបស់ ព្រះតេជគុណ ត្រូវផ្លាស់ប្តូរជាបន្តបន្ទាប់ពីកន្លែងមួយទៅកន្លែងមួយទៀត ។ ព្រះ-តេជគុណ និងកងទ័ពផ្សេងទៀត ត្រូវបានបញ្ជូនបន្តមកដល់ព្រែកក្តាម ហើយស្នាក់នៅវត្តដងទង់ ក្បែរភ្នំប្រសិទ្ធ ។ នៅទីនោះ ព្រះ-តេជគុណ ត្រូវបានចាត់តាំងឲ្យនៅក្នុងកងពល៣១០ ក្រោមការគ្រប់គ្រងរបស់ តាអឿន ដែលជាប្រធានកងពល ។

ការប្រយុទ្ធរវាងកងទ័ពខ្មែរក្រហមនិងទាហានលន់នល់ មានសភាពស្វិតស្វាញនិងគ្រោះថ្នាក់បំផុត ។ ជាញឹកញាប់ ព្រះតេជ-គុណ ត្រូវស្ថិតនៅក្នុងលេណដ្ឋានដែលពោរពេញដោយទឹកនិងភក់ដើម្បីគេចពីការទម្លាក់គ្រាប់បែក ហើយគាត់ចេញមកក្រៅបានតែពេលយប់ដើម្បីហូបអាហារប៉ុណ្ណោះ ។ នៅទីនោះ ព្រះ-តេជគុណ ត្រូវបានចាត់តាំងឲ្យធ្វើការក្នុងកងស្វែងសែងកងទ័ពរបួសដោយសារការប្រយុទ្ធគ្នាមកដាក់ជំរំ ។

ព្រះតេជគុណ បានរៀបរាប់ថា ពេលវាយចូលដល់ទីក្រុងភ្នំពេញ មេបញ្ជាការរបស់គាត់បានបញ្ជាឲ្យបង្ហូតបាយនិងទឹកដល់ប្រជាជននៅក្នុងទីក្រុង ។ ព្រះតេជគុណ បន្តថា គាត់និងក្រុមរបស់គាត់ជាអ្នកដើរប្រមូលរបស់ជយភណ្ឌទុកក្នុងឃ្លាំង ហើយក្រុមរបស់គាត់អាចយករបស់របរ និងអាហារមកហូបដោយសេរី ។ អង្គភាពរបស់ ព្រះតេជគុណ មានទីស្នាក់ការនៅម្តុំវត្តភ្នំ ។


ព្រះតេជគុណ ទុំ អោក

នៅឆ្នាំ១៩៧៦ ក្រោយការចាប់ខ្លួនរបស់ កុយ ធួន លេខាភូមិភាគឧត្តរ មេទ័ពនិងកម្មាភិបាលជាន់ខ្ពស់ជាច្រើនត្រូវបានចាប់ខ្លួនពីបទក្បត់បដិវត្តន៍ ។ ព្រះតេជគុណ និងមិត្តភក្តិត្រូវបានរំសាយ ហើយបញ្ជូនឲ្យមកធ្វើស្រែនៅបឹងបាយ៉ាប ។ ព្រះតេជ-គុណ បានរៀបរាប់ថា ជីវិតរស់នៅទីនោះ មានភាពលំបាកវេទនាណាស់ ព្រោះគាត់ជាប់ក្នុងការសង្ស័យថាជាខ្មែរខ្មាំង ។ ឆ្នាំ១៩៧៧ នៅពេលដែលសង្គ្រាមជាមួយវៀតណាមមានសភាពកាន់តែស្រួចស្រាល់ ព្រះតេជគុណ ត្រូវអង្គការបញ្ជូនឲ្យទៅសមរភូមិក្បែរព្រំដែនវៀតណាមនៅខេត្តកំពត ។ ក្រោយមក ព្រះ-តេជគុណ ត្រូវបានបញ្ជូនឲ្យមកយាមសាលាមន្ទីរក្រែកក្នុងខេត្តកំពង់ចាម ។ នៅទីនោះ ព្រះតេជគុណ បានលួចដោះលែងអ្នកទោសម្នាក់ឈ្មោះ ឡៃ ដែលត្រូវបានចោទថាក្បត់ ហើយហៀបតែត្រូវយកទៅសម្លាប់ទៅហើយ ។ ព្រះតេជគុណ បានប្រាប់ ឡៃ ឲ្យរត់គេចខ្លួន ។ រស់នៅទីនោះមួយរយៈ ព្រះតេជគុណ មានជំងឺគ្រុនចាញ់ ហើយត្រូវបានបញ្ជូនមកព្យាបាលនៅមន្ទីរពេទ្យវត្តសួង ។ ព្រះតេជគុណ បានមើលឃើញមនុស្សជាច្រើន ដែលត្រូវ

ខ្មែរក្រហមចងបណ្តើរយកទៅសម្លាប់ទាំងខ្សែៗ ។ ព្រះតេជគុណ បានអះអាងថា គាត់ធ្លាប់ឃើញទាហានខ្មែរក្រហមវះពោះយក ថ្លើមមនុស្សដាក់ក្នុងថង់ទៀតផង ។

នៅដើមឆ្នាំ១៩៧៩ ពេលវៀតណាមវាយចូលកម្ពុជា ក្រុមរបស់ ព្រះតេជគុណ ត្រូវកងទ័ពវៀតណាមឡោមព័ទ្ធចាប់ បាន ។ ក៏ប៉ុន្តែកងទ័ពវៀតណាមទាំងនោះមិនបានធ្វើបាបគាត់ទេ ហើយឲ្យគាត់ធ្វើដំណើរត្រឡប់ទៅស្រុកកំណើតវិញ ។

សព្វថ្ងៃ ព្រះតេជគុណ មានអាយុ៥៥ឆ្នាំ និងបានបួសជា សង្ឃម្តងទៀតនៅវត្តខ្សាច់ នៅឃុំសង្វើយ ស្រុកជីក្រែង ខេត្ត សៀមរាប ។ ក្នុងរបបខ្មែរក្រហម ព្រះតេជគុណ បាត់បង់បងប្អូន ៦នាក់ ។

**ហ៊ិន សុផានី**

# បដិវត្តន៍ទៅរកភាពឯកោ

ប្រជាជនជាច្រើនបានចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ អ្នក ខ្លះចូលដោយស្ម័គ្រចិត្ត ខ្លះចូលដោយការបង្ខិតបង្ខំ ។ រឿងដែល គួរឲ្យកត់សម្គាល់នៅក្នុងប្រវត្តិសាស្ត្រខ្មែរក្រហមនោះគឺការស្ម័គ្រ ចិត្តចូលបម្រើបដិវត្តន៍ដ៏ច្រើនលើសលប់របស់ប្រជាជននៅតាម មូលដ្ឋានក្នុងដើមទសវត្សរ៍ឆ្នាំ១៩៧០ ។ ជាលទ្ធផល ជីវិតបដិវត្តន៍ របស់អ្នកទាំងនោះមិនបានសមប្រកប ដូចអ្វីដែលខ្លួនគិតទុកនោះទេ ហើយអ្វីដែលនឹកស្មានមិនដល់នោះ គឺការរងទុក្ខវេទនា ការអត់ អាហារ ការបាត់បង់ជីវិត ការបែកបាក់គ្រួសារនិងពិការភាព ។ អ្នកទទួលខុសត្រូវចំពោះរឿងទាំងអស់នេះមិនទាន់ត្រូវបានរក ឃើញនៅឡើយ ។ អ្វីដែលរកឃើញនោះ គឺវិប្បដិសារីនិងភាព បាក់ស្បាតរបស់អ្នកដែលនៅរស់រានមានជីវិតពីរបបនេះទាំងជន រងគ្រោះនិងជនដៃដល់ ។ ជុំ នៅ ដែលជាអតីតយុទ្ធនារីខ្មែរ ក្រហម តើមានវិប្បដិសារីអ្វីខ្លះក្នុងជីវិតបដិវត្តន៍របស់គាត់?

កើតក្នុងត្រកូលកសិករម្នាក់ដែលមានដើមកំណើតនៅខេត្ត ព្រៃវែង ជុំ នៅ បានស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍ ក្រោយថ្ងៃរដ្ឋ ប្រហារ ១៨ មីនា ឆ្នាំ១៩៧០ តាមការឃោសនារបស់កងទ័ព ខ្មែរក្រហមដែលថា រំដោះទឹកដីឲ្យរួចពីរបបជិះជាន់របស់ពួក សក្តិភូមិនិងអភិជន ។

នៅ ត្រូវបានប្រជាជននៅក្នុងតំបន់រំដោះបោះឆ្នោតឲ្យ ធ្វើជាប្រធាននារីភូមិ ទទួលខុសត្រូវនាំយុវជនទៅសមរភូមិ ។

នៅក្នុងរវាងឆ្នាំ១៩៧២-១៩៧៣ នៅ ត្រូវបានតែងតាំង ជាប្រធាននារីឃុំ គ្រប់គ្រងនារីនៅឃុំ ជីក្លាងទាំងមូល ។ ក្រៅពី ការងារនេះគាត់ត្រូវទទួលការងារជាច្រើនទៀត ជាពិសេស ការងារអប់រំ សីលធម៌និងដើរបំផុសចលនាប្រជាជននៅតាមភូមិ តាមការណែនាំរបស់ថ្នាក់លើ ។ មុនពេលចុះទៅអប់រំប្រជាជន ម្តងៗ នៅ ត្រូវឆ្លងកាត់ការសិក្សាវគ្គទ្រឹស្តីពីអង្គការថ្នាក់លើជា មុនសិនទើបយកមកផ្សព្វផ្សាយបន្តនៅថ្នាក់ក្រោម ។ ការអប់រំ នោះច្រើនលើកយកពាក្យជិះជាន់មកនិយាយដោយធ្វើការប្រៀប ធៀបសង្គមមួយទៅសង្គមមួយ ជាពិសេសផ្សព្វផ្សាយសីលធម៌ ១២ប្រការដែលគាត់ត្រូវតែទន្ទេញឲ្យចាំមាត់ដើម្បីយកទៅអប់រំ ប្រជាជន ប៉ុន្តែឥឡូវនេះគាត់នៅចងចាំបានតែសីលធម៌ទី៦ដែល «ហាមយុវជន-យុវនារីមិនឲ្យទាក់ទងគ្នា»ប៉ុណ្ណោះ ។ នៅ ធ្លាប់ បានចូលរួមបម្រើបាយទឹកកម្មាភិបាលធំៗរបស់ខ្មែរក្រហម ដូចជា ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម នៅក្នុងពេលបើកវគ្គអប់រំ នយោបាយ ទូទាំងប្រទេសនៅឃុំជីក្លាងរយៈពេលមួយខែ ។

នៅក្នុងឆ្នាំ១៩៧៣ នៅ ឡើងឋានៈជាប្រធានក្រុមក្នុង កងទ័ពនារី ទទួលភារកិច្ចដឹកជញ្ជូនស្បៀងនិងគ្រាប់ទៅសមរភូមិ ។ នៅ បានទទួលការបង្ហាត់បង្រៀនឲ្យចេះកាន់និងបាញ់កាំភ្លើង ដើម្បីការពារខ្លួន ។ ពេលឡើងមកដល់ភូមិភាគ នៅ ឈប់ធ្វើការ ឃោសនាអប់រំប្រជាជនដូចពេលនៅភូមិឃុំទៀតហើយ ។

ក្នុងឆ្នាំ១៩៧៤ នៅ ត្រូវបានដំឡើងឋានៈជាកងទ័ពនារីភូមិ ភាគបូព៌ា បម្រើការនៅក្នុងកងអនុសេនាតូចលេខ៧ ។ ការងារ នៅទីនោះគឺដឹកជញ្ជូនស្បៀងទៅឲ្យកងទ័ពនៅខ្សែត្រៀម ។ នៅ ត្រូវសិក្សាក្បួនយុទ្ធសាស្ត្ររយៈពេល៦ខែនៅសាលាស-២០០ ម្តុំស្រែស្តែ ស្រុកអូររាំងឪ ដើម្បីឡើងសមរភូមិ ។ សាលានេះ ត្រូវបានហៅជាទូទៅថា«សាលាស្ទពល» មានន័យថាយុទ្ធជន

យុទ្ធនារី ត្រូវឆ្លងកាត់ការហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រ ឬវគ្គនយោបាយរយៈពេល៦ខែមុនពេលឡើងប្រយុទ្ធ ។

ពេលដែលកងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញនៅក្នុងខែមេសា ឆ្នាំ១៩៧៥ នៅ ត្រូវអង្គការបញ្ជូនមកធ្វើការនៅភ្នំពេញផ្នែកភស្តុភារសេនាធិការក្នុងអង្គភាពស-៨០ ដែលមានទីតាំងនៅម៉ុំទួលគោក ។ នៅ មាននាទីជាអ្នកយាមឃ្លាំងគ្រាប់និងដឹកជញ្ជូនអាវុធគ្រប់ធុនដែលនាំចូលពីប្រទេសចិននិងគ្រាប់ ដែលនៅសេសសល់ពីរបបលន់នល់មករក្សាទុកក្នុងឃ្លាំងនៅភ្នំពេញ ហើយគ្រាប់ទាំងអស់ត្រូវរៀបទុកតាមប្រភេទនីមួយៗ ។ នៅ មានប្រសាសន៍ថា "*មីងចេះភាសាបារាំងខ្លះដែរ ព្រោះនៅសំបកឡាំងមានអក្សរបារាំងអីចឹងទៅ យើងសរសេរអក្សរខ្មែរបិទផ្លាកហើយតម្រៀបទៅតាមប្រភេទរបស់វា*" ។ នៅ ធ្វើការនៅឃ្លាំងគ្រាប់រហូតដល់ឆ្នាំ១៩៧៧ ទើបអង្គការបញ្ជូនមកមន្ទីរគុកព្រៃស ។

ការងារគ្រប់គ្រងឃ្លាំងគ្រាប់បានបន្សល់ទុកនូវអំបែងគ្រាប់៩បំណែកនៅក្នុងដៃម្ខាងរបស់ នៅ ដែលតែងតែធ្វើទុក្ខគាត់នៅពេលរដូវរងាម្តងៗ ទោះបីជាគាត់បានចាក់ថ្នាំការពារតេតាណូសរួចហើយក៏ដោយ ។

នៅចុងឆ្នាំ១៩៧៦ នៅ បានរៀបការជាមួយយុទ្ធជនម្នាក់ឈ្មោះ មឿន ដែលជាអតីតយុទ្ធជនមកពីភូមិភាគឧត្តរនិងជាអ្នកយាមឃ្លាំងគ្រាប់ដូចគ្នា ។ អ្នកទាំងពីរស្គាល់គ្នានៅពេលទៅដឹកគ្រាប់ចេញពីកប៉ាល់ ។ ក្រោយមក មឿន បានស្នើទៅប្រធាននារីរបស់គាត់ដើម្បីសុំរៀបការ ហើយថ្ងៃដែលអ្នកទាំងពីររៀបការនៅភ្នំពេញជាមួយគូស្វាមីភរិយាពីរគូទៀត ។

ក្រោយពេលរៀបការ អ្នកទាំងពីរមិនរស់នៅក្នុងផ្ទះជាមួយគ្នាទេ ព្រោះត្រូវរវល់ធ្វើការរៀងៗខ្លួន ប៉ុន្តែគាត់ទាំងពីរអាចទៅរកគ្នាទៅវិញទៅមកបាន ។ "*យើងអាចឆ្លងកាត់ផ្ទះ ដូចថាប្តីខ្ញុំអាចមកផ្ទះខ្ញុំបាន ខ្ញុំអាចទៅផ្ទះប្តីខ្ញុំបានដោយមិនមានបញ្ហាអីទេ ។ បើយើងនឹកគ្នា ចង់ទៅដេកផ្ទះខាងប្តីក៏ទៅៗ អ្នកយាមមិនឃាត់ឃាំងទេ យើងចេញចូលសេរី ប្តីខ្ញុំមកកន្លែងខ្ញុំក៏មិនមានបញ្ហាអីដែរមកតាមចិត្ត*" ។

## ពីរឆ្នាំនៅព្រៃស

នៅដើមឆ្នាំ១៩៧៧ ខ្មែរក្រហមចាប់ផ្តើមតាមដានប្រវត្តិរូបរបស់ នៅ ។ ក្រោយមក គាត់ត្រូវបានផ្លាស់ទៅកន្លែងផ្សេងវិញ ។ នៅ នឹកក្នុងចិត្តដែរថា ប្រហែលជាមានបញ្ហាអ្វីកើតឡើងនៅឯផ្ទះហើយបានជាអង្គការដកឈ្មោះគាត់ដែលត្រូវចុះទៅតាមដានប្រវត្តិរូបយុទ្ធជន-យុទ្ធនារីនៅមូលដ្ឋានឲ្យទៅកន្លែងផ្សេងហើយដាក់អ្នកដទៃជំនួសវិញ ។ នៅ បានសុំឲ្យអ្នកដែលចុះទៅតាមដានប្រវត្តិរូបនៅមូលដ្ឋានគាត់ប្រាប់ពីស្ថានភាពក្រុមគ្រួសារគាត់នៅឯស្រុកផង ។ ពេលត្រឡប់មកវិញអ្នកតាមដានប្រវត្តិរូបនោះប្រាប់គាត់ថា ក្រុមគ្រួសាររបស់គាត់ដែលនៅសហករណ៍នោះលំបាកខ្លាំងណាស់ ។ រៀបការមិនបានប៉ុន្មានខែផង អ្នកទាំងពីរត្រូវអង្គការបញ្ជូនទៅព្រៃសជាបន្តបន្ទាប់ ។ "*គេ(ថ្នាក់លើ)បញ្ជូនខ្ញុំទៅជុំប្តីដែលគេដកចេញពីអង្គភាព ។ ខ្ញុំមិនទាន់ដល់ព្រៃសភ្លាមទេ ខ្ញុំនៅជួបជុំប្តីបានមួយខែដែរ ទើបដកប្តីខ្ញុំចេញទៅ ។ ពីរបីថ្ងៃក្រោយ ទើបគេបញ្ជូនខ្ញុំមកតាមក្រោយ*" ។ នៅ សន្និដ្ឋានថាប្រហែលមកពីមូលហេតុបួនយ៉ាងដែលនាំឲ្យគាត់ជាប់គុកព្រៃស ទីមួយ ប្តីគាត់ជាកូនចៅរបស់ តាអឿន ប្រធានកងពល៣១០ នៅភូមិភាគឧត្តរត្រូវអង្គការចាប់ខ្លួន ។ ទីពីរ គាត់មកពីភូមិភាគបូព៌ាដែលគ្រប់គ្រងដោយ សោ ភឹម ត្រូវអង្គការចាប់ខ្លួនដោយចោទថាក្បត់សមគំនិតជាមួយវៀតណាម ។ ទីបី បងថ្លៃម្នាក់មកពីហាណូយធ្វើការនៅក្នុងចង្កោមគណៈតំបន់២០ ។ និងទី៤ ដោយសារគាត់ធ្វើការនៅភស្តុភារសេនាធិការយាមឃ្លាំងគ្រាប់នៅភ្នំពេញ ហើយធ្លាប់ប្រឆាំងជាមួយប្រធានអង្គភាពស-៨០ ព្រោះគាត់បានចោទប្រធានរបស់គាត់ថាបោះកន្ទុយបារីបង្កឲ្យមានភ្លើងឆេះនៅម៉ុំទួលគោកក្បែរឃ្លាំងគ្រាប់ ។ អង្គការឲ្យ នៅ ជាអ្នកតាមដានរឿងនេះ ប្រធានរបស់គាត់ចោទគាត់ថាតាមដានប្រវត្តិរូបរបស់គេ ។

មុនពេលចាប់ខ្លួនអង្គការបានស្នើ មឿន ឲ្យទៅរៀនសូត្រ ។ នៅ បានរៀបចំអីវ៉ាន់ និងជូនដំណើរប្តីឡើងឡាន ។ ប្តីរបស់ នៅ ដឹងខ្លួនថាច្បាស់ជាជាប់គុក ប៉ុន្តែមិនរត់ទេ ព្រោះគាត់ដឹងថា ប្រសិនបើរត់ ប្រពន្ធនិងកូននឹងត្រូវស្លាប់មិនខាន ព្រោះកាលណោះ នៅ មានផ្ទៃពោះជាង៤ខែ ។ ប្រហែលជាមួយខែក្រោយមក នៅ ត្រូវបញ្ជូនទៅលត់ដំដែរ ។ នៅ បានសួរប្រធាននារីថា ហេតុអ្វីបានជាបញ្ជូនគាត់មកទីនេះ ប្រធាននារីនោះឆ្លើយថាគេយកមក

ឲ្យលត់ដំ ព្រោះ ឯងធ្លាប់នៅទីក្រុង ។

មុនពេលទៅដល់គុកព្រៃស នៅ ត្រូវបានបញ្ជូនទៅលត់ដំនៅកន្លែងផ្សេងៗដូចជា ព្រែកត្នោត និងស្ទឹងជ្រៅនៅម្តុំតាខ្មៅ ។ នៅ បញ្ជាក់ថាមន្ទីរទាំងពីរនេះសម្រាប់ដាក់ជនជាប់សង្ស័យ ឬជនជាប់និន្នាការដើម្បីស្រាវជ្រាវបន្ថែមទៀត ។ កន្លែងលត់ដំនៅទីនោះមិនធ្ងន់ធ្ងរដូចនៅព្រៃសទេ ។ ការងាររបស់ នៅ គឺដាំដំណាំដូចជាពោត ល្ង សណ្តែក ។ ប្រហែលជា៥ខែក្រោយ នៅ សម្រាលបានកូនប្រុសមួយ ។ បន្ទាប់ពីសម្រាល កូនបានប្រហែលជាពីរសប្តាហ៍ ប្រធានសន្តិសុខបញ្ជូន នៅ ទៅមន្ទីរព្រៃសបានបីថ្ងៃក៏បញ្ជូនមកកាន់ស្ទឹងជ្រៅវិញ ។ នៅ ត្រូវបានចាត់តាំងឲ្យមើលថែទាំកុមាររហូតដល់កូនរបស់គាត់មានអាយុបីខែ ទើបបញ្ជូនទៅធ្វើស្រែវិញ ។ នៅ ប្រាប់ថាគាត់គ្មានអារម្មណ៍ខ្លាចទេ ពេលនោះ ព្រោះថា «យើងដឹងថាស្អែកងាប់ អីចឹងថ្ងៃហ្នឹងនិយាយឲ្យអស់ចិត្ត» ។

នៅ ធ្លាប់ត្រូវគេហៅឡើងឡានយកទៅសម្លាប់ពីរលើកដែរ ប៉ុន្តែបានរួចខ្លួនវិញដោយសារការហៅឈ្មោះច្រឡំត្រកូលទាំងពីរលើក ។ នៅ រំឭកថា «កំពុងតែដកស្ទូង ខ្ញុំមួរជើងខោប្រឡាក់ស្រមក ។ គេ(សន្តិសុខ)បក់ដៃហៅខ្ញុំ ។ ខ្ញុំថាលាងខ្លួនសិន ។ គេថាមិនបាច់ទេ ពេលខ្ញុំទៅដល់ឡាន គេឲ្យខ្ញុំឡើងឡាន ពេលឡើងទៅអង្គុយនៅលើឡានស្រាប់តែពេទ្យ វ៉ាន់ ដែលជួយចាក់ថ្នាំព្យាបាលជំងឺខ្ញុំស៊ីញ៉ូដៃឲ្យខ្ញុំថា «ចុះមកវិញច្រឡំត្រកូលទេ មិនមែនត្រកូលបងឯងទេ» ។ នៅ មិនដឹងថាពេទ្យ វ៉ាន់ នោះមានឋានៈអ្វីទេ ប៉ុន្តែគាត់បានជួយជីវិត នៅ ទាំងពីរលើក ។ នៅចុងឆ្នាំ១៩៧៨ កូនមីងស្លាប់ដោយសារលាប់កញ្ជ្រឹល ។


ជុំ នៅ

## ចាកចេញពីព្រៃស

នៅយប់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ នៅ និងអ្នកទោសជាច្រើន បាននាំគ្នារត់ចេញពីព្រៃសជាមួយកម្មាភិបាលខ្មែរក្រហមរាប់ម៉ឺននាក់ ។ ពេលទៅដល់ក្នុងព្រៃ នៅ ព្យាយាមរត់ចេញច្រើនដងដែរ ប៉ុន្តែរត់មិនរួច «យើងព្យាយាមរត់ចេញពីអង្គភាព តែរត់មិនរួច ។ គេ (កងទ័ពខ្មែរក្រហម) ចេះតែតាមទាន់ ។ គេមានសេះពីរ-បីក្បាលសម្រាប់កៀងយើងឲ្យទៅជាមួយ» ។ មានពេលមួយ នៅ បានរត់គេចហើយត្រូវកងទ័ពខ្មែរក្រហមចាប់បញ្ជូនទៅឲ្យ ឌុច សួរចម្លើយនៅម្តុំថ្មពួក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ ឌុច បានដកកាំភ្លើងខ្លីចេញពីចង្កេះមកភ្ជង់គាត់ត្រង់សៀតផ្កា ហើយ «សួរឈ្មោះខ្ញុំ ។ នៅ(ព្រៃស)ប៉ុន្មានខែប៉ុន្មានថ្ងៃ? ខ្ញុំឆ្លើយថា ខ្ញុំមកនៅពីរឆ្នាំហើយ ។ ឌុច បើកភ្នែកហើយនិយាយថា មិនដែលមានពីណានៅយូរអីចឹងទេ ។ ឌុច សួរទៀតថា ហេតុអីបានជាមិត្តនារីឯងនៅបានយូរដល់ទៅពីរឆ្នាំ?» ចម្លើយដែលគ្មានភាពតក់ស្លុតរបស់ នៅ ធ្វើឲ្យ ឌុច លាន់មាត់ថា «តាំងពីចេះសួរចម្លើយមក មិនដែលនរ-ណាឆ្លើយសើចទេ ។ ទើបតែមិត្តនារីឯងមួយ ម៉េចក៏មិនតក់ស្លុត?» តាមពិត នៅ ព្យាយាមរត់ចេញពីក្រុមខ្មែរក្រហមមែន តែរត់មិនរួចហើយត្រូវប្រធាននារីឈ្មោះ រី រាយការណ៍ទៅថ្នាក់លើ ។ ក្រៅពី ឌុច មានអ្នកយាមបួននាក់ទៀត ឈរភ្ជង់កាំភ្លើងនៅជុំវិញខ្លួនរបស់ នៅ ។ ឌុច សួរទៀតថា ហេតុអីបានជាចង់រត់ចេញពីអង្គភាព? នៅ បានឆ្លើយដោះសាថា គាត់មិនចង់រត់ទេ ប៉ុន្តែ គ្រាប់ហោះវ៉ឺតៗពីលើក្បាល បើមិនឲ្យក្រាប មិនឲ្យរត់ ធ្វើម៉េច ។ គ្មាននរណាទៅពាំងគ្រាប់ឈ្នះទេ» ។ ក្រោយពីសួរចម្លើយរួច នៅ ត្រូវដោះលែងមកវិញ ។ នៅ រស់នៅជាមួយខ្មែរក្រហមក្នុងព្រៃអស់រយៈពេលជិត៨ខែ ។ ពេល

ដែលការប្រយុទ្ធគ្នារវាងខ្មែរក្រហម និងកងទ័ពវៀតណាមមានសភាពកាន់តែខ្លាំងឡើង នៅ បានព្យាយាមរត់ចេញម្តងទៀត ។ នៅ បានរត់ទៅដល់គិរីរម្យក្នុងខេត្តកំពង់ស្ពឺ វង្វេងក្នុងព្រៃអស់មួយរយៈទៀត ទើបបានត្រឡប់មកដល់ផ្ទះវិញ ក្រោយពេលបុណ្យចូលឆ្នាំខ្មែរក្នុងឆ្នាំ១៩៨០ ។

**អតីតកាលដែលមិនត្រូវបំភ្លេច**

នៅពេលរំឭករឿងពីអតីតកាល នៅ និយាយថា "គ្រាន់តែឮពាក្យបដិវត្តន៍ ខ្ញុំណាយ ខ្ញុំស្អែតព្រោះគ្មានបានលទ្ធផលអ្វីទេ ខាតពេលវេលា ហើយជីវិតខ្លួនឯងសឹងតែមិនរស់ទៀត" ។ នៅ តែងតែនិយាយប្រាប់កូនៗរបស់អំពីជីវិតបដិវត្តន៍របស់គាត់ ជាពិសេសក្នុងអំឡុងពេលរស់នៅព្រៃសនិងនៅក្នុងព្រៃជាមួយខ្មែរក្រហម ។ លទ្ធផលចុងក្រោយ នៅ បាត់បង់អ្វីៗទាំងអស់ បាត់ប្តី កូន និងបងប្អូនទៀត ។ នៅ បាននិយាយថា "ពេលយើងធ្វើបដិវត្តន៍យើងចង់បានឲ្យល្អ តែដល់លទ្ធផលចុងក្រោយមកជាប់គុក អត់បាយ នៅក្នុងព្រៃវេទនាស្ទើរតែស្លាប់ខ្លួន ចំណែកក្រុមគ្រួសារនៅភូមិត្រូវបញ្ជូនទីណាត់ទីណែងបែកគ្នាអស់" ។

នៅ យល់ថា រឿងខ្មែរក្រហមមិនត្រូវបំភ្លេចចោលទេ ត្រូវតែមានឯកសារទុកឲ្យអ្នកជំនាន់ក្រោយសិក្សា ដើម្បីកសាងសង្គមមួយឲ្យល្អ ប្រសិនបើបំបិទចោលដោយគ្មានឯកសារ ឬគ្មានការបំភ្លឺពីអ្នកធ្លាប់ឆ្លងកាត់របបនេះទេ រឿងខ្មែរក្រហមនឹងសាបសូន្យ ។ ការកាត់ទោសមេដឹកនាំខ្មែរក្រហមមានប្រយោជន៍ពីរ ទី១) វាជាសារមួយប្រាប់ថាបើធ្វើអំពើបែបហ្នឹងត្រូវប្រវត្តិ-សាស្ត្រចារទុកកេរ្តិ៍ឈ្មោះដ៏អាស្រូវតកូនតចៅរហូត និងទី២) ឲ្យមនុស្សរំសាយគំនុំគុំកួនគ្នា មានការផ្សះផ្សា និងអធ្យាស្រ័យគ្នាដើម្បីរួបរួមគ្នាអភិវឌ្ឍន៍សង្គមជាតិ ។

**ឆាយ ណារឿន**

# ការទស្សនាសាជាថ្មីនៅទីតាំងប្រល័យពូជសាសន៍ និងការសិក្សាអំពីច្បាប់យុត្តិធម៌

ថ្ងៃទី២៧និង២៨ ខែមីនា ប្រជាជនចំនួន៤០នាក់និងមេដឹកនាំសាសនាអ៊ីស្លាម១០នាក់បានទៅទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង វាលពិឃាតជើងឯក បន្ទប់សវនាការនៃអង្គជំនុំជម្រះវិសាមញ្ញនិងមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ថ្ងៃទីមួយនៃកម្មវិធីត្រូវចាប់ផ្តើមដោយការដើរទស្សនានៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។ សារមន្ទីរនេះដែលជាមន្ទីរសន្តិសុខថ្នាក់មជ្ឈិមរបស់ប៉ុលពតមានដាក់តាំងរូបថតអ្នកទោសមន្ទីរស-២១រាប់ពាន់សន្លឹកនិងវត្ថុតាងយ៉ាងច្បាស់ ។ សម្រាប់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ដែលបានមកឃើញរូបថតទាំងនេះផ្ទាល់នឹងភ្នែកបានរំឭកឡើងវិញនូវបទពិសោធន៍ដ៏ឈឺចាប់របស់គាត់ ជាពិសេស បទពិសោធន៍នៃការបាត់បង់មនុស្សជាទីស្រឡាញ់របស់ខ្លួន ។

កម្មវិធីនេះមានអ្នកមកចូលរួមពីរនាក់ដែលធ្លាប់បានជួបគ្នាកាលពីសម័យខ្មែរក្រហម ប៉ុន្តែមានតែភាគីម្ខាងទេដែលចាំរឿងនេះ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មីង សើ ម៉ក ជាអ្នកចែកបបរ និងតា តាក សួ ជាអ្នកធ្វើការក្នុងកងកុមារ ។ នៅបូជនីយដ្ឋានវាលពិឃាតជើងឯក មីងម៉ក ត្រូវបានស្នើសុំឲ្យនិយាយរឿងរ៉ាវរបស់គាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ពេលកំពុងធ្វើបទសម្ភាសន៍ យើងសង្កេតឃើញ សើ ម៉ក មានអារម្មណ៍ភ័យខ្លាចដោយនិយាយបញ្ចេញសំឡេងតិចៗ ។ ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ មីងម៉ក ជួបប្រទះនូវរឿងរ៉ាវដ៏រន្ធត់ពីរគឺ ការសម្រាលកូនដ៏លំបាកនិងការចាប់ខ្លួនចោទពីបទខុសសីលធម៌ជាមួយ"ប្រជាជនថ្មី" (ប្រជាជនទីក្រុងដែលខ្មែរក្រហមចាត់ទុកថាពុករលួយមិនស្អាតស្អំ) ។ ម៉ក មិនសូវបញ្ចេញពីទុក្ខលំបាកក្នុងពេលធ្វើការឡើយ គាត់គ្រាន់តែបង្ហើបឲ្យដឹងថាគាត់បង្កើតកូនស្រីដោយខ្លួនឯង ។ ថ្ងៃមួយ ម៉ក ត្រូវបានចោទពីបទខុសសីលធម៌ កម្មាភិបាលខ្មែរក្រហមបានសួរចម្លើយគាត់ ។ ម៉ក បានបដិសេធការចោទប្រកាន់នេះ ។ ម៉ក ធ្លាប់ធ្វើការជាមួយ

ប្រជាជនថ្មីម្នាក់ ហើយ ម៉ក សង្ស័យថា ប្រហែលជាប្រជាជនមូលដ្ឋានរាយការណ៍បំផ្លើសពីរឿងគាត់ហើយ ។

មានព្រឹត្តិការណ៍មួយដែល ម៉ក មិនបានរំពុក ។ រឿងនោះកើតឡើងនៅរវាងឆ្នាំ១៩៧៥និង១៩៧៨ ពេលដែលគាត់ធ្វើការជាអ្នកចែកបបរឲ្យអ្នកជំងឺនៅតាមផ្ទះ ។ គោលការណ៍ចែករបបនៅពេលនោះគឺមនុស្សម្នាក់ទទួលបានបបរមួយវែក ។ ប្រសិនបើអ្នកជំងឺសុំបបរថែមមួយវែក ម៉ក តែងតែថែមឲ្យមិនដែលខានឡើយ ។ ពេលអ្នកធ្វើការជាមួយគាត់សួរគាត់ថា មិនខ្លាចមានរឿងដោយសារធ្វើការខុសគោលការណ៍អង្គការទេឬ ម៉ក ឆ្លើយវិញថាគាត់ខ្លាច តែមានអ្នកជំងឺច្រើនណាស់ស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរ ។

យោងតាមសម្ដី តាក សួ ឲ្យដឹងថា ម៉ក បដិសេធមិនឲ្យបបរ ។ នៅពេលនោះ សួ មានអាយុទើបតែ៦ឆ្នាំប៉ុណ្ណោះ ប៉ុន្តែគាត់ចាំច្បាស់ថា ម៉ក មិនព្រមចែកបបរឲ្យប្អូនប្រុសគាត់ដែលមានរូបរាងស្គមកំព្រឹងទេ ។ សួ និងប្អូនគាត់ដែលពេលនោះស្ថិតក្នុងកងកុមារធ្វើជី ។ បងប្អូនបង្កើតរបស់គាត់៥នាក់ទៀតត្រូវបញ្ជូនទៅកងកុមារផ្សេងៗគ្នា ។ ជារៀងរាល់ថ្ងៃ គាត់ត្រូវក្រោកពីព្រលឹមស្រាងៗដើម្បីធ្វើការ ។ ដោយសារការហូបមិនគ្រប់គ្រាន់បណ្ដាលឲ្យខ្លួនគាត់កើតជំងឺហើម ។ នៅពេលយប់ស្ងាត់ សួ ចេញទៅលួចចំណីយកមកហូបជាមួយប្អូន ។ ថ្ងៃមួយ ប្អូនគាត់ស្រែកយំព្រោះឃ្លានខ្លាំង ។ ព្រដូច្នោះ សួ សម្រេចចិត្តកាន់ចាននាំប្អូនដើរទៅសុំបបរនៅសហករណ៍មួយទៀតដែលមាន ម៉ក ធ្វើការនៅសហករណ៍នោះ ។ សួ សុំបបរពីគាត់យកមកឲ្យប្អូនដែលកំពុងតែឃ្លានខ្លាំង ប៉ុន្តែ ម៉ក មិនព្រមឲ្យ ហើយថែមទាំងគំរាមចង់វៃគាត់និងប្អូនទៀតផង ។ ទាំងពីរនាក់បងប្អូនយំហើយដើរត្រឡប់ទៅសហករណ៍ខ្លួនវិញ ។ សព្វថ្ងៃបងប្អូនទាំងពីរនាក់រស់នៅក្នុងភូមិជាមួយគ្នា ។

សួ និយាយថា ពីដំបូងគាត់ខឹង ម៉ក ខ្លាំងណាស់ ប៉ុន្តែមិនយូរប៉ុន្មានកំហឹងក៏រលាយបាត់អស់ ។ ក្នុងនាមជាមនុស្សវ័យកណ្ដាលម្នាក់ ពេលគាត់ក្រឡេកមើលអតីតកាលគាត់ជឿថា ប្រសិនបើ យាយម៉ក ឲ្យបបរគាត់ថ្ងៃនោះ ម្ល៉េះ យាយម៉ក ច្បាស់ជាមានរឿងមិនខាន ។ សួ ធ្លាប់បានសួរ យាយម៉ក ពីរឿងនេះពីរបីដងដែរ ប៉ុន្តែ យាយម៉ក និយាយថា គាត់មិនចាំរឿងបងប្អូនពីរនាក់សុំបបរទេ ។ នេះប្រហែលជា យាយម៉ក មិនចាំរឿងក្មេងប្រុសពីរនាក់យំសុំបបរក្នុងចំណោមមនុស្សរាប់រយនាក់ដែលគាត់ចែកបបរឲ្យនោះមែន ។ ចំពោះ សួ វិញ យាយម៉ក ជាមនុស្សម្នាក់ដែលគាត់ចងចាំក្នុងចិត្តរហូត ។

នៅវេលាម៉ោង៣រសៀល ប្រជាជនដែលចូលរួមដំណើរទស្សនកិច្ចបានទៅដល់បន្ទប់សវនាការនៃអង្គជំនុំជម្រះវិសាមញ្ញ ។ មន្ត្រីទទួលបន្ទុកផ្នែកព័ត៌មាន លោក រាជ សម្បត្តិ មានវត្តមាននិងរង់ចាំទទួលស្វាគមន៍យ៉ាងកក់ក្ដៅ ។ កូនសៀវភៅណែនាំពីព័ត៌មានអង្គជំនុំជម្រះវិសាមញ្ញត្រូវបានចែកចាយដល់ប្រជាជនខណៈដែលគាត់ទាំងអស់គ្នាចូលអង្គុយតាមកន្លែង ។ លោក រាជ សម្បត្តិ បានចែករំលែកព័ត៌មានទូទៅស្ដីពីអង្គជំនុំជម្រះវិសាមញ្ញ បន្ទាប់មកបុគ្គលិកជាតិនិងអន្តរជាតិ ថ្នាក់សវនាការ (សាលាដំបូងនិងសាលាកំពូល) ផ្ដល់ព័ត៌មានថ្មីៗទាក់ទិននឹងដំណើរការតុលាការ ។ សំណួរដែលលើកឡើងរួមមាន ហេតុអ្វីបានជាមេដឹកនាំខ្មែរក្រហមសម្លាប់ប្រជាជនគ្នាឯង? តើអ្នកណានឹងត្រូវយកមកកាត់ទោសខ្លះ? តើប្រទេសដែលជាប់ពាក់ព័ន្ធទាំងប៉ុន្មាននឹងត្រូវយកមកកាត់ទោសទេ? ហេតុអ្វីបានជាទោសធ្ងន់បំផុត ត្រឹមដាក់គុកមួយជីវិត បើ ប៉ុល ពត សម្លាប់មនុស្សច្រើន? តើមានការសុំលើកលែងទោសនៅក្នុងច្បាប់កាត់ទោសខ្មែរក្រហមទេ? លោក រាជ សម្បត្តិ បានលើកបង្ហាញនូវផ្ទាំងរូបភាពអង្គជំនុំជម្រះវិសាមញ្ញនិងពន្យល់ពីអត្ថន័យនៃរូបភាពទាំងនោះ ។

លោក រាជ សម្បត្តិ បានលើកឡើងថា សំណួរនេះត្រូវបានចោទសួរជាច្រើនលើកហើយ ចំពោះការជាប់ពាក់ព័ន្ធរបស់បរទេសនៅក្នុងរយៈកាលរបបខ្មែរក្រហមនិងឆ្នាំបន្ទាប់នោះ ។

លោក អាឡិច បេត្យ មកពីការិយាល័យសហព្រះរាជអាជ្ញាបានធ្វើការបកស្រាយដ៏ល្អឥតខ្ចោះស្ដីពីផ្នែកមូលដ្ឋាននិងមុខងារនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមាន លី សុខឃាង ជាអ្នកជួយប្រែសម្រួលភាសាអង់គ្លេសមកភាសាខ្មែរ ។ អាឡិច បេត្យ បាននិយាយពីការិយាល័យព្រះរាជអាជ្ញាការិយាល័យមេធាវីការពារក្ដី និងការិយាល័យសហចៅក្រមស៊ើបអង្កេត និងបានពន្យល់បុគ្គលផ្សេងៗដែលត្រូវពាក់ព័ន្ធនឹងដំណើរការតុលាការនិងសវនាការ ។ អាឡិច បេត្យ បានកត់

សម្គាល់ថា “ជនរងគ្រោះជាមនុស្សសំខាន់នៅក្នុងដំណើរការទាំងមូល” តួនាទីរបស់ជនរងគ្រោះគឺជាសាក្សីឬជាអ្នកធ្វើពាក្យបណ្តឹង ។ ដំណើរការអង្គជំនុំជម្រះវិសាមញ្ញនេះធ្វើឡើងក្នុងបីដំណាក់កាលគឺ ការស៊ើបអង្កេតធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ការត្រួតពិនិត្យឡើងវិញនូវលទ្ធផលពីការស៊ើបអង្កេតនិងការសិក្សាស្រាវជ្រាវបន្ថែមធ្វើឡើងដោយការិយាល័យចៅក្រមស៊ើបអង្កេត ហើយការត្រួតពិនិត្យចុងក្រោយធ្វើឡើងដោយការិយាល័យសហព្រះរាជអាជ្ញានឹងមានសវនាការជាសាធារណៈ ។ អាឡិច បេត្ស បន្តថា បន្ទាប់ពីបានអានឯកសាររាប់ពាន់សន្លឹក ជួបសម្ភាសបុគ្គលមួយចំនួនដែលអាចជាអនាគតសាក្សីនិងបានទៅទស្សនាទីកន្លែងឧក្រិដ្ឋកម្មផ្សេងៗ ការិយាល័យសហព្រះរាជអាជ្ញាជិតបញ្ចប់ការងារស៊ើបអង្កេតដែលចាប់ផ្តើមតាំងពីខែកក្កដា ឆ្នាំ២០០៦ ។ អាឡិច បេត្ស ក៏បានលើកឡើងពីបញ្ហាបទបញ្ជាផ្ទៃក្នុងដោយសង្កត់ធ្ងន់ថា តុលាការនីមួយៗត្រូវការបទបញ្ជាផ្ទៃក្នុងជាចាំបាច់ ។

បន្ទាប់ពីបញ្ចប់ការស្រាយបំភ្លឺ អាឡិច បេត្ស ជំរុញឲ្យប្រជាជនសួរសំណួរ ។ សំណួរជាច្រើនដែលត្រូវបានសួរទាក់ទិននឹងការចោទប្រកាន់ក្នុងដំណើរការកាត់ក្តី ។ សំណួរទី១សួរថា ប្រសិនបើជនជាប់ចោទគ្មានវត្តមានក្នុងសវនាការ តើជនជាប់ចោទត្រូវបានកាត់ក្តីទេ? ២) តើមេដឹកនាំខ្មែរក្រហមថ្នាក់ណានឹងយកមកកាត់ទោស ឬថាតើមានលក្ខណៈណាខ្លះដែលអាចចាត់ថា បុគ្គលមួយជាមេដឹកនាំជាន់ខ្ពស់? ទី៣) ប្រសិនបើមេដឹកនាំជាន់ខ្ពស់ភាគច្រើនស្លាប់អស់ តើតុលាការនឹងកាត់ទោសមេដឹកនាំថ្នាក់បន្ទាប់ឬទេ? ៤) តើនឹងមានរឿងអ្វីកើតឡើងប្រសិនបើជនជាប់ចោទម្នាក់កំហុសទាំងស្រុងលើ ប៉ុល ពត ឬមេដឹកនាំដទៃទៀតដែលបានស្លាប់ដោយមិនអាចមកបំភ្លឺរឿងនេះបាន?

នៅម៉ោង១១ លោក វ៉ាន់ថាន់ ពៅដារ៉ា បាននិយាយបង្ហាញពីសិទ្ធិរបស់ជនរងគ្រោះ និងជនចុងចោទនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ ការបង្ហាញនេះបន្តដោយកម្មវិធីសំណួរចម្លើយផងដែរ ។ កម្មវិធីទាំងអស់ត្រូវបានបញ្ចប់នៅវេលាថ្ងៃត្រង់ ។


យុវសិស្សឡើងសួរសំណួរនៅក្នុងអគារសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

នៅព្រឹកថ្ងៃពុធ ដោយអវត្តមានរបស់វាគ្មិនដែលមិនមានការគ្រោងទុកជាមុន លោក ឌី ខាំបូលី ជាអ្នកនិពន្ធសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យបានរៀបរាប់អំពីសៀវភៅរបស់ខ្លួនឲ្យប្រជាជនស្តាប់និងទស្សនាខ្សែភាពយន្តឯកសារ“នៅគៀនជញ្ជាំងមន្ទីរស-២១” ។ ខ្សែភាពយន្តនេះនិយាយអំពីជីវិតអ្នកទោសមន្ទីរស-២១ ដោយលើកនូវបទពិសោធន៍របស់ជនរងគ្រោះបីនាក់ក្នុងនោះ មានពីរនាក់ជាអតីតអ្នកទោសនិងម្នាក់ទៀតជាឆ្មាំគុកថ្នាក់មជ្ឈិម ។ មនុស្សទាំងបីនាក់មានរឿងរ៉ាវប្រកបដោយឥទ្ធិពលនិងគួរឲ្យចាប់អារម្មណ៍ ប៉ុន្តែការរៀបរាប់របស់អ្នកទាំងបី ចំពោះព្រឹត្តិការណ៍តែមួយគឺខុសៗគ្នា ។ ដូចគ្នានឹង

រឿង យាយម៉ក មិនចាំ ពូស្លូ និងប្អូនប្រុសគាត់កាលនៅកុមារភាពដែរ អតីតឆ្មាំមន្ទីរស-២១ មិនចាំពីទំនាក់ទំនងរបស់ខ្លួនជាមួយអ្នកទោសទាំងពីរនាក់ឡើយ ។ ពេលដែលខ្សែភាពយន្តឯកសារនេះបញ្ចាំងចប់ លី សុខឃាង បានលើកទឹកចិត្តឲ្យប្រជាជនមានយោបល់លើខ្សែភាពយន្តនេះ ។

បន្ទាប់មក បូលី បានលើកឡើងនូវការពិភាក្សាពីសៀវភៅ “ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ” ដែលខ្លួនសរសេរនិងបញ្ចូរអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។ សៀវភៅនេះទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជាឲ្យប្រើប្រាស់ជាឯកសារពិគ្រោះនៅតាមសាលារៀន ។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងបង្កើតវគ្គបណ្តុះបណ្តាលសម្រាប់លោកគ្រូអ្នកគ្រូអំពីវិធីសាស្ត្របង្រៀនសិស្សវិទ្យាល័យស្តីពីអំពើប្រល័យពូជសាសន៍ដែលប្រព្រឹត្តក្នុងអំឡុងឆ្នាំ១៩៧៥ដល់១៩៧៩ ។ បន្ទាប់ពីបញ្ចប់ការណែនាំពីសៀវភៅសិក្សានេះ មានសំណួរចំនួនប្រាំត្រូវបានលើកឡើង ១) ហេតុអ្វីបានជាសហគមន៍អន្តរជាតិមិនជួយធ្វើអន្តរា-គមន៍ ពេលដែលការសម្លាប់កំពុងកើតមាន? ២) តើ ខៀវ សំផន មានមុខតំណែងនិងភារកិច្ចទទួលខុសត្រូវអ្វីខ្លះក្នុងរបបខ្មែរក្រហម? ៣) ហេតុអ្វីបានជាខ្មែរក្រហមនិងវៀតណាមវាយប្រហារគ្នាទៅវិញទៅមកពេលរបបខ្មែរក្រហមជិតរលំ ព្រោះកាលពីដើម ភាគីទាំងពីរធ្លាប់សហការគ្នា? ៤) តើមានប្រទេសណាខ្លះដែលដាក់ស្ថានទូតនៅប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហម? ៥) ហេតុអ្វីបានជាស្ថានទូតទាំងនោះមិនផ្សព្វផ្សាយពីព្រឹត្តិការណ៍ក្នុងស្រុកឲ្យពិភពលោកបានដឹង? សំណួរទាំងនេះបង្ហាញពីអារម្មណ៍ដែលប្រជាជនមួយចំនួនគិតចំពោះការចូលរួមពីសហគមន៍អន្តរជាតិ ឬកង្វះខាតការចូលរួមពីសហគមន៍អន្តរជាតិនៅក្នុងរយៈកាលរបបប្រល័យពូជសាសន៍និងក្រោយរបបនោះដួលរលំ ។

សម្រាប់ប្រជាជនមកពីខេត្តបន្ទាយមានជ័យចំនួន៤០នាក់ នេះជាលើទីមួយ ហើយដែលគាត់បានមកទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង វាលពិឃាតជើងឯក និងបន្ទប់សវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សម្រាប់មេដឹកនាំ សាសនាអ៊ីស្លាម១០នាក់ ទោះបីជានេះជាលើកទី២ សម្រាប់គាត់ទាំងអស់គ្នាក៏ដោយ ក៏ដំណើរទស្សនកិច្ចនេះនៅតែធ្វើឲ្យគាត់រំជួលចិត្ត ។ មេដឹកនាំសាសនាអ៊ីស្លាមម្នាក់ដែលត្រូវបានហៅថា ហាកឹម (គ្រូបង្រៀនសាសនាអ៊ីស្លាម) បានដើរជុំវិញបរិវេណវាលពិឃាតជើងឯកដោយទឹកមុខមាំ ហើយសរសេរដាក់លើបាតដៃឆ្វេងរបស់គាត់ ។

យើងសង្ឃឹមថា ប្រជាជនមានវត្តមានក្នុងកម្មវិធីនេះ មិនត្រឹមតែពាំនាំនូវរូបភាពដែលខ្លួនបានឃើញប៉ុណ្ណោះទេ ថែមទាំងទទួលបានចំណេះដឹងបន្ថែមពីរបបកម្ពុជាប្រជាធិបតេយ្យនិងសាលាក្តីខ្មែរក្រហម ។ ប្រជាជនមកចូលរួមមួយចំនួននឹងត្រូវអញ្ជើញម្តងទៀតឲ្យមកចូលរួមអង្គុយក្នុងកៅអីចំនួន៦០០ដើម្បីស្តាប់សវនាការនៅភ្នំពេញ ដែលនឹងចាប់ផ្តើមនៅចុងឆ្នាំ២០០៧ ។ នេះជាការសំខាន់ដែលប្រជាជនកម្ពុជាបានមកមើលឃើញនិងស្តាប់ផ្ទាល់ពីដំណើរការស្វែងរកយុត្តិធម៌ដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបង្កើតឡើងដើម្បីស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះពីរបបប្រល័យពូជសាសន៍ ។

គោលបំណងនៃកម្មវិធីនេះ គឺផ្តល់ការអប់រំអំពីដំណើរការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដល់សាធារណជនកម្ពុជា ជាពិសេសប្រជាជនរស់នៅតាមជនបទដែលស្ទើរតែគ្មានលទ្ធភាពទទួលបានព័ត៌មាន ។ អ្នកដែលចូលរួមនឹងក្លាយជាអ្នកពាំនាំព័ត៌មានទៅផ្សព្វផ្សាយតាមស្រុកភូមិ បន្ទាប់ពីគាត់វិលត្រឡប់ទៅភូមិឋានវិញ ។ នៅក្នុងអំឡុងរបបរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យកាន់អំណាចពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាមិនមានប្រព័ន្ធតុលាការឡើយ ។ បច្ចុប្បន្នតុលាការប្រព័ន្ធច្បាប់បារាំងគួបផ្សំ និងច្បាប់អន្តរជាតិនឹងកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមពីឧក្រិដ្ឋកម្មប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទោះបីជាប្រជាជនកម្ពុជាជាច្រើនគាំទ្រដំណើរការតុលាការដើម្បីយុត្តិធម៌មួយដើម្បីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមក៏ដោយ ក៏គាត់ទាំងអស់គ្នាយល់ដឹងតិចតួចណាស់ពីដំណើរការនេះ ។ ផ្នែកមួយជាឧបសគ្គនៃតុលាការគឺស្ថិតលើប្រជាជនខ្វះខាតការយល់ដឹងពីដំណើរការផ្លូវច្បាប់ ដែលប្រជាជនសាមញ្ញពិបាកនឹងយល់ ជាពិសេស ករណីដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

**កែវ ជាស៊ីល**

# ជនរងគ្រោះនៅតែចងចាំ

ចាប់តាំងពីការចាក់ផ្សាយភាពយន្តឯកសារ "វាលស្រែខ្មែរក្រហម ៖ រឿងរ៉ាវរបស់ជនរងគ្រោះម្នាក់ដោយការរំលោភផ្លូវភេទនៅក្នុងរបបខ្មែរក្រហម" ជាងពីរឆ្នាំកន្លងមកនេះ តាំង គីម ដែលជាតួអង្គសំខាន់ក្នុងរឿងនេះ តែងតែយល់សប្តិឃើញខ្មែរក្រហមធ្វើទារុណកម្មលើគាត់ ។

យើងបានចុះទៅសួរសុខទុក្ខ តាំង គីម នៅផ្ទះរបស់គាត់ក្នុងខេត្តកំពង់ឆ្នាំងកាលពីថ្ងៃព្រហស្បតិ៍ទី៥ ខែមេសា កន្លងទៅនេះ ។



តាំង គីម ឆ្នាំ២០០៧

ក្នុងខណៈពេលដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាពីរនាក់មានវត្តមាននៅមុខផ្ទះរបស់គាត់ តាំង គីម កំពុងតែឈរត្រួតពិនិត្យមើលជាងធ្វើផ្ទះជាច្រើននាក់ ដែលកំពុងពុះដើមត្នោតដ៏ធំមួយដើមជាពីរបំណែក ។ ភ្លាមនោះ តាំង គីម ដើរយ៉ាងលឿនមកទទួលយើងឲ្យចូលក្នុងបរិវេណផ្ទះ និងបន្ទាប់មករៀបចំកន្ទេលអង្គុយលេង ។ តាំង គីម មានរូបរាងស្គមស្តើង ដំណើរស្វាហាប់ ភ្នែកទាំងគូភ្លឺថ្លា បញ្ចេញស្នាមញញឹមដែលបង្កប់ជ្រៅដោយអត្ថន័យ ។

ដំណើរទៅដល់របស់យើងលើកនេះគឺគ្រាន់តែសួរសុខទុក្ខនិងពិនិត្យមើលស្ថានភាពរស់នៅបច្ចុប្បន្នរបស់គាត់ប៉ុណ្ណោះ ។ តាំង គីម បច្ចុប្បន្នមិនមែនជាដូនជីដូចនៅក្នុងភាពយន្តឯកសារដែលបានថតនៅក្នុងឆ្នាំ២០០៤នោះទេ ។ តាំង គីម កាត់សក់ខ្លីក្រោមត្រចៀកបន្តិចក្នុងសម្លៀកបំពាក់អាវពណ៌ក្រហមក្រមៅ និងខោពណ៌ខ្មៅ ។ នៅក្នុងពេលសម្ភាសន៍ តាំង គីម បានបញ្ចេញស្នាមញញឹមពីរបីលើក ក៏ប៉ុន្តែទោះជាយ៉ាងណានេះ ជាភស្តុតាងដែលបង្ហាញថា តាំង គីម កំពុងតែប្រឈមមុខនឹងបញ្ហាជាច្រើន ។ តើនោះជាបញ្ហាអ្វី?

អង្គុយលើកៅអីជ័រមួយ តាំង គីម រៀបរាប់អំពីដើមត្នោតចំនួនបួនដើមដែលត្រូវបានផ្តួលរលំថា ដើមត្នោតនេះត្រូវបានពុះជាច្រើនចម្រៀកដើម្បីយកមកធ្វើមេដំបូលនិងផ្ទោងផ្ទះថ្មី ពីព្រោះថា ផ្ទះចាស់របស់គាត់ត្រូវសត្វកណ្តៀរបំផ្លាញ ។ តាំង គីម សម្លឹងមើលគំនរឈើនិងដើមត្នោតមិនដាក់ភ្នែកជាមួយអារម្មណ៍សោកស្តាយនិងអាក់អន់ចិត្តនឹងជាងដែលបានផ្តួលរំលំដើមត្នោតដួលសង្កត់លើគំនរឈើ បណ្តាលឲ្យបាក់ឈើមេដំបូល ។ តាំង គីម បន្តថា អ្វីដែលធ្វើឲ្យគាត់ព្រួយបារម្ភខ្លាំង គឺខ្លាចដើមត្នោតរលំសង្កត់ផ្ទះ ព្រោះ នៅពេលខ្យល់បក់បោកខ្លាំងម្តងៗ ដើមត្នោតទាំងនេះទោរមកផ្ទះរបស់គាត់ដែលអាចនឹងបំផ្លាញផ្ទះ និងបង្កគ្រោះថ្នាក់ធំដល់ក្រុមគ្រួសារគាត់ ។ ម្យ៉ាងទៀត គាត់មិនមានថវិកាគ្រប់គ្រាន់សម្រាប់ទិញឈើមកសាងសង់ទេ ដូច្នេះមានតែវិធីនេះទើបអាចជួយកាត់បន្ថយការចំណាយរបស់គាត់បាន ។ ក្នុងខណៈដែលកំពុងសន្ទនាជាមួយ តាំង គីម នៅក្នុងខ្ទមតូចមួយ ជាងធ្វើផ្ទះកំពុងដាប់ដើមត្នោតយ៉ាងប្រញាប់ដៃនៅក្រោមកម្តៅហែងជាមួយនឹងដំបងឈើដ៏ធំដើម្បីដំដាប់បញ្ចូលដែកទៅក្នុងសាច់ត្នោតដើម្បីបំបែកដើមត្នោតចេញជាពីរចំណែក ។

តាំង គីម បច្ចុប្បន្នប្រកបមុខរបរលក់ខសជាមួយកូនៗ ។ ខសដែលរកបានត្រូវកាប់ជាដុំៗរួចចងជាបាច់តូចៗ ហើយយក

ទៅលក់ឲ្យអតិថិជននៅឯទីរួមខេត្ត ។ មុខរបរនេះអាចជួយដោះស្រាយជីវភាពបានមួយកម្រិត ក៏ប៉ុន្តែ ដោយសារតែចំនួនអ្នកកាប់ឈើកាន់តែច្រើន បានធ្វើឲ្យចំនួនឈើដែលគាត់អាចកាប់បាននោះ ចុះថយពីមួយឆ្នាំទៅមួយឆ្នាំ ។ «ដើមឈើធំៗទាំងអស់ត្រូវបាត់បង់អស់ជាច្រើនឆ្នាំកន្លងមកហើយ» ប្រការនេះ បានធ្វើសេដ្ឋកិច្ចគ្រួសាររបស់គាត់ជួបការលំបាក ។ តាំង គីម លាចាកពីការសាងផ្នួសនេះដោយសារតែកូនទាំងបីត្រូវការភាពកក់ក្តៅពីគាត់ ម្យ៉ាងទៀតមកពីបញ្ហាសុខភាពនិងការព្រួយបារម្ភអំពីអនាគតកូនទាំងពីរដែលមិនទាន់រៀបការផង ។

ការបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ មិនមែនមានន័យថាជាទីបញ្ចប់នៃការឈឺចាប់និងកំហឹងសម្រាប់អ្នកដែលរួចជីវិតពីរបបនោះទេ ។ តាំង គីម ស្វែងយល់ថា ការបួសធ្វើជាដូនជីអាចជួយកាត់បន្ថយនូវកំហឹងនិងសេចក្តីសោកសៅរបស់គាត់បាន ។ ព្រោះថា ក្នុងរយៈពេលដែលគាត់ទៅសុំសីលនៅឯវត្តនិងរៀនធម៌ គាត់ពុំសូវយល់សប្តិអាក្រក់ឡើយ ហើយសុខភាពផ្លូវចិត្តរបស់គាត់ក៏ធូរស្រាលជាងមុនដែរ ។ ការតាំងអារម្មណ៍ដោយសូត្រតាមសៀវភៅធម៌ពេញមួយថ្ងៃ បានធ្វើឲ្យអារម្មណ៍របស់គាត់បំភ្លេចអស់នូវបញ្ហាជាច្រើន ជាពិសេសអតីតកាលដែលយោធាខ្មែរក្រហមមួយក្រុមរំលោភគាត់កាលពី៣១ឆ្នាំមុន ។ ក៏ប៉ុន្តែចាប់តាំងពីលាបួសពីជីវិតដូនជី សប្តិអាក្រក់បានលេចឡើងវិញនៅក្នុងសុបិនរបស់ តាំង គីម ជាញឹកញាប់ ។ តាំង គីម បានមានប្រសាសន៍ថា គាត់ទើបតែយល់សប្តិអាក្រក់កាលពីដើមសប្តាហ៍ ។ នៅក្នុងសុបិននោះ តាំង គីម ត្រូវយោធាខ្មែរក្រហមដេញចាប់ក្នុងពេលយប់ដ៏ងងឹតមួយ ។ សុបិននេះបានធ្វើ តាំង គីម ភ័យរន្ធត់ភ្ញាក់ឡើងទៅជាឈឺ ។ តាំង គីម បានឲ្យដឹងថា ដំណេករបស់គាត់ងាយនឹងរងនូវការរំខានខ្លាំងណាស់ សូម្បីសូរសំឡេងដែលបន្លឺឡើងតិចៗក៏អាចធ្វើឲ្យគាត់ភ្ញាក់បានដែរ ។ ក្រៅពីការឈឺក្បាលដោយការយល់សប្តិអាក្រក់ និងសម្រាន្តមិនស្កប់ស្កល់ធ្វើឲ្យគាត់ឈឺម្តងម្កាលដែរ ។ តាំង គីម នឹងវិលទៅរកជីវិតជាដូនជីវិញនៅពេលដែលអ្វីៗត្រូវបានដោះស្រាយរួច ដូចជាការសាងសង់ផ្ទះថ្មីនិងរៀបចំកូនទាំងពីរឲ្យមានគូស្រករចប់សព្វគ្រប់ ។

កូនប្រុសពៅរបស់ តាំង គីម ឈ្មោះ មាស ចន្ទី បាននិយាយថា ខ្លួនចង់ឲ្យម្តាយបន្តបួសជាដូនជីវិញ ពីព្រោះនៅពេលដែលគាត់នៅផ្ទះ គាត់តែងតែគិតឃើញបញ្ហាជាច្រើន បណ្តាលឲ្យគាត់ទៅជាឈឺក្បាលឬមានជំងឺ ។ ប្រសិនបើ គាត់សំណាក់នៅវត្តគាត់មានតែពេលវេលាអានសៀវភៅធម៌និងចូលរួមក្នុងពិធីបុណ្យផ្សេងៗប៉ុណ្ណោះដែលធ្វើឲ្យគាត់បំភ្លេចអតីតកាលបាន ។ ចន្ទី សង្ឃឹមថា បន្ទាប់ពីបញ្ចប់ថ្នាក់វិទ្យាល័យក្នុងរយៈពេលពីរឆ្នាំខាងមុខនេះ ខ្លួននឹងអាចស្វែងរកការងារធ្វើដើម្បីរកកម្រៃផ្គត់ផ្គង់ជីវភាពគ្រួសារ ហើយជួយម្តាយឲ្យវិលត្រឡប់ទៅបួសជាដូនជីវិញ ។ ចន្ទី ដែលចេះនិយាយភាសាអង់គ្លេសគួរសមនោះ ហាក់ដូចជាយុវជនដែលចង់ចេះចង់ដឹង ថ្វីបើស្ថានភាពគ្រួសាររបស់ខ្លួនជួបប្រទះនូវការខ្វះខាតក៏ដោយ ។ នៅពេលថ្ងៃ ចន្ទី ទៅរៀនអក្សរសាស្ត្រខ្មែរនៅសាលារៀនខេមរៈវង្សនិងនៅពេលល្ងាចទៅរៀនភាសាអង់គ្លេស ។ ថវិកាដែលមកពីការលក់ឌីវីឌីភាពយន្តឯកសារខាងលើត្រូវបានប្រគល់ជូន តាំង គីម សម្រាប់ចំណាយលើការសិក្សារបស់កូនប្រុសគាត់ ។

នៅពេលបញ្ចប់ការសិក្សា ចន្ទី មានបំណងចង់ធ្វើការងារនៅអង្គការក្រៅរដ្ឋាភិបាលមួយ ឬធ្វើជាគ្រូបង្រៀន ។ បច្ចុប្បន្ន ចន្ទីបង្រៀនភាសាអង់គ្លេសដល់ក្មេងជាច្រើននៅក្នុងភូមិ ។ នៅពេលទំនេរ ចន្ទី ចូលចិត្តរៀនភាសាអង់គ្លេសនិងទស្សនាវដ្តី «ស្វែងរកការពិត» ជាភាសាខ្មែរនិងភាសាអង់គ្លេសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ នៅពេលសួរថាតើ ចន្ទី ធ្លាប់បានសួរម្តាយអំពីរបបខ្មែរក្រហមដែរឬទេ? ចន្ទី បានឆ្លើយថា ពុំធ្លាប់សួរទេ ពីព្រោះមិនចង់ឲ្យគាត់មានការឈឺចាប់តទៅទៀត ។ តាំង គីម ក៏ត្រូវបានសួរផងដែរថា តើគាត់ធ្លាប់បាននិយាយប្រាប់កូនៗអំពីរឿងរ៉ាវអតីតរបស់គាត់ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ដែរឬទេ? គាត់ឆ្លើយថា ធ្លាប់និយាយប្រាប់ម្តងម្កាលដែរ ដោយលើកយកចំណុចខ្លះនៅក្នុងរបបខ្មែរក្រហមជាឧទាហរណ៍ដល់កូន នៅពេលកូនៗមានបុកពាមិនល្អ ឬធ្វើអ្វីមួយមិនសមបំណងនោះ ។ ទោះបីជាយ៉ាងណាក៏ដោយ តាំង គីម មិនអាចរៀបរាប់លម្អិតអំពីរឿងរ៉ាវជីវិតជូរចត់របស់គាត់ឲ្យកូនៗបានដឹងឡើយ គាត់ទុកឲ្យកូនរបស់គាត់ស្វែងយល់ដោយខ្លួនឯងប្រសើរជាងគាត់និយាយ ។ ចន្ទី

*សង្ឃឹមថា ការអប់រំអំពីរបបកម្ពុជាប្រជាធិបតេយ្យនឹងត្រូវបានដាក់បញ្ចូលបន្ថែមទៅក្នុងកម្មវិធីសិក្សារបស់សាលានៅថ្ងៃណាមួយជាមិនខាន ។*

*តាំង គីម មានជីវភាពរស់នៅប្រសើរជាងមុនបន្តិច មិនដូចពេលដែល តាំង គីម កំពុងថតភាពយន្តនៅក្នុងឆ្នាំ២០០៤នោះឡើយ ។ បន្ទាប់ពីនិយាយអំពីរឿងរ៉ាវរំលោភផ្លូវភេទរបស់គាត់នៅក្នុងបទសម្ភាសន៍នៃភាពយន្តឯកសារ តាំង គីម នៅតែមិនអាចកាត់បន្ថយកំហឹងនិងការឈឺចាប់របស់គាត់ឡើយ ។ កំហឹងនិងកង្វល់ទាំងនេះបានធូរស្រាលនៅពេលដែលគាត់សំណាក់នៅវត្តបួសជាដូនជី ។ ការឈឺចាប់និងកំហឹងទាំងនេះក៏បានវិលត្រឡប់មកជាមួយគាត់វិញ នៅពេលដែលគាត់វិលត្រឡប់មករស់នៅផ្ទះជាមួយកូនៗ ។ តាំង គីម សង្ឃឹមថាទៅថ្ងៃមុខ កូនៗរបស់គាត់នឹងមានគ្រួសារនិងរស់នៅយ៉ាងមានសេចក្តីសុខ នឹងអាចចិញ្ចឹមគាត់វិញនៅពេលគាត់ចាស់ ។ ដោយមានចំណង់បួសជាដូនជី តាំង គីម បានអះអាងថា គាត់នឹងមិនបោះបង់ការបួសជាដូនជីទេ “ខ្ញុំប្តេជ្ញាថា ស្លាប់ដោយស្លៀកពាក់ស្បង់ពណ៌ស” ។* **កែវ ជាស៊ីល**

# អ្នកបើករថយន្តដឹកអង្ករ

*ម៉ី ស៊ីលន់ អាយុ៥៦ឆ្នាំ ជាអតីតអ្នកបើករថយន្តដឹកអង្ករនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សព្វថ្ងៃគាត់ប្រកបរបរធ្វើចម្ការ ដាំអំពៅ ស្វាយចន្ទី ស្វាយ ដូង ខ្នុរ នៅក្នុងស្រុកស្ទឹងត្រែងជាមួយប្រពន្ធនិងកូន ។ ស៊ីលន់ ខស្សាហ៍និយាយពីប្រវត្តិរបស់គាត់ប្រាប់កូនចៅនិងក្មេងៗដែលកើតមិនទាន់របបខ្មែរក្រហមដើម្បីឲ្យដឹងពីភាពសាហាវរបស់របបនេះ ។*

*ស៊ីលន់ រៀនបានត្រឹមថ្នាក់ទី១០នៅសាលាបឋមសិក្សាក្នុងភូមិ ។ បន្ទាប់មក ស៊ីលន់ បានរៀនជំនាញដំឡើងនិងជួសជុលម៉ាស៊ីន និងចាប់ផ្តើមបម្រើការងារដំបូងជាមួយបងប្រុសនៅមន្ទីរសាធារណការខេត្ត(ស្ទឹងត្រែង) ដែលមានតួនាទីជាអ្នកបើកបរ ។ មួយរយៈខ្លី ស៊ីលន់ ត្រូវបានអនុញ្ញាតឲ្យបើកបររថយន្តដឹកដីដោយខ្លួនឯងនិងទទួលបានប្រាក់បៀវត្សរ៍៥០រៀលក្នុងមួយខែ ។ ជាមួយភាពប៉ិនប្រសប់ក្នុងការងារ ស៊ីលន់ បានទទួលតួនាទីជាភ្នាក់ងារដឹកជញ្ជូនខេត្តនិងទទួលបានប្រាក់បៀវត្ស១១០០រៀលក្នុងមួយខែ ។ ដោយមានជីវភាពធូរធារល្មម ស៊ីលន់ បានរៀបការប្រពន្ធក្នុងឆ្នាំ១៩៦៩ ។*

*ក្រោយខែមីនាឆ្នាំ១៩៧០ ស៊ីលន់ សម្រេចចិត្តឈប់បើករថយន្តឲ្យរដ្ឋការ ហើយប្រកបមុខរបរទិញនិងលក់ជ័រទឹកវិញ ។ ស៊ីលន់ ដើរប្រមូលទិញជ័រនៅតាមភូមិផ្សេងៗ ហើយយកទៅលក់បោះដុំឲ្យអ្នកធ្វើទូកនិងកាណូតនៅទីរួមខេត្ត ។ ឆ្លៀតពេលទំនេរ ស៊ីលន់ ធ្វើស្រែនិងចម្ការជាមួយប្រពន្ធបន្ថែមទៀតដើម្បីផ្គត់ផ្គង់ជីវភាព ។ ក៏ប៉ុន្តែភាពសុខសាន្តនៅក្នុងគ្រួសាររបស់ ស៊ីលន់ ត្រូវបានរសាយបាត់បន្តិចម្តងៗនៅពេលដែលកងទ័ពរំដោះចូលមកគ្រប់គ្រងក្នុងភូមិ-ឃុំរបស់គាត់ ។ ស៊ីលន់ និងប្រជាជននៅក្នុងភូមិទាំងឡាយក៏ដូចគ្នាដែរ គឺចាប់ផ្តើមផ្លាស់ប្តូររបៀបរបបក្នុងការរស់នៅ ។ កងទ័ពរំដោះបានបែងចែកប្រជាជនឲ្យរស់នៅជាក្រុម ជាពួក និងត្រូវបង្កបង្កើនផលតាមរបៀបប្រវាស់ដៃ ។ ស៊ីលន់ បានឈប់ប្រកបមុខរបរនេះ ហើយមកបង្កបង្កើនផលនៅក្នុងទឹកដីរំដោះវិញ ។*

*មួយរយៈខ្លីក្រោយមកប្រធានក្រុមប្រវាស់ដៃបានចាប់ផ្តើមស្រាវជ្រាវរកអ្នកចេះបើករថយន្ត ដើម្បីដឹកស្បៀងទៅកាន់តំបន់រំដោះផ្សេងទៀត ។ ដោយមានជំនាញខាងបើករថយន្តស្រាប់ ស៊ីលន់ បានចុះឈ្មោះបំពេញការងារ ដែលគាត់សង្ឃឹមថាការងារនេះ អាចផ្គត់ផ្គង់ជីវភាពគ្រួសាររបស់គាត់ដូចក្នុងរបបគ្រប់គ្រងមុនៗ ។ ក៏ប៉ុន្តែតួនាទីជាអ្នកបើករថយន្តនៅពេលនេះ មិនដូចពេលមុនឡើយ ។ ស៊ីលន់ ត្រូវចេញទៅធ្វើការឆ្ងាយពីប្រពន្ធនិងកូនទាំង៣នាក់ ។ យូរៗទើប ស៊ីលន់ អាចបានមកជួបសួរសុខទុក្ខក្រុមគ្រួសារម្តង ។*

*ក្រោយពេលកងទ័ពរំដោះវាយបានទីក្រុងភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ ប្រពន្ធនិងកូនរបស់ ស៊ីលន់ ត្រូវអង្គការរៀបចំឲ្យទៅរស់នៅក្នុងសហករណ៍គីឡូម៉ែត្រ១២ក្នុងនាមជាប្រជាជនមូលដ្ឋាន ។ ចំណែក ស៊ីលន់ កាន់តែមមាញឹកក្នុងការ*

ដឹកជញ្ជូនស្បៀងដាក់តាមសហករណ៍ផ្សេងៗ ។ ស៊ីលន់ តែងនឹកគិតពីសុខទុក្ខរបស់ប្រពន្ធនិងកូនជានិច្ច ក៏ប៉ុន្តែគាត់មិនអាចដកខ្លួនចេញពីក្រុមបើកបរមកវិញឡើយ ។ ស៊ីលន់ បានរំឭកថា “គេឲ្យខ្ញុំទៅ ខ្ញុំស្មានតែចូលហើយអាចមកសម្រាកផ្ទះវិញ ដល់នេះជាប់រហូត ។ ខ្ញុំទៅបើករថយន្តបាត់ តែគ្រួសារខ្ញុំនៅសហករណ៍ ។ ខ្ញុំបើករថយន្តរហូតអត់បាននៅជួបជុំប្រពន្ធកូនទេ” ។

ក្នុងនាមជាអ្នកបើករថយន្ត ស៊ីលន់ និងសមាជិកអ្នកបើកបរទាំង១២នាក់ ត្រូវអង្គការកំណត់ឲ្យរស់នៅផ្សេងពីអ្នកបង្កបង្កើនផល ។ ការងារដឹកជញ្ជូនស្បៀងមិនមានកំណត់ពេលវេលាធ្វើការច្បាស់លាស់ទេ ។ ស៊ីលន់ និងអ្នកបើកបរឯទៀតទទួលបញ្ជាដឹកជញ្ជូនស្បៀងឲ្យដល់គោលដៅ ទោះបីជាពេលថ្ងៃឬយប់ក៏ដោយ ។ នៅរដូវប្រមូលផល (sic) នៅរដូវប្រូតកាត់ ស៊ីលន់ មមាញឹកជាងខែធម្មតា ព្រោះថាអង្គការត្រូវបញ្ជូនស្រូវនិងអង្ករទាំងនោះទៅឲ្យសហករណ៍ផ្សេងទៀតឲ្យទាន់ពេលវេលា ។ ក្រោមបញ្ជាការផ្ទាល់ពីប្រធានក្រុម ស៊ីលន់ ចេញទៅដឹកស្រូវនិងអង្ករជាមួយតៃកុងអែបរបស់គាត់ និងសមាជិកផ្សេងទៀតដែលមានរថយន្តទាំងអស់១០គ្រឿង ។ ស៊ីលន់ រំឭកថា មុនពេលគាត់ចេញដំណើរទៅដឹកអង្ករម្តងៗ ប្រធានក្រុមតែងប្រាប់ពីផែនការការងារនិងទីតាំងជាមុន ហើយនៅពេលដឹកអង្ករទៅដល់ទិសដៅ គាត់ត្រូវទៅជួបមេកងឬប្រធានក្រុមប្រចាំការនៅទីកន្លែងនោះដើម្បីប្រាប់និងផ្ទេរអង្ករ រួចទើបបើករថយន្តទទេត្រឡប់មកវិញ ។

ចំពោះការហូបចុកវិញ ស៊ីលន់ មិនសូវជួបការលំបាកឬខ្វះខាតឡើយ ។ ស៊ីលន់ អាចឈប់ដាំបាយសម្រាប់ហូបខ្លួនឯងនៅពេលឃ្លាន ។ “កាលនោះរបបអាហារអីដូចថាមិនខ្វះដែរ ព្រោះយើងដឹកជញ្ជូនអង្ករ យើងដាំបាយខ្លួនឯង ហូបឆ្អែត មិនដូចនៅសហករណ៍ទេ ។ រឿងរបបអង្ករអត់កំណត់ទេព្រោះយើងអ្នកបើករថយន្ត ។ ធ្វើម៉េចឲ្យតែមានអង្ករនៅក្នុងរថយន្ត ។ អង្ករកន្លះបាវឬក៏ត្រឹម៣៨គីឡូក្រោមដាក់ប្រចាំជាប់ ខ្លាចរថយន្តខូចតាមផ្លូវ ។ កន្លែងណាថ្កុតត្រពាំង យើងនាំគ្នាបាចយកត្រីមកស្ងហូប” ។

ចាប់តាំងពីពេលចេញទៅបើករថយន្តជូនអង្គការ ស៊ីលន់ មិនសូវបានដឹងពីជីវភាពរស់នៅរបស់ប្រពន្ធនិងកូននៅឯសហករណ៍ទេ ព្រោះនៅពេលដែលគាត់ត្រូវបានអនុញ្ញាតឲ្យទៅលេងផ្ទះម្តងៗ ប្រធានសហករណ៍តែងរៀបចំនិងទទួលគាត់យ៉ាងសមរម្យ ។ ប៉ុន្តែមានម្តងនោះ ស៊ីលន់ បានដឹងថាប្រពន្ធនិងកូនរបស់គាត់ទទួលបានរបបបាយតែម្នាក់មួយចានចង្កឹះប៉ុណ្ណោះ ។ ប្រពន្ធរបស់គាត់ឈូសដំឡូងឈើធ្វើនំដើម្បីទុកឲ្យកូនហូបបន្ថែម ។

នៅខែមករាឆ្នាំ១៩៧៩ របបខ្មែរក្រហមត្រូវបានផ្តួលរំលំ ។ កងទ័ពនិងកម្មាភិបាលខ្មែរក្រហម បានភៀសខ្លួនទៅកាន់ភាគខាងលិចប្រទេស ។ ស៊ីលន់ បានធ្វើដំណើរត្រឡប់មករកក្រុមគ្រួសារនៅស្រុកស្ទឹងត្រែងវិញ ហើយបន្តអាជីពជាអ្នកបើករថយន្តរហូតដល់ឆ្នាំ១៩៩៣ដែលជាឆ្នាំបោះឆ្នោតសាកលលើកដំបូងនៅប្រទេសកម្ពុជា ។

ក្រោយពេលត្រឡប់មកកាន់ភូមិកំណើតវិញ ស៊ីលន់ និងសាច់ញាតិបាននិយាយប្រាប់គ្នាទៅវិញទៅមកពីជីវិតរបស់ខ្លួននៅក្នុងរបបខ្មែរក្រហម ហើយបានដឹងពីទុក្ខលំបាករបស់ប្រជាជននៅតាមសហករណ៍ ។ នៅពេលជាមួយគ្នានេះដែរ ស៊ីលន់ បានឮពីការនិយាយថា មានការសម្លាប់មនុស្ស និងបានឃើញផ្ទាល់នឹងភ្នែកនូវរណ្តៅសាកសពនៅភូមិគីឡូម៉ែត្រលេខ៤ និងកន្លែងសម្លាប់មនុស្សនៅក្នុងភូមិរាជានុកូលក្នុងស្រុកស្ទឹងត្រែង ។ “អ្នកជិតខាងទៅមកប្រាប់ថាបាត់អ្នកនេះ បាត់អ្នកនោះណា៎ ខ្ញុំចេះតែចាំមើលទៅ គ្មានហ៊ានមាត់ ខ្ញុំចាំមើល ។ ដល់មកដាក់ស្តែង យើងវ៉ៃបែកជនាន់ ប៉ុល ពត ហ្នឹង បានមកឃើញរណ្តៅកប់មនុស្សនៅគីឡូ៤ និងកន្លែងសម្លាប់មនុស្សនៅភូមិរាជានុកូល ។ រណ្តៅច្រើនណាស់ ។ មិនជឿម៉េច បើឃើញឆ្អឹងដែរ” ។

ស៊ីលន់ ក៏បានឮដំណឹងពីតុលាការកាត់ទោសខ្មែរក្រហមដែរ គាត់ក៏សង្ឃឹមថាតុលាការនឹងជួយរកយុត្តិធម៌ជូនជនរងគ្រោះនិងបង្កើតនូវបទដ្ឋានគំរូមួយដើម្បីពង្រឹងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ។

ការនិទានរឿងរ៉ាវផ្ទាល់ខ្លួនរបស់អ្នកធ្លាប់ឆ្លងកាត់របបខ្មែរក្រហមប្រាប់ដល់អ្នកដែលកើតក្រោយរបបនោះ ដូចដែល ស៊ីលន់ និយាយប្រាប់កូនចៅរបស់គាត់ គឺជាមធ្យោបាយមួយដ៏មានប្រសិទ្ធភាព បន្ថែមទៅលើចំណេះដឹងបន្តិចបន្តួចដែលកូនចៅរបស់គាត់ទទួលបាននៅឯសាលារៀន ឲ្យយល់ដឹងកាន់តែច្រើនពីប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួនដើម្បីការពារកុំឲ្យរបបនោះ កើតមានម្តងទៀតលើទឹកដីកម្ពុជា ។

**ណាយ សុផារី**

# យន្តការសាលាក្តីខ្មែរក្រហម : វិធាននីតិវិធី និង វិធានភស្តុតាង

*(តចប់)*

## *ការបង្ហាញនិងការពិនិត្យភស្តុតាង*

នៅក្នុងពេលជំនុំជម្រះក្តី ភស្តុតាងទាំងអស់ត្រូវយកមកបង្ហាញនិងត្រួតពិនិត្យនៅក្នុងតុលាការ ។ ភស្តុតាងទាំងនេះ រួមមានឯកសារនិងកសិណដែលបានពីសាក្សី ។ ចុងចោទក៏អាចផ្តល់ជាកសិណបានដែរ ទោះបីជាច្បាប់អង្គជំនុំជម្រះវិសាមញ្ញមិនតម្រូវឲ្យចុងចោទផ្តល់ជាកសិណក៏ដោយ ។ ដោយខុសពីប្រព័ន្ធច្បាប់ខមមិនឡ (ដែលមេធាវីជាអ្នកដឹកនាំការសួរចម្លើយ) នៅក្នុងប្រទេសកម្ពុជានិងនៅក្នុងប្រព័ន្ធច្បាប់រដ្ឋប្បវេណីដទៃទៀត ចៅក្រមត្រូវសួរចុងចោទនិងសាក្សី ហើយព្រះរាជអាជ្ញានិងមេធាវីការពារក្តី អាចចោទសួរជាសំណួរបន្ថែមទៅលើសំណួររបស់ចៅក្រម ។ សាក្សីខាងព្រះរាជអាជ្ញានឹងត្រូវសាកសួរមុនគេ និងបន្ទាប់មកបុគ្គលដែលត្រូវផ្តល់ជាកសិណដល់ខាងមេធាវីការពារក្តី ។

មុខងារសំខាន់នៃវិធានភស្តុតាងគឺការកំណត់បទដ្ឋានទាំងឡាយដែលចៅក្រមពិនិត្យនិងវាយតម្លៃលើព័ត៌មានទាក់ទិននឹងពិរុទ្ធភាពឬភាពគ្មានទោសរបស់ជនជាប់ចោទ ។ ទោះបីជាតុលាការនឹងទទួលយកភស្តុតាងដែលត្រូវបង្ហាញក្នុងទម្រង់ផ្សេងៗគ្នាជាច្រើនក៏ដោយ ចៅក្រមនឹងត្រូវពិចារណាតែលើព័ត៌មានណាដែលឆ្លើយតបទៅនឹងបទដ្ឋាននៃការទទួលយកភស្តុតាងប៉ុណ្ណោះ ។ នីតិវិធីព្រហ្មទណ្ឌកម្ពុជា អនុញ្ញាតឲ្យមានបទដ្ឋានទន់ភ្លន់សម្រាប់ការពិនិត្យភស្តុតាង ក៏ប៉ុន្តែអង្គជំនុំជម្រះវិសាមញ្ញប្រហែលជាតម្រូវឲ្យភស្តុតាងទាំងអស់មានលក្ខណៈសម្បត្តិជាក់លាក់មួយចំនួនដែលអាចទទួលយកបាន ។ ភស្តុតាងដែលប្រឆាំងនឹងអតីតមេដឹកនាំខ្មែរក្រហម នៅក្នុងតុលាការត្រូវមានការពាក់ព័ន្ធ ត្រូវមានភាពជាក់លាក់ និងត្រូវមានភាពត្រឹមត្រូវតាមច្បាប់ ។ បទដ្ឋាននៃការទទួលយកភស្តុតាងក្នុងកម្រិតអប្បបរមាទាំងនេះត្រូវបានបង្កើតឡើងដើម្បីអះអាងបញ្ជាក់ថាភស្តុតាងទាំងអស់ដែលបង្ហាញចំពោះមុខតុលាការមានការពាក់ព័ន្ធនឹងសំណុំរឿងក្តីនិងមានភាពអាចជឿទុកចិត្តបាន ។

ការទទួលយកភស្តុតាង ខុសពីទម្ងន់នៃភស្តុតាងដែលចៅក្រមនឹងដាក់បន្ទុកចំពោះភស្តុតាងមួយ បន្ទាប់ពីភស្តុតាងនេះត្រូវបានពិនិត្យរួច ។ ការទទួលយកជាភស្តុតាងមិនមែនមានន័យថា ចៅក្រមនឹងពឹងផ្អែកទៅលើភស្តុតាងនេះដើម្បីកំណត់ពិរុទ្ធភាព ឬភាពគ្មានទោសរបស់ចុងចោទនោះទេ ។ ទាំងព្រះរាជអាជ្ញា និងមេធាវីការពារក្តី ត្រូវបង្ហាញភស្តុតាងទាំងឡាយដែលមិនត្រឹមតែឆ្លើយតបទៅនឹងធាតុចាំបាច់នៃការទទួលយកភស្តុតាង តែថែមទាំងទទួលខុសត្រូវកំណត់អតិបរមានូវទម្ងន់នៃព័ត៌មានផង ។

*ការពាក់ព័ន្ធនិងតម្លៃប្រើប្រាស់នៃភស្តុតាង*

ភស្តុតាងនឹងត្រូវបានចាត់ទុកថាពាក់ព័ន្ធនិងមានតម្លៃប្រើប្រាស់ល្អិកណាការដាក់បង្ហាញភស្តុតាងទាំងនោះទៅក្នុងតុលាការអាចធ្វើឲ្យអង្គហេតុពិតប្រាកដមានលក្ខណៈជាក់ស្តែងបានកម្រិតណា ។ ការពាក់ព័ន្ធនៃភស្តុតាង រាប់បញ្ចូលទាំងតម្លៃប្រើប្រាស់នៃភស្តុតាង (ទំនោរដ៏សមហេតុសមផលក្នុងការបង្ហាញឬមិនបង្ហាញអង្គហេតុ) ព្រមទាំងវត្ថុតាង (ថាតើភស្តុតាងដែលផ្តល់ឲ្យមានពាក់ព័ន្ធទៅនឹងអង្គហេតុឬទេ ។ ភស្តុតាងដែលពាក់ព័ន្ធអាចជាភស្តុតាងដោយផ្ទាល់ ឬដោយប្រយោល ហើយសាលាក្តីខ្មែរក្រហមនឹងពិនិត្យមើលភស្តុតាងទាំងពីរប្រភេទនេះ ។

ភស្តុតាងដោយផ្ទាល់ ជាប្រភេទភស្តុតាងដែលមានអាចនាំឲ្យរកឃើញដោយផ្ទាល់នូវអំពើឧក្រិដ្ឋ ឬឧក្រិដ្ឋជន ។ ជាឧទាហរណ៍ នៅក្នុង អង្គជំនុំជម្រះវិសាមញ្ញ ភស្តុតាងដោយផ្ទាល់ មានភស្តុ-តាងកោសល្យវិច័យដែលបង្ហាញអំពីមធ្យោបាយសម្លាប់ជនរងគ្រោះ ឬឯកសារដែលបញ្ជាក់ថាជាឯកសារដើមពិតប្រាកដដែលបង្ហាញថា មេបញ្ជាការខ្មែរក្រហមបានបង្គាប់បញ្ជាឲ្យអ្នកនៅក្រោមបង្គាប់របស់ខ្លួនសម្លាប់“ខ្មាំង” ។ ដោយឡែក ភស្តុតាងប្រយោលមិនបានផ្តល់នូវទំនាក់ទំនងផ្ទាល់ទេ ក៏ប៉ុន្តែ ភស្តុតាងបែបនេះបង្ហាញនូវទំនាក់ទំនងមួយដែលអាចនាំឲ្យមានការសន្និដ្ឋានបានថា អង្គហេតុដែលចោទប្រកាន់មួយមានពិតឬមិនពិត ។ ភស្តុតាងដោយប្រយោលមិនមែនមិនសូវមានការទាក់ទងច្រើន

ជាងភ័ស្តុតាងទេ ក៏ប៉ុន្តែបើមានតែភ័ស្តុតាងដោយប្រយោលតែមួយគត់នោះ វានឹងមិនគ្រប់គ្រាន់ដើម្បីបង្ហាញឲ្យឃើញការពិត ឬមិនពិត ស្តីពីអង្គហេតុតាមការចោទប្រកាន់នោះឡើយ ។ ដូច្នេះ ភ័ស្តុតាងដោយប្រយោលដែលមានលក្ខណៈបញ្ចុះបញ្ចូលបំផុត ត្រូវបានបញ្ជាក់ឡើងតាមរយៈចំណែកខ្វះនៃភ័ស្តុតាងដោយផ្ទាល់ ឬភ័ស្តុតាងដោយប្រយោលដូចជាកសិណសាក្សីជាដើម ។ តាមមធ្យោបាយនេះ ភ័ស្តុតាងដោយផ្ទាល់ និងភ័ស្តុតាងដោយប្រយោលបូកបញ្ចូលគ្នាបង្ហាញពីសាច់រឿងទាំងមូល ។

ប្រការដែលថាទំនាក់ទំនងនៃភ័ស្តុតាងដើរតួនាទីសំខាន់ច្រើន ឬតិចក្នុងការទទួលយកភ័ស្តុតាង គឺអាស្រ័យលើប្រភេទនៃប្រព័ន្ធច្បាប់ ។ ប្រព័ន្ធច្បាប់ខមមិនឡ ដូចជាប្រព័ន្ធច្បាប់ខមមិនឡសហរដ្ឋអាមេរិកជាដើម បានដាក់កំហិតនូវបទដ្ឋានទំនាក់ទំនងដ៏តឹងរ៉ឹង ពីព្រោះប្រព័ន្ធច្បាប់ទាំងនេះ ពឹងផ្អែកទៅលើក្រុមប្រឹក្សាតំណាងប្រជាជនដែលជាអ្នកវិនិច្ឆ័យអង្គហេតុ ។ តម្រូវការចាំបាច់ជាបឋម ដូចជាទំនាក់ទំនងភ័ស្តុតាងជាដើម គឺភ័ស្តុតាងនេះពុំត្រូវមានលក្ខណៈរើសអើងចំពោះអ្នកវិនិច្ឆ័យ ។ ផ្ទុយទៅវិញ ប្រព័ន្ធច្បាប់រដ្ឋប្បវេណី ផ្តល់ភាពទន់ភ្លន់យ៉ាងទូលំទូលាយជាងក្នុងការពិនិត្យភ័ស្តុតាង ពីព្រោះអ្នកស្វែងរកអង្គហេតុ គឺជាចៅក្រមដែលមានវិជ្ជាជីវៈត្រឹមត្រូវដែលមិនងាយនឹងទទួលរងនូវការរើសអើងក្នុងករណីដែលប្រឈមមុននឹងភ័ស្តុតាងដែលមានលក្ខណៈរើសអើង ។

ជាទូទៅ តុលាការអន្តរជាតិ អនុវត្តនូវបទដ្ឋានទទួលយកភ័ស្តុតាង ដែលមានលក្ខណៈទន់ភ្លន់នៅក្នុងប្រព័ន្ធច្បាប់រដ្ឋប្បវេណី បើទោះបីជាតុលាការអន្តរជាតិបានបញ្ចូលធាតុផ្សំមួយចំនួននៃប្រព័ន្ធច្បាប់ខមមិនឡក៏ដោយ ។ ជាឧទាហរណ៍ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងរ៉្វាន់ដា មិនបានត្រួតពិនិត្យភ័ស្តុតាងទេ នៅពេលដែលប្រសិទ្ធភាពដែលអាចបង្កឲ្យមានគ្រោះថ្នាក់ដល់ភ័ស្តុតាងនេះសំខាន់ជាងតម្លៃបញ្ជាក់នៃភ័ស្តុតាង ។ ជាឧទាហរណ៍ នៅក្នុងសំណុំរឿងក្តីសម្លាប់រង្គាល រូបថត និងរឿងរ៉ាវដ៏គួរឲ្យតក់ស្លុតផ្សេងៗអាចចាត់ចូលទៅក្នុងប្រភេទភ័ស្តុតាងបញ្ជាក់ដែលត្រូវយកមកបង្ហាញនៅក្នុងតុលាការ ។ ក៏ប៉ុន្តែ ការទទួលយករូបថតធ្វើជាភ័ស្តុតាង មានការរើសអើងនិងប៉ះពាល់ទៅដល់អារម្មណ៍អ្នកវិនិច្ឆ័យចំពោះចុងចោទ ។ ក្នុងករណីដែលតុលាការជឿជាក់ថា ការរើសអើងបែបនេះនឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់តម្លៃប្រើប្រាស់នៃភ័ស្តុតាង ភ័ស្តុតាងបែបនេះនឹងមិនត្រូវបានរាប់បញ្ចូលឡើយ ។ ចៅក្រមដែលមានវិជ្ជាជីវៈនៅក្នុងប្រព័ន្ធច្បាប់រដ្ឋប្បវេណី ទំនងជាមិនរើសអើងចំពោះភ័ស្តុតាងបែបនេះ ជាងចៅក្រមក្នុងប្រព័ន្ធច្បាប់ខមមិនឡ ។ ដូចនេះ វាមិនប្រាកដដែរថាសាលាក្តីខ្មែរក្រហមនឹងមិនរាប់បញ្ចូលភ័ស្តុតាងជាច្រើនទាំងនេះដោយផ្អែកលើមូលដ្ឋាននេះឡើយ ។

*ភាពដែលអាចជឿទុកចិត្តបាននៃភ័ស្តុតាង*

ភ័ស្តុតាងមួយត្រូវតែមានលក្ខណៈអាចជឿទុកចិត្តបាន មុននឹងបញ្ជូនទៅតុលាការពិនិត្យ ។ ភ័ស្តុតាងស្ថិតក្នុងទម្រង់ជាច្រើន ក៏ប៉ុន្តែចៅក្រមទំនងជានឹងប្រើប្រាស់ទម្រង់ភ័ស្តុតាងមួយចំនួនដែលអាចជឿទុកចិត្តបានជាងទម្រង់ភ័ស្តុតាងដទៃទៀត ។ ភ័ស្តុតាងមានសេចក្តីទុកចិត្តកាន់តែច្រើន ចៅក្រមអាចវិនិច្ឆ័យ ពិរុទ្ធភាព ឬភាពគ្មានទោសរបស់ចុងចោទបានកាន់តែខ្លាំង ។ ជាការពិតណាស់ រាល់ទម្រង់នៃភ័ស្តុតាងសុទ្ធតែមានគុណសម្បត្តិ និងគុណវិបត្តិ ។ ជាទូទៅ ភ័ស្តុតាងជាឯកសារត្រូវបានចាត់ទុកជាប្រភេទភ័ស្តុតាងដែលអាចជឿទុកចិត្តបានច្រើនជាងគេបំផុត តែភ័ស្តុតាងដែលជាប់ទាក់ទិននឹងបទឧក្រិដ្ឋ ត្រូវការព័ត៌មានដែលអាចជឿទុកចិត្តបានជាងនេះទៅទៀត ។ កសិណសាក្សី អាចផ្តល់ភ័ស្តុតាងគ្រប់គ្រាន់ក្នុងការបង្កើតសំណុំរឿងបឋមប្រឆាំងនឹងជនជាប់ចោទ ប៉ុន្តែកសិណបែបនេះ ក៏មានលក្ខណៈរើសអើងចំពោះជនជាប់ចោទផងដែរ ដោយសារតែកង្វះចន្លោះនៃការចងចាំរបស់មនុស្ស ។ កសិណសាក្សីជំនាញដើរតួនាទីសំខាន់នៅក្នុងសវនាការ ចំណែកភ័ស្តុតាងតម្រូវឲ្យមានការបកស្រាយដើម្បីបញ្ជាក់ពីអត្ថន័យដែលបង្កប់ក្នុងនោះ ។ ក៏ប៉ុន្តែ កសិណសាក្សីជំនាញប្រហែលជាមានភាពរើសអើងក្នុងខ្លួនរបស់ពួកគេរួចទៅហើយ ។ ការបញ្ជាក់ការពិត ឬពាក្យសម្បថរបស់សាក្សី ឬជនរងគ្រោះ អាចនឹងត្រូវពិនិត្យដើម្បីស្វែងរកអង្គហេតុនៃការបញ្ជាក់ការពិត ឬពាក្យសម្បថនេះ ក៏ប៉ុន្តែការណ៍នេះនឹងបដិសេធចំពោះការផ្តល់ឱកាសដល់ភាគីម្ខាងទៀតក្នុងការពិនិត្យលើសេចក្តីទុកចិត្តរបស់សាក្សីនៅក្នុងតុលាការជាមិនខាន ។ ភ័ស្តុតាងកោសល្យវិច័យជាភ័ស្តុតាងដ៏សំខាន់មួយក្នុងការបង្ហាញពីពេលវេលានិងហេតុផលដែលនាំឲ្យមានអំពើឧក្រិដ្ឋកម្ម

កើតឡើង ក៏ប៉ុន្តែ ភស្តុតាងនេះមិនបង្ហាញដោយផ្ទាល់ថាចុងចោទណាមួយបានប្រព្រឹត្តឧក្រិដ្ឋកម្មឡើយ ។ ភាគីជម្លោះទាំងឡាយនឹងត្រូវប្រឆាំងភស្តុតាងផ្សេងៗ បញ្ចូលគ្នាដើម្បីកំណត់នូវកម្រិតអតិបរមានៃអានុភាពរបស់ភស្តុតាងនីមួយៗ ។

ឯកសារអាចជាភស្តុតាងដោយផ្ទាល់ ឬប្រយោលដែលបង្ហាញ (ឬមិនបង្ហាញ) ធាតុផ្សំនៃអំពើឧក្រិដ្ឋ ។ ភស្តុតាងជាឯកសាររាប់បញ្ចូលទាំងភស្តុតាងដែលកត់ត្រាក្នុងទម្រង់ផ្សេងៗ ដូចជា ឯកសារផ្លូវការ សំបុត្រ ឬរូបថត ។ ភស្តុតាងបែបនេះអាចបង្ហាញអំពីពេលវេលាដែលអំពើឧក្រិដ្ឋបានកើតឡើង ដូចជាលិខិតបញ្ជាឲ្យសម្លាប់របស់កម្មាភិបាលខ្មែរក្រហម នៅក្នុងឆ្នាំ១៩៧៨ជាដើម ។ ជាងនេះទៀត ភស្តុតាងខ្លះ បាននឹងកំពុងត្រូវបានកត់ត្រាជាបន្តបន្ទាប់ ដូចជាបទសម្ភាសន៍ជាមួយសាក្សីដែលត្រូវបានថតចម្លងទុកក្នុងកាសែ្សតជាដើម ។ ភស្តុតាងជាឯកសាររាប់ម៉ឺនសន្លឹកទៀត ទំនងជានឹងត្រូវពិនិត្យនៅក្នុងតុលាការផងដែរ ក៏ប៉ុន្តែ ជាទូទៅ ភស្តុតាងដែលធ្វើឡើងជិតឬចំពេលដែលឧក្រិដ្ឋកម្មបានកើតឡើង ចៅក្រមត្រូវទទួលស្គាល់ថាជាព័ត៌មានដែលមានសារសំខាន់បំផុត ។

កត្តាសំខាន់នៃភាពគួរឲ្យជឿទុកចិត្តបាននៃភស្តុតាង គឺមិនមែនបរិមាណព័ត៌មាននោះទេ តែគឺគុណភាពនៃភស្តុតាងទៅវិញ ។ ជាឧទាហរណ៍ តុលាការទំនងជានឹងធ្វើការពិចារណាទៅលើរបាយ-ការណ៍របស់សន្តិសុខគុក ស្តីអំពីការធ្វើទារុណកម្មនៅទួលស្លែងថាជារបាយការណ៍ដែលអាចជឿទុកចិត្តមួយ ពីព្រោះរបាយការណ៍នេះធ្វើឡើងចំពេលមានការប្រព្រឹត្តនូវអំពើឧក្រិដ្ឋ ។ ផ្ទុយទៅវិញ តុលាការប្រហែលជានឹងមិនផ្តោតជាសំខាន់ទៅលើការរៀបរាប់អំពីការធ្វើទារុណកម្មនៅទួលស្លែងដែលមាននៅក្នុងញត្តិជនរងគ្រោះដែលធ្វើឡើងតាមការទទូចសុំរបស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិប-តេយ្យឡើយ ។ ពេលវេលាដែលកន្លងហួស ជាហេតុផលមួយដែលធ្វើឲ្យភស្តុតាងបែបនេះពុំត្រូវបានទទួលយក ។ ម្យ៉ាងវិញទៀត អ្នកវិភាគមួយចំនួនជឿជាក់ថារបបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានដាក់គំនាបឲ្យប្រជាពលរដ្ឋខ្មែរកត់ត្រារឿងរ៉ាវរបស់ខ្លួនដើម្បីទុកប្រើប្រាស់ជាឧបករណ៍នយោបាយរបស់ខ្លួន ។ ប្រការនេះ អាចធ្វើឲ្យចៅក្រមមួយចំនួនចាត់ទុកឯកសារប្រភេទនេះថាជាឯកសារដែលអាចទុកចិត្តបានតិចតួច ។

នៅក្នុងការជំនុំជម្រះក្តីបទឧក្រិដ្ឋ កសិណសាក្សីជំនាញ ឬមិនជំនាញអាចផ្តល់ទំនុកចិត្តបន្ថែមទៅលើភស្តុតាងប្រភេទឯកសារបាន ។ សាក្សីដែលសន្យាផ្តល់កសិណអំពីភស្តុតាងដោយផ្ទាល់ ឬស្ថានភាពនៃឧក្រិដ្ឋកម្ម (ដោយឆ្លងកាត់ការសច្ចាប្រណិធាន) ក៏អាចផ្តល់នូវព័ត៌មានបន្ថែមនៅក្នុងឯកសារ ឬផ្តល់ឲ្យតុលាការនូវព័ត៌មានសំខាន់ៗដែលមិនធ្លាប់បានផ្តល់ឲ្យទៅកន្លែងផ្សេងៗទៀត ។ ជាឧទាហរណ៍ កសិណសាក្សីនៅតុលាការ នឹងជាភស្តុតាងដ៏សំខាន់ក្នុងការបង្ហាញនូវរចនាសម្ព័ន្ធគ្រប់គ្រងនៅក្នុងរបបកម្ពុជាប្រជា-ធិបតេយ្យ ពីព្រោះព័ត៌មានជាឯកសារជាច្រើនត្រូវបានបំផ្លាញ ឬបាត់បង់អស់ទៅហើយ ។ មានបញ្ហាផ្សេងៗស្តីអំពីភស្តុតាងដែលទាក់ទិនទៅនឹងប្រភេទសាក្សីនីមួយៗ ។

កសិណសាក្សីដែលឃើញផ្ទាល់នឹងភ្នែក ត្រូវបានចាត់ទុកជាប្រភេទនៃភស្តុតាងដែលអាចជឿទុកចិត្តបានតិចតួច ដោយសារតែចន្លោះពេលវេលានិងការបាត់បង់ការចងចាំរបស់មនុស្ស ។ ការជឿទុកចិត្តលើកសិណសាក្សីនឹងត្រូវបាត់បង់បន្តិចម្តងៗ ដោយមូលហេតុថា រឿងរ៉ាវនេះកន្លងហួសអស់រយៈពេលជិត៣០ឆ្នាំ ចាប់តាំងពីការដួលរលំនៃរបបខ្មែរក្រហម ។ ម្យ៉ាងទៀត សាក្សីតែងតែចង់បានលទ្ធផលពិតប្រាកដមួយសម្រាប់ការកាត់សេចក្តីដែលលទ្ធផលនេះនឹងឆ្លុះបញ្ចាំងដល់ការបរិយាយរឿងរ៉ាវពីអតីតកាលរបស់ខ្លួន ។ ឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានលក្ខណៈធំធេងនិងបង្កការខូចខាតយ៉ាងខ្លាំង ។ ដោយហេតុនេះ សាក្សីជាច្រើនទំនងជាចង់ឲ្យមានការកាត់ទោសឧក្រិដ្ឋកម្មទាំងនោះ ។ ដោយហេតុថាកសិណបែបនេះមានភាពមិនត្រឹមត្រូវ កសិណខ្លះត្រូវបានកែតម្រូវតាមរយៈការផ្ទៀងផ្ទាត់ចម្លើយដោយភាគីបដិបក្ខ ដែលជាដំណើរការមួយដែលអាចធ្វើឲ្យមេធាវីគាំទ្រឲ្យភាគីបដិបក្ខរបស់ខ្លួនពិនិត្យលើភាពដែលអាចជឿទុកចិត្តបាននិងសច្ចភាពរបស់សាក្សីរបស់ខ្លួន ។ ទោះបីជាយ៉ាងណាក៏ដោយ ព្រះរាជអាជ្ញា ទំនងជាមិនអាចស្វែងរកសាក្សីជាច្រើនដែលយ៉ាងហោចណាស់មិនបានបង្ហាញនូវចំណាប់អារម្មណ៍ចំពោះភាពអាចជឿទុកចិត្តបាន ។

បញ្ហាសំខាន់មួយនៃភាពដែលអាចជឿទុកចិត្តបាននៅក្នុងបរិបទនៃកសិណសាក្សី គឺពាក្យចចាមអារ៉ាមដែលជាពាក្យបង្កើតឡើងនៅក្រៅតុលាការនៃច្បាប់ក្នុងការលាតត្រដាងនូវការពិតនៃបញ្ហាដែលត្រូវបានអះអាង ។ ពាក្យចចាមអារ៉ាម មិនត្រូវបានរាប់បញ្ចូលនៅក្នុងតុលាការនៃប្រព័ន្ធច្បាប់ខមមិនឡទេ ពីព្រោះពាក្យចចាមអារ៉ាមនេះ មិនបានផ្តល់ឱកាសឲ្យភាគីចុងចោទសាកសួរជនដែលបង្កើតពាក្យចចាមអារ៉ាម ហើយពាក្យចចាមអារ៉ាមនេះមានភាពលម្អៀងចំពោះក្រុមប្រឹក្សាចៅក្រមថែមទៀត ។ ចំណែកឯប្រព័ន្ធច្បាប់រដ្ឋប្បវេណី មិនបានហាមប្រាមក្នុងការរាប់បញ្ចូលពាក្យចចាមអារ៉ាមទេ ក៏ប៉ុន្តែតម្រូវឲ្យពិនិត្យពាក្យចចាមអារ៉ាមនេះដោយសន្មតទុកជាមុនថា ចៅក្រមដែលមានវិជ្ជាជីវៈត្រូវពិនិត្យពាក្យចចាមអារ៉ាមក្នុងកម្រិតស្រាលជាងភ័ស្តុតាងដទៃទៀត ។ ជាប្រវត្តិសាស្ត្រ តុលាការអន្តរជាតិក៏បានត្រួតពិនិត្យភ័ស្តុតាងជាពាក្យចចាមអារ៉ាម ដោយយកតាមបទដ្ឋាននៃប្រព័ន្ធច្បាប់រដ្ឋប្បវេណី ។ គេរំពឹងថាសាលាក្តីខ្មែរក្រហមនឹងអនុវត្តតាមគំរូតុលាការអន្តរជាតិដទៃទៀតក្នុងការទទួលយកពាក្យចចាមអារ៉ាម ពីព្រោះប្រព័ន្ធច្បាប់កម្ពុជាបានអនុញ្ញាតឲ្យ ។ ម្យ៉ាងទៀត ហេតុផលជាក់ស្តែងគាំទ្រឲ្យមានការទទួលយកពាក្យចចាមអារ៉ាមនៅក្នុងបរិបទនៃសាលាក្តីខ្មែរក្រហម ពីព្រោះសាលាក្តីនេះមិនអាចកោះហៅជនដែលបង្កើតពាក្យចចាមអារ៉ាមមកស្រាយបំភ្លឺនៅក្នុងតុលាការបានដោយសារតែបញ្ហាភ័ស្តុភារនិងការចំណាយថវិកាក្នុងការធ្វើដំណើរ ឬដោយសារតែជននោះបាត់បង់ជីវិត ឬបាត់ខ្លួនអស់រយៈពេលជិត៣០ឆ្នាំចាប់តាំងពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

ភ័ស្តុតាងដោយពាក្យចចាមអារ៉ាម ទំនងជាដើរតួនាទីសំខាន់នៅក្នុងសាលាក្តីខ្មែរក្រហម ដោយសារតែប្រភេទនៃភ័ស្តុតាងជាក់លាក់មួយចំនួនដែលត្រូវបានប្រមែប្រមូលនោះពិបាកនឹងចោទប្រកាន់អតីតកម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់ ។ ពាក្យសម្តីផ្ទាល់របស់អ្នកដែលរស់រានមានជីវិតពីអំពើឃោរឃៅខ្មែរក្រហមផ្ទុកទៅដោយព័ត៌មានសំខាន់ៗដែលព្រះរាជអាជ្ញាអាចប្រើប្រាស់ដើម្បីស្វែងរកអត្តសញ្ញាណរបស់ជនរងគ្រោះសាក្សី និងជនដៃដល់ ។ ពាក្យសម្តីទាំងនេះ ជាពាក្យចចាមអារ៉ាមពីព្រោះពាក្យសម្តីនេះ មិនត្រូវបានធ្វើឡើងនៅក្នុងតុលាការនៃច្បាប់ដែលផ្តន្ទាទោស ដោយក្រុមប្រឹក្សាចៅក្រមទេ ។ ដូចដែលបានពិភាក្សាខាងលើពាក្យចចាមអារ៉ាមទំនងជាត្រូវបានទទួលយកធ្វើជាភ័ស្តុតាងនៅក្នុងតុលាការ បើទោះបីជាអ្នកបង្កើតពាក្យចចាមអារ៉ាមទាំងនេះ មិនអាចផ្តល់កសិណនៅក្នុងតុលាការក្នុងការផ្តល់សេចក្តីទុកចិត្តចំពោះពាក្យចចាមអារ៉ាមនេះក៏ដោយ ។ ក៏ប៉ុន្តែ តម្លៃនៃការទទួលយកភ័ស្តុតាងជាពាក្យចចាមអារ៉ាមនៅក្នុងសវនាការត្រូវចៅក្រមទទួលស្គាល់ថា មិនមានលក្ខណៈធ្ងន់ធ្ងរជាងភ័ស្តុតាងដទៃទៀតទេ ពីព្រោះចៅក្រមពុំមានទំនុកចិត្តលើពាក្យសម្តីដែលគ្មានអំណះអំណាងបញ្ជាក់ជាទម្រង់នៃភ័ស្តុតាងដទៃទៀតនោះ



លោក ម៉ាសែល ឡឺមុន (រូបកណ្តាល) សហចៅក្រមស៊ើបអង្កេត

ឡើយ ។ ដូច្នេះ ពាក្យចចាមអារ៉ាមរាប់ពាន់អាចមានតម្លៃបញ្ជាក់ស្មើនឹងភ័ស្តុតាងឯកសារដែលអាចជឿទុកចិត្តមួយតែប៉ុណ្ណោះ ។

ការប្រើប្រាស់សាក្សីជំនាញដើម្បីបញ្ជាក់ព័ត៌មានក្នុងឯកសារអាចដោះស្រាយបញ្ហាជំនឿទុកចិត្តបានមួយចំនួនដែលទាក់ទងទៅនឹងការទទួលយកពាក្យចចាមអារ៉ាម ។ សាក្សីជំនាញដោយរាប់បញ្ចូលទាំងអ្នកស្រាវជ្រាវប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ អ្នកជំនាញខាងវិភាគកោសល្យវិច័យនិងអ្នកជំនាញខាងអក្សរសរសេរដោយដៃផ្ទាល់ ទំនងជានឹងត្រូវតុលាការកោះហៅឲ្យចូលស្រាយបំភ្លឺខ្លឹមសារ ឬបញ្ជាក់ឯកសារថាត្រឹមត្រូវ

តាមឯកសារដើម ។ សាក្សីទាំងនេះ ត្រូវតែឆ្លើយតបតាមបទដ្ឋាននៃភាពជឿទុកចិត្តបានមួយចំនួន មុននឹងអនុញ្ញាតឲ្យផ្តល់ជាកសិណ ។ សាក្សីជំនាញត្រូវបញ្ជាក់នូវទស្សនៈយល់ឃើញរបស់ខ្លួនអំពីភស្តុតាងជាក់លាក់ណាមួយ ។ ដោយហេតុថា មានគម្លាតពេលវេលាខ្លាំងពេករវាងរបបកម្ពុជាប្រជាធិបតេយ្យនិងតុលាការ ក្រុមអ្នកជំនាញអាចមានទស្សនៈយល់ឃើញដាច់ដោយឡែកៗពីគ្នាអំពីការជឿទុកចិត្តលើភស្តុតាង ។

*ការបញ្ជាក់ភស្តុតាងថាត្រឹមត្រូវតាមឯកសារដើម*

ការបញ្ជាក់ភស្តុតាងថាត្រឹមត្រូវតាមឯកសារដើម ជាដំណើរការបង្ហាញវត្ថុតាងដែលអះអាងបញ្ជាក់នូវការពិត ។


ជនជាតិបារាំងនៅក្នុងអគារសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម

ដំណើរការនេះ ត្រូវបានប្រើប្រាស់នូវភស្តុតាងជាឯកសារដើម្បីបង្ហាញអត្តហេតុ ដូចជាអត្តសញ្ញាណរបស់ម្ចាស់ឯកសារ និងកាលបរិច្ឆេទនៃការធ្វើឯកសារ ។ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ឯកសារទាំងនេះចាំបាច់ត្រូវតែបញ្ជាក់ថាត្រឹមត្រូវតាមឯកសារដើមក្នុងការបង្ហាញថា កម្មាភិបាលខ្មែរក្រហមបានដឹងថាមានអំពើឧក្រិដ្ឋ ឬបានបង្គាប់បញ្ជាឲ្យប្រព្រឹត្តអំពើឧក្រិដ្ឋនោះ ។ ដំណើរការនេះ ក៏ជួបការលំបាកដងដែរ ដោយសារតែអាយុឯកសារនិងការពិតដែលម្ចាស់ឯកសារជាច្រើនដែលអាចផ្តល់ជាកសិណក្នុងការបញ្ជាក់ឯកសាររបស់ខ្លួនថាត្រឹមត្រូវតាមឯកសារដើមនោះ ពុំមានព័ត៌មាននៅសេសសល់ ។ នៅក្នុងច្បាប់អង្គជំនុំជម្រះវិសាមញ្ញពុំមានការទាមទារឲ្យបញ្ជាក់ឯកសារថាត្រឹមត្រូវតាមឯកសារដើមទេ ក៏ប៉ុន្តែដើម្បីឲ្យដូចគ្នានឹងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងរ៉្វាន់ដា សាលាក្តីខ្មែរក្រហមមានអំណាចទាមទារឲ្យមានការបញ្ជាក់ថាភស្តុតាងនេះត្រឹមត្រូវតាមច្បាប់មុននឹងតុលាការទទួលយកភស្តុតាងនោះ ។

ឯកសារមួយចំនួន ដូចជាអត្ថបទដែលចុះផ្សាយលើទំព័រកាសែតជាដើម ជាទូទៅត្រូវបានចាត់ជាប្រភេទឯកសារដែលបញ្ជាក់ថាជាឯកសារដើមពិតប្រាកដដោយខ្លួនឯង ពីព្រោះឯកសារទាំងនេះជាឯកសារសាធារណៈចាប់តាំងពីការបង្កើតឯកសារនេះ ។ ដូចនេះ ឯកសារទាំងនេះមិនអាចក្លែងបន្លំដោយងាយស្រួល ឬកែប្រែដោយមិនបានបន្សល់ទុកនូវឯកសារចម្លងដែលមិនត្រូវបានកែប្រែជាច្រើនដែលកំពុងចរាចរចុះឡើងនោះទេ ។ ប្រភេទឯកសារផ្សេងៗទៀត ចាំបាច់ត្រូវតែបញ្ជាក់ឲ្យបានត្រឹមត្រូវតាមច្បាប់ដោយប្រើប្រាស់ភស្តុតាងដោយផ្ទាល់ ឬដោយប្រយោល ។ វិធីដ៏ល្អបំផុតសម្រាប់ឲ្យសាក្សី អ្នកវិភាគ ឬម្ចាស់ឯកសារ ដើម្បីបញ្ជាក់ថាឯកសាររបស់ខ្លួនជាឯកសារដើមពិតប្រាកដនៅក្នុងតុលាការនោះគឺពួកគេត្រូវស្បថនៅចំពោះមុខតុលាការ ។ ក៏ប៉ុន្តែឯកសារមួយចំនួន ដូចជាសំបុត្របង្គាប់បញ្ជាជាលាយលក្ខអក្សរដោយកម្មាភិបាលខ្មែរក្រហមនឹងមានការលំបាកក្នុងការបញ្ជាក់ភស្តុតាងកសិណថា ជាឯកសារដើមពិតប្រាកដ ពីព្រោះអ្នកធ្វើឯកសារប្រហែលជាស្លាប់ក្នុងចន្លោះរយៈកាលនោះទៅហើយ ។ ក្នុងករណីបែបនេះ ឯកសារអាចនឹងត្រូវបានបញ្ជាក់ថាត្រឹមត្រូវតាមឯកសារដើមពិតប្រាកដដោយការវិភាគវត្ថុតាង ឬដោយការបង្ហាញនូវខ្សែសង្វាក់នៃការរក្សាភស្តុតាង ។

ការវិភាគមួយប្រភេទលើវត្ថុតាងនោះ គឺការវិភាគទៅលើឯកសារដែលសរសេរដោយដៃដែលត្រូវបានវិភាគដោយអ្នកជំនាញ ឬដោយម្ចាស់ឯកសារដែលស្គាល់ច្បាស់អក្សររបស់អ្នកធ្វើឯកសារដែលអាចស្រាយបំភ្លឺបញ្ជាក់វត្ថុតាងនោះ ។ ឯកសារសរសេរដោយដៃក៏អាចបញ្ជាក់ថាជាឯកសារដើមពិតប្រាកដបានដែរ តាមរយៈការប្រើប្រាស់ភស្តុតាងនិទស្សន៍ឬប្រយោល

ដូចជាការផ្ទៀងផ្ទាត់អក្សរនៅក្នុងឯកសារនោះជាមួយនឹងឯកសារសរសេរដោយដៃផ្ទាល់របស់អ្នកធ្វើឯកសារនៅក្នុងឯកសារផ្សេងទៀត ។ ឯកសារដទៃទៀតនឹងមានភាពងាយស្រួលជាងក្នុងការបញ្ជាក់ថាឯកសារនោះជាឯកសារដើមពិតប្រាកដ តាមរយៈភស្តុតាង និទស្សន៍ឬប្រយោល ពីព្រោះភស្តុតាងប្រភេទនេះមានកំណត់សម្គាល់ផ្សេងៗគ្នា ដូចជាឈ្មោះស្ថាប័ននិងអាសយ-ដ្ឋាននៅលើក្បាលសំបុត្រ ឬត្រា ។ ជាចុងក្រោយ ការពិនិត្យនូវភស្តុតាង កោសល្យវិច័យ អាចផ្តល់ជាភស្តុតាងដោយប្រយោលដែលបញ្ជាក់ថាឯកសារនោះត្រឹមត្រូវតាមឯកសារដើមពិតប្រាកដបានដែរ ដូចជាកាលបរិច្ឆេទផលិត ភស្តុតាង ឬភស្តុតាងដែលមិនបញ្ជាក់ឯកសារនោះថាត្រឹមត្រូវតាមឯកសារដើមពិតប្រាកដ ដូចជាការកែកុនសញ្ញាផ្សេងៗនៃឯកសារ ។

ការកាន់កាប់ឯកសារ មានការផ្លាស់ប្តូរជាច្រើនលើកច្រើនសា ចាប់តាំងពីពេលផលិតឯកសាររហូតដល់ពេលដែលឯកសារទាំងនោះត្រូវបានប្រើប្រាស់ជាភស្តុតាងនៅក្នុងសវនាការ ។ ការតាមដានខ្សែចង្វាក់នៃការរក្សាទុកភស្តុតាង ផ្តល់ជាភស្តុតាងដោយប្រយោល ដែលបញ្ជាក់ថាឯកសារទាំងនោះត្រឹមត្រូវតាមឯកសារដើមពិតប្រាកដ ។ ឯកសារមួយចំនួនដែលផលិតដោយកម្មាភិបាលខ្មែរក្រហមបាននឹងកំពុងតែត្រូវបានតាមដានដើម្បីរកប្រភពកម្មសិទ្ធិដើមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តាមរយៈការព្រមព្រៀងនិងកសិណសាក្សី ។ ឯកសារជាច្រើនត្រូវបានរក្សាទុកដោយអង្គការក្នុងនិងក្រៅរដ្ឋាភិបាលដែលអាចផ្តល់ជាកសិណ អំពីវិធីដែលអង្គការទាំងនេះទទួលបានឯកសារនិងកិច្ចការដែលអង្គការទាំងនេះការពារឯកសារពីការក្លែងបន្លំក្នុងខណៈពេលឯកសារទាំងនោះស្ថិតក្នុងការថែរក្សារបស់ខ្លួន ។ ការបង្ហាញជំហាននីមួយៗស្តីពីខ្សែចង្វាក់នៃការថែរក្សាឯកសារ នឹងទំនងជាការបង្ហាញដ៏ចាំបាច់មួយសម្រាប់ឯកសារដែលពុំសូវមានសញ្ញាសម្គាល់ផ្សេងៗនៃប្រភេទភស្តុតាងណាមួយ ពីព្រោះភស្តុតាងភាគច្រើនត្រូវតែមានការបញ្ជាក់យ៉ាងច្បាស់ដោយការប្របាច់ភស្តុតាងដោយប្រយោលបញ្ចូលគ្នា ។

សរុបជារួម ភស្តុតាងទាំងអស់ដែលត្រូវបង្ហាញចំពោះមុខសាលាក្តីខ្មែរក្រហម ត្រូវឆ្លើយតបតាមតម្រូវការចាំបាច់ដំបូងនៃទំនាក់ទំនងនិងតម្លៃប្រើប្រាស់នៃភស្តុតាង ។ ម្យ៉ាងទៀត ប្រសិនបើភស្តុតាងនោះជាឯកសារចាំបាច់ត្រូវមានការបញ្ជាក់លើឯកសារនោះថា ជាឯកសារដើមពិតប្រាកដ ។ ភស្តុតាងផ្តល់ទំនុកចិត្តកាន់តែច្រើន ចៅក្រមផ្តល់តម្លៃលើភស្តុតាងនោះក៏កាន់តែច្រើនដែរ ។ រីឯពាក្យចចាមអារ៉ាមទំនងជាអាចទទួលយកធ្វើជាភស្តុតាងបាន ក៏ប៉ុន្តែ ការទទួលយកនេះនឹងប៉ះពាល់ទៅដល់ទម្ងន់នៃភស្តុតាងបន្ទាប់ពីភស្តុតាងត្រូវបានទទួលយក ។

### ***សិទ្ធិរបស់ជនជាប់ចោទក្នុងពេលសវនាការ***

ដូចដែលបានកត់សម្គាល់ខាងលើ វិធាននីតិវិធីមួយក្នុងចំណោមវិធាននីតិវិធីជាមូលដ្ឋានជាច្រើន គឺការផ្តល់សិទ្ធិដល់ជនជាប់ចោទ ។ សិទ្ធិទាំងនេះ នឹងត្រូវអនុវត្តនៅក្នុងដំណាក់កាលបុរេជំនុំជម្រះនិងសវនាការ ។ ច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានប្រើប្រាស់និយាមតែមួយ នៅក្នុងដំណើរការកាត់សេចក្តីដូចគ្នានឹងការប្រើប្រាស់និយាមរបស់តុលាការអន្តរ-ជាតិដទៃទៀតដែរ ។ អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងជាប់ប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមានការការពារឲ្យបានត្រឹមត្រូវចំពោះជនរងគ្រោះនិងសាក្សី ។ ជាទូទៅ សិទ្ធិរបស់ជនជាប់ចោទនៅក្នុងសាលាក្តីខ្មែរក្រហមឆ្លុះបញ្ចាំងអំពីបទដ្ឋានជំនុំជម្រះក្តីដោយយុត្តិធម៌ដែលទទួលស្គាល់ជាអន្តរជាតិ ។

ដូចគ្នានឹងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងរ៉ាន់ដា សិទ្ធិរបស់ជនជាប់ចោទដែលមានចែងនៅក្នុងច្បាប់អង្គជំនុំជម្រះវិសាមញ្ញ ត្រូវបានយកធ្វើជាគំរូដោយយោងតាមមាត្រា១៤នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ។ ទោះបីជាយ៉ាងណាក៏ដោយ មានបញ្ហាមួយទាក់ទិនទៅនឹងប្រសិទ្ធិភាពការការពារខ្លួនជាវិជ្ជមាននៅក្នុងសាលាក្តីខ្មែរក្រហម ។ ការការពារខ្លួនជាវិជ្ជមានគឺជាការទទួលកំហុសព្រមទាំងស្រាយបំភ្លឺអំពីស្ថានភាពនៃការប្រព្រឹត្តអំពើឧក្រិដ្ឋ ។ ចុងចោទស្នើសុំឲ្យមានការការពារខ្លួនជាវិជ្ជមានដោយសង្ឃឹមថាអាចបញ្ចុះបញ្ចូលចៅក្រមឲ្យលុបចោលនូវការកាត់ទោសឬសម្រាលទោសរបស់ខ្លួន ។ ច្បាប់អន្តរជាតិបានទទួលស្គាល់សិទ្ធិ

ទូទៅរបស់ជនជាប់ចោទក្នុងការការពារខ្លួនចំពោះបទចោទប្រកាន់ថាខ្លួនបានប្រព្រឹត្តអំពើឧក្រិដ្ឋ ។ ការការពារខ្លួនជាវិជ្ជមាននិងដ៏សាមញ្ញបំផុតនៅក្នុងតុលាការអន្តរជាតិនឹងការការពារខ្លួនជាវិជ្ជមានដែលចងក្រងដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ រួមមានភាពគ្មានអនាម័យ ការបំពុល ការការពារខ្លួន ការឃុំឃាំង ភាពចាំបាច់ កំហុស ការបង្គាប់បញ្ជារបស់ថ្នាក់លើ និងអាជ្ញាយុកាលនៃច្បាប់ ។

ច្បាប់អង្គជំនុំជម្រះវិសាមញ្ញ មិនអនុញ្ញាតឲ្យចុងចោទលើកឡើងនូវការការពារខ្លួនជាវិជ្ជមានមួយចំនួនចំពោះឧក្រិដ្ឋកម្មជាតិ និងអន្តរជាតិដែលស្ថិតនៅក្រោមដែនយុត្តាធិការរបស់តុលាការទេ ។ ជាឧទាហរណ៍ មាត្រា២៩នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញ ចែងថា «ប្រការដែលថាជនសង្ស័យ បានប្រព្រឹត្តអំពើឧក្រិដ្ឋតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬរបស់ថ្នាក់លើណាមួយ មិនអាចជួយជនសង្ស័យនេះឲ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះបានឡើយ» ។ ដូច្នេះ ការការពារខ្លួនពីការបង្គាប់បញ្ជារបស់ថ្នាក់លើ មិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ជាការការពារខ្លួនជាវិជ្ជមានចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញបានទេ ។ មានន័យថាអតីតកម្មាភិបាលខ្មែរក្រហម មិនអាចធានាបាននូវភាពរួចទោសរបស់ខ្លួន ដោយគ្រាន់តែលើកហេតុផលថាខ្លួនបានដឹងថាអំពើនោះជាអំពើឧក្រិដ្ឋ ប៉ុន្តែខ្លួនមិនហ៊ានជំទាស់នឹងបទបញ្ជាឡើយដោយភ័យខ្លាចនឹងការដាក់ទោសរបស់ថ្នាក់លើ ។ ជាធម្មតា ការការពារខ្លួនបែបនេះ ត្រូវច្បាប់អន្តរជាតិបដិសេធចោលចំពោះបទឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរ ដូចជាអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក៏ប៉ុន្តែ ច្បាប់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងរ៉ាន់ដា ចែងយ៉ាងច្បាស់ថា ការចេញបញ្ជារបស់ថ្នាក់លើ អាចនឹងត្រូវពិភាក្សាក្នុងការសម្រាលទោសរបស់ជនជាប់ចោទដែលត្រូវកាត់ទោស ។ ច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនបានចែងច្បាស់ស្តីពីលទ្ធភាពការពារខ្លួនបែបនោះឡើយ ។ លើសពីនេះទៀត ភាសានៅក្នុងច្បាប់នេះ បញ្ជាក់ថាការការពារខ្លួនបែបនេះ អាចនឹងត្រូវបានបដិសេធក្នុងការការពារខ្លួនពីឧក្រិដ្ឋកម្មជាតិ បើទោះបីជាច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦បានអនុញ្ញាតឲ្យមានការការពារខ្លួនពីការបញ្ជារបស់ថ្នាក់លើក្នុងស្ថានភាពមួយចំនួនយ៉ាងណាក៏ដោយ ។

ច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនបានចែងយ៉ាងលម្អិតថាតើចុងចោទអាចប្រើប្រាស់នូវការការពារខ្លួនជាវិជ្ជមាននៅពេលណា និងថាតើការការពារខ្លួនបែបនេះនឹងត្រូវប្រើប្រាស់ច្បាស់លាស់យ៉ាងពិតប្រាកដប៉ុនណានោះទេ ។ ដោយសារតែច្បាប់កម្ពុជាមានចែងបន្តិចបន្តួចដែនយុត្តាធិការលើការការពារខ្លួនជាវិជ្ជមាន ចៅក្រមចាំបាច់ត្រូវតែពិភាក្សាច្បាប់អន្តរជាតិសម្រាប់ជាការណែនាំនៅពេលដែលចៅក្រមសម្រេចថាតើត្រូវទទួលយក ឬ មិនទទួលយកនូវការការពារខ្លួនជាវិជ្ជមានបែបនេះដែរឬយ៉ាងណា ។

សិទ្ធិសំខាន់មួយទៀតដែលត្រូវបានការពារដោយអនុសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងដែលអនុម័តដោយអង្គជំនុំជម្រះវិសាមញ្ញ គឺសិទ្ធិមិនធ្វើពិរុទ្ធកម្មលើខ្លួនឯង ។ នៅក្នុងប្រព័ន្ធច្បាប់ជាតិជាច្រើន សិទ្ធិមិនធ្វើពិរុទ្ធកម្មលើខ្លួនឯងនេះ រួមមានសិទ្ធិនៅស្ងៀមមិនចេញស្តីនៅពេលដែលចៅក្រម ឬព្រះរាជអាជ្ញាចោទសួរ ។ ក៏ប៉ុន្តែ នៅក្នុងច្បាប់នីតិវិធីកម្ពុជា ចៅក្រមមានសិទ្ធិកំណត់មួយក្នុងការចោទសួរជនជាប់ចោទមុនពេលព្រះរាជអាជ្ញា ឬមេធាវីការពារក្តីបង្ហាញភ័ស្តុតាងបាននោះឡើយ ។ ដោយចៅក្រមត្រូវបានអនុញ្ញាតឲ្យចោទសួរចុងចោទនៅក្នុងដំណាក់នេះ ហើយចុងចោទអាចនឹងត្រូវបានបង្ខំឲ្យឆ្លើយប្រឆាំងនឹងខ្លួនឯងជាជាងសំអាងលើសិទ្ធិនៅស្ងៀមមិនចេញស្តីរបស់ខ្លួន ។ ច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសំអាងលើបទដ្ឋានអន្តរជាតិតាមរយៈការការពារការសន្មតទុកជាមុននូវភាពគ្មានទោស និងសិទ្ធិរបស់ជនជាប់ចោទដែល «មិនត្រូវបានបង្ខំឲ្យឆ្លើយប្រឆាំងខ្លួនឯង ឬសារភាពទោសកំហុស» ។ ដូច្នេះ ការការពារនូវសិទ្ធិនៅស្ងៀមមិនចេញស្តី ជាគំរូមួយដែលចៅក្រមត្រូវប្រើប្រាស់ការពារយ៉ាងពេញទំហឹងដោយច្បាប់អន្តរជាតិ ដែលបច្ចុប្បន្នមានចែងនៅក្នុងច្បាប់អង្គជំនុំជម្រះវិសាមញ្ញជាជាងការពារដោយច្បាប់ក្នុងស្រុក ។

បន្ថែមពីនេះ ច្បាប់អង្គជំនុំជម្រះវិសាមញ្ញ បានកំណត់នូវសិទ្ធិទទួលបានមេធាវី ។ មាត្រា២១នៃកិច្ចព្រមព្រៀងរវាងរាជ

រដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិចែងថា មេធាវីបរទេសចាំបាច់ត្រូវអនុវត្តតាមវិធាននៃច្បាប់កម្ពុជាស្តីពីលក្ខន្តិកៈមេធាវី ហើយវិធានទាំងនេះហាមប្រាមមេធាវីបរទេសក្នុងការអនុវត្តដោយឯករាជ្យនៅក្នុងតុលាការកម្ពុជា ។ ចៅក្រមត្រូវពិនិត្យបទបញ្ញត្តិដែលមានចែងក្នុងមាត្រា១៣នៃកិច្ចព្រមព្រៀង (សិទ្ធិជ្រើសរើសរកមេធាវីដោយខ្លួនឯងដូចដែលបានធានានៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ) ដោយសេរី និងអនុញ្ញាតឲ្យមានការបង្ហាញដោយមេធាវីបរទេសដោយមិនគិតពីច្បាប់កម្ពុជាឡើយ ។ ក៏ប៉ុន្តែ កិច្ចព្រមព្រៀងនេះមិនបានធានាថាចៅក្រមនឹងគោរពសិទ្ធិរបស់ចុងចោទក្នុងការជ្រើសយកមេធាវីបរទេសទេ ។

តុលាការអន្តរជាតិនិងប្រព័ន្ធច្បាប់ក្នុងស្រុកជាច្រើន បង្កើតដំណាក់កាលកាត់ទោសនិងជំនុំជម្រះដោយឡែកពីគ្នា ។ មានន័យថា ពិរុទ្ធភាពឬភាពគ្មានទោសរបស់ចុងចោទ ត្រូវកំណត់មុនពេលដែលចុងចោទត្រូវបានស្នើសុំឲ្យបង្ហាញអំណះអំណាងរបស់ខ្លួនដើម្បីសម្រាលទោសកំហុសរបស់ខ្លួន ប្រសិនបើចុងចោទត្រូវបានរកឃើញថាមានទោសពិតប្រាកដមែន ។ យន្តការនេះបញ្ជាក់ថា ជនជាប់ចោទពុំចាំបាច់បង្ហាញនូវអំណះអំណាងរបស់ខ្លួនដែលជួយសម្រាលទោសកំហុសរបស់ខ្លួននោះទេ មុនពេលដែលតុលាការរកឃើញថាមានទោស ហើយយន្តការនេះបានការពារនូវសិទ្ធិមិនធ្វើពិរុទ្ធកម្មលើខ្លួនឯងរបស់ចុងចោទថែមទៀត ។ ទោះបីជាយ៉ាងណាក៏ដោយ នីតិវិធីព្រហ្មទណ្ឌកម្ពុជា បានច្របាច់ដំណាក់កាលទាំងពីរនេះបញ្ចូលគ្នា ហើយច្បាប់អង្គជំនុំជម្រះវិសាមញ្ញ មិននិយាយអ្វីអំពីបញ្ហានេះទេ ។ ដូច្នេះ វាមានសារសំខាន់ដែលអង្គជំនុំជម្រះវិសាមញ្ញ ច្របាច់ដំណាក់កាលទាំងពីរនេះបញ្ចូលគ្នា ដោយដាក់បន្ទុកទៅលើចុងចោទនិងផ្តល់គ្រឿងលើកទឹកចិត្តដល់ចុងចោទក្នុងការបង្ហាញភ័ស្តុតាងដាក់បន្ទុកខ្លួនឯងដើម្បីជួយសម្រាលដល់ការផ្តន្ទាទោសរបស់ខ្លួន ។

### ***សិទ្ធិរបស់ជនរងគ្រោះនិងសិទ្ធិរបស់សាក្សី***

ប៉ុន្មានឆ្នាំថ្មីៗនេះ ច្បាប់អន្តរជាតិ បានចាប់ផ្តើមបង្កើតនីតិវិធីពិសេសៗសម្រាប់ការយកចិត្តទុកដាក់លើជនរងគ្រោះ និងសាក្សីនៅក្នុងដំណើរការកាត់ក្តីអំពើឧក្រិដ្ឋ ។ និន្នាការនេះ ទទួលស្គាល់ថាសវនាការអាចធ្វើឲ្យជំងឺផ្លូវចិត្តរបស់ជនរងគ្រោះនិងសាក្សីដែលបានជួបប្រទះក្នុងអំពើឃោរឃៅសើរើឡើងវិញ ។ តុលាការអន្តរជាតិដែលបានបង្កើតឡើងក្រោយសម័យសង្គ្រាមត្រជាក់ បានបង្កើតអង្គភាពសាក្សីនិងជនរងគ្រោះពិសេស ដែលទទួលស្គាល់តម្រូវការចាំបាច់ពិសេសរបស់កុមារ មនុស្សចាស់ ជនពិការ និងជនរងគ្រោះដោយអំពើហិង្សាផ្លូវភេទ និងការរើសអើងភេទ ។ តុលាការអន្តរជាតិទាំងនេះក៏បញ្ចូលវិធានការការពារសន្តិសុខ និងការផ្តល់ប្រឹក្សាអំពីជំងឺផ្លូវចិត្តដល់ជនរងគ្រោះនិងសាក្សី ។

ក្នុងការរក្សាជំហរនេះ សាលាក្តីខ្មែរក្រហម បានចែងនូវបទបញ្ញត្តិមួយចំនួនដែលទទួលស្គាល់តម្រូវការពិសេសរបស់ជនរងគ្រោះនិងសាក្សី ។ ម្យ៉ាងទៀត សាលាក្តីនេះក៏ទប់ស្កាត់នូវការកាត់ក្តី និងការឃុំខ្លួនជនរងគ្រោះនិងអ្នកជំនាញ ឬការដាក់កម្រិតណាមួយទៅលើសិទ្ធិសេរីភាពរបស់ជនរងគ្រោះនិងអ្នកជំនាញ ។ បទបញ្ញត្តិមួយផ្សេងទៀតបានបង្កើតនូវនីតិវិធីមួយដែលចៅក្រមអាចពិនិត្យភ័ស្តុតាងដែលងាយនឹងប្រេះស្រាំដោយមតិសាធារណៈក្នុងការការពារអត្តសញ្ញាណ ឬសុវត្ថិភាពរបស់សាក្សី ។ ទោះបីជាបទបញ្ញត្តិទាំងនេះ ជាជំហានវិជ្ជមានក៏ដោយ កង្វះការសម្របសម្រួលដល់ការយកចិត្តទុកដាក់ជនរងគ្រោះនិងសាក្សី ក៏អាចបង្កជាបញ្ហាប្រឈមមុខមួយដែរ ។ ដោយខុសពីអង្គភាពការពារសាក្សីនិងជនរងគ្រោះនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបង្កើតការិយាល័យចំនួនបីគឺ ការិយាល័យសហចៅក្រមស៊ើបអង្កេត ការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យចៅក្រម ដើម្បីចែករំលែកនូវការទទួលខុសត្រូវចំពោះការការពារខ្លួន ហើយច្បាប់នេះមិនបានកំណត់ឲ្យបានច្បាស់ថាតើសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងចៅក្រម ត្រូវសម្រួលដល់កំហុសឆ្គងដែលកំពុងប្រតិបត្តិដោយរបៀបណានោះទេ ។ កង្វះការសម្របសម្រួលនេះអាចបង្កគ្រោះថ្នាក់ដល់សិទ្ធិរបស់ជនរងគ្រោះនិងសាក្សីដែលមិនត្រូវបានផ្តល់សិទ្ធិ ឬមិនត្រូវបានដោះស្រាយឲ្យបានត្រឹមត្រូវនៅពេលដែលតុលាការត្រូវបានបង្កើតឡើង ។ ជនរងគ្រោះ និងសាក្សីនឹងប្រឈមមុខនឹងការព្រួយបារម្ភផ្សេងៗ រាប់ចាប់ពីការភ័យខ្លាចចំពោះចម្លើយតបរបស់ឧក្រិដ្ឋជនរហូតដល់ការធ្វើឲ្យ

សើរើនូវជំងឺបាក់ស្បាតឡើងវិញនៅពេលដែលជនរងគ្រោះនិងសាក្សីផ្តល់ចម្លើយនៅក្នុងតុលាការ ។ ចៅក្រម មេធាវី និងបុគ្គលិកតុលាការ ត្រូវតែធានាថា ការស៊ើបអង្កេតនិងការកាត់សេចក្តីនេះនឹងមិនបង្កជំងឺផ្លូវចិត្តបន្ថែមទៀតទៅដល់ជនរងគ្រោះ មិនត្រូវធ្វើឲ្យជនរងគ្រោះ ប្រឈមមុខនឹងគ្រោះថ្នាក់ឯកជន ឬរំលោភសិទ្ធិរបស់ជនរងគ្រោះឡើយ ។ កង្វះវិធានការការពារនិងតួនាទីច្បាស់លាស់ នឹងបង្កជាបញ្ហាជាច្រើនដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងការសម្របសម្រួលយ៉ាងមានប្រសិទ្ធភាពនូវការការពារនិងការថែទាំជនរងគ្រោះនិងសាក្សី ជាពិសេសចំពោះធនធានដែលអាចប្រើប្រាស់ ។

សាលាក្តីខ្មែរក្រហម ពុំមានធនធានគ្រប់គ្រាន់សម្រាប់ការផ្សព្វផ្សាយឲ្យជនរងគ្រោះបានដឹងទេ ។ ដោយហេតុនេះ អង្គការមិនមែនរដ្ឋាភិបាលនឹងដើរតួនាទីដឹកនាំក្នុងការធានាឲ្យបានថាជនរងគ្រោះមានឱកាសចូលរួមនៅក្នុងដំណើរការកាត់សេចក្តី ។ ប្រការគួរឲ្យកត់សម្គាល់នោះគឺ សាលាក្តីខ្មែរក្រហម ក៏នៅមានកង្វះយន្តការសម្រាប់ការសងជំងឺចិត្តដល់ជនរងគ្រោះ ។ ការលុបចោលនូវសំណងលើការជួសជុលប៉ះទង្គិចជាមួយនឹងនិន្នាការដែលកំពុងរីកដុះដាលនៅក្នុងច្បាប់អន្តរជាតិចំពោះបទដ្ឋាន "យុត្តិធម៌ផ្សះផ្សា" ចំពោះជនរងគ្រោះ ដែលត្រូវបានបង្ហាញតាមរយៈការបង្កើតនូវមូលនិធិស្មគ្រចិត្តសម្រាប់ជនរងគ្រោះនៅក្រោមច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ដូចដែលមាននៅក្នុងតុលាការអន្តរជាតិដទៃទៀត កង្វះមូលនិធិសម្រាប់ការសងជំងឺចិត្តដល់ជនរងគ្រោះនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ឆ្លុះបញ្ចាំងអំពីការដាក់កម្រិតផ្នែកហិរញ្ញវត្ថុយ៉ាងពិតប្រាកដ និងថែមទាំងប៉ះពាល់យ៉ាងខ្លាំងដល់ការគាំទ្ររបស់ជនរងគ្រោះចំពោះតុលា-ការ ។ នៅក្រោមច្បាប់កម្ពុជា ជនរងគ្រោះអាចដាក់ពាក្យបណ្តឹងរដ្ឋប្បវេណីដាច់ដោយឡែកដើម្បីទារសំណងជំងឺចិត្តស្របគ្នាជាមួយនឹងបណ្តឹងព្រហ្មទណ្ឌ ហើយច្បាប់អង្គជំនុំជម្រះវិសាមញ្ញមិនបានរារាំងជនរងគ្រោះក្នុងការដាក់ពាក្យបណ្តឹងបែបនេះទេ ។ ក៏ប៉ុន្តែ ធាតុពិតជាក់ស្តែង កង្វះមូលនិធិស្មគ្រចិត្តសម្រាប់ជនរងគ្រោះនៅក្នុងច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាផ្ទាល់ទំនងជាមិនអាចផ្តល់លទ្ធភាពទៅដល់ជនរងគ្រោះក្នុងការទទួលបាននូវសំណងជំងឺចិត្តនៅក្នុងសាលាក្តីខ្មែរក្រហមបានទេ ។

**ដំណាក់កាលប្តឹងឧទ្ធរណ៍**

ផ្នែកមុនៗ បានបកស្រាយអំពីប្រភេទផ្សេងៗនៃសិទ្ធិរបស់ភាគីជម្លោះ ។ សិទ្ធិចុងក្រោយក្នុងចំណោមសិទ្ធិទាំងនេះ គឺសិទ្ធិប្តឹងឧទ្ធរណ៍ចំពោះសាលក្រមសម្រេចនៃសាលាដំបូង ។ នៅក្នុងច្បាប់កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិ ភាគីជម្លោះត្រូវបានអនុញ្ញាតឲ្យប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចចាប់ពីសាលាដំបូងរហូតដល់តុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញ ។ ច្បាប់កិច្ចព្រមព្រៀងនេះ ជាដំបូង បានរាប់បញ្ចូលទាំងសាលាឧទ្ធរណ៍ ក៏ប៉ុន្តែ សាលាឧទ្ធរណ៍នេះត្រូវបានដកចេញទៅវិញនៅក្នុងកិច្ចព្រមព្រៀងចុងក្រោយជាមួយអង្គការសហប្រជាជាតិ ។ ដូច្នេះ តុលាការកំពូលនឹងដើរតួជាសាលាឧទ្ធរណ៍ផង និងចេញសាលក្រមសម្រេចកាត់ទោសចុងក្រោយផង ។ តុលាការកំពូលត្រូវមានសមាសភាពចៅក្រមចំនួន៧រូបគឺ ចៅក្រមខ្មែរ៤រូប និងចៅក្រមបរទេស៣រូប ។ ដូចគ្នានឹងសាលាដំបូងដែរ សាលក្រមចុងក្រោយរបស់តុលាការកំពូល ត្រូវមានមតិគាំទ្រភាគច្រើនពីចៅក្រមប្រាំរូបយ៉ាងតិច ដែលក្នុងចំណោមនោះចាំបាច់ត្រូវមានមតិគាំទ្រពីចៅក្រមអន្តរជាតិយ៉ាងតិចមួយរូបក្នុងការចូលរួមបោះឆ្នោតនេះ ។

ដោយប្រកាន់ភ្ជាប់ជាមួយនឹងប្រពៃណីនៃប្រព័ន្ធច្បាប់រដ្ឋប្បវេណីរបស់ប្រទេសខ្លួន ព្រះរាជអាជ្ញានិងចុងចោទអាចប្តឹងឧទ្ធរណ៍ចំពោះលើការភ័ន្តច្រឡំនៃអង្គច្បាប់ ឬការភ័ន្តច្រឡំនៃអង្គហេតុដែលផ្អែកទៅលើសេចក្តីសម្រេចរបស់សាលាដំបូង ។ មាត្រា៣៦នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអនុញ្ញាតឲ្យមានបណ្តឹងឧទ្ធរណ៍ចំពោះការភ័ន្តច្រឡំនៃអង្គច្បាប់ ឬការភ័ន្តច្រឡំនៃអង្គហេតុ ។ បណ្តឹងឧទ្ធរណ៍បែបនេះមានលក្ខណៈល្អប្រសើរជាង«ខ»បណ្តឹងឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងរ៉ាន់ដាដែលអនុញ្ញាតឲ្យមានត្រឹមតែការប្តឹងឧទ្ធរណ៍លើការភ័ន្តច្រឡំបញ្ហាអង្គច្បាប់តែប៉ុណ្ណោះដែល "មិនបានផ្តល់តម្លៃសាលក្រមសម្រេចរបស់តុលាការ" ឬការភ័ន្តច្រឡំនៃអង្គហេតុដែល "ធ្វើឲ្យមានការខុសឆ្គងក្នុងការស្វែងរកយុត្តិធម៌" ។ ដោយសារតែសាលាក្តី

ខ្មែរក្រហមនៅមានកង្វះការរិតបន្តឹងទៅលើច្បាប់លក្ខន្តិកៈស្តីពីលទ្ធភាពរបស់តុលាការកំពូលក្នុងការវែកញែកដោះស្រាយបញ្ហាទាំងនេះដែលតុលាការនឹងទទួលតាមបណ្តឹងឧទ្ធរណ៍ ព្រះរាជអាជ្ញានិងចុងចោទអាចប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចណាមួយរបស់តុលាការបាន ។ មាត្រា៣៦នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏បានអនុញ្ញាតឲ្យជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចរបស់សាលាដំបូងដោយគ្មានការរឹតបន្តឹងណាមួយឡើយ ។ ដូច្នេះ ជាការសំខាន់ខ្លាំងណាស់ដែលដំណើរការប្តឹងឧទ្ធរណ៍នេះនឹងត្រូវអូសបន្លាយពេល ប្រសិនបើតុលាការកំពូលមិនទាន់ដោះស្រាយសំណុំរឿងក្តីទាំងនោះចប់សព្វគ្រប់ទេនោះ ។

## សន្និដ្ឋាន

សារសំខាន់នៃវិធាននីតិវិធីនិងវិធានភស្តុតាងនៅក្នុងតុលាការព្រហ្មទណ្ឌមិនអាចនិយាយបំផ្លើសបានទេ ។ វិធាននីតិវិធី និងវិធានភស្តុតាង មានសារសំខាន់ក្នុងការធានានូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ជាមូលដ្ឋាន ដែលបញ្ជាក់ថាការកាត់សេចក្តីលើជនដែលរំលោភបំពានសិទ្ធិមនុស្ស ត្រូវបានគេមើលឃើញថា មានភាពត្រឹមត្រូវតាមច្បាប់ ។ វិធាននីតិវិធីបានការពារសិទ្ធិរបស់ភាគីទាំងអស់ដែលពាក់ព័ន្ធនៅក្នុងដំណើរការកាត់សេចក្តី ដោយគិតចាប់ពីជនជាប់ចោទ ជនរងគ្រោះ និងសាក្សី ។ ទោះបីជាច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ខ្វះអង្គវិធាននីតិវិធីដូចគ្នានេះក៏ដោយ តុលាការអន្តរជាតិមុនៗបានបង្កើតគោលការណ៍ទូទៅដែលបានកំណត់គ្រប់ដំណាក់កាលនៃការកាត់ក្តីទាំងអស់ ដូចជាការប្រមូលភស្តុតាងនៅពេលស៊ើបអង្កេត ការបង្ហាញភស្តុតាងចំពោះមុខចៅក្រមអង្គជំនុំជម្រះ ការសម្រេចចិត្តនិងការដាក់ទោសរបស់ចៅក្រម និងដំណាក់កាលប្តឹងឧទ្ធរណ៍ ។

ដោយខុសពីច្បាប់លក្ខន្តិកៈតុលាការអន្តរជាតិដទៃទៀត (ដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី និងរ៉្វាន់ដា) ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានកំណត់ពីវិធាននីតិវិធីនិងវិធានភស្តុតាងនិងមិនបានផ្តល់សិទ្ធិអំណាចទៅដល់ចៅក្រមក្នុងការតាក់តែង (ជ្រើសរើស) វិធានផ្ទាល់ខ្លួនទេ ។ ផ្ទុយទៅវិញ ច្បាប់នេះអនុញ្ញាតឲ្យចៅក្រមពឹងផ្អែកជាបឋមទៅលើក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជានិងដោយយោងលើច្បាប់អន្តរជាតិចាំបាច់ក្នុងការបំពេញបន្ថែមលើចន្លោះខ្វះខាតនិងបញ្ជាក់ឲ្យបានច្បាស់នូវភាពមិនស្របគ្នា ។ វិធាននីតិវិធីនិងវិធានភស្តុតាង ត្រូវបានព្រាងមុនការបង្កើតតុលាការ ។ ក៏ប៉ុន្តែ ក្នុងករណីវិធាននីតិវិធីនិងវិធានភស្តុតាងមិនត្រូវបានព្រាងទុកមុនទេនោះ កិច្ចការនេះនឹងធ្លាក់ទៅលើអង្គជំនុំជម្រះវិសាមញ្ញជាអ្នកធានាអះអាងថា វិធាននីតិវិធីនិងវិធានភស្តុតាងឆ្លើយតបទៅបទដ្ឋានអន្តរជាតិស្តីពីភាពត្រឹមត្រូវនិងយុត្តិធម៌ ។

វិធាននីតិវិធីនិងវិធានភស្តុតាង អាចធានាដល់ភាពយុត្តិធម៌របស់តុលាការបាន ក៏ប៉ុន្តែវិធាននេះ ក៏មានការលំបាកច្រើន ក្នុងការចោទប្រកាន់ឧក្រិដ្ឋជនដែរ ។ ប្រជាពលរដ្ឋខ្មែរអាចលើកឡើងជាសំណួរស្តីអំពីបំណងដែលបន្ទាក់ដំណើរការយ៉ាងប្រញាប់ប្រញាល់ក្នុងការដាក់ឲ្យអតីតមេដឹកនាំខ្មែរក្រហមទទួលខុស ឬ យ៉ាងហោចណាស់អាចដាក់ឲ្យមេដឹកនាំមួយចំនួនដែលមិនទាន់បានកាត់ទោសទទួលខុសត្រូវចំពោះបទឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្ត ។ តុលាការមួយដែលគ្មានវិធាននីតិវិធីនិងវិធានភស្តុតាងក៏អាចកាត់ទោសបានដែរ ក៏ប៉ុន្តែការកាត់ទោសបែបនេះត្រូវប្រើប្រាស់ថវិកាអស់ជាច្រើន ។ ដោយកង្វះវិធាននីតិវិធី អង្គជំនុំជម្រះវិសាមញ្ញនឹងញ៉ាំងឲ្យមានការសម្រេចចិត្តតាមអំពើចិត្ត ហើយបើកទូលាយឲ្យមានការរិះគន់អង្គជំនុំជម្រះវិសាមញ្ញដែលធ្វើឡើងផ្ទុយស្រឡះទៅនឹងប្រព័ន្ធច្បាប់កម្ពុជាទាំងមូល ។ ប្រការនេះ គឺមានលក្ខណៈផ្ទុយស្រឡះទៅនឹងទិសដៅចម្បងរបស់សាលាក្តីខ្មែរក្រហម ដែលត្រូវការពេលវេលាយូរដើម្បីដោះស្រាយអំពើអយុត្តិធម៌នៃរឿងរ៉ាវអតីតកាលរបស់កម្ពុជា ។ ជម្រើសមួយបែបទៀតក្នុងការអនុម័តវិធាននីតិវិធីនិងវិធានភស្តុតាងដែលឆ្លើយតបតាមបទដ្ឋានអន្តរជាតិ ផ្តល់លទ្ធភាពដល់តុលាការបណ្តុះបណ្តាលមន្ត្រីតុលាការខ្មែរឲ្យស្វែងយល់អំពីបទដ្ឋានអន្តរជាតិដើម្បីការជំនុំជម្រះក្តីដោយយុត្តិធម៌ ។ មធ្យោបាយនេះនឹងដឹកនាំតុលាការឆ្ពោះទៅកាន់ឯករាជ្យភាពនិងសមត្ថភាព ព្រមទាំងពង្រឹងនីតិរដ្ឋនៅកម្ពុជាថែមទៀត ។

**ខេតទ្រីណា អេនឌីសុន**

# វិធានសម្រាប់ការការពារក្តី ៖ មួយជំហានថយក្រោយ

ចាប់តាំងពីបើកការិយាល័យនៅខែកក្កដាឆ្នាំ២០០៦ អង្គជំនុំជម្រះវិសាមញ្ញដែលមានភារកិច្ចជំនុំជម្រះសេចក្តីអតីតមេដឹកនាំខ្មែរក្រហម បានជាប់គាំងដោយការខកខានមិនបានអនុម័តវិធានផ្ទៃក្នុងនិងនីតិវិធី ។ ឥឡូវនេះ សាលាក្តីទំនងជាមានអនុម័តវិធាននេះនៅត្រឹមដំណាច់ខែឧសភា ។ នៅថ្ងៃទី២៨ ខែមេសា ប្រាំខែបន្ទាប់ពីមានភាពទ័លច្រកមក គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានជម្នះឧបសគ្គធំចុងក្រោយដោយយល់ព្រមបន្ទាបតម្លៃនៃការចុះឈ្មោះរបស់មេធាវីបរទេសពី៤៩០០ ដុល្លារមកនៅត្រឹមតែ៥០០ដុល្លារ រ៉ូភើត ស្មៀលបេក ប្រធានអង្គភាពមេធាវីការពារក្តី បានផ្តល់បទសម្ភាសន៍ជាមួយកាសែត International Justice Tribune ស្តីអំពីបញ្ហាដែលជាការព្រួយបារម្ភទាក់ទងទៅនឹងការការពារក្តី ។



រូភើត ស្មៀលបេក ប្រធានមេធាវីការពារក្តី

*តើមានបញ្ហាអ្វីខ្លះនៅសេសសល់ដែលត្រូវស្រាយបំភ្លឺទាក់ទងនឹងការការពារក្តីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ?*

វិធានផ្ទៃក្នុងគួរតែបញ្ជាក់ពីវិធីដែលដល់មេធាវីបរទេសដែលនឹងត្រូវអនុញ្ញាតឲ្យបង្ហាញមុខនៅក្នុងតុលាការ ។ កិច្ចការនេះមើលទៅដូចជាថា មេធាវីបរទេសនឹងត្រូវបានអនុញ្ញាតឲ្យនិយាយ ។ ដូច្នេះហើយយើងសង្ឃឹមថាបញ្ហានោះនឹងត្រូវបានដោះស្រាយ ។ អ្វីដែលត្រូវការស្រាយបំភ្លឺនោះគឺដំណើរការដែលមេធាវីបរទេសនឹងទទួលបាននូវសិទ្ធិពិតប្រាកដពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ហើយអ្វីដែលនឹងកើតឡើងនោះ ប្រសិនបើគណៈមេធាវីបដិសេធការផ្តល់សិទ្ធិឲ្យមេធាវីណាម្នាក់ ឬប្រសិនបើគណៈមេធាវីដាក់វិន័យទៅលើមេធាវីបរទេសណាម្នាក់ ហើយលុបឈ្មោះចេញពីក្នុងបញ្ជី ។

*តើប្រព័ន្ធនៃការបង់ប្រាក់សម្រាប់មេធាវីការពារក្តីប្រព្រឹត្តឡើងយ៉ាងដូចម្តេច?*

កត្តាសំខាន់ដែលបានស្នើឡើងនោះគឺថា ជនជាប់ចោទម្នាក់ៗនឹងមានសហមេធាវីពីរនាក់ដែលម្នាក់ជាជនជាតិកម្ពុជា និងម្នាក់ទៀតជាបរទេស ។ សហមេធាវីទាំងពីរនាក់នោះនឹងមានការជួយឧបត្ថម្ភពីសំណាក់អ្នកចាត់ចែងរឿងក្តីដែលបានចុះក្នុងកិច្ចសន្យាជាមួយអង្គភាពមេធាវីការពារក្តីដើម្បីធ្វើការលើរឿងក្តីនោះ ។ ថវិកាទាំងអស់របស់មូលនិធិជំនួយផ្នែកច្បាប់គឺ៤,៧លាន ដុល្លារសហរដ្ឋអាមេរិក ។ ចំនួនថវិកាសម្រាប់ជនជាប់ចោទម្នាក់ដែលនឹងត្រូវចំណាយទៅលើសមាជិក៤ទៅ៥នាក់នៃក្រុមការពារក្តី គឺមានចំនួនលើសពី ៤សែនដុល្លារ ។ បញ្ហាសំខាន់ក្នុងការរក្សាតម្លៃនេះកើតមានឡើងក្នុងករណីដែលការជំនុំជម្រះក្តីមានរយៈពេលយូរ ។ នៅត្រង់ចំណុចនេះ យើងកំពុងសម្លឹងមើលទៅលើដំណាក់កាលស៊ើបអង្កេតមុនសវនាការ ដែលមានរយៈពេលដប់ខែ ដោយមានដំណាក់កាលជំនុំជម្រះរយៈពេល៥ខែ និងដំណាក់កាលបណ្តឹងឧទ្ធរណ៍មានរយៈពេល៤ខែ ។

*តើនីតិវិធីច្បាប់ស៊ីវិលមិនអាចជួយបន្ទាបតម្លៃនៃការការពារក្តីបានទេ?*

មានមនុស្សជាច្រើនបញ្ចេញទស្សនៈថា ក្នុងដំណាក់កាល

ស៊ើបអង្កេត មេធាវីការពារក្តីមិនធ្វើអ្វីសោះ ការណ៍នេះគឺខុសទាំងស្រុងក្នុងករណីនេះ ។ វាមានសារសំខាន់ខ្លាំងណាស់ដែលមេធាវីការពារក្តីត្រៀមខ្លួនសម្រាប់ការជំនុំជម្រះក្តី ។ មេធាវីការពារក្តីនឹងមានពេលច្រើនខែដើម្បីស្វែងយល់នូវព័ត៌មានគ្រប់គ្រាន់ស្តីអំពីរបៀបដែលរបបខ្មែរក្រហមបានដំណើរការ និងអ្វីដែលរបបនេះបានធ្វើក្នុងអំឡុងឆ្នាំ១៩៧៥និង១៩៧៩ ។ ការត្រៀមរៀបចំអំពីប្រវត្តិនោះទាមទារឲ្យយើងចំណាយពេលវេលាច្រើនក្នុងដំណាក់កាលស៊ើបអង្កេត ។ ដូច្នេះ គ្មានការសន្សំសំចៃប្រាក់កាសនោះទេ ហើយតាមពិតទៅយើងប៉ាន់ស្មានថាសហមេធាវីនឹងចំណាយពេលតែហាសិបភាគរយនៃពេលវេលារបស់ខ្លួនតែប៉ុណ្ណោះ ដើម្បីធ្វើកិច្ចការលើរឿងក្តីនោះក្នុងដំណាក់កាលស៊ើបអង្កេត ។

*តើនរណានឹងបង់ថ្លៃ?*

គឺអង្គភាពមេធាវីការពារក្តី ។ យើងគ្មានក្រឡាបញ្ជីទេនៅឯអង្គជំនុំជម្រះវិសាមញ្ញនោះ ។ យើងមានតែការិយាល័យរដ្ឋបាលដែលមាននាទីផ្តល់ដល់ភាគីទាំងអស់នូវការគាំទ្រខាងរដ្ឋបាល ប៉ុន្តែការិយាល័យនេះគ្មានតួនាទីខាងផ្លូវច្បាប់អ្វីនោះទេ ។ ដូច្នេះហើយ សេចក្តីសម្រេចនានាទាក់ទងនឹងការបង់ប្រាក់នឹងត្រូវធ្វើឡើងដោយអង្គភាពមេធាវីការពារក្តី ។

*តើមេរៀនអ្វីខ្លះដែលទាញចេញពីតុលាការនៅប្រទេសសេរ៉ាឡេអូន និងបូស្នៀរដើម្បីយកមកអនុវត្តនៅក្នុងប្រទេសកម្ពុជាប្រកបដោយជោគជ័យ?*

មេរៀនដ៏សំខាន់បំផុតមួយដែលរៀនពីសាលាក្តីមុនៗនោះ គឺ មេធាវីការពារក្តីត្រូវតែតែងតាំងឡើងនៅជំហានដំបូងបំផុត ។ យើងមានក្តីសង្ឃឹមថា មេធាវីការពារក្តីនឹងទទួលបានសិទ្ធិនៅក្នុងសាលាក្តីនេះតាមរយៈការតែងតាំងមេធាវីការពារក្តីក្នុងរយៈពេលតែប៉ុន្មានខែបន្ទាប់ពីបានតែងតាំងព្រះរាជអាជ្ញាដែលជាការតែងតាំងមួយលឿនជាកន្លែងណាៗទាំងអស់ ។ រឿងដ៏សំខាន់មួយផ្សេងទៀតនោះគឺ ត្រូវតែមានមេធាវីនៅក្នុងអង្គភាពមេធាវីការពារក្តី ដែលយល់ដឹងពីច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ហើយមិនមែនយល់ដឹងត្រឹមតែច្បាប់រដ្ឋបាលនោះទេ ។ ចំពោះហេតុផលហិរញ្ញវត្ថុ យើងមិនអាចមានលទ្ធភាពយកនីតិវិធីរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិដែលបំបែកការទទួលខុសត្រូវខាងផ្នែករដ្ឋបាលចំពោះការបង់ថ្លៃនេះ ហើយរក្សាទុកនូវបញ្ជីមេធាវីដែលស្រង់ចេញពីផ្នែកគាំពារខាងផ្លូវច្បាប់និងការិយាល័យប្រឹក្សាយោបល់នោះទេ ។ ប៉ុន្តែបុគ្គលិកដែលយើងជ្រើសរើសមកគឺអ្នកដែលធ្លាប់ធ្វើការក្នុងរយៈពេលមួយសមរម្យទាក់ទងនឹងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ហើយមានលទ្ធភាពផ្តល់ការគាំទ្រដ៏សមស្របដល់មេធាវីការពារក្តី និងជាពិសេសមេធាវីការពារក្តីកម្ពុជា ។

*ហើយអ្វីដែលមិនសូវផ្តល់នូវសារសំខាន់?*

ជាអកុសល មើលទៅហាក់ដូចជាថាវិធានផ្ទៃក្នុងជាការបោះមួយជំហានថយក្រោយនៅក្នុងការរកយុត្តិធម៌លើបទឧក្រិដ្ឋកម្មអន្តរជាតិនៅត្រង់ថា វិធាននេះបានកាត់បន្ថយលទ្ធភាពរបស់អង្គភាពមេធាវីការពារក្តីក្នុងការផ្តល់ការគាំទ្រដល់មេធាវី និងជនជាប់ចោទនៅចំពោះមុខសាលាក្តី ។ មើលទៅហាក់ដូចថា អង្គភាពមេធាវីការពារក្តីនឹងគ្មានសិទ្ធិទៅរកទស្សនិកជនណាម្នាក់ដែលការណ៍នេះគឺជាការបោះមួយជំហានថយក្រោយទាក់ទងទៅនឹងលទ្ធភាពធ្វើជាតំណាងដ៏សមស្របឲ្យដល់ស្មាក្តីនៅក្នុងដំណាក់កាលដំបូង ។ យើងនឹងត្រូវរង់ចាំរយៈពេលពីរឬបីខែទើបមេធាវីបរទេសអាចចូលមកបាន ។ ជំហានថយក្រោយមួយទៀតនេះគឺ លទ្ធភាពក្នុងការគាំទ្រដល់សហមេធាវីកម្ពុជា ។ លើសពីនេះទៀត វាហាក់ដូចជាថា ការិយាល័យមេធាវីការពារក្តីនឹងមិនអនុញ្ញាតឲ្យផ្តល់ការប្រឹក្សាលើផ្នែកច្បាប់នោះទេ ។ យើងគ្រាន់តែទទួលបានការអនុញ្ញាតឲ្យផ្តល់នូវការស្រាវជ្រាវផ្នែកច្បាប់ប៉ុណ្ណោះ ។ ជាថ្មីម្តងទៀត នោះហើយគឺជាការបោះមួយជំហានថយក្រោយ ដោយយោងតាមបទពិសោធន៍នៅក្នុងសាលាក្តីផ្សេងៗទៀត កិច្ចការនេះ គឺជារឿងសំខាន់ ។ ដូច្នេះហើយ តាមពិតទៅតួនាទីរបស់មេធាវីការពារក្តីត្រូវបានកាត់បន្ថយយ៉ាងច្រើនបើប្រៀបធៀបទៅនឹងសាលាក្តីផ្សេងៗទៀត បើទោះបីជាអង្គភាពមេធាវីការពារក្តីអាចមានលទ្ធភាពធ្វើកិច្ចការទាំងអស់នោះបាន និងមានការរឹតត្បិតជាច្រើនក៏ដោយ ។

**ធារី គ្រួលីអ័រ**

***អត្ថបទដកស្រង់ពីព្រឹត្តិបត្រសាលាក្តីយុត្តិធម៌អន្តរជាតិលេខ១៦៧ ហើយមានការអនុញ្ញាតដោយនិពន្ធនាយករបស់ព្រឹត្តិបត្រនេះ ។***

***គេហទំព័រ : www.justicetribune.com***

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យនិងព្រឹត្តិការណ៍វិវត្តន៍នៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

“ការិយាល័យព័ត៌មានសាធារណៈ” មានផ្តល់ជូននូវសេវា៣យ៉ាង ៖

**១) បណ្ណាល័យ** ៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ** ៖ មជ្ឈមណ្ឌលមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជា-ធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ** ៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង សម មករា តាមរយៈទូរស័ព្ទលេខ ០២៣ ២២១ ១៦៥ ។ សូមអរគុណ ។


ប្រជាជនខ្មែរអ៊ីស្លាមជួបសំណេះសំណាលជាមួយនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា


ប្រជាជនខ្មែរអ៊ីស្លាមបន្ទាប់ពីការជួបសំណេះសំណាលជាមួយនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

# ការសិក្សាអំពីទម្រង់ប្រព័ន្ធសន្តិសុខខ្មែរក្រហម ប្រៀបធៀបនឹងប្រទេសផ្សេងទៀត

នៅរវាងឆ្នាំ១៩៧៥-១៩៧៩ ប្រជាជនប្រមាណ១,៥ លាននាក់ បានបាត់បង់ជីវិតដោយសារកង្វះអាហារ ការធ្វើស្រែចម្ការសព្វសារពើ និងជំងឺតម្កាត់ផ្សេងៗដែលទទួលការព្យាបាលមិនត្រឹមត្រូវ ។ តាមការប៉ាន់ស្មានមានប្រជាជនជាង២សែននាក់ទៀតស្លាប់ ប៉ុន្តែស្ថិតិនេះនៅមិនទាន់ជាក់ច្បាស់នៅឡើយ ហើយតួលេខអាចខ្ពស់ជាងតួលេខក្នុងឯកសារស្រាវជ្រាវឯទៀតទាក់ទិននឹងបញ្ហានេះ ។ ក្នុងអំឡុងពេលនេះ ប្រទេសជាតិស្ថិតនៅក្រោមការត្រួតត្រារបស់ខ្មែរក្រហមដឹកនាំដោយក្រុមឆ្វេងនិយមលទ្ធិម៉ាក្សលេនីនមួយក្រុមដែលបញ្ឈរយ៉ាងល្អិតល្អន់លើការសម្លាប់ក្នុងជួរ«បដិវត្តន៍» ។ បដិវត្តន៍កម្ពុជាប្រជាធិបតេយ្យ (កម្ពុជាក្រោមការកាន់កាប់នៃរបបខ្មែរក្រហម) ដាច់ខាតមិនអនុញ្ញាតឲ្យមានការបត់បែនណាមួយ ហើយខ្មែរក្រហមតែងបន្តបោសសម្អាតខ្មាំងបដិវត្តន៍ឥតឈប់ឈរ ។ ប្រជាជនរាប់ពាន់នាក់ត្រូវបានដាប់ឈ្មោះជា«ខ្មាំង»និងត្រូវយកទៅសម្លាប់ដោយមិនបានឆ្លងកាត់សវនាការ ។ មនោគមវិជ្ជានៃបក្សកុម្មុយនីស្តកម្ពុជា (បក្សដឹកនាំដោយមេដឹកនាំកំពូល «បងធំ» ខ្មែរក្រហម) គឺទម្រង់គ្រប់គ្រងផ្តាច់ការបំផុតនៃរបបកុម្មុយនីស្ត ដែលប្រែក្លាយប្រទេសជាតិទាំងមូលទៅកាន់រដ្ឋកសិកម្ម ។

អតីតវិទ្យាល័យទួលស្លែងបានក្លាយជាទីបញ្ជាការសន្តិសុខផ្ទៃក្នុង(ឬហៅថាសន្តិបាល)របស់ខ្មែរក្រហម និងជាកន្លែងសួរចម្លើយដែលជាក់ស្តែងមាន«ខ្មាំងរដ្ឋ» ប្រមាណជា១៤ពាន់នាក់ឆ្លងកាត់ការសួរចម្លើយ ការធ្វើទារុណកម្ម និងការចាប់បង្ខំឲ្យសារភាពពីបទប្រឆាំងនឹងបដិវត្តន៍ ខណៈដែលអ្នកទាំងនោះកំពុងជាប់ឃុំឃាំងនៅមន្ទីរស-២១ ។ នៅក្នុងបរិវេណមន្ទីរសន្តិសុខមានអគារលាបកំបោរពណ៌សបួនខ្នង កម្ពស់បីជាន់ដែលយើងច្រើនហៅថា ស-២១ នោះជាឈ្មោះសម្ងាត់របស់ខ្មែរក្រហម ដើម្បីបង្ហាញពីទីបញ្ជាការមន្ទីរសន្តិសុខ ។ នៅឆ្នាំ១៩៨១ លោក ដេវីដ ឆេនល័រ អ្នកនិពន្ធសៀវភៅ «សំឡេងពីមន្ទីរស-២១» បានធ្វើដំណើរមកប្រទេសកម្ពុជានិងទស្សនាបរិវេណមន្ទីរសន្តិសុខ ។ ក្រោមការរៀបចំដោយរបបគាំទ្រដោយវៀតណាមនៅឆ្នាំ១៩៧៩ មន្ទីរសន្តិសុខនេះបានក្លាយជាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ឆ្លងកាត់ការសិក្សាយ៉ាងហ្មត់ចត់លើឯកសារចម្លើយសារភាពនិងរបាយការណ៍សួរចម្លើយ លោក ឆេនល័រ អាចសរុបទម្រង់សំណួរមួយចំនួនដែលឆ្លើយតបនឹងចម្លើយសរសេរក្នុងឯកសារ ។ គំនិតដំបូងបង្អស់របស់លោក ឆេនល័រ គឺសរសេរសៀវភៅមួយស្តីពីកម្លាំងបះបោរប្រឆាំងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលជាផ្នែកមួយនៅមិនទាន់មាននរណាស្រាវជ្រាវនៅឡើយ ។ ភ្លាមនោះ លោក ឆេនល័រ យល់ឃើញថា យើងគ្មានផ្លូវវាស់ស្ទង់ថា



កម្មាភិបាលបម្រើការនៅមន្ទីរសន្តិសុខគុកទួលស្លែងហូបបាយរួមគ្នា

តើចម្លើយសារភាព កត់ត្រាដោយអ្នកសួរចម្លើយនៅមន្ទីរស-២១ជាចម្លើយពិត ឬប្រឌិតក្រោមឥទ្ធិពលនៃទារុណកម្មដោយបង្ខំឡើយ ។ ចំណុចផ្តោតសំខាន់ក្នុងការសិក្សារបស់លោក ឆេនល័រ គឺរឿងរ៉ាវពិស្តារស្តីពីរចនាសម្ព័ន្ធ និងរបៀបរបបផ្សេងៗក្នុងការអនុវត្តន៍នៅក្នុងបរិវេណមន្ទីរឃុំឃាំង ។ លោក ឆេនល័រ ផ្តង់អារម្មណ៍ទៅលើបញ្ហាស្ថានភាពការងារនៅក្នុងគុក សត្រូវរបស់ខ្មែរក្រហមដែលជាប់ឃុំឃាំង វិធីសាស្ត្រធ្វើទារុណកម្ម និងទំនោរទៅរកមនោគមវិជ្ជានៃមន្ទីរសន្តិសុខ ។ នៅក្នុងសៀវភៅ "សំឡេងពីមន្ទីរស-២១" លោក ឆេនល័រ បានប្រៀបធៀបសមាសភាពមន្ទីរឃុំឃាំងទៅនឹងទម្រង់ប្រហាក់ប្រហែលគ្នានៅអតីតសហភាពសូវៀត ចិន វៀតណាម របបណាហ្ស៊ីនៅអាល្លឺម៉ង់និងអាហ្សង់ទីន ។ តាមរយៈការប្រៀបធៀបនេះ លោក ឆេនល័រ បានលើកបង្ហាញពីការវិភាគលក្ខណៈប្រៀបធៀបដើម្បីផ្តល់នូវការយល់ដឹងបន្ថែមពីលើរចនាសម្ព័ន្ធនៃរបបខ្មែរក្រហម ។ ការប្រៀបធៀបនេះថែមទាំងផ្តល់នូវបរិបទជាអន្តរជាតិដល់ការសិក្សារបស់គាត់និងធ្វើឲ្យគាត់អាចសន្និដ្ឋានបានថា ស-២១ ជា"ព្រឹត្តិការណ៍ដ៏ចម្លែកនៃសតវត្សរ៍ទី២០ ដែលនាំកម្ពុជាទៅជារបបកម្មុយនីស្ត" ។

ពេលលោក ឆេនល័រ បានឈានជើងចូលមន្ទីរសន្តិសុខ ស-២១ នៅឆ្នាំ១៩៨១ គាត់មានបទពិសោធន៍យល់ដឹងពីឯកសារជាច្រើន ដែលសព្វថ្ងៃនៅមិនទាន់ធ្វើឲ្យបានជោគជ័យនៅឡើយ ។ ឯកសារត្រូវបានយកទៅវិភាគដោយអ្នកប្រាជ្ញជាច្រើននៅអាស៊ី-អាគ្នេយ៍ ។ ដូចបង្ហាញតាមរយៈប្រភពខាងក្រោម ឯកសារទាំងនោះផ្តល់នូវមូលដ្ឋានជាច្រើនសម្រាប់ការសិក្សាពីរចនាសម្ព័ន្ធនៃមន្ទីរស-២១ សន្តិសុខផ្ទៃក្នុងនិងបរិបទធំទូលាយទាក់ទិននឹងប្រធានបទការមិនទុកចិត្តគ្នារបស់ខ្មែរក្រហម និងអំពើហិង្សាក្នុងតំបន់អាស៊ី-អាគ្នេយ៍ ។

គំនរឯកសារជាច្រើនគរកម្ពស់រាប់ម៉ែត្រនៅក្នុងទូកញ្ចក់ លើតុនិងផ្តេកក្បែរជញ្ជាំង ។ ឯកសារភាគច្រើនជាប្រភេទ ឯកសារចម្លើយសារភាពសរសេរដោយដៃ ។ ឯកសារចម្លើយសារភាពមួយចំនួនដែលទទួលបានពីអ្នកទោសជាអតីតមន្ត្រីរដ្ឋការថ្នាក់ខ្ពស់មានរាប់រយសន្លឹក ។ ឯកសារឯទៀតនៅក្នុងបណ្ណសារដ្ឋានមានបញ្ជីកត់ត្រាឈ្មោះអ្នកទោសចូលមន្ទីរស-២១ និងបញ្ជីសម្លាប់កំណត់ហេតុរបស់អ្នកសួរចម្លើយ សៀវភៅសិក្សាកម្មាភិបាល និងប្រវត្តិរូបអ្នកធ្វើការនៅទួលស្លែង ។

នៅអំឡុងឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៨ លោក ឆេនល័រ ធ្វើការសិក្សាលើអត្ថបទចម្លើយសារភាពជាងមួយពាន់ច្បាប់ ។ មុននោះលោកធ្លាប់បានគ្រប់គ្រងដំណើរការម៉ៃក្រូហ្វីលដែលជាផ្នែកមួយដ៏ធំនៃបណ្ណសារសម្រាប់សាកលវិទ្យាល័យខនណែលនិងក្រសួងវប្បធម៌កម្ពុជា ។ ក្រៅពីអត្ថបទចម្លើយសារភាព និងសៀវភៅវិភាគផ្សេងៗ លោក ឆេនល័រ បានធ្វើបទសម្ភាសន៍ជាមួយអ្នកនិពន្ធនិងអ្នករស់រានពីរបបកម្ពុជាប្រជាធិបតេយ្យជាច្រើននាក់ ដើម្បីប្រមូលព័ត៌មានសម្រាប់ធ្វើជាមូលដ្ឋានគ្រឹះក្នុងការសិក្សារបស់លោក ។ លោក ឆេនល័រ ទទួលបាននូវ"ជំនួយមិនអាចកាត់ថ្លៃបាន" ពីអ្នកជំនួយការស្រាវជ្រាវរបស់គាត់គឺលោក សុខ ភិរម្យ ដែលជាអ្នកជួយរៀបចំការសម្ភាសន៍និងជួយបកប្រែឯកសារសំខាន់ៗមួយចំនួនធំ ។ បទសម្ភាសន៍ដែលធ្វើឡើងដោយអ្នកស្រាវជ្រាវជាន់ខ្ពស់ជាច្រើនទៀត (ដូចជា លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា) ក៏ត្រូវបានប្រើប្រាស់ដើម្បីពង្រឹងមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវនេះដែរ ។ ទន្ទឹមនឹងមានឯកសារទាក់ទិននឹងរបបកម្ពុជាប្រជាធិបតេយ្យ ឯកសារវិភាគមួយចំនួនទាក់ទងនឹងប្រទេសកុម្មុយនីស្តនិងមិនមែនកុម្មុយ-នីស្តត្រូវបានប្រើប្រាស់ដើម្បីប្រៀបធៀបឲ្យបានស៊ីជម្រៅទៅនឹងទម្រង់មន្ទីរឃុំឃាំងជាលក្ខណៈសាកលរួម ។ ការយល់ដឹងផ្នែកប្រវត្តិសាស្ត្ររបស់លោក ឆេនល័រ រួមផ្សំនឹងភាពប៉ិនប្រសប់ផ្នែកភាសាជាតិ ធ្វើឲ្យគាត់ក្លាយជាបុគ្គលដ៏ស័ក្តិសមបំផុតក្នុងការស្រាវជ្រាវពីប្រភពឯកសារសំណៅដើមនិងឯកសារវិភាគដ៏ច្រើនសន្ធឹកសន្ធាប់ ។ ដូចដែលមានកត់ត្រាទុកក្នុងការសិក្សារបស់គាត់ថា ÷ "ឯកសារដ៏ច្រើនដែលយើងអាចប្រើប្រាស់បាន គឺគ្រប់គ្រាន់ល្មមនឹងគាំទ្រការសិក្សាស្រាវជ្រាវពិស្តារអំពីមន្ទីរឃុំឃាំង" ។

លោក ឆេនល័រ បានយកលំនាំវិធីសាស្ត្រអព្យាក្រឹតក្នុងការប្រើប្រាស់ប្រភពឯកសារ ដែលជាហេតុធ្វើឲ្យការសិក្សាស្រាវជ្រាវពីមន្ទីរស-២១ក្លាយជាបរិបទធំទូលាយនិយាយពីចិត្ត

គំនិតរួមមួយរបស់ខ្មែរក្រហម ។ វេទិកាជជែកវែកញែកជាច្រើនស្តីពីប្រវត្តិភូមិសាស្ត្រទាក់ទិននឹងរបបខ្មែរក្រហម ជាទូទៅផ្តោតទៅលើមេដឹកនាំនៃរបបនោះ ។ តាមរយៈការសរសេររៀបរាប់របស់លោក បានបង្ហាញនូវទស្សនៈថ្មីចំពោះចិត្តគំនិតរបស់ខ្មែរក្រហមថា ជារបបមានលក្ខណៈលួចលាក់និងការមិនទុកចិត្តដែលទទួលយកអំពើហិង្សាក្នុងទម្រង់ជាទណ្ឌកម្មដើម្បីបង្ហាញពីអំណាចផ្តាច់ការ ។ ប្រភពឯកសារត្រូវបានប្រើប្រាស់យ៉ាងជិតដល់បំផុតនៅក្នុងការសិក្សារបស់លោក ដោយសារលោកដឹងថាមានឯក-សារច្រើនទៀតនៅមិនទាន់លាតត្រដាង ដោយសារមានការលំបាកក្នុងការពិនិត្យបញ្ជាក់ឡើងវិញនូវបញ្ជីនានានៅក្នុងមន្ទីរឃុំឃាំង និងដោយសារមិនមានឯកសារផ្សេងទៀតដើម្បីផ្ទៀងផ្ទាត់ ។ ភាគច្រើនការបរិយាយរឿងមានលេចចេញមកពីចម្លើយសារភាពឆ្នាំ១៩៧៩របស់អតីតអ្នកបម្រើការមន្ទីរសន្តិសុខ ។ ឯកសារចម្លើយសារភាពនេះបង្ហាញពីបែបបទការងារ ទម្រង់នៃការសួរចម្លើយ និងការប្រើប្រាស់ទារុណកម្ម ។ របាយការណ៍របស់អ្នកសួរចម្លើយមានសារប្រយោជន៍ច្រើនក្នុងការបង្ហាញពី"ទំនាក់ទំនងលម្អៀងរវាងជនដៃដល់និងជនរងគ្រោះ" ។ ក្នុងន័យកាន់តែទូលាយ របាយការណ៍នេះជាសមាសភាពផ្សំនៃចិត្តគំនិតរួមរបស់ខ្មែរក្រហម ។ ជាងនេះទៅទៀត ការរៀបចំរចនាសម្ព័ន្ធរបស់មន្ទីរស-២១ គឺជាការពណ៌នាអំពីរបបគ្រប់គ្រងក្នុងសង្គមនាសម័យនោះ ។ ម៉ីលឡូវ៉ាន ឌីឡាស វែកញែកថា "ប្រភពឯកសារទាំងនេះបង្ហាញពីគោលគំនិតនិងវិធីសាស្ត្ររបស់អ្នកត្រួតត្រាសង្គម" ។

ប្រវត្តិវិទូជាច្រើនបានព្យាយាមចោទសួរថា ហេតុអ្វីបានជារបបគ្រប់គ្រងអំពើប្រល័យពូជសាសន៍កម្ពុជាបានរក្សាទុកឯកសារដ៏ច្រើនបែបនេះ ។ នេះជាសំណួរមួយដែលលើកឡើងដើម្បីភ្ជាប់ នឹងអំពើប្រល័យពូជសាសន៍នៅប្រទេសផ្សេងៗទៀតក្នុងសតវត្សរ៍ទី២០ ដូចជា ណាហ្ស៊ីនៅអាល្លឺម៉ង់ និងអតីតសហភាពសូវៀតក្រោមការដឹកនាំរបស់ស្តាលីន ។ ក្នុងសៀវភៅ "សំឡេងពីមន្ទីរស-២១" លោក ឆេនល័រ បានឆ្លើយតបនឹងសំណួរនេះ ដោយបង្ហាញពីចរិតលាក់ការណ៍និងមិនទុកចិត្តគ្នាឯងបង្កប់ក្នុងរបបខ្មែរក្រហម និងបង្ហាញពីមហិច្ឆតានិងអំណាចផ្តាច់ការ ។ លោក ស៊ីវ ហេដឌ័រ អ្នកប្រាជ្ញល្បីល្បាញខាងផ្នែកប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យវែកញែកថា ឯកសារដែលរកឃើញនៅមន្ទីរស-២១ ត្រូវបានផ្តល់ឲ្យមជ្ឈិមបក្សនូវឯកសារដ៏ច្រើនសន្ធឹកសន្ធាប់ ហើយមិនសរសេររឿងរ៉ាវប្រវត្តិសាស្ត្ររបស់បក្សនិងជ័យជម្នះរបស់បក្ស ក្នុងការប្រឆាំងនឹងកម្លាំងប្រឆាំងទេ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការវែកញែករបស់លោក ហេដឌ័រ ជាចម្លើយគួរឲ្យទទួលយកបានបំផុតនៅក្នុងការស្រាវជ្រាវរបស់ លោក ឆេនល័រ ក្រៅពីនោះនៅមានហេតុផលជាច្រើនទាក់ទងនឹងការរក្សាទុកឯកសារដ៏ច្រើននេះ ។ ប៉ុល ពត "បងធំទី១ និងជាមេដឹកនាំខ្មែរក្រហម" មានចំណាប់អារម្មណ៍ចំពោះទ្រឹស្តីសមគំនិតក្បត់ជាមួយនឹងកម្មាភិបាលជាន់ខ្ពស់បក្សឯទៀត ហើយ ប៉ុល ពត ប្រហែលជាចង់ដកស្រង់ចម្លើយសារ-ភាពនេះ ដើម្បីឆ្លុះបញ្ចាំងពីរឿងរ៉ាវដែលកើតឡើងក្នុងអំឡុងពេលដែលសមាជិកបក្សដំបូងបង្កើតឡើងដោយលួចលាក់ក្នុងទសវត្សរ៍ឆ្នាំ១៩៥០ ដោយលាក់ខ្លួននិងចេញច្បាំងក្នុងសង្គ្រាមស៊ីវិលក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ។ មូលហេតុចុងក្រោយ គឺជាបំណងប្រាថ្នារបស់បក្សផ្ទាល់ដើម្បីបង្ហាញពីជោគជ័យលើកម្លាំងប្រឆាំងនឹងបដិវត្តន៍ ហើយតាមរយៈការរក្សាទុកឯកសារដ៏ច្រើនដូច្នេះ ធ្វើឲ្យប្រវត្តិសាស្ត្ររបស់ខ្លួនកាន់តែលូតលាស់ ។ លោក ឆេនល័រ លើកឡើងថា បក្សនេះប្រហែលជានឹងទទួលឥទ្ធិពលពីការផ្សព្វផ្សាយនៅឆ្នាំ១៩៣៩ ស្តីពី "ប្រវត្តិសាស្ត្រនៃបក្សកុម្មុយនីស្តសហភាពសូវៀត" ដែលសរសេរពីជ័យជម្នះរបស់ស្តាលីនលើសត្រូវផ្ទៃក្នុងរបស់បក្ស ។ មូលហេតុនេះធ្វើឲ្យការរក្សាទុកឯកសារដ៏ច្រើននេះក្លាយជាប្រធានបទពិភាក្សាដ៏ទូលាយដូចជាឥទ្ធិពលមនោគមវិជ្ជានៃបក្សជាដើម ។

ខណៈដែលលោក ឆេនល័រ "អ្នកនិពន្ធល្បីល្បាញ"លើប្រធានបទកម្ពុជាប្រជាធិបតេយ្យ ការប្រើប្រាស់សំណៅឯកសារដើមនិងឯកសារវិភាគផ្សេងៗធ្វើឲ្យការសិក្សាស្រាវជ្រាវរបស់គាត់មានភាពសំខាន់ដើម្បីឈានទៅរកការយល់ដឹងពីគោលគំនិតរួមនៃរបបខ្មែរក្រហម ។ ការសិក្សានេះ ចង្អុលបង្ហាញពីចរិតលក្ខណៈលាក់ការណ៍និងការមិនទុកចិត្តគ្នានូវរាល់សកម្មភាពរបស់ខ្មែរក្រហម និងចង្អុលបង្ហាញពីប្រពៃណីខ្មែរក្នុងការគោរពនិងការ

ប្រឆាំងនឹងអំណាចដែលបង្ហាញជាសង្ខេបតាមរយៈទំនាក់ទំនងរវាងអ្នកសួរចម្លើយនិងជនរងគ្រោះ ។ ការសិក្សារបស់លោកមិនត្រឹមតែជាប្រភពឯកសារស្រាវជ្រាវពីគំនិតរួមរបស់ខ្មែរក្រហមប៉ុណ្ណោះទេ ថែមទាំងបង្ហាញពីស្ថានភាព"ក្នុងព្រំដែន អំពើអមនុស្សធម៌របស់មនុស្សមកលើមនុស្សជាតិដូចគ្នា" ។ ការវិភាគប្រៀបធៀបពីទ្រង់ទ្រាយមន្ទីរឃុំឃាំងនៅបណ្តាប្រទេសផ្សេងៗ ធ្វើឲ្យលោកអាចគូររូបភាពដ៏គួរឲ្យរន្ធត់នៃអំពើហិង្សាដ៏ឃោរឃៅ ។ យ៉ាងណាមិញ ចំណុចខ្សោយនៃការសិក្សារបស់លោក ឆេនល័រ គឺកង្វះការយកចិត្តទុកដាក់លើទំនោររបស់ប្រទេសកម្ពុជាទៅរកអំពើហិង្សាដែលកើតឡើងផ្ទួនៗគ្នាក្នុងប្រវត្តិសាស្ត្រកម្ពុជា ។ យោងតាមការប្រើប្រាស់ឯកសារដើមភាពស្ទាត់ជំនាញរបស់លោក ឆេនល័រ លើប្រធានបទនិងចំណេះដឹងដ៏ទូលាយគ្របដណ្តប់លើប្រធានបទនេះ យើងអាចនិយាយដោយជឿជាក់ថា សៀវភៅ "សំឡេងពីមន្ទីរស-២១ មានឥទ្ធិពលពិសេសក្នុងការសិក្សាស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍" ។

**អ៊ីសាក ថាប័រ**

# ការពិនិត្យមើលទៅលើគម្រោងនៃការសិក្សាអំពីប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

***អត្ថបទនិងគោលបំណង***

ការបោះពុម្ពផ្សាយសៀវភៅសិក្សាប្រវត្តិសាស្ត្រថ្មីមួយសម្រាប់សិស្ស គឺជាព្រឹត្តិការណ៍ដែលអាចនឹងបង្កឲ្យមានការពិភាក្សាដ៏ខ្លាំងក្លាមួយ ហើយជួនកាលអាចនឹងបង្កឲ្យមានជម្លោះ ផ្នែកការទូតរវាងប្រទេសនិងប្រទេសទៀតផង ។ ឧទាហរណ៍ថ្មីៗនេះ មានបញ្ហាជម្លោះរវាងប្រទេសចិន និងប្រទេសកូរ៉េអំពីបញ្ហា "ស្រីបម្រើតណ្ហា" និងជម្លោះរវាងប្រទេសចិននិងកោះតៃវ៉ាន់អំពីការប្រើប្រាស់ភាសាដែលត្រូវបានអះអាងថា បានជំរុញឲ្យមានបុព្វហេតុទាមទារឯករាជ្យរបស់កោះតៃវ៉ាន់ ។ រឿងនេះបានរំឭកឲ្យខ្ញុំអំពីសុភាសិតបុរាណមួយដែលលើកឡើងថា អ្នកទាំងឡាយណាដែលគ្រប់គ្រងអតីតកាលគឺជាអ្នកកំណត់អនាគតកាល ។ ទោះបីជាឧទាហរណ៍ទាំងនេះរំឭកយើងថា ប្រវត្តិសាស្ត្រអាចបម្រើឲ្យផលប្រយោជន៍នយោបាយក៏ដោយ ក៏ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលជាស្នាដៃនិពន្ធរបស់លោក ឌី ខាំបូលី គឺជាលទ្ធផលការងាររបស់ស្ថាប័នស្រាវជ្រាវឯករាជ្យមួយដែលធ្វើការស្វែងរក "ការពិត" ដើម្បីជំរុញគោលបំណងដ៏គួរឲ្យកោតស្ញប់ស្ញែង គឺការចងចាំ យុត្តិធម៌ និងការផ្សះផ្សាជាតិ




សេចក្តីព្រាងចុងក្រោយនៃអត្ថបទនេះផុសចេញពីដំណើរការដ៏ហ្មត់ចត់មួយដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបង្កើតឡើងក្នុងគោលបំណងផ្តល់ជូនសិស្សថ្នាក់ទី១២នៅកម្ពុជានូវព័ត៌មានពិតឥតលម្អៀងអំពីព្រឹត្តិការណ៍ដ៏ខ្មៅងងឹតក្នុងអតីតកាលថ្មីៗនេះ ដែលបានធ្វើឲ្យប៉ះពាល់ដោយផ្ទាល់ដល់ជីវភាពគ្រួសារ និងការអភិវឌ្ឍន៍ប្រទេសជាតិ ។

ទោះបីជាការស្ទាបស្ទង់មតិទៅលើនិស្សិតថ្នាក់ឧត្តមសិក្សា ដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាបង្ហាញថា ការបដិសេធទាំងស្រុងចំពោះព្រឹត្តិការណ៍ដែលកើតមានឡើងក្នុងអតីតកាលមិនមែនជាបញ្ហាចម្បងនៅកម្ពុជាក៏ដោយ ក៏ជាភ័ស្តុតាងបង្ហាញថា កូនចៅកម្ពុជាជំនាន់ក្រោយបាន

ដឹងតិចតួចណាស់អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ វាមិនមែនជារឿងដ៏គួរឲ្យភ្ញាក់ផ្អើលទេ ដែលថាមកត្រឹមឆ្នាំ២០០២ មេរៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យត្រូវបានដកចេញទាំងស្រុងពីសៀវភៅសិក្សា ហើយលទ្ធភាពក្នុងការស្វែងរកប្រភពសិក្សាផ្សេងៗដូចជា ភាពយន្តនិងប្រព័ន្ធអ៊ិនធឺណែតនៅមានកំណត់ ។ ហេតុដូចនេះ គម្រោងនៃការសិក្សាអំពីរបបកម្ពុជាប្រជាធិបតេយ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានលើកបង្ហាញនូវចន្លោះខ្វះខាតដ៏សំខាន់នៅក្នុងចំណេះដឹងរបស់សិស្ស ។ ជាងនេះទៅទៀត ជាការលើកទឹកចិត្តមួយក្នុងការកត់សម្គាល់ថា មានកិច្ចសហប្រតិបត្តិការល្អជាមួយរដ្ឋាភិបាលដើម្បីធានាឲ្យបានថា លោកគ្រូអ្នកគ្រូនៅទូទាំងប្រទេសនឹងទទួលបានសៀវភៅសិក្សាថ្មីនេះ ។ ការបោះពុម្ពផ្សាយសៀវភៅនេះគឺស្ថិតក្នុងពេលវេលាដ៏សមស្របមួយ ព្រោះថាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមមួយចំនួននឹងទាញការចាប់អារម្មណ៍របស់សាធារណជនមកលើព្រឹត្តិការណ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

## អ្នកនិពន្ធនិងដំណើរការនៃការសរសេរ

សមិទ្ធផលដ៏គួរឲ្យកត់សម្គាល់មួយនៃគម្រោងនេះគឺប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យជាសៀវភៅប្រវត្តិសាស្ត្រដំបូងមួយ ដែលសរសេរឡើងដោយជនជាតិខ្មែរម្នាក់ ។ វាមានសារសំខាន់ណាស់ ដែលសិស្សានុសិស្សនៅកម្ពុជាយ៉ាងហោចណាស់សិក្សាផ្នែកខ្លះនៃប្រវត្តិសាស្ត្ររបស់ខ្លួន តាមរយៈប្រភពធនធានដែលផលិតឡើងដោយជនរួមជាតិរបស់ខ្លួន ។ វាជាកាតព្វកិច្ចរបស់ជនជាតិខ្មែរដែលត្រូវធ្វើជាម្ចាស់ លើសៀវភៅប្រវត្តិសាស្ត្រនិងស្វែងរកអនាគតសម្រាប់ខ្លួនឯង ក្នុងនាមជាប្រជាជននៃប្រជាជាតិឯករាជ្យមួយ ។ ឌី ខាំបូលី ទោះបីជាមិនបានសិក្សាផ្នែកប្រវត្តិសាស្ត្របុផ្នែកអប់រំក៏ដោយ ក៏លោកធ្លាប់ទទួលការហ្វឹកហាត់ និងបទពិសោធន៍ជាច្រើនក្នុងរយៈពេលនៃការបំពេញកម្មសិក្សានៅសារមន្ទីរប្រល័យពូជសាសន៍និងវិទ្យុផ្សាយសំឡេងជាភាសាខ្មែររបស់សហរដ្ឋអាមេរិក ។ នៅទីនោះ លោកបានសិក្សាអំពីការបង្កើតកម្មវិធីសិក្សានិងការរៀបចំសម្ភារសម្រាប់ការអប់រំ ។

ដំណើរការនៃការស្រាវជ្រាវសៀវភៅនេះទាក់ទងនឹងការអានសៀវភៅដែលបានបោះពុម្ពផ្សាយជាភាសាអង់គ្លេសជាច្រើនដែលរួមបញ្ចូលទាំងសៀវភៅអំពីជនជាតិភាគតិចផងដែរ ។ ជាងនេះទៅទៀត អ្នកនិពន្ធបានធ្វើការសិក្សាទៅលើឯកសារជាច្រើនក្នុងបណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ដូច្នេះសៀវភៅនេះមិនមែនគ្រាន់តែជាការប្រមូលបញ្ចូលគ្នាជាមួយសៀវភៅដែលបានបោះពុម្ពរួចហើយនោះទេ ប៉ុន្តែក៏បានផ្តល់ឲ្យសិស្សមានលទ្ធភាពសិក្សាពីប្រភពឯកសារដើមផងដែរ ។ អត្ថបទសិក្សានេះរួមមានទាំងលេខយោងនិងគន្ថនិទ្ទេសដែលអាចឲ្យសិស្សនិងគ្រូបង្រៀនស្វែងរកព័ត៌មានសម្រាប់អានបន្ថែម ។ ជាងនេះទៅទៀត អ្នកអានអាចស្វែងយល់បានខ្លះអំពីរបៀបដែលយើងអាចដឹងពីព្រឹត្តិការណ៍ក្នុងរយៈកាលនោះ ។ ឧទាហរណ៍លេខយោងមួយបានបង្ហាញពីការប៉ាន់ស្មានផ្សេងៗគ្នានូវចំនួនតួលេខមនុស្សស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនិងបានបង្ហាញថាតើ តួលេខទាំងនេះត្រូវបានគណនាឡើងដោយរបៀបណា ។ ការបង្ហាញពីការប៉ាន់ស្មានចំនួនតួលេខខុសៗគ្នានេះ គឺជាឧទាហរណ៍ដ៏ល្អមួយក្នុងការសិក្សាស្រាវជ្រាវសម្រាប់សិស្ស ហើយថែមទាំងបើកឱកាសឲ្យមានការពិភាក្សានៅក្នុងថ្នាក់រៀន ថាតើតួលេខរបៀបនេះត្រូវបានធ្វើឡើងដោយរបៀបណា ។ ការសិក្សាអំពីដំណើរ



កងចល័តកុមារ

ការនៃការបង្រៀនសៀវភៅប្រវត្តិសាស្ត្រនឹងជួយជំរុញឲ្យមានការគិតឲ្យបានហ្មត់ចត់ និងសមត្ថភាពក្នុងការបែងចែករវាង«ការពិត» និង«ការឃោសនា» ។ ប្រការនេះមានសារសំខាន់ខ្លាំងណាស់ ប្រសិនបើយើងត្រូវធ្វើការទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគត ។

សេចក្តីព្រាងសៀវភៅនេះត្រូវបានពិនិត្យពិច័យយ៉ាងហ្មត់ចត់ពីអ្នកជំនាញខាងប្រវត្តិសាស្ត្រ ។ គួរកត់សម្គាល់ផងដែរថា ប្រវត្តិវិទូខាងប្រវត្តិសាស្ត្រកម្ពុជាសម័យទំនើបដ៏ល្បីល្បាញជាអន្តរជាតិ ដេវីដ ឆេនដ៏ល័រ បានជួយអ្នកនិពន្ធក្នុងការកែលម្អអត្ថបទប្រវត្តិសាស្ត្រនេះឲ្យកាន់តែប្រសើរឡើង ។ ការណ៍នេះធានាឲ្យបាននូវកម្រិតខ្ពស់បំផុតនៃការពិតឥតលម្អៀង ។ រាជរដ្ឋាភិបាលកម្ពុជាក៏បានជួយផ្តល់យោបល់អំពីការប្រើប្រាស់ពាក្យពេចន៍មួយចំនួននៅក្នុងអត្ថបទ ។ ការកែប្រែទាំងនេះមិនមែនជាសម្បទាននៃឯករាជភាពនៃការស្រាវស្រាវជ្រាវនោះទេ ។ ទោះជាយ៉ាងនេះក្តី បើតាមខ្ញុំដឹងវាជាការគួរឲ្យសោកស្តាយមួយដែលរហូតមកដល់ពេលនេះ មិនមានគ្រូបង្រៀនណាម្នាក់ចូលរួមនៅក្នុងដំណើរការនេះនៅឡើយ ។ លោកគ្រូអ្នកគ្រូទាំងអស់ គឺសមាសភាពដ៏សំខាន់បំផុតក្នុងការផ្តល់យោបល់ថាតើអត្ថបទនេះត្រូវរៀបចំឡើងដោយរបៀបណាដើម្បីឲ្យស្របទៅនឹងគោលការណ៍គរុកោសល្យ ហើយថែមទាំងអាចផ្តល់នូវដំបូន្មានអំពីជម្រៅនៃអត្ថបទ និងភាសាដែលសមស្របសម្រាប់សិស្សថ្នាក់ទី១២ ។ ក្នុងនាមជាគ្រូបង្រៀនប្រវត្តិវិទ្យាម្នាក់នៅសាលាអន្តរជាតិនៅអាស៊ី-អាគ្នេយ៍ ដែលធ្លាប់មានបទពិសោធន៍ក្នុងការអប់រំផ្នែកប្រវត្តិសាស្ត្រនៅប្រទេសអូស្ត្រាលីនិងសហរដ្ឋអាមេរិក ទស្សនៈរបស់ខ្ញុំនៅក្នុងការពិនិត្យមើលនេះគឺធ្វើឡើងដោយខ្ញុំមិនបានដឹងអំពីកម្មវិធីសិក្សាថ្នាក់ជាតិនិងការអនុវត្តគរុកោសល្យនៅកម្ពុជានោះទេ ។

## ទម្រង់និងរបៀបនៃការសរសេរ

ទម្រង់ដ៏សំខាន់នៃសៀវភៅនេះគឺការសរសេរដែលមានលក្ខណៈជាកាលប្បវត្តិ ដោយសៀវភៅនេះបានលើកឡើងអំពីការឡើងកាន់អំណាច ការបង្កើតរបបគ្រប់គ្រងនិងការដួលរលំនៃរបបកុម្មុយនីស្ត ។ ជាមួយនឹងការសរសេរបែបរឿងនិទាន សៀវភៅនេះក៏បានរៀបរាប់ពីចំណុចផ្សេងៗគ្នានៃរបៀបគ្រប់គ្រងរដ្ឋរបស់ខ្មែរក្រហមដូចជា រដ្ឋបាល គោលនយោបាយសេដ្ឋកិច្ច ជីវិតរស់នៅប្រចាំថ្ងៃ សន្តិសុខ គុកទួលស្លែង និងទំនាក់ទំនងការបរទេស ។ ការរៀបចំគម្រោងសរសេរបែបនេះគឺមានលក្ខណៈសមស្របនិងមានប្រសិទ្ធភាព ព្រោះថាវាបានផ្តល់ឲ្យនូវភាពតក្ជាប់គ្នាពីចំណុចមួយទៅចំណុចមួយទៀត និងមានការពន្យល់ច្បាស់លាស់ ។ ជាងនេះទៅទៀត សៀវភៅនេះត្រូវបានសរសេរឡើងដោយបំបែកសាច់រឿងទាំងមូលទៅជាផ្នែកមួយចំនួនដែលមានអត្ថន័យនិងមានទំនាក់ទំនងគ្នាទៅវិញទៅមក ។ ជាការពិតណាស់សៀវភៅនេះបានផ្តល់ឲ្យនូវហេតុការណ៍តាមលំដាប់លំដោយដែលគ្រូបង្រៀនមានការងាយស្រួលក្នុងការតាមដាន ។

ជាទូទៅ សៀវភៅនេះគឺជាសៀវភៅប្រវត្តិសាស្ត្រនយោបាយនៃរបបមួយ ទោះបីជាផ្នែកដែលនិយាយអំពីជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបនោះអាចចាត់ទុកថាជាប្រវត្តិវិទ្យាសង្គមក៏ដោយ ។ អត្ថបទនេះភាគច្រើនមានទម្រង់ជាការនិទាន និងការរៀបរាប់ ហើយក៏បានពន្យល់សង្ខេបពីព្រឹត្តិការណ៍មួយចំនួនផងដែរ ។ រាល់ការវិភាគនិងការពិភាក្សាអំពីប្រធានបទដែលនាំទៅដល់ជម្លោះត្រូវបានចៀសវាង ។ ទោះបីជាប្រហែលជាមានការតវ៉ាថា ការពណ៌នាអំពីសាច់រឿងពិតគឺជាវិធីដ៏ល្អបំផុត សម្រាប់គោលបំណងនៃភាពមិនលម្អៀង ក៏ខ្ញុំនៅតែកត់សម្គាល់ឃើញថា ភាពលម្អៀងអាចនៅជាប់ជាមួយនឹងហេតុការណ៍ពិតមួយចំនួន ក៏ដូចជាការបកស្រាយនិងភាសាផងដែរ ។ វាជារឿងដែលចៀសមិនរួច ។ ខ្ញុំមិនមែនចោទប្រកាន់អំពីភាពលម្អៀងនៅក្នុងអត្ថបទនេះទេ ប៉ុន្តែខ្ញុំគ្រាន់តែចង់បង្ហាញអំពីប្រធានបទមួយធំជាងនេះ ទាក់ទងនឹងសារធាតុនៃការពិតជាប្រវត្តិសាស្ត្រ ក៏ដូចជាទស្សនវិជ្ជានិងគរុកោសល្យនៃការអប់រំ ។ ឧទាហរណ៍ មូលហេតុនៃការឡើងកាន់អំណាចរបស់ខ្មែរក្រហមមានលក្ខណៈស្មុគស្មាញ ដែលមានការពាក់ព័ន្ធគ្នាទៅវិញទៅមករវាងកត្តាសេដ្ឋកិច្ច សង្គម នយោបាយ មនោគមវិជ្ជា និងការទូត ។ វិធីសាស្ត្រផ្សេងៗក្នុងការសរសេរប្រវត្តិសាស្ត្រនេះបានធ្វើឲ្យកត្តាមួយ ឬការរួមបញ្ចូលគ្នាដ៏ជាក់លាក់មួយក្នុងចំណោមកត្តាទាំងនេះកាន់តែមានសារសំខាន់ថែមទៀត ។ វាប្រហែលជាងាយស្រួលក្នុងការកំណត់ការពិតនៃហេតុការណ៍

ដែលបានកើតឡើងដាច់ដោយឡែកមួយ ។ ក៏ប៉ុន្តែ វាមិនមែនជាការងាយស្រួលទេ ហើយក៏មិនមានវិធីសាស្ត្រដែលទទួលបានការយល់ស្របជាសាកលក្នុងការកំណត់អំពីថាតើហេតុអ្វីបានជាគ្រោះមហន្តរាយដូចជាអំពើប្រល័យពូជសាសន៍នៅកម្ពុជាអាចកើតមានឡើង ។ ទោះបីសិស្សថ្នាក់មធ្យមសិក្សាត្រូវការអត្ថបទមួយសាមញ្ញងាយស្រួលយល់ក៏ដោយ ខ្ញុំមិនគិតថា វានឹងអាចជួយឲ្យសិស្សស្វែងយល់បានច្បាស់លាស់អំពីរឿងរ៉ាវប្រកបដោយភាពចម្រូងចម្រាស់នេះទេ ។

នៅក្នុងមុខវិជ្ជាប្រវត្តិសាស្ត្រដែលខ្ញុំបានដឹងច្រើន សិស្សត្រូវបានជំរុញឲ្យធ្វើការពន្យល់អំពីការវិវឌ្ឍន៍នៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ។ ជាងនេះទៅទៀតសិស្សត្រូវបានជំរុញឲ្យធ្វើការពណ៌នានិងវិភាគយ៉ាងហ្មត់ចត់អំពីការបកស្រាយប្រវត្តិសាស្ត្រផ្សេងៗគ្នា ។ ដូច្នេះ សៀវភៅសិក្សាអំពីប្រវត្តិសាស្ត្របែបនេះជាទូទៅផ្តល់នូវគម្រោងនិងការពិភាក្សាអំពីប្រធានបទទាក់ទងនឹងប្រវត្តិសាស្ត្រ ក៏ដូចជាការពណ៌នាអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ។ ទាំងនេះនឹងផ្តល់ឲ្យសិស្សនូវការបកស្រាយផ្សេងៗគ្នាជាច្រើន ដើម្បីសិក្សាបន្ថែមនិងអនុញ្ញាតឲ្យសិស្សធ្វើការវិនិច្ឆ័យដោយខ្លួនឯង ។ ខ្ញុំគិតថា គ្រូបង្រៀនដែលពេញចិត្តវិធីសាស្ត្របែបនេះនៅតែអាចប្រើប្រាស់សៀវភៅ *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិប-តេយ្យ* ប្រកបដោយប្រសិទ្ធភាព (វិធីសាស្ត្រមួយចំនួននឹងត្រូវបានផ្តល់ជូននៅក្នុងការពិភាក្សាអំពីមាតិកាខាងក្រោម) ។

ទោះជាយ៉ាងនេះក្តី គ្រូបង្រៀននៅតែត្រូវការប្រភពបន្ថែមទៀត ។ នេះគឺជាការអនុវត្តតាមកម្រិតស្តង់ដារមួយ នៅតាមសាលារៀននៅក្នុងប្រទេសជាច្រើន ។ ប៉ុន្តែ ដោយសារធនធាននិងពេលវេលានៅមានកម្រិតនោះ ការបង្កើតសៀវភៅណែនាំនឹងជួយដល់ការបង្រៀនបានច្រើន ។ ប្រហែលជាសៀវភៅសម្រាប់គ្រូបង្រៀននឹងត្រូវបានបោះពុម្ពនាពេលអនាគត ។

## មាតិកា

ផ្នែកនេះនឹងពិនិត្យមើលទៅលើមាតិការបស់សៀវភៅនៅក្នុងផ្នែកតូចៗចំនួនបី ៖ ការឡើងកាន់អំណាចរបស់ខ្មែរក្រហម (ជំពូកទី២និង៣), ការបង្កើតនិងការគ្រប់គ្រងនៃរបបនេះ(ជំពូក ៤-១០) និងការដួលរលំនៃកម្ពុជាប្រជាធិបតេយ្យ(ជំពូក១១) ។

## ការឡើងកាន់អំណាចរបស់ខ្មែរក្រហម

ជំពូកទី២បង្ហាញពីសំណួរដែលថា "តើខ្មែរក្រហមជាអ្នកណា? តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា?" ខ្មែរក្រហមត្រូវបានកំណត់យ៉ាងច្បាស់ថាជា "ចលនាកុម្មុយនីស្តនៅកម្ពុជា" ដែលគោលបំណងរបស់ក្រុមនេះគឺធ្វើការតស៊ូប្រឆាំងនឹងការគ្រប់គ្រងរបស់បារាំងនៅក្នុងទសវត្សរ៍ឆ្នាំ១៩៤០ ។ យើងបានដឹងថា អ្នកគាំទ្រក្រុមនេះគឺជា"កសិករ" និង"ក្រុមនិស្សិតជាតិនិយម" ។ ជាងនេះទៅទៀត មានការពណ៌នាអំពីប្រវត្តិខាងដើមនៃចលនានេះ ដែលបានរៀបរាប់យ៉ាងលម្អិត និងដោយប្រយ័ត្នប្រយែងអំពីទំនាក់ទំនងជាមួយចលនាកុម្មុយនីស្តនៅវៀតណាមនិងព្រឹត្តិការណ៍នៅក្នុងប្រទេស ។ មេដឹកនាំកុម្មុយនីស្តនៅកម្ពុជាត្រូវបានសម្គាល់តាមរយៈឈ្មោះនិងការរៀបរាប់អំពីតួនាទី ។ សៀវភៅនេះ ក៏បានបង្ហាញអំពីមូលហេតុនៃជោគជ័យរបស់ខ្មែរក្រហមនៅក្នុងសង្គ្រាមស៊ីវិលផងដែរ ។

ជំពូកនេះបានបង្ហាញអំពីសំណួរ "អ្នកណា" "អ្វីខ្លះ" "ពេលណា" "នៅកន្លែងណា" និង "ដោយរបៀបណា" ។ ប៉ុន្តែ សំណួរដែលសំខាន់និងគួរឲ្យចាប់អារម្មណ៍ជាងនេះ គឺ "ហេតុអ្វី" សំណួរនេះមិនត្រូវបានបកស្រាយឲ្យបានគ្រប់គ្រាន់ទេ ។ មានការបញ្ជាក់បង្ហាញច្រើនពេកទៅលើបុគ្គលនិងស្ថាប័នបក្សកុម្មុយនីស្តកម្ពុជា (ទោះជាយ៉ាងនេះក្តី តួនាទីរបស់អ្នកទាំងនេះមានសារសំខាន់) ។ ការពណ៌នាអំពីរចនាសម្ព័ន្ធសង្គមគឺជារឿងចាំបាច់ ដែលរួមមានជាតិពន្ធុ សាសនា ក៏ដូចជាការបែងចែកឋានៈ ។ យ៉ាងហោចក៏មានពីរ-បីប្រយោគដែលរៀបរាប់អំពីរយៈកាលនៃការត្រួតត្រារបស់បារាំង ។ ការរៀបរាប់អំពីការផ្លាស់ប្តូរសេដ្ឋកិច្ចក៏មានសារសំខាន់ដែរ ។ ដូច្នេះ សិស្សអាចស្វែងយល់អំពីទុក្ខវេទនារបស់កសិករនិងសិស្ស និងអំពីមូលហេតុដែលអ្នកទាំងនេះមើលឃើញពីគុណសម្បត្តិនៃមនោគមវិជ្ជារបស់បក្សកុម្មុយនីស្ត ។

វាមានសារសំខាន់ខ្លាំងណាស់ក្នុងការដាក់ព្រឹត្តិការណ៍ដែលកើតមានឡើងនៅកម្ពុជាភ្ជាប់ទៅនឹងផ្នែកនៃសង្គ្រាមដែលកើតក្រោយសម័យអាណានិគម និងភ្ជាប់ព្រឹត្តិការណ៍នេះនឹងព្រឹត្តិ-ការណ៍ជាក់ស្តែងក្នុងសង្គ្រាមត្រជាក់ ។ ប្រសិនបើសិស្សអាចស្វែងរកពីចំណុចដូចគ្នា និងចំណុចមួយចំនួនរវាងព្រឹត្តិការណ៍

នៅកម្ពុជានិងនៅប្រទេសផ្សេងៗទៀត ដែលការគ្រប់គ្រងរបស់របបអាណានិគមត្រូវបានបញ្ចប់ទៅបន្ទាប់ពីសង្គ្រាមលោកលើកទីពីរ(ដូចជាកូរ៉េ) នោះ សិស្សនឹងអាចស្វែងយល់បានកាន់តែច្រើនអំពីប្រវត្តិសាស្ត្រប្រទេសរបស់ខ្លួន ។ ព្រឹត្តិការណ៍នៃសង្គ្រាមត្រជាក់នឹងជួយពន្យល់អំពីផលប៉ះពាល់ពីខាងក្រៅមកលើហេតុ-ការណ៍នៅកម្ពុជា ។ ឧទាហរណ៍ សិស្សអាចសិក្សាស្វែងយល់ថាតើហេតុអ្វីបានជាសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែកមកលើកម្ពុជានៅឆ្នាំ១៩៧៣ (រៀបរាប់នៅទំព័រ១២) ។ ខ្ញុំមិនមែនផ្តល់យោ-បល់ថា អ្នកនិពន្ធគួរតែដាក់បញ្ចូលការប្រៀបធៀបព្រឹត្តិការណ៍ទាំងស្រុងនោះទេ ។ ខ្ញុំគ្រាន់តែឲ្យយោបល់ថា គួរតែដាក់បញ្ចូលចំណុចមួយចំនួនដែលអាចជួយឲ្យសិស្សតភ្ជាប់ការយល់ដឹងរបស់



គម្រោងលើកទំនប់
(ថតពេលដែលកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមធ្វើដំណើរទស្សនកិច្ចទៅកាន់តំបន់នេះ)

ខ្លួនទៅប្រធានបទពាក់ព័ន្ធផ្សេងៗទៀត ហើយដែលប្រធានបទនោះអាចត្រូវបានដាក់ឲ្យសិក្សាជាផ្នែកមួយនៃមុខវិជ្ជាប្រវត្តិ-សាស្ត្រ ។ ដូចដែលសៀវភៅនេះបានបង្ហាញទំនាក់ទំនងជាមួយវៀតណាមត្រូវបានសង្កត់ធ្ងន់(មានការនិយាយយោងអំពីវៀត-ណាមតែ៩ទំព័រប៉ុណ្ណោះ) ។ ចំណុចនេះប្រហែលជាការពិភាក្សាទៅលើប្រធានបទផ្សេងៗទៀត ។ ខ្ញុំគិតថា ការណ៍នេះបានឆ្លុះបញ្ចាំងពីការសង្កត់ធ្ងន់ទៅលើប្រវត្តិស្ថាប័ននៃបក្សកុម្មុយនីស្តកម្ពុជា ជាជាងបង្ហាញពីព្រឹត្តិការណ៍ដែលមានលក្ខណៈលម្អៀង ។ ទោះជាយ៉ាងនេះក្តី ខ្ញុំមានការបារម្ភថាតើសិស្សនឹងអានផ្នែកនេះដោយរបៀបណា ។

ជំពូកទី៣និយាយអំពីការដណ្តើមអំណាចរបស់ខ្មែរក្រហមបន្ទាប់ពីជ័យជម្នះក្នុងសង្គ្រាមត្រជាក់ ។ ការពិពណ៌នាអំពីការរំដោះទីក្រុងភ្នំពេញកាន់តែមានទម្ងន់ខ្លាំងថែមទៀត តាមរយៈការដកស្រង់យករឿងរ៉ាវផ្ទាល់ខ្លួនរបស់ប្រជាជនសាមញ្ញ ដែលរួមមានទាំងអ្នកធាក់ស៊ីក្លូដែលបានរៀបរាប់ពីអ្វីដែលគាត់បានឃើញក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុង ។ ខ្ញុំនឹងធ្វើការពិភាក្សាអំពីតម្លៃនៃប្រភព ទាំងនេះនៅក្នុងផ្នែកខាងក្រោម ដែលនិយាយអំពីរបបគ្រប់គ្រងរបស់កម្ពុជាប្រជាធិប-តេយ្យ ។ ខ្ញុំមានការភ្ញាក់ផ្អើលអំពីការប្រើប្រាស់ពាក្យ “រំដោះ” ដោយមិនដាក់វានៅក្នុងវង់ក្រចក ។ ខ្ញុំគិតថាការប្រើពាក្យនេះគឺតំណាងឲ្យទស្សនៈរបស់ខ្មែរក្រហមនៅពេលនោះ ។ វាប្រហែលជាគួរឲ្យចាប់អារម្មណ៍ក្នុងការពិភាក្សាអំពីបញ្ហានេះនៅក្នុងថ្នាក់រៀន ។ ជំពូកនេះក៏រួមមានទាំងការរៀបរាប់ដោយសង្ខេបអំពីគោលបំណងរបស់របបថ្មីនេះ ។ ប៉ុន្តែ រឿងនេះមិនត្រូវបានវិភាគ ហើយក៏មិនត្រូវបានដាក់បញ្ចូលទៅក្នុងប្រធានបទអ្វីមួយដែរ ។ ព្រឹត្តិការណ៍ដ៏សំខាន់ដូចជាការជម្លៀសជាដើម ចាំបាច់ត្រូវការឲ្យមានការពន្យល់ឲ្យបានពេញលេញបន្ថែមទៀត ។

## ការបង្កើតនិងរបបគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ

ជំពូកកណ្តាលនៃប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យបង្ហាញអំពីការពណ៌នាយ៉ាងទូលំទូលាយអំពីប្រទេសកម្ពុជានៅក្រោមការគ្រប់គ្រងរបស់“អង្គការ”ដ៏សម្ងាត់ ។ យើងបានដឹងថាអង្គការ“ត្រូវបានបង្កើតឡើងដោយបុរសស្ត្រីដែលជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា” (ទំព័រ១៨) ។ យើងបានដឹងអំពីរបៀបគ្រប់គ្រងប្រទេស ។ ចំណុចមួយនិយាយអំពីគោលការណ៍ដ៏សំខាន់ក្នុងការធ្វើសមូហភាវូបនីយកម្មកសិកម្ម និងជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនទាំងពីរថ្នាក់ (ប្រជាជនមូលដ្ឋាននិងប្រជាជនថ្មី) នៅក្នុងរបបនេះក៏ត្រូវបានរៀបរាប់ផងដែរ ។ មានការពិភាក្សាមួយចំនួនអំពីការបះបោរ ជាពិសេសការបះបោររបស់ជនជាតិ

ចាម ។ ជាងនេះទៅទៀត ការបង្ក្រាបនិងការសម្លាប់រង្គាលត្រូវបានលើកឡើងយ៉ាងច្បាស់តាមរយៈជំពូកពីរដែលរួមមានការរៀបរាប់អំពីគុកទួលស្លែងនៅទីក្រុងភ្នំពេញ ដែលឥឡូវនេះគឺជាសារមន្ទីរដ៏សំខាន់មួយដែលសិស្សរស់នៅក្នុងឬតំបន់ក្បែរទីក្រុងអាចចូលមកទស្សនា ដែលជាផ្នែកមួយនៃការសិក្សាអំពីរយៈកាលនោះ ។ ដូចដែលបានពន្យល់អំពីការរៀបចំសង្គមទាំងមូលឡើងវិញដោយរបបនេះយើងដឹងថា ខ្មែរក្រហមមានបំណងធ្វើទំនើបកម្មវិស័យកសិកម្ម និងធ្វើឲ្យកម្ពុជាមានឯករាជ្យភាពទាំងវិស័យសេដ្ឋកិច្ចនិងវិស័យនយោបាយ ។ វានឹងមានប្រយោជន៍ច្រើន ប្រសិនបើយើងរៀបរាប់ចំណុចនេះដោយសង្ខេប ហើយធ្វើការប្រៀបធៀបជាមួយ ស្តាលីន នៃប្រទេសរុស្ស៊ី និង ម៉ៅ នៃប្រទេសចិន ធ្វើបែបនេះ សិស្សប្រហែលជានឹងអាចធ្វើការសិក្សាស្វែងយល់អំពី “សមូហភាវូបនីយកម្ម” នៅក្នុងបរិបទទូលំទូលាយជាងនេះ ហើយថែមទាំងអាចស្វែងយល់ប្រសើរជាងមុនអំពីលក្ខណៈដោយឡែកនៃបទពិសោធន៍របស់ប្រជាជនកម្ពុជាដែលក្រុមគ្រួសារត្រូវបានបំបែកចេញពីគ្នា ។



ការវិលត្រឡប់របស់អ្នករស់រានមានជីវិតបន្ទាប់ពីការដួលរលំរបស់ខ្មែរក្រហម ខែមករា ឆ្នាំ១៩៧៩

ជំពូកអំពីជីវិតរស់នៅប្រចាំថ្ងៃ ប្រព័ន្ធសន្តិសុខនិងគុកទួល-ស្លែង គឺជាជំពូកដ៏គួរឲ្យចាប់អារម្មណ៍ ។ ការដកស្រង់រឿងរ៉ាវផ្ទាល់ខ្លួនរបស់អ្នកនៅរស់រានមានជីវិតនឹងជួយឲ្យអ្នកអានស្វែងយល់អំពីជីវិតរស់នៅនាពេលនោះតាមរយៈបទពិសោធន៍របស់ប្រជាជនកម្ពុជាសាមញ្ញ ដោយសារថាបុរសស្ត្រីទាំងនេះមកពីតំបន់ផ្សេងគ្នាមានដើមកំណើតជាតិសាសន៍ផ្សេងគ្នា ។ នេះគឺជាលក្ខណៈពិសេសនៃសៀវភៅនេះ ។ សៀវភៅនេះមិនត្រឹមតែទាក់ទាញអារម្មណ៍សិស្សប៉ុណ្ណោះទេ ជាថ្មីម្តងទៀត សៀវភៅនេះថែមទាំងធ្វើឲ្យអ្នកអានអាចស្វែងយល់ថា“តើយើងសិក្សាពីអតីតកាលដោយរបៀបណា” ។ ការដកស្រង់ពាក្យសម្តីរបស់អ្នកនៅរស់រានមានជីវិត គឺបានបង្ហាញពីការពិតនៃជីវិតរបស់អ្នកទាំងនោះ ហើយជាងនេះ ទៅទៀត អ្នកនិពន្ធបានផ្តល់ឱកាសឲ្យអ្នកដទៃបានបញ្ចេញសំឡេងតាមរយៈសៀវភៅនេះផង ។ សៀវភៅនេះថែមទាំងបានផ្តល់មធ្យោបាយសម្រាប់បង្ហាញអំពីប្រធានបទប្រវត្តិសាស្ត្រដ៏មានសារសំខាន់និងបង្កើតឲ្យមានជំនាញក្នុងការគិតឲ្យបានជ្រៅជ្រះ ។ គ្រូបង្រៀនអាចពិភាក្សាជាមួយសិស្សអំពីតម្លៃ និងទំហំនៃការដកស្រង់សម្រាប់ជាប្រភពមេរៀនប្រវត្តិ-សាស្ត្រ ។ សិស្សអាចពិនិត្យមើលទៅលើការដកស្រង់រឿងរ៉ាវផ្ទាល់ខ្លួនទាំងនេះ ហើយពិចារណាថាតើរឿងរ៉ាវអំពីសង្គមកម្ពុជានាពេលនោះ បានបង្ហាញត្រឹមត្រូវដែរឬទេ? ប្រធានបទអំពីការចងចាំ ការបំភ្លេីស ការដកព័ត៌មានចេញ ការកែងបន្លំ និងភាពលម្អៀង អាចត្រូវបានបង្ហាញតាមរយៈការស្វែងរកប្រភពនិងគោលបំណងនៃប្រធានបទទាំងនេះ ។ សិស្សអាចត្រូវបានរំពឹកឲ្យធ្វើការសាកសួរក្រុមគ្រួសារដែលធ្លាប់រស់នៅឆ្លងកាត់រយៈកាលនោះ ។ គម្រោង “ប្រវត្តិសាស្ត្រផ្ទាល់មាត់”តូចមួយអាចត្រូវបានបង្កើតឡើង ។ ដូចគ្នានេះដែរ ពាក្យស្លោកខ្មែរក្រហមដែលជាលក្ខណៈពិសេសដ៏គួរឲ្យចាប់អារម្មណ៍មួយទៀតនៃជំពូកទាំងនេះអាចត្រូវបានយកមកវិភាគ ។ ផ្នែកនេះមានលក្ខណៈគរុកោសល្យច្រើនដែលអនុ-ញ្ញាតឲ្យសិស្សក្លាយជាអ្នកចង់ដឹងចង់ឮយ៉ាងសកម្មជាជាងអ្នកអានសាមញ្ញម្នាក់ ។

ជំពូកអំពីទំនាក់ទំនងការបរទេស បានធ្វើឲ្យមានការចាប់អារម្មណ៍ទៅលើប្រទេសចិននិងវៀតណាម ដែលជាប្រទេសមាន

ឥទ្ធិពលខ្លាំងជាងគេមកលើកម្ពុជានាពេលនោះ ។ សៀវភៅនេះបានរៀបរាប់លម្អិតអំពីជំនួយរបស់ចិនមកឲ្យរបបនេះ ប៉ុន្តែមិនមានការពន្យល់អំពីគោលបំណងរបស់ចិនទេ ។ នៅត្រង់ចំណុចនេះ គោលបំណងចម្បងគឺចង់បង្ហាញអំពីទំនាក់ទំនងនៃជម្លោះរវាងចិននិងសូវៀត ។

## ការដួលរលំរបស់កម្ពុជាប្រជាធិបតេយ្យ

ជំពូកទី១១បង្ហាញពីមូលហេតុបីយ៉ាង ដែលនាំដល់ការដួលរលំនៃរបបនេះ ពោលគឺ សុខភាពទ្រុឌទ្រោមរបស់ប្រជាជន វិសុទ្ធកម្ម និងជម្លោះជាមួយវៀតណាម ។ មូលហេតុចម្បង (ប្រសិនបើខ្ញុំគិតមិនខុសទេ) គឺជាការឈ្លានពានរបស់វៀត-ណាម ។

ជំពូកចុងក្រោយនៃសៀវភៅនេះសង្ខេបពីព្រឹត្តិការណ៍សំខាន់ៗនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការសង្កត់ធ្ងន់នៅក្នុងជំពូកនេះគឺសោកនាដកម្មនៃមនុស្សជាតិដែលកើតមានឡើងក្នុងអំឡុងពេលពីឆ្នាំ១៩៧៥ - ១៩៧៩ ។ មានការបង្ហាញដ៏សំខាន់ថា មនោគមវិជ្ជារបស់ខ្មែរក្រហមចេញមកអំពីចលនាកុម្មុយនីស្តនៅប្រទេសចិន អតីតសហភាពសូវៀតនិងវៀតណាម ។ ខ្ញុំគិតថាគួរតែមានការពិភាក្សាមួយចំនួនអំពីលក្ខណៈពិសេសនៃសង្គមកម្ពុជា ។ ទោះជាយ៉ាងនេះក្តី វាមានសារសំខាន់ណាស់ក្នុងបញ្ជាក់អំពីការចម្លងតាមគំរូកុម្មុយនីស្ត ដូចដែលបានបញ្ជាក់ទាំងស្រុងទៅលើព្រឹត្តិការណ៍នៅកម្ពុជា ដែល«អំពើប្រល័យពូជសាសន៍» បង្ហាញអំពីការប្រៀបធៀបប្រវត្តិសាស្ត្រផ្សេងៗគ្នា ដែលមិនមានសុពលភាពច្បាស់លាស់ ។

## រូបថតនិងរូបភាព

អត្ថបទនេះមានបញ្ចូលរូបភាពជាច្រើន ជាពិសេសរូបថតពីរបបខ្មែរក្រហម ។ រូបថតទាំងនេះជារូបថតមេដឹកនាំខ្មែរក្រហម កងទ័ពកម្មាភិបាលជាន់ខ្ពស់ និងគម្រោងសាងសង់ដូចជាការសាងសង់ប្រព័ន្ធទំនប់ប្រឡាយ ។ មានផែនទីដែលបង្ហាញអំពីទីតាំងរណ្តៅសាកសពនិងភូមិភាគនិងតំបន់ក្នុងរបបកម្ពុជាប្រជាធិប-តេយ្យ ។ ទង់ជាតិនិងសញ្ញាជាតិរបស់កម្ពុជាប្រជាធិបតេយ្យក៏ត្រូវបានដាក់បង្ហាញ ហើយមានរូបភាពឯកសារមួយដែលត្រូវបានរក្សាទុកនៅក្នុងបណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ រូបភាពទាំងនេះមិនត្រឹមតែធ្វើឲ្យអត្ថបទកាន់តែគួរឲ្យចាប់អារម្មណ៍ប៉ុណ្ណោះទេ តែថែមទាំងធ្វើឲ្យសិស្សចូលចិត្តអានទៀតផង ។ រូបភាពក៏បានជួយបង្ហាញអំពីអត្តសញ្ញាណរបស់ខ្មែរក្រហមនិងសារធាតុនៃរបបនេះ ។ រូបថតគឺជាប្រភពធនធានទីមួយដ៏សំខាន់ដែលគ្រូអាចប្រើប្រាស់ជាមធ្យោបាយក្នុងការអនុវត្តលំហាត់វិភាគ ។ ឧទាហរណ៍ សិស្សអាចត្រូវបានប្រាប់ឲ្យប្រើប្រាស់រូបថតដើម្បីឆ្លើយនឹងសំណួរ «តើខ្មែរក្រហមជាអ្នកណា?» ជាងនេះទៅទៀត សិស្សអាចពិភាក្សាអំពីតម្លៃនៃរូបថតទាំងនេះជាភស្តុតាងប្រវត្តិសាស្ត្រ ។

ទោះបីជាមានរូបថតជាច្រើនបង្ហាញអំពីសារមន្ទីរទួលស្លែងក៏មិនមានរូបថតអ្នកទោសដែលជាប់ឃុំឃាំងនៅគុកទួលស្លែងនៅក្នុងសៀវភៅនេះដែរ គេនឹងអាចរកមើលឃើញនៅក្នុងគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ រូបថតទាំងនេះគឺជាប្រភពធនធានដ៏មានសារសំខាន់និងបានឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ការសម្លាប់ប្រជាជនកម្ពុជាជិតពីរលាននាក់ដែលបណ្តាលមកពីសកម្មភាពនិងគោលនយោបាយនៃរដ្ឋាភិបាលកម្ពុជាប្រជា-ធិបតេយ្យ ។ នេះគឺជាគោលដៅចម្បងរបស់សៀវភៅនេះ ។ ខ្ញុំគិតថា អត្ថបទនេះនឹងកាន់តែមានលក្ខណៈប្រសើរថែមទៀតដោយការជ្រើសរើសរូបថតជាតំណាងដែលប្រហែលជាបង្ហាញអំពីការឈឺចាប់ផ្នែកផ្លូវចិត្ត ។

## សេចក្តីបញ្ចប់

ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥ - ១៩៧៩) គឺជាផលិតផលដ៏មានតម្លៃនៃគម្រោងមួយដែលត្រូវបានធ្វើឡើងប្រកបដោយការយល់ដឹងនិងមានលក្ខណៈវិជ្ជាជីវៈខ្ពស់ ។ សៀវភៅនេះបានបង្ហាញពីការពណ៌នាច្បាស់លាស់ ឥតលម្អៀង និងចំគោលដៅ ហើយថែមទាំងមានបញ្ចូលរឿងរ៉ាវរបស់អ្នកដែលនៅរស់រានមានជីវិត និង(ប្រហែលជា)រូបថតផ្លូវការទៀតផង ដែលធ្វើឲ្យអត្ថបទកាន់តែល្អឡើង ។ ខ្ញុំជឿជាក់ថា សៀវភៅនេះនឹងក្លាយទៅប្រភពធនធានដ៏មានតម្លៃសម្រាប់លោកគ្រូអ្នកគ្រូក៏ដូចជាសិស្សានុសិស្សទូទៅដែរ ។ ទោះបីជាខ្ញុំមានការឆ្ងើងឆ្ងល់មួយចំនួនអំពីវិសាលភាពនៃការរៀបរាប់អំពីការឡើងកាន់អំណាចរបស់ខ្មែរក្រហម និងសកម្មភាពរបស់របបនេះក៏ដោយ

ក៏ការអានបន្តទៅមុខទៀតនឹងប្រាប់យើងឲ្យបានដឹងច្បាស់ ។ ប្រធានបទនៃសៀវភៅនេះក៏គួរឲ្យចាប់អារម្មណ៍ និងមានសារសំខាន់សម្រាប់សិស្សនិងអ្នកអានទូទៅនៅក្រៅប្រទេសកម្ពុជាដែរ ។ សោកនាដកម្មរបស់មនុស្សជាតិដែលកើតមានឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺជារឿងមួយដែលទាំងសហគមន៍អន្តរជាតិក៏ដូចជាមេដឹកនាំខ្មែរក្រហមត្រូវតែទទួលខុសត្រូវ ។ ដូចដែលលោក ភីធ័រ ម៉ាក្វាយអ័រ អះអាងថា អង្គការសហប្រជាជាតិបានបរាជ័យក្នុងការការពារប្រជាជនកម្ពុជា ដោយសារតែការពិចារណាផ្នែកនយោបាយមានទម្ងន់ជាងបញ្ហាសិទ្ធិមនុស្ស ។ ការរួមចំណែករបស់អង្គការសហប្រជាជាតិនិងអង្គការក្រៅរដ្ឋាភិបាលជាច្រើន ក្នុងការស្តារនិងកសាងប្រទេសឡើងវិញបន្ទាប់ពីសង្គ្រាមស៊ីវិលបានបង្ហាញថា អ្នកទាំងនេះទទួលយកការទទួលខុសត្រូវមួយចំនួនហើយ ។ ប្រសិនបើយើងត្រូវចៀសវាងសោកនាដកម្មប្រហាក់ប្រហែលគ្នានេះ សិស្សានុសិស្សនៅទូទាំងពិភពលោកត្រូវតែដឹងអំពីរបបកម្ពុជាប្រជាធិបតេយ្យ (ដែលជារបបមួយក្នុងចំណោមរបបដែលរំលោភបំពានសិទ្ធិមនុស្សដ៏គួរឲ្យរន្ធត់នៅក្នុងសតវត្សរ៍ដ៏ហិង្សានេះ) ។

ជាការពិត បទពិសោធន៍របស់ប្រជាជនកម្ពុជាត្រូវបានបង្ហាញនៅក្នុងការស្រាវជ្រាវប្រវត្តិសាស្ត្រពិភពលោក (ក៏ដូចជាប្រវត្តិសាស្ត្រកម្ពុជា) ជាច្រើននៅក្នុងសតវត្សរ៍ទី២០នេះ ដែលការសិក្សាទាំងនេះត្រូវបានបោះពុម្ពឡើងជាភាសាអង់គ្លេស ។ ឧទាហរណ៍ នៃការសិក្សាស្រាវជ្រាវមួយក្នុងពេលថ្មីៗនេះ គឺការស្រាវជ្រាវរបស់ប្រវត្តិវិទូអង់គ្លេសដ៏ល្បីល្បាញ លោក នីអាល ហ្វឺហ្គូសាន់ ដែលបានសរសេរសៀវភៅ “សង្គ្រាមនៃពិភពលោក ៖ រយៈកាលប្រវត្តិសាស្ត្រនៃការស្អប់ខ្ពើម” ។ លោកព្យាយាមពន្យល់ពីអំពើហិង្សាដ៏ខ្លាំងក្លាបំផុតនៅក្នុងសតវត្សរ៍ចុងក្រោយនេះ ។ ដូច្នេះ ការដាក់បញ្ចូលប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទៅក្នុងកម្មវិធីសិក្សាប្រវត្តិសាស្ត្រថ្នាក់មធ្យមសិក្សានៅកម្ពុជាដូចដែលអង្គការមធ្យមសិក្សាអន្តរជាតិ បានធ្វើមានសារសំខាន់ខ្លាំងណាស់សម្រាប់កម្ពុជា ។ សេចក្តីព្រាងកម្មវិធីសិក្សាថ្មីមួយបានចាត់បញ្ចូល“ប្រទេសកម្ពុជា” ជាប្រធានបទសិក្សានៅក្នុងសតវត្សរ៍ទី២០នេះ ។ មានអត្ថបទល្អៗមួយចំនួនដែលជាភាសាអង់គ្លេសអំពីអាស៊ី-អាគ្នេយ៍ អាចឲ្យសិស្សថ្នាក់វិទ្យាល័យសិក្សាបាន ។ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) គឺជាប្រភពធនធានបន្ថែមដ៏មានតម្លៃសម្រាប់បណ្ណាល័យ និងសាលាជាច្រើនទៀត ជាពិសេសសាលាអន្តរជាតិនៅក្នុងតំបន់ ។ ដោយសៀវភៅជាភាសាអង់គ្លេសត្រូវបានបោះពុម្ពរួចរាល់អស់ហើយ ខ្ញុំគិតថា វាគឺជាឱកាសមួយដ៏ប្រសើរក្នុងការធ្វើការផ្សព្វផ្សាយនាពេលនេះ ។

**ម៉ាក ភ្លេមិន**

## ពាក្យស្លោកខ្មែរក្រហម

- ប្រយុទ្ធ និងចលនាធាហានខ្លាំង ហើយបំផុសមហាជនឱ្យក្រោកឡើងវាយដណ្តើមសិទ្ធិអំណាចធ្វើម្ចាស់ទឹកដី។
- ប្រយុទ្ធដោយឯករាជម្ចាស់ការ រួមផ្សំយ៉ាងជិតស្និទ្ធខាងទ័ពស្រួច តំបន់ និងឈ្លប ហើយពង្រីកងទ័ពទាំង៣ប្រភេទនេះ។

(សៀវភៅកំណត់ហេតុលេខ២០០)

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម បាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
*Email: dccam@online.com.kh*
*Home page: www.dccam.org*

# ប្រវត្តិជីវិតសែនកម្សត់របស់ខ្ញុំ

***(តចប់)***

## មរណភាពកូនស្រីខ្ញុំ

លុះដល់ខែច្រូតកាត់ កូនស្រីខ្ញុំឈឺកាន់តែធ្ងន់ឡើងៗ ។ រូបកាយរបស់នាងកាន់តែស្វិតគ្រៀមដូចជា កូនរុក្ខជាតិដែលចាប់ផ្តើមងាប់ដើម ។ ពេលសម្លឹងមើលកូន ខ្ញុំនឹកឃើញដល់ក្មេងស្រីដ៏ស្អាតម្នាក់ ដែលមានកែវភ្នែកខ្មៅក្រិប ដៃជើងវែងស្រលូត ខ្ពង់ខ្ពស់ ប្រមុះស្រួច ញញឹមដាក់ខ្ញុំ ។ ក៏ប៉ុន្តែការស្រមៃនោះបានរលត់ បាត់ទៅវិញនៅពេលដែលកូនខ្ញុំយកដៃមកកេះខ្ញុំ និងហាមាត់ដូចជាចង់និយាយអ្វីប្រាប់ ។ ខ្ញុំយកទឹកបន្តក់បញ្ចូលមាត់កូន ដោយមិនដឹងថា កូនចង់ប្រាប់ម្តាយថាលាហើយទេ ។ កូនខ្ញុំស្លាប់បីថ្ងៃបន្ទាប់ពីប្អូនប្រុសពៅរបស់ខ្ញុំស្លាប់ដោយជំងឺ និងខ្វះជីវជាតិ ។



លឹម ស្រីដល្លា ឆ្នាំ១៩៧៩

ពេលកូនស្រីខ្ញុំស្លាប់ ខ្ញុំបានកោរសក់ ព្រោះខ្ញុំនៅតែស្រមៃឃើញកូនស្រីនៅនឹងមុខ ហើយមានពេលខ្លះខ្ញុំយល់សប្តិឃើញនាងរត់មកទទួលពេលខ្ញុំត្រឡប់មកពីធ្វើការវិញ ។

ខ្ញុំចាប់ផ្តើមមានអារម្មណ៍ឯកោនិងអស់សង្ឃឹម ។ ខ្ញុំមិននឹកស្មានថាមានហេតុការណ៍នេះកើតឡើងចំពោះខ្ញុំទេ ប្រសិនបើខ្ញុំដឹងមុនថាការធ្វើដំណើរតាមបញ្ជារបស់អង្គការបណ្តាលឲ្យជួបទុក្ខវេទនានិងបែកបាក់គ្រួសារបែបនេះ ខ្ញុំប្រាកដជាមិនចេញពីភ្នំពេញទេ ខ្ញុំសុខចិត្តឲ្យកងទ័ពរំដោះបាញ់សម្លាប់នៅនឹងកន្លែងប្រសើរជាង ។ ស្វាមីនិងឪពុកខ្ញុំតែងតែលួងលោមខ្ញុំខ្លាចក្រែងខ្ញុំឈឺម្នាក់ទៀត ។ ស្វាមីខ្ញុំបានយកអីវ៉ាន់របស់កូនខ្ញុំចែកឲ្យកូនអ្នកស្រុក តែខ្ញុំលាក់ទុកបានខ្លះ រហូតដល់ត្រឡប់មកភ្នំពេញវិញ ។

ប៉ុន្មានថ្ងៃក្រោយមក ប្រធានក្រុមបានហៅខ្ញុំឲ្យចុះទៅធ្វើពលកម្មនឹងគេ ហើយស្វាមីខ្ញុំក៏ជំរុញឲ្យខ្ញុំទៅធ្វើការងារនឹងគេដែរ ព្រោះគាត់មិនចង់ឲ្យខ្ញុំនៅសំងំតែក្នុងផ្ទះ ។ នៅថ្ងៃដំបូង ខ្ញុំមិនទាន់ចេះកាន់កណ្តៀវច្រូតស្រូវបានត្រឹមត្រូវនៅឡើយ បណ្តាលឲ្យខ្ញុំមុតកូនដៃឈាមហូរយ៉ាងច្រើន បន្សល់ទុកនូវអនុស្សាវរីយ៍ដ៏ជូរចត់មួយរហូតដល់សព្វថ្ងៃ ។ បន្ទាប់ពីច្រូតកាត់ ខ្ញុំត្រូវទៅបញ្ជាន់ស្រូវទៀត ពេលនោះជារដូវរងា ខ្ញុំមិនមានអាវដៃវែងពាក់ឡើយ ខ្ញុំចូលក្នុងចំបើងរាល់ព្រឹក ។ ពេលបោកបែនស្រូវរួច ខ្ញុំត្រូវទៅសាបស្រូវប្រាំងម្តង ។ អង្គការឲ្យខ្ញុំទូលស្រូវដែលត្រាំទឹកទៅសាប ។ រាល់ពេលត្រឡប់ពីស្ទូងដកឬច្រូតកាត់ម្តងៗ ខ្ញុំឈឺចុកចាប់ត្រង់ចង្កេះ ។

ដើមឆ្នាំ១៩៧៦ អង្គការចាត់តាំងខ្ញុំនិងស្វាមីទៅការដ្ឋានជីកប្រឡាយលើកទំនប់នៅពងទឹក ប៉ុន្តែយើងត្រូវធ្វើការបែកគ្នា បុរសនៅរោងម្ខាង នារីត្រូវនៅរោងម្ខាងទៀតចម្ងាយប្រហែល៣០០ម៉ែត្រពីគ្នា ។ លើកដីនៅការដ្ឋានអស់រយៈពេលជិតកន្លះខែ ខ្ញុំក៏ធ្លាក់ឈាម ។ ប្រធានក្រុមអនុញ្ញាតឲ្យស្វាមីខ្ញុំយកកង់ឌុបខ្ញុំត្រឡប់មកភូមិវិញ ។ ពេលមកដល់ផ្ទះ មានអ្នកភូមិខ្លះចិត្តល្អបានជួយយកខសមកដុតភ្លើងឆ្អើរនិងព្យាបាលខ្ញុំ ។ ពេលធូរស្រាលបានបន្តិច ប្រធានក្រុមចាត់តាំងខ្ញុំឲ្យទៅធ្វើការនៅក្នុងភូមិជាមួយមនុស្សចាស់ ។ ដំបូង អង្គការចាត់ខ្ញុំឲ្យនៅក្នុងក្រុមវ័យក្មេងដែលជាកម្លាំងស្រួច ទើបខ្ញុំត្រូវទៅការដ្ឋានជីកប្រឡាយនិងលើកទំនប់ ។ ក្រោយមក អង្គការបំបែកពួកខ្ញុំឲ្យទៅ

នៅភូមិមួយទៀតគឺភូមិតាំងរលាង ។ មុនទៅនៅភូមិថ្មីមួយថ្ងៃ បងថ្លៃខ្ញុំត្រូវទៅឆ្លងទន្លេនៅពេទ្យស្អាង ហើយស្វាមីខ្ញុំដឹកគាត់ទៅពេទ្យ ។ តាំងពីពេលនោះមក ពួកយើងបាត់ដំណឹងបងថ្លៃស្រីរហូតមិនដឹងថាសុខទុក្ខយ៉ាងណា?

នៅក្នុងភូមិថ្មី អង្គការមិនជឿថាខ្ញុំមានប្ដីនិងកូនទេ ព្រោះស្វាមីខ្ញុំចាស់ជាងខ្ញុំ អង្គការចោទថាខ្ញុំលាក់កម្លាំងពលកម្ម ហើយយកខ្ញុំទៅកសាងនៅកណ្ដាលវាលស្រែ ប៉ុន្តែមានបងស្រីម្នាក់ឈ្មោះ សៀម ជាប្រធាននារីភូមិចាស់បានជួយអះអាងថា ខ្ញុំពិតជាមានប្ដីនិងមានកូនមួយដែលទើបតែស្លាប់ ។ ពេលចុះធ្វើការងារ ខ្ញុំតែងតែធ្វើបានរាល់កិច្ចការដូចជាដកស្ទូងជាដើម ។ អ្នកមូលដ្ឋានសរសើរខ្ញុំថា អ្នកភ្នំពេញចេះស្ទូងបានរហ័សដូចអ្នកស្រែ ។ ខ្ញុំចេះស្ទូងគ្រប់បែបទាំងអស់ តាំងពីស្ទូងរបៀបព័ទ្ធជុំវិញខ្លួនជាស្នែងក្របី ស្ទូងបញ្ឆិតជាចំណិតត្រសក់ និងស្ទូងតាមរបៀបមុំចង្ក្រាន ។ អ្នកមូលដ្ឋានខ្លះក៏ស្ទូងចាញ់ខ្ញុំដែរ ។ ខ្ញុំអាចដកសំណាបបានរហ័ស ដូចពួកអ្នកចាស់ ខ្ញុំចាញ់អ្នកមូលដ្ឋានត្រង់ស្ទូងអង្ករតែប៉ុណ្ណោះ បើជាន់អង្ករ អុំអង្ករ រែងអង្ករ ខ្ញុំចេះទាំងអស់ ។

នៅក្នុងឆ្នាំ១៩៧៦ ប្អូនថ្លៃស្រីរបស់បងប្រុសខ្ញុំដែលទៅធ្វើការនៅកងចល័ត ហើយមានជំងឺគ្រុនចាញ់ ត្រូវត្រឡប់មកក្រោយវិញ ។ នាងរងារញាក់ពេញមួយថ្ងៃ អ្នកមូលដ្ឋានប្រាប់ឲ្យយកម្អមដាក់ក្នុងទឹកត្នោតជូរផឹក ។ បានកន្លះខែជំងឺនាងក៏ជាសះស្បើយ ។ ដោយឃើញរូបរាងនាងធាត់ជាងមុន ប្រជាជនមូលដ្ឋានបានចោទប្រកាន់នាងថា "ខូចសីលធម៌"ជាមួយស្វាមីខ្ញុំ ។ អ្នកមូលដ្ឋានបានតាមដានពួកយើងអស់ពេលយ៉ាងយូរ ទម្រាំរឿងរ៉ាវនេះស្ងប់ស្ងាត់ទៅវិញ ។ ក្រោយមកទៀតពេលទៅស្ទូងស្រែប្រាំង ប្រធានក្រុមបានចាត់តាំងឲ្យយើងទាំងបីនាក់ធ្វើខ្ទមនៅជាមួយគ្នាទៀតដើម្បីតាមដាន ។ ក្រោយពីតាមដានមិនឃើញអ្វី ទើបអង្គការអនុញ្ញាតឲ្យពួកយើងត្រឡប់មកភូមិវិញ ។ ប្អូនថ្លៃបងខ្ញុំ ត្រូវបញ្ជូនត្រឡប់ទៅកងចល័ត ហើយខ្ញុំនិងស្វាមីធ្វើការនៅក្នុងក្រុមជាធម្មតាវិញ ។

នៅពាក់កណ្ដាលឆ្នាំ១៩៧៦ ភាពអត់ឃ្លានកាន់តែកើតមានឡើង ម្ដាយទីពីរខ្ញុំបានបន្លំបើកអង្ករពីរដង ហើយត្រូវអង្គការតាមទាន់ ។ គាត់ត្រូវយកទៅឃុំឃាំងនៅរោងមួយនៅចុងភូមិនៅ "ទួលតាំងចុង" (តាមអ្នកស្រុកនិយាយជាកន្លែង"ដាំតែអុង") ។ ពេលថ្ងៃគាត់ត្រូវចុះធ្វើការធម្មតា នៅពេលល្ងាចគាត់ត្រូវត្រឡប់ទៅនៅទួលនោះវិញ ។

មានពេលមួយនៅដើមឆ្នាំ១៩៧៧ អង្គការចាត់តាំងឲ្យពួកយើងទៅការដ្ឋានព្រៃទទឹង ឪពុកខ្ញុំក៏ទៅជាមួយដែរ ។ នៅទីនោះពួកយើងគ្មានអ្វីហូបទេ មានតែស្លឹកស្ពៅ ពួកយើងនាំគ្នាបេះយកមកស្រុះទឹកក្ដៅហូបបន្ថែមលើបបរដើម្បីឲ្យពេញក្រពះ ។ ខ្ញុំហូបរហូតដល់រាកមួល ។ មានថ្ងៃមួយ ពេលអ្នកគ្រប់គ្នាកំពុងសម្រាកថ្ងៃត្រង់ ខ្ញុំបានងើបដើរចេញពីរោងដើម្បីទៅបត់ជើងតូច ពេលត្រឡប់មកវិញ ស្រាប់តែខ្ញុំងងឹតមុខដួលទៅប៉ះនឹងស្លឹករោងព្រុសប្រាវ បណ្ដាលឲ្យភ្ញាក់ដល់អ្នកទាំងអស់គ្នាក្នុងរោង ។ ឃើញខ្ញុំសន្លប់គេក៏សែងខ្ញុំចូលក្នុងរោង ហើយជួយសង្គ្រោះតាមវិធីផ្សេងៗ ។ ពេលខ្ញុំដឹងខ្លួនវិញ ខ្ញុំឈឺគ្រប់កន្លែងទាំងអស់ ។ មីងម្នាក់ដែលជាអ្នកជិតខាងរបស់ខ្ញុំនៅទីក្រុងភ្នំពេញអាណិតខ្ញុំពេកគាត់យំ ព្រោះឃើញមុខខ្ញុំស្លេកដូចខ្មោចទៅហើយ ។ គាត់និយាយថា "ឥឡូវអស់អីហើយ" ។ គាត់សើចទាំងទឹកភ្នែក ហើយខ្ញុំតបគាត់វិញថា "ប្រហែលយមរាជមិនទាន់ត្រូវការខ្ញុំទេមើលទៅ!" អ្នកទាំងអស់គ្នានៅជុំវិញនោះក៏ផ្ទុះជាសំណើចឡើង ។

ពាក់កណ្ដាលឆ្នាំ១៩៧៧ អង្គការចាប់ផ្ដើមហៅប្រុសៗទៅរៀនសូត្រ ឬទៅធ្វើការនៅកន្លែងផ្សេងទៀត ។ អង្គការតែងតែដើរហៅមនុស្សតាមផ្ទះរាល់យប់ ។ អ្នកភូមិចាប់ផ្ដើមភ័យខ្លាចពីផែនការថ្មីនេះ ។ អ្នកដែលត្រូវអង្គការយកចេញទៅហើយមិនដែលបានត្រឡប់មកវិញទេ ។ ចំណែកកន្លែងធ្វើការរបស់ក្រុមនារីវិញ អង្គការតែងចាត់អ្នកស៊ើបការណ៍ម្នាក់ឬពីរនាក់ឲ្យបន្លំធ្វើការជាមួយ និងនិយាយលេងសើចពីនេះពីនោះដើម្បីសួរប្រវត្តិរូបពីមុន ។ នេះជាមធ្យោបាយមួយរបស់ខ្មែរក្រហមក្នុងការស្វែងរកខ្សែចង្វាក់កម្មែលមូលធននិយម ។ ដោយទុក្ខវេទនាតាមយាយីរាល់ថ្ងៃ ប្រជាជនខ្លះបានរំឭកពីភាពសប្បាយហ៊ឺហារបស់ខ្លួននៅក្នុងរបបចាស់ និងអួតប្រាប់ពីសមាសភាពរបស់ខ្លួននៅក្នុងរបបចាស់ដោយមិនដឹងខ្លួន ។ អ្នកខ្លះនិយាយភ្លេចខ្លួនយប់ឡើងកងឈ្លបបានមកហៅប្ដីយកទៅរៀនសូត្រ ឬថាឲ្យទៅបាចទឹកឬសែងពាង ។ ក៏ប៉ុន្តែអ្នកទាំងនោះសុទ្ធតែត្រូវបានបង

បណ្តើរតាមទំនប់ក្រោយភូមិទៅបាធាយ ហើយមិនដែលបានត្រឡប់មកវិញទេ ។

## ផ្លែត្របែក

ខែ៩ឆ្នាំ១៩៧៧ នៅយប់មួយ ខ្ញុំយល់សុបិនឃើញផ្លែត្របែកធំៗ ខ្ញុំក៏បេះ តែបេះមិនបានត្របែកធំធ្លាក់ទៅក្នុងទឹក ។ ព្រឹកឡើង ខ្ញុំដើរទៅធ្វើការតាមទម្លាប់ដោយមិនបានចាប់អារម្មណ៍នឹងការយល់សប្តិឡើយ ។ លុះដល់ពេលល្ងាចត្រឡប់មកវិញ ឃើញប្រធានក្រុមមកប្រាប់ឲ្យឪពុកខ្ញុំទៅប្រជុំនៅរោងបាយ ខ្ញុំក៏លួចទៅស្តាប់ការប្រជុំនោះ ។ ប្រធានភូមិបានប្រាប់អ្នកដែលមកប្រជុំឲ្យទៅរៀបចំអីវ៉ាន់ ព្រោះអង្គការនឹងយកទៅនៅកន្លែងថ្មីគឺទឹកដីថ្មី ហើយហាមមិនឲ្យយកអ្វីទៅក្រៅពីកំសៀវទឹកឡើយ សម្ភារក្រៅពីនោះអង្គការនឹងចែកឲ្យប្រើពេលទៅដល់ ។ ឪពុកខ្ញុំមកសួរខ្ញុំថា "តើកូនទៅជាមួយប៉ាទេ? បើកូនមិនទៅយើងមុខជាបែកគ្នារហូតហើយ ព្រោះដីអាពតគេមិនឲ្យយើងដើររហេតរហូតទេ" ខ្ញុំប្រាប់គាត់ថា "ប៉ាទៅណាក៏ខ្ញុំទៅជាមួយដែរ ៗ" ឪពុកខ្ញុំ ឮពាក្យខ្ញុំដូច្នេះ គាត់ត្រេកអរណាស់ ហើយគាត់ប្រញាប់ប្រញាល់នាំខ្ញុំទៅជួបប្រធានភូមិដើម្បីចុះឈ្មោះខ្ញុំនិងស្វាមីបន្ថែមទៀត ។ យើងត្រូវរៀបចំអីវ៉ាន់ភ្លាមៗដើម្បីចាកចេញ ។ ខ្ញុំបានប្រាប់ស្វាមីខ្ញុំថា "គេឲ្យយើងទៅនៅកន្លែងផ្សេងទៀត ត្រូវរៀបចំអីវ៉ាន់ពេលនេះ ហើយអង្គការមិនឲ្យយកអ្វីទៅតាមក្រៅពីកំសៀវទឹកឡើយ" ។

ស្វាមីខ្ញុំថា "កុំអាលទៅអី! ឲ្យប៉ាទៅមុនទៅ! យ៉ាងណាៗចាំយើងទៅតាមក្រោយ" ។

ខ្ញុំក៏ឆ្លើយថា "យើងត្រូវតែទៅ ព្រោះខ្ញុំបានទៅចុះឈ្មោះបន្ថែមនឹងប្រធានភូមិរួចហើយ!"

គាត់អង្វរខ្ញុំទៀតថា "កាលចេញពីភ្នំពេញ ខ្លួនឯងតាមប៉ាម្តងហើយ ខ្ញុំចង់ទៅខាងរកាកោងទៅកាន់ព្រៃកគាគង់ ព្រៃកលាបតែឯងពុំព្រម ។ ឥឡូវតាមខ្ញុំម្តងទៅយ៉ាងណាៗខ្ញុំទទួលខុសត្រូវឲ្យខ្ញុំសំពះឯងក៏ខ្ញុំព្រមដែរ" ។ ប្តីខ្ញុំនាំខ្ញុំដើររកប្រធានភូមិដើម្បីលុបឈ្មោះវិញ ប្រធានភូមិក៏ព្រមលុបឈ្មោះ ហើយនិយាយថា "មិត្តឯងទៅទីណាក៏ធ្វើស្រែដែរ មិនបាច់ទៅទេ នៅទីនេះហើយ" ។ មូលហេតុពិតប្រាកដែលប្តីខ្ញុំមិនចង់ចេញពីភូមិនោះគឺ ដោយសារគាត់ទើបតែយកនាឡិកាដៃរបស់ខ្ញុំដូរបានអង្ករ៩គីឡូក្រាម ហើយមិនចង់ឲ្យអង្គការឃើញ ខ្លាចអង្គការយកទៅវាយចោល ។ ខ្ញុំបានប្រាប់ឪពុកខ្ញុំថាមិនទៅវិញ ។

ឪពុកខ្ញុំខឹងមុខឡើងក្រហមពេលឮដូច្នេះ ហើយគាត់មិននិយាយអ្វីទាំងអស់ ។ ខ្ញុំហុចអង្ករមួយកំប៉ុងជូនគាត់ ក៏គាត់នៅតែមិនស្តីរកខ្ញុំ ។ មួយសន្ទុះក្រោយមក អង្គការមកហៅគាត់ឲ្យទៅស្នាក់នៅវត្តមួយយប់ដើម្បីចេញដំណើរនៅថ្ងៃស្អែក ។ ឪពុកខ្ញុំបារម្ភពីខ្ញុំណាស់ ខ្លាចក្រែងខ្ញុំមិនមានត្រីសាច់អ្វីញាំ ព្រោះស្វាមីខ្ញុំមិនចេះរក ។ នៅយប់នោះ គាត់និងប្រពន្ធគាត់មកគាស់ដំឡូងដែលគាត់លួចលាក់ដាំនៅទួលមួយខាងត្បូងផ្ទះ រួចគាត់ឲ្យម្តាយក្រោយខ្ញុំយកមកស្ងោរនៅខ្ទមរបស់ខ្ញុំ ។ ពេលស្ងោរដំឡូងឆ្អិន ខ្ញុំបានផ្តាំថា "ទោះបីប៉ានិងម៉ែទៅដល់ទីណា ក៏ត្រូវឲ្យដំណឹងមកខ្ញុំផង" ។ ម្តាយក្រោយខ្ញុំក៏ទទួលពាក្យ ហើយយកដំឡូងស្ងោរចេញទៅ ។ ពួកយើងក៏បែកគ្នាតាំងពីនោះមក ។

ព្រឹកឡើងខ្ញុំឃើញរទេះគោចេញពីភូមិយ៉ាងច្រើនដើម្បីដឹកអ្នកទាំងនោះទៅថ្នល់ជាតិ ។ ពេលអ្នកបររទេះគោត្រឡប់មកវិញ ខ្ញុំក៏សួរ គេប្រាប់ថាឃើញឡានមកដឹកប្រជាជនទាំងនោះចេញទៅមួយភ្លែតរួចក៏ត្រឡប់មកដឹកវិញ ហើយបន្តដឹកតទៅទៀតដូច្នេះប្រហែលជានៅជិតៗទេ មើលទៅដូចជាម៉ុំស្គន់ ។ ក្រោយពីឪពុកខ្ញុំចេញទៅបានពីរបីថ្ងៃ ស្រាប់តែខ្ញុំឃើញប្រធានក្រុមយកខោអាវចានឆ្នាំង និងកំសៀវទឹក មកចែកចាយអ្នកមូលដ្ឋានដោយប្រាប់ថាជារបស់ជយភណ្ឌបានមកពីភ្នំពេញ ។ ពេលនោះខ្ញុំឃើញក្មេងប្រុសម្នាក់នៅក្នុងភូមិពាក់អាវយឺតដូចអាវប្អូនប្រុសខ្ញុំ ខ្ញុំក៏ប្រាប់ស្វាមីខ្ញុំពីរឿងនេះ ។ ស្វាមីខ្ញុំថា"អាវមានដូចគ្នាច្រើនណាស់ កុំសង្ស័យអ្វី" ។

ពួកយើងចេះតែរង់ចាំដំណឹងពីពួកគាត់ តែបាត់ស្ងាត់សូន្យឈឹងដូចពាក្យឪពុកខ្ញុំនិយាយថា "ដីអាពត តែបែកហើយមិនងាយជួបវិញឡើយ ៗ" អ្នកខ្លះនិយាយថា គាត់ច្បាស់ជានៅចម្ការលើ ហើយមិនខ្វះអ្វីហូបទេ ។ នេះគ្រាន់តែជាពាក្យចចាមអារ៉ាមឯការពិតយើងមិនដឹងទាំងអស់គ្នា ។ អស់រយៈពេលជិតមួយឆ្នាំ អង្គការចាត់ឲ្យខ្ញុំទៅធ្វើការនៅក្នុងភូមិ ចំណែកស្វាមីខ្ញុំឲ្យទៅការដ្ឋានលើកទំនប់ដីកប្រឡាយ ។

បន្ទាប់ពីនោះខ្ញុំត្រូវទៅកាប់ព្រៃនៅវាលក្រោម«អន្លង់ធំ» ។ ពេលទៅដល់កន្លែងកាប់ព្រៃ ខ្ញុំឃើញមានឆ្អឹងខ្មោចនិងសម្ភារប្រើប្រាស់នៅក្នុងព្រៃ ហើយប្រជាជនមូលដ្ឋានបានប្រាប់ខ្ញុំថា «អ្នកដែលស្លាប់នេះគឺប្រជាជនថ្មីដែលរត់គេចពីការគ្រប់គ្រងរបស់អង្គការ» ។ សម្តីនេះបានធ្វើឲ្យខ្ញុំនឹកឃើញពីហេតុការណ៍នៅដើមឆ្នាំ១៩៧៦ ដែលប្រជាជនថ្មីមកបបួលខ្ញុំនិងស្វាមីឲ្យរត់ដែរ តែខ្ញុំមិននឹកស្មានថាអ្នកទាំងនោះត្រូវស្លាប់អស់ ។


បងថ្លៃរបស់ លឹម ស្រីផល្លា ឆ្នាំ១៩៥០,អ្នកបើកយន្តហោះ


ឪពុករបស់ លឹម ស្រីផល្លា


បងប្រុសរបស់ លឹម ស្រីផល្លា ឆ្នាំ១៩៦៨, យុវ័នភ្លេង


ប្អូនប្រុសរបស់ លឹម ស្រីផល្លា ឆ្នាំ១៩៧៤ អាយុ១៦ឆ្នាំ

មានយប់មួយ ខ្ញុំយល់សប្តិឃើញព្រលឹងខ្ញុំសុំច្បាប់ប្រធានកងសម្រាកមួយថ្ងៃដើម្បីប៉ះខោអាវ ។ ពេលកំពុងអង្គុយប៉ះខោអាវ ឪពុកខ្ញុំមកឈរនៅមុខខ្ទមខ្ញុំ គាត់មិននិយាយអ្វីទាំងអស់ទោះបីជាខ្ញុំសួរគាត់យ៉ាងម៉េចក៏គាត់មិននិយាយតបដែរ ។ ខ្ញុំអញ្ជើញគាត់ឲ្យចូលក្នុងខ្ទម ក៏គាត់មិនមាត់មិនកអ្វីឡើយ ។ ព្រលឹងខ្ញុំយំ ហើយសួរគាត់ថា«ហេតុអ្វីប៉ាមិននិយាយស្តីរកខ្ញុំ? ឬក៏ប៉ាខឹងនឹងខ្ញុំ?» ព្រលឹងខ្ញុំយំរហូតដល់ដឹងខ្លួនភ្ញាក់ឡើង ។ ខ្ញុំមិនអស់ចិត្តសោះ ហេតុអ្វីបានជាយល់សប្តិឃើញដូច្នេះ ប្រហែលជាឪពុកខ្ញុំគាត់ខឹងនឹងខ្ញុំមែនហើយ ។

ព្រឹកឡើងខ្ញុំចេញទៅកាប់ព្រៃដូចធម្មតា ប៉ុន្តែអារម្មណ៍ខ្ញុំមិនស្ងប់ ព្រោះនៅមន្ទិលពីរឿងយល់សប្តិ ។ ខ្ញុំបានរៀបរាប់ពីសុបិននេះប្រាប់មីងម្នាក់ដែលកាប់ព្រៃជាមួយគ្នា ។ ស្តាប់ហើយគាត់ពោលថា «មីងមិនចេះកាត់សប្តិទេ តែមីងសូមប្រាប់ឯងឲ្យដឹងថា គេយកអ្នកភ្នំពេញទៅសម្លាប់ចោលទាំងឡានៗ នេះតាមសម្តីកូនមីងដែលនៅជួរមុខប្រាប់ ។ តែឯងត្រូវសន្សំហ្នឹងមីង កុំនិយាយប្រាប់អ្នកណាឲ្យសោះ ប្រយ័ត្នអង្គការដឹងគេសម្លាប់មីងចោល ហើយប៉ាឯងប្រហែលជាគេយកទៅសម្លាប់ដែរហើយ!» ។ នៅពេលឮពាក្យនោះ ស្រាប់តែខ្ញុំចាប់អារម្មណ៍នឹងខោអាវដែលប្រធានក្រុមយកមកចែកប្រជាជនមូលដ្ឋាន ហើយប្រកាសប្រាប់ថាជារបស់ជយភណ្ឌ ។ យប់នោះខ្ញុំសាប់សល់គេងមិនលក់ ដោយចេះតែនឹកបារម្ភដល់ការយល់សប្តិនេះ ខ្ញុំខំបន់កុំឲ្យមានហេតុការណ៍អាក្រក់កើតឡើងឲ្យសោះ ។ ពេលកំពុងតែបន់ស្រាប់តែយាយម្នាក់ដែលនៅជាប់ខ្ទមខ្ញុំស្រែកសួរថា «មីនាងដេកលក់ហើយឬនៅ?» ។ គាត់ជាអ្នកនៅខេត្តកំពង់ឆ្នាំង ត្រូវអង្គការជម្លៀសមកមុនអ្នកភ្នំពេញប៉ុន្មានថ្ងៃ គេដាក់ឈ្មោះថា ពួក១៨ ។ គាត់សួរខ្ញុំថា «មីនាងឯងដែលបានដំណឹងអ្វីពីប៉ាឯងដែរឬទេ?» ខ្ញុំក៏តបថា «មិនដែលបានដំណឹងអ្វីទេ តែខ្ញុំយល់សប្តិ!» គាត់ក៏សួរបញ្ជាក់ «តើឯងយល់សប្តិឃើញអ្វី?» ខ្ញុំប្រាប់ពីសុបិននេះ ហើយគាត់ឆ្លើយភ្លាមមកថា «ប៉ាឯងស្លាប់ហើយ» ខ្ញុំភ្ញាក់ខ្លួនព្រើត ហើយសួរគាត់ថា «ម៉េចយាយដឹង?» «តាមចំណាំចាស់ៗពីបុរាណមកថា មនុស្សឲ្យតែបែកគ្នាហើយ យល់សប្តិឃើញមិននិយាយស្តីនោះ បញ្ជាក់ឲ្យយើងដឹងថា ពិតជាស្លាប់ហើយ» ។ ខ្ញុំអួលណែន ដើម-កនិយាយលែងចេញ ។ យាយលែងឮខ្ញុំនិយាយក៏ខំដើរមកមើលខ្ញុំ ហើយគាត់លួងលោមខ្ញុំឲ្យកាត់ចិត្តធ្វើម៉េចបើយ៉ាងនេះទៅហើយ ។

ខ្ញុំនឹកមិនអស់ចិត្ត ហេតុអ្វីបានជាអង្គការសម្លាប់មនុស្សទាំងឡានៗដូច្នេះ? តើអ្នកទាំងនោះខុសអ្វី? ការកាប់សម្លាប់របស់ខ្មែរក្រហមមកលើក្រុមគ្រួសារខ្ញុំនិងប្រជាជនស្លូតត្រង់ជាច្រើនរយគ្រួសារនៅក្នុងភូមិដែលខ្ញុំរស់នៅគួរឲ្យអាណោចអាធ័មណាស់ ។ ខ្ញុំនៅតែឆ្ងល់រហូតដល់សព្វថ្ងៃថាតើហេតុអ្វីបានជាគេសម្លាប់មនុស្សច្រើនដូច្នេះ?

ពេលស្វាមីខ្ញុំមកលេងភូមិ ខ្ញុំបាននិយាយរឿងរ៉ាវទាំងនេះ

ប្រាប់តែគាត់មិនជឿ ។ គាត់និយាយថា សម្រាប់មនុស្សច្រើនយ៉ាងនេះមានប្រយោជន៍អ្វី? បើអីចឹងគេប្រមូលពួកយើងមកពីភ្នំពេញធ្វើអ្វី? កុំជឿពាក្យគេប្រយ័ត្នអង្គការដឹង ។ ក្រោយមកពួកមូលដ្ឋានចេះតែរកលេសចាប់កំហុសពួកយើងជាប្រជាជនថ្មី តែពួកយើងប្រយ័ត្នប្រយែងមិនធ្វើអ្វីឲ្យខុសឆ្គងឡើយ ។ ពេលថ្ងៃយើងហត់នឿយនឹងការងារ ពេលយប់ភ័យព្រួយខ្លាចគេមកហៅប្រុសៗយកទៅ ។ ពេលអង្គការមកហៅមនុស្សដោយនិយាយថា «ទៅបាចទឹកស្រែ ឬសែងពាង ឬទៅរកក្របីរួច» ។

មានយប់មួយឈ្លបមកហៅខ្ញុំទៅប្រជុំនៅផ្ទះប្រធានសង្កាត់ ។ ស្វាមីខ្ញុំភ័យណាស់ គាត់ឲ្យខ្ញុំពាក់អាវឲ្យក្រាស់ បើគេវាយមិនសូវឈឺ ហើយយកក្រមាទៅតាមខ្លួនផង ។ ពេលទៅនោះមានអ្នកមូលដ្ឋានបីបួននាក់ដែរ ។ ប្រធានសង្កាត់ឲ្យពួកយើងនិយាយពីកំហុសដែលធ្វើពីដំបូង ។ ខ្ញុំមិនយល់សោះ ព្រោះមិនដឹងថាខ្លួនខុសអ្វី? ក្រោយមកគេសួរបញ្ឆក់ថា«មិត្តឯងមានដូរអ្វីទេពីថ្ងៃ?» ខ្ញុំឆ្លើយថា «មានមិត្ត ។ ខ្ញុំដូរអាវមួយបានអង្ករពីរកំប៉ុង» ប្រធានសង្កាត់នោះព្រមានថា «ក្រោយៗមិត្តឯងមិនត្រូវដោះដូរអ្វីទេ ព្រោះអង្គការមិនឲ្យមិត្តឯងដាច់ពោះស្លាប់ឯណា»? ក្រោយពីពួកយើងប្តេជ្ញាចិត្តគ្រប់ៗគ្នា ប្រធានសង្កាត់ក៏អនុញ្ញាតឲ្យខ្ញុំត្រឡប់មកខ្ទមវិញ ។

តាំងពីពេលនោះមក ទោះបីអត់យ៉ាងណាក៏ខ្ញុំមិនហ៊ានដូរដោះអ្វីទៀតដែរ ខ្ញុំដើរបេះបន្លែបន្ថែមមាន ជីស្លាបទា ត្រកួនដំឡូង... បំពេញបន្ថែមលើបបរវាវកក្តុកដើម្បីឲ្យពោះឆ្អែត ។ ក៏ប៉ុន្តែបន្លែបង្ការទាំងនោះមិនបានជួយឲ្យខ្ញុំមានកម្លាំងកំហែងឡើយ ខ្ញុំរាករាល់ថ្ងៃ ។ មានថ្ងៃមួយ ខ្ញុំត្រឡប់មកពីធ្វើការដើម្បីបើកបបរឆៀតពេលថ្ងៃត្រង់ ខ្ញុំមិនសម្រាកទេ ខ្ញុំដើរបេះជីអាចម៍មាន់ ជីស្លាបទាទុកលាយបបរពេលល្ងាចទៀត ។ ពេលត្រឡប់មកខ្ទមវិញ ខ្ញុំងងឹតមុខដួល ប៉ុន្តែប្តីខ្ញុំបានជួយសង្គ្រោះទាន់ពេលវេលា ។ បបរដែលអង្គការចែកឲ្យប្រជាជននោះគឺមួយខ្ទះខ្មៅតមានតែអង្ករ៤កំប៉ុងប៉ុណ្ណោះ ។ ដោយខ្វះជាតិសាច់ ស្ករ ធ្វើឲ្យហើមខ្លួន ខ្លះដើរមិនរួច ខ្លះហើមចេញទឹក ខ្លះទៀតឃ្លានពេករហូតដេកដាច់ខ្យល់ស្លាប់ក៏មាន ។ មនុស្សចេះតែស្លាប់ជាហូរហែ ក្នុងមួយថ្ងៃយ៉ាងហោចណាស់ក៏ពីរបីនាក់ដែរ ។

មានយប់មួយខ្ញុំចាំមិនភ្លេច ឈ្លបបានមកហៅស្វាមីខ្ញុំថា «ទៅបាចទឹក ព្រោះភ្លៀងខ្លាំងលិចស្រូវ» ។ ខ្ញុំភ័យណាស់ ព្រោះភាសានេះខ្ញុំធ្លាប់ឮ ធ្លាប់ដឹងរួចមកហើយ អ្នកដែលចេញទៅមិនបានត្រឡប់មកវិញឡើយ ។ ខ្ញុំឲ្យគាត់ពាក់អាវពីរជាន់និងយកក្រមាទៅផង ។ នៅយប់នោះ ខ្ញុំបន់ស្រន់គុណឪពុក គុណម្តាយ ព្រះពុទ្ធ ព្រះធម៌ សូមឲ្យគាត់បានត្រឡប់មកវិញ ។ នៅយប់នោះខ្ញុំរង់ចាំគាត់មិនហ៊ានគេងទេ ។ ប្រហែលពាក់កណ្តាលអធ្រាត្រទើបឃើញគាត់ត្រឡប់មកវិញ ។ គាត់ប្រាប់ខ្ញុំថា «គេសួរចម្លើយបងថាធ្លាប់ធ្វើទាហានទេ ហើយគេយកកាំភ្លើងមកឲ្យបងបាញ់សាក តែបងធ្វើជាមិនចេះបាញ់ កាន់កាំភ្លើងឆ្គង ឃើញដូច្នេះគេក៏ព្រមជឿបង ។ ចុងបញ្ចប់ប្រធានកងប្រាប់បងថា សុំចិញ្ចៀននៅដៃអូនឯង» ខ្ញុំប្រាប់គាត់ថា «យកទៅឲ្យវាចុះ ខ្ញុំមិនស្តាយទេ ឲ្យតែជីវិតរស់ ។ ចិញ្ចៀនដែលខ្ញុំពាក់ជាត្បូងទទឹមពណ៌ក្រហមល្អណាស់ ទំហំវាប្រហែលជាង១០លី ខ្ញុំពាក់ជាប់នឹងដៃមិនដែលដោះទេ ពេលស្ទូងដកត្រូវពន្លឺព្រះអាទិត្យ ពន្លឺចិញ្ចៀនដេញព្រាកៗ អ្នកណាក៏ចាប់អារម្មណ៍ដែរ ។ អ្នកមូលដ្ឋានស្រឡាញ់ចិញ្ចៀននេះណាស់ ខ្លះលួងខ្ញុំដូរដោយសន្យាថាឲ្យអង្ករមួយតៅ តែខ្ញុំមិនដូរព្រោះចិញ្ចៀននេះជាកម្លាំងញើសឈាមដែលខ្ញុំខំរកស៊ីតាំងពីនៅលីវ ។ ស្វាមីខ្ញុំក៏យកចិញ្ចៀននិងអាវរបស់ខ្ញុំមួយទៀតទៅឲ្យវា ។ តាំងពីនោះមក ប្រធានកងលែងរករឿងអ្វីទាំងអស់ ។

នៅចុងឆ្នាំ១៩៧៨ ប្រហែលខែ១០ មានប្រជាជនមកពីបូព៌ាយ៉ាងច្រើនត្រូវអង្គការបញ្ជូនមកស្នាក់នៅវត្តមេព្រីងដែលជាកន្លែងពួកកងចល័តស្នាក់នៅ ហើយកងចល័តត្រូវរំសាយមកនៅតាមផ្ទះរៀងៗខ្លួនវិញ ។ អង្គការប្រាប់ប្រជាជនថ្មីថា «បន្តិចទៀតទាំងអ្នកចាស់និងទាំងអ្នកថ្មីត្រូវទៅលើកទំនប់ទាំងអស់គ្នា ហាមដើរផ្តេសផ្តាស» ។ ខ្ញុំចេះតែឆ្ងល់ថា ហេតុអ្វីពេលនេះហើយនៅតែមានជម្លៀសមនុស្សមកពីបូព៌ាទៀត? ចម្ងល់នេះខ្ញុំបានដឹងច្បាស់បន្ទាប់ពីថ្ងៃរំដោះ៧មករា១៩៧៩ ថាពួកបូព៌ាប្រុងក្បត់ ។

ថ្ងៃទី៦ មករា ១៩៧៩ ពួកយើងត្រូវបញ្ជូនទៅច្រូតស្រូវនៅស្រែវាលលើក្បែរផ្លូវជាតិ ប៉ុន្តែអង្គការហាមមិនឲ្យយើងឡើងទៅផ្លូវជាតិទេ ។ ពេលច្រូតបានពាក់កណ្តាលព្រឹក ស្រាប់តែ

ឮស្នូរផ្ទុះ កាំភ្លើងក្តុងក្តាំង អ្នកខ្លះភ័យក្រាបក្នុងស្រែ អ្នកខ្លះស្រវាច្បូតស្រូវដាក់ក្នុងក្រមារួតរះមកខ្ទមវិញ ។ ខ្ញុំនឹកក្នុងចិត្តថា "ច្បាស់ជាមានហេតុការណ៍អ្វីកើតឡើង ហើយប្រហែលជាសភាពការណ៍ល្អប្រសើរ" ។ ពេលមកខ្ទមវិញ ខ្ញុំប្រាប់ប្តីខ្ញុំពីហេតុការណ៍នេះ គាត់ក៏ចេញពីខ្ទមឃើញយន្តហោះបាចខិត្តប័ណ្ណពាសពេញភូមិ និងវាលស្រែ ។ គាត់រើសបានក្រដាសមកអានទើបដឹងថាមានទ័ពរណសិរ្សសង្គ្រោះជាតិកម្ពុជាមករំដោះប្រជាជនស្លូតត្រង់និងឲ្យវិលត្រឡប់ទៅលំនៅដ្ឋានវិញ ។

ថ្ងៃទី៧មករា កងទ័ពវៀតណាមចូលដល់ក្រុងភ្នំពេញ ។ វិទ្យុចាប់ផ្តើមផ្សាយដំណឹងពាសពេញប្រទេស ដោយមានចាក់បទចម្រៀង "ឱ!ភ្នំពេញអើយ" ធ្វើឲ្យខ្ញុំហូរទឹកភ្នែកដោយមិនដឹងខ្លួន ។ ខ្ញុំទទូចសុំប្តីត្រឡប់ទៅស្រុកវិញជាមួយគេ ប៉ុន្តែស្វាមីខ្ញុំឃាត់ថា ចាំគាត់ស៊ើបមើលសភាពការណ៍និងរកស្រូវអង្ករទុកហូបសិន ។ មិនថាតែខ្ញុំទេ អ្នកទាំងអស់គ្នាក៏សុទ្ធតែចង់បាន ស្រូវ ស្ករត្នោតដែរ ព្រោះខានញ៉ាំផ្អែតយូរហើយ ។ យើងជាប្រជាជនថ្មីយកបានត្រឹមតែល្មមៗ រីឯអ្នកមូលដ្ឋានគេមានរទេះដឹកយកបានច្រើន ។ ខ្ញុំបានកិនស្រូវបុកអង្ករទុកដាក់ត្រៀមលក្ខណៈចេញដំណើរទៅភ្នំពេញ ។

អ្នកខ្លះចាប់ផ្តើមយកស្រូវអង្ករដូរយករបស់របរ អ្នកខ្លះធ្វើបុណ្យបញ្ជូនកុសលដល់អ្នកដែលស្លាប់ ។ ពួកយើងមានសិទ្ធិធ្វើអ្វីៗបានតាមចិត្ត ចង់ទៅណាក៏បាន ចំណែកពួកខ្មែរក្រហម ទាំងចៅសង្កាត់ យោធា បានរត់បាតដើងសព្រាត ។ ដោយឡែកប្រធានភូមិភ័យពេក ចងកសម្លាប់ខ្លួននៅលើដើមឈើមួយក្បែរផ្លូវទៅស្រះថ្មី ។

ខ្ញុំនិងស្វាមីរៀបចំចេញដំណើរមកភ្នំពេញនៅខែកុម្ភៈ ។ មុនចេញដំណើរ ខ្ញុំសុបិនឃើញបាក់ធ្មេញ ហើយហូរឈាមច្រើន តែខ្ញុំមិនចាប់អារម្មណ៍នឹងសុបិននេះទេ ពីព្រោះរវល់គិតពីរឿងចេញដំណើរ ។ ធ្វើដំណើរទៅដល់ស្ពានបាក់(ស្ពានត្រស់) កាត់តាមវាលស្រែ ខ្ញុំបានជួបអ្នកភូមិដែលត្រឡប់មកពីបាត់ដំបងបានប្រាប់ដំណឹងខ្ញុំថា បងប្រុសខ្ញុំស្លាប់ ចំណែកប្អូនស្រីខ្ញុំធ្វើដំណើទៅខេត្តសៀមរាបជាមួយម្តាយមីងខ្ញុំ ហើយប្តីរបស់ប្អូនស្រីខ្ញុំត្រូវខ្មែរក្រហមយកទៅសម្លាប់តាំងពីឆ្នាំ១៩៧៧ ។

ក្រោយពីទទួលដំណឹងអាក្រក់នេះ ខ្ញុំគ្មានអារម្មណ៍ចង់ទៅភ្នំពេញទៀតទេ ពីព្រោះគោលបំណងធំបំផុតដែលខ្ញុំទៅភ្នំពេញគឺដើម្បីជួបជុំបងប្អូន ។ ខ្ញុំតូចចិត្តនឹងវាសនារបស់ខ្លួនណាស់ ប្តីខ្ញុំចេះតែលួងលោមខ្ញុំថា អ្នកណាក៏ដូចជាអ្នកណាដែរសុទ្ធតែជួបប្រទះការព្រាត់ស្លាប់ព្រាត់រស់ដូចតែគ្នាទេ ។ យើងក៏បន្តដំណើរទៅមុខទៀតរហូតដល់កំពង់ចម្លងព្រែកក្តាមនិងធ្វើដំណើរតាមផ្លូវជាតិលេខ៥មកភ្នំពេញវិញ ។ ខ្ញុំនិងស្វាមីស្នាក់នៅគីឡូម៉ែត្រលេខ៧មួយរយៈ រួចពួកយើងបានចុះឈ្មោះក្នុងបញ្ជីស្ថិតិ ហើយប្រាប់ថាចង់ចូលធ្វើការនៅក្នុងក្រុង ដោយប្រាប់ពីមុខជំនាញរបស់យើងដើម្បីដាក់ក្នុងប្រវត្តិរូប ។

ក្នុងរយៈពេលស្នាក់នៅ យើងទាំងអស់គ្នាលួចចូលក្នុងក្រុងយកបានអីវ៉ាន់ ដូចជាកាំកង់ ដុំកង់ ឈ្នាន់កង់ សំបកកង់ ឬរបស់របរផ្សេងៗយកមកដូរយកអង្ករពីអ្នកស្រែ ។ មានថ្ងៃមួយ ខ្ញុំនិងប្អូនថ្លៃស្រី បងប្រុសរបស់ខ្ញុំ នាំគ្នាដើរទៅដល់ផ្សារតូចយកបានបាវក្រចៅម្នាក់បានប្រហែលដប់ ។ ប៉ុន្តែពេលចេញមកវិញ ត្រូវកងទ័ពវៀតណាមសម្គុតបាញ់កាំភ្លើងឡើងលើមួយគ្រាប់ដើម្បីបំបាក់ស្មារតី ។ ពួកយើងក៏នាំគ្នាចេញមកវិញដោយមិនបានយករបស់អ្វីសោះ ។ យើងបានត្រឹមតែរអ៊ូព្រោះធ្វើអ្វីអ្នកទាំងនោះមិនបាន ។

ខ្ញុំស្នាក់នៅគីឡូម៉ែត្រលេខ៧អស់រយៈពេលយ៉ាងយូរ ខ្ញុំយកម្សៅមីធ្វើនំប៉ោងលក់ (ដៃខ្ញុំនៅស្នាមដល់សព្វថ្ងៃព្រោះរលាកខ្លាញ់ពេលស្រង់នំ) ។ ខ្ញុំសន្សំបានអង្ករជាច្រើនបាវ ។ មានថ្ងៃមួយ ខ្ញុំបានជួបប្អូនស្រីជីដូនមួយខាងឪពុក វាបានប្រាប់ខ្ញុំថា បងប្រុសខ្ញុំត្រូវអង្គការយកទៅឃុំឃាំងនៅលើភ្នំក្នុងស្រុកតំបែនិងសម្លាប់ចោលជាមួយអ្នកទោសដទៃទៀតបីថ្ងៃមុនពេលកងទ័ពវៀតណាមចូលដល់ ហើយខ្មែរក្រហមទាំងអស់នោះនាំគ្នាភៀសខ្លួនចេញពីតំបន់នោះអស់ ប៉ុន្តែក្រោយមកទៀតខ្មែរក្រហមចូលមកដុតភូមិនោះខ្ទេចអស់ ។ ចំណែកគ្រួសារខាងប្រពន្ធបងប្រុសខ្ញុំមិនដឹងជាយ៉ាងណាទេ (តាមសម្តីប្អូនជីដូនមួយខ្ញុំនិយាយថាមានច្រើនគ្រួសារខាងឪពុកខ្ញុំបានបាត់ដំណឹងនៅស្រុកតំបែ) ។

ដោយឈឺចិត្តពេក ខ្ញុំក៏បបួលស្វាមីខ្ញុំភៀសខ្លួនទៅទល់ដែនកម្ពុជា-ថៃ ប៉ុន្តែស្វាមីខ្ញុំបដិសេធ ។ ចំណែកប្អូនស្រីជីដូនមួយខ្ញុំ

ធ្វើដំណើរទៅប្រទេសវៀតណាមជាមួយឪពុកដើម្បីរកមធ្យោបាយចេញទៅប្រទេសទី៣ ។

មានថ្ងៃមួយបងប្រុសជីដូនមួយរបស់ខ្ញុំបានឆ្លងពីត្រើយម្ខាង(ព្រែកលាប)មករកខ្ញុំ ។ ពួកយើងរៀបរាប់ពីរឿងរ៉ាវប្រាប់គ្នាទៅវិញទៅមក ។ គាត់នៅសល់បងប្អូន៤នាក់ សព្វថ្ងៃគាត់បើកអាហារដ្ឋានមួយនៅព្រែកលាបឈ្មោះថា "ម្ជប់ស្វាយធំថ្មី" ។ ខ្ញុំនៅតែទទូចចង់ចេញទៅប្រទេសទី៣នឹងគេ ប៉ុន្តែត្រូវស្វាមីខ្ញុំឃាត់រហូត ។

ថ្ងៃមួយក្នុងខែមីនា ឆ្នាំ១៩៧៩ ស្វាមីខ្ញុំបានជួបនឹងអ្នកកាសែតបរទេសម្នាក់ ហើយនិយាយគ្នាយ៉ាងយូរ អ្នកកាសែតបរទេសបានសុំថតរូបខ្ញុំដោយឲ្យខ្ញុំកាន់រូបថតពីជំនាន់មុនទៅផ្សាយរកបងប្អូននៅក្រៅប្រទេស ។ នៅក្នុងខែដដែលស្វាមីខ្ញុំត្រូវបានអញ្ជើញឲ្យទៅធ្វើការ ហើយគាត់ត្រូវសាលាក្រុងចាត់តាំងឲ្យធ្វើជាប្រធានមន្ទីរសាធារណការក្រុង ។

ខ្ញុំរស់នៅជាយក្រុងប្រកបមុខរបរដូរអង្ករ ស្ករ ខ្ទឹម ម្រេច និងប៊ីចេង ។ នៅខែឧសភា វៀតណាមយករថយន្តមកដឹកខ្ញុំចូលទីក្រុង មកស្នាក់នៅផ្ទះមួយដែលផ្ទះនោះនៅមុខមន្ទីរសាធារណការក្រុងជាផ្ទះខ្ញុំកំពុងរស់នៅសព្វថ្ងៃក្នុងសង្កាត់វត្តភ្នំ ។

ដំបូង គេឲ្យខ្ញុំបោសសំរាមពីវត្តភ្នំរហូតដល់វិមានឯករាជ្យ និងពីមុខស្ថានីយរថភ្លើងទៅដល់ផ្ទុំពេទ្យចិន ។ ខែមិថុនា វៀតណាមចាត់តាំងឲ្យខ្ញុំធ្វើជាគ្រូបង្រៀនកូនចៅបុគ្គលិកកម្មករទាំងអស់ក្នុងមន្ទីរ ។ នៅខែសីហា មន្ទីរអប់រំបានប្រមូលគ្រូនិងសិស្សទាំងអស់ឲ្យនៅក្រោមឱវាទរបស់មន្ទីរអប់រំរដ្ឋធានីភ្នំពេញ ដោយមាននាយិកាម្នាក់ឈ្មោះ ស សាអ៊ី ។ នៅខែតុលា ខ្ញុំត្រូវបញ្ជូនទៅរៀនសូត្រផ្នែកបច្ចេកទេសនិងនយោបាយ ។ រយៈពេលខ្ញុំកំពុងរៀន ពួកខ្ញុំបានចុះទស្សនកិច្ចព្រះបរមរាជវាំង និងគុកទួលស្លែង (មន្ទីរស-២១) ។ ដំបូងខ្ញុំមើលមិនស្គាល់គុកទួលស្លែងថាជាអតីតវិទ្យាល័យផង ពីព្រោះបរិវេណវិទ្យាល័យនេះព័ទ្ធជុំជិតដោយស័ង្កសីនិងបន្លាលួស ។ ចូលដល់ខាងក្នុងបរិវេណ ខ្ញុំឃើញអគារបួននិងអគារមួយតូចទាបនៅកណ្តាលឆៀងខាងត្បូង ធ្វើឲ្យខ្ញុំនឹកឃើញថា "ហាក់ដូចជាវិទ្យាល័យពញាយ៉ាតដែលខ្ញុំធ្លាប់រៀន" ពេលនោះអ្នកនាំភ្ញៀវបានប្រាប់ថា "ទីនេះជាវិទ្យាល័យពញាយ៉ាត ខ្មែរក្រហមយកកន្លែងនេះធ្វើជាគុកឃុំឃាំងអ្នកទោសដែលសុទ្ធតែជាប្រជាជន កសិករ កម្មករ និស្សិត បញ្ញវន្ត និងកម្មាភិបាល" ។ ខ្ញុំឃើញឈាមជិតដាមនៅលើក្រឡាឥដ្ឋ ដញ្ញាំង និងសាកសពចំនួនប្រាំបួននាក់ដែលខ្មែរក្រហមសម្លាប់មុនពេលចាកចេញ ។ បន្ទាប់មកខ្ញុំដើរមើលអគារ "សេ" និង "ដេ" ដែលមានខណ្ឌដោយឥដ្ឋជាបន្ទប់តូចៗសម្រាប់ដាក់មនុស្សម្នាក់ដោយមិនអាចងាកចុះឡើងបាន ។ ក្រោយមកយើងមកជុំគ្នានៅបន្ទប់ធំមួយនៅអគារ "បេ" ពេលនោះលោក អ៊ីង ប៊ុច គាត់បានរៀបរាប់ពីទុក្ខវេទនារបស់អ្នកទោសនៅគុកទួលស្លែងរួមទាំងខ្លួនគាត់ផង ។

ក្រោយពីរៀនសូត្រវគ្គគរុកោសល្យនិងនយោបាយចប់ ខ្ញុំបានចូលបម្រើការជាគ្រូបង្រៀនសិស្សថ្នាក់ទី២និងទី៣រយៈពេលមួយឆ្នាំសិក្សា និងបន្តអាជីពជាគ្រូបង្រៀនរហូតមកដល់បច្ចុប្បន្ន ។ ចំណែកស្វាមីខ្ញុំជាមន្ត្រីចូលនិវត្តន៍ ។

រឿងរ៉ាវឈឺចាប់ទាំងប៉ុន្មាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យធ្វើឲ្យខ្ញុំមិនអាចបំភ្លេចបានឡើយ ។ ខ្ញុំនៅចាំសម្តីរបស់ជីដូនខ្ញុំថា "*ចៅឯងត្រូវរៀនសន្សំសំចៃរបស់របរប្រើប្រាស់ក៏ដោយអំបិលប្រហុកក៏ដោយ ថ្ងៃក្រោយអំបិលប្រហុកថ្លៃជាងមាសទៅទៀត បាយមួយគ្រាប់ជាប់កន្ទុយឆ្កែក៏ដណ្តើមគ្នាដែរ ។ មានផ្ទះអត់មនុស្សនៅ មានផ្លូវអត់មនុស្សដើរ ស្ត្រីបាត់លក្ខណា សាសនាបាត់បង់ ត្រូវចេះទុកដាក់កុំខ្ជះខ្ជាយឲ្យសោះ*" ។ ពាក្យទាំងអស់នេះត្រូវឥតខ្ចោះនៅក្នុងរបបប្រល័យពូជសាសន៍ ។ ដួនពេលខ្វះមាសដូរយកអំបិលមិនបានផង ស្ត្រីហូបចុកមិនគ្រប់គ្រាន់រាំងរដូវសារពាង្គកាយស្គមស្គាំងមើលសឹងមិនដឹងថា ប្រុស ឬស្រី ។ ខ្មែរក្រហមបំបាត់សាសនា វាយបំបាក់ព្រះពុទ្ធបដិមារំលាយវត្តអារាម បំបាត់សិល្បៈដែលជាព្រលឹងរបស់ជាតិខ្មែរ ។ ទីក្រុងបានក្លាយទៅជាទីរហោឋាន មនុស្សត្រូវបានបង្ខំឲ្យធ្វើការដូចជាទាសករដាច់ថ្លៃដោយផ្តល់របបអាហារតិចតួចបំផុតបណ្តាលមនុស្សស្លាប់ជាច្រើន និងត្រូវសម្លាប់ស្ទើរផុតពូជខ្មែរ ។

ខ្ញុំនៅតែឆ្ងល់ក្នុងចិត្តរហូតដល់សព្វថ្ងៃ ហេតុអ្វីក៏ខ្មែរយើងធ្វើដូច្នេះមកលើពូជសាសន៍ខ្លួនឯង? ព្រោះការកាប់សម្លាប់នេះគ្មានបរទេសណាមកកាប់សម្លាប់ទេគឺខ្មែរសម្លាប់ខ្មែរ ។ តើអ្នកណាជាអ្នកបង្កឡើង?

### ក្រោយឆ្នាំ១៩៧៩

ការដែលខ្ញុំសរសេររៀបរាប់ខាងលើមកនេះ គ្រាន់តែចង់បញ្ជាក់ប្រាប់ពិភពលោកទាំងមូលនិងតុលាការដើម្បីផ្តល់ភាពយុត្តិ-ធម៌ដល់ជនរងគ្រោះ ដែលបានស្លាប់និងកំពុងនៅរស់សព្វថ្ងៃនេះ ហើយសង្ឃឹមថាជនដៃដល់និងអ្នកបញ្ជាឲ្យចេះទទួលស្គាល់កំហុសដែលខ្លួនបានប្រព្រឹត្តនឹងចេញមុខសារភាពចំពោះមុខមហាជន ។ ចំពោះរូបខ្ញុំក៏ដូចជាប្រជាពលរដ្ឋទាំងអស់ សំណូមពរដល់អង្គជំនុំជម្រះក្តីមេត្តាផ្តល់នូវភាពយុត្តិធម៌សម្រាប់មនុស្សជាតិដែលរស់នៅលើទឹកដីកម្ពុជា និងអ្នកដែលបានស្លាប់ទៅដោយគ្មានកំហុសយ៉ាងឃោរឃៅបំផុត ។

**លឹម ស្រីផល្លា**

# ដំណឹងស្វែងរកបងស្រី និងបងថ្លៃ

នាងខ្ញុំ យូ សៀមអេង ភេទស្រី អាយុ៥៨ឆ្នាំ ពីមុនរស់នៅភូមិខ្សា ឃុំដា ស្រុកក្រចេះ ខេត្តក្រចេះ បច្ចុប្បន្នរស់នៅភូមិខាងជើងស្ទឹង ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ។ ឪពុកឈ្មោះ យូ ប៉េងស៊ា និងម្តាយឈ្មោះ វ៉ាន់ សាវុន សូមស្វែងរកបងស្រីឈ្មោះ យូ សៀមចេង និងបងថ្លៃ ជឹង ហាំងវេង ។ មុនឆ្នាំ១៩៧៥ បងស្រីនិងបងថ្លៃរស់នៅទីក្រុងភ្នំពេញ អ្នកទាំងពីរត្រូវអង្គការជម្លៀសទៅខេត្តបាត់ដំបង ។ ក្រោយមកឮដំណឹងថាបងថ្លៃស្លាប់ នៅរស់តែបងស្រីនិងកូន ។ នៅឆ្នាំ១៩៧៩ បានឮដំណឹងថាបងស្រីរស់នៅទីកថ្វាក្រុងភ្នំពេញ ។ ប៉ុន្តែចាប់តាំងពីនោះមក នាងខ្ញុំពុំដែលបានទទួលដំណឹងពីគាត់ទៀតឡើយ ។

ដូច្នេះបើបងស្រី ឬបងប្អូនបានស្គាល់ឈ្មោះខាងលើនេះ សូមជួយទាក់ទងមកតាមអសយដ្ឋានខាងលើកុំបីខាន ។ សូមអរគុណ ។

# ដំណឹងស្វែងរកបងស្រី និងបងប្រុស

នាងខ្ញុំឈ្មោះ ឈុន រុំ អាយុ៥៣ឆ្នាំ រស់នៅភូមិមមាញ ឃុំរលួស ស្រុកប្រាសាទបាគង ខេត្តសៀមរាម មានបងប្អូន៥នាក់ ។ ឪពុកឈ្មោះ ឈុន ផម និងម្តាយឈ្មោះ យុន រឿន ។ នាងខ្ញុំសូមស្វែងរក ៖ ១) បងស្រី ឈុន រ៉ែន និងប្តី (ជាប្អូនបង្កើតរបស់អ្នកចម្រៀងឈ្មោះ មាស សាម៉ន) ជាអតីតទាហានអាម៉ារីនមុនឆ្នាំ១៩៧៥ អ្នកទាំងពីររស់នៅទីក្រុងភ្នំពេញ ហើយបាត់ដំណឹងតាំងពីពេលអង្គការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ ២) បងប្រុស ឈុន រៀន ដែលបានចេញទៅបម្រើកងទ័ពរំដោះនៅឆ្នាំ១៩៧២ ហើយក៏បាត់ដំណឹងរហូត ។ មុនឡើងរថយន្តចាកចេញពីភូមិជាមួយយុទ្ធជនដទៃទៀត រៀនបានផ្ញើសំបុត្រមួយច្បាប់ប្រាប់ក្រុមគ្រួសារថាខ្លួនចាកចេញពីភូមិហើយ ហើយឲ្យក្រុមគ្រួសារទៅយកកង់របស់ខ្លួនពីកន្លែងហ៊ីកហាត់នៅជិតមន្ទីរឃុំ ។

ដូច្នេះបើបងប្រុសនិងបងស្រីបានឮឬបានអានសេចក្តីប្រកាសនេះសូមរកប្អូនតាមអាសយដ្ឋានខាងលើកុំខាន ។ សូមអរគុណ ។

## ដំណឹងស្វែងរកកូនប្រុសឈ្មោះ ហេង ហួយ

ខ្ញុំបាទឈ្មោះ គីម ហេង អាយុ៨៣ឆ្នាំ បច្ចុប្បន្នរស់នៅភូមិតាត្រាវ ឃុំស្វាយចេក ស្រុកអង្គរធំ ខេត្តសៀមរាប សូមស្វែងរកកូនប្រុសឈ្មោះ ហេង ហួយ ដែលបានបាត់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ហួយ បានឈប់រៀនត្រឹម ថ្នាក់ទី១២ ដើម្បីចូលបម្រើបដិវត្តន៍ ។ នៅឆ្នាំ១៩៧៥ ហួយ ត្រូវអង្គការបញ្ជូនឲ្យទៅភ្នំពេញ ធ្វើការនៅតាមផ្លូវជាតិលេខ៦ និងបន្ទាប់មក ហួយត្រូវបានផ្លាស់ឲ្យមកធ្វើការនៅខេត្តសៀមរាប ហើយក៏បាត់ដំណឹងរហូតមក ។

ប្រសិនបើបងប្អូនណាបានឮដំណឹងអំពីឈ្មោះនេះសូមមេត្តាជួយផ្តល់ព័ត៌មានមកនាងខ្ញុំតាមអាសយដ្ឋានដូចបានរៀបរាប់ខាងលើ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកបងប្រុស និងបងស្រី

បន្ទាប់ពីខ្ញុំបានអានព័ត៌មាននិងបានដឹងថាអង្គការរបស់លោកជួយស្វែងរកសមាជិកគ្រួសារដែលបានបាត់ខ្លួន នាងស្នើសុំឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាជួយស្វែងរកបងប្រុសនិងបងស្រីរបស់ខ្ញុំដែលបានបែកពីខ្ញុំនៅក្នុងឆ្នាំ១៩៧៥ ។


ណាអូមិ ហាមម័រស្ទី

ខ្ញុំនិងបងស្រីភ្លោះរបស់ខ្ញុំ កើតក្នុងខែមករា ឆ្នាំ១៩៧៥ នៅក្នុងទីក្រុងភ្នំពេញ ។ មួយសប្តាហ៍ក្រោយ យើងទាំងពីរត្រូវបានបញ្ជូនទៅកាន់មណ្ឌលកុមារកំព្រានៅទីក្រុងភ្នំពេញដែលមានឈ្មោះថា ផ្ទះកាណាដា ។ នៅក្នុងខែមីនា ឆ្នាំ១៩៧៥ យើងទាំងពីរត្រូវបានគ្រួសារជនជាតិកាណាដាមួយ យកទៅចិញ្ចឹមនៅប្រទេសកាណាដា ។ សព្វថ្ងៃយើងខ្ញុំទាំងពីរនាក់កំពុងតែស្វែងរកព័ត៌មានស្តីពីបងប្រុស និងបងស្រីដែលត្រូវបានទុកចោលនៅទីក្រុងភ្នំពេញ ។

យើងខ្ញុំទាំងពីរពុំដឹងថាឪពុកម្តាយបងប្អូនរបស់ខ្ញុំមានឈ្មោះអ្វីខ្លះ និងក៏ពុំដឹងថាយើងទាំងពីរនាក់កើតនៅទីណានោះទេ ។ យើងខ្ញុំទាំងពីរនាក់គ្រាន់តែដឹងព័ត៌មានបន្តិចបន្តួចពីស្ត្រីជនជាតិកាណាដាដែលបម្រើការនៅមណ្ឌលកុមារកំព្រាតែប៉ុណ្ណោះ ។

ឪពុករបស់យើងខ្ញុំទាំងពីរនាក់ បានស្លាប់នៅមុនពេលដែលយើងទាំងពីរនាក់កើតមកម្ល៉េះ ហើយគាត់ទំនងជាទាហាន លន់ នល់ ។ បន្ទាប់ពីម្តាយរបស់ខ្ញុំបានផ្តល់កំណើតឲ្យយើងទាំងពីរនាក់នៅក្នុងឆ្នាំ១៩៧៥មក សុខភាពរបស់គាត់បានចុះទន់ខ្សោយដោយសារតែកង្វះអាហារបរិភោគ និងធ្វើឲ្យគាត់មិនអាចចិញ្ចឹមបីបាច់យើងទាំងពីរបាន ។ បន្ទាប់ពីបុគ្គលិកមណ្ឌលកុមារកំព្រាទទួលបានព័ត៌មានអំពីខ្ញុំទាំងពីរ ពួកគេបានស្វែងរកយើងរហូតបានប្រទះឃើញយើងនៅដេកលើគំនរសំរាមនៅក្នុងខ្ទមមួយ ។ បន្ទាប់មកក៏បាននាំយើងទាំងពីរទៅកាន់ផ្ទះកាណាដា និងយកម្តាយរបស់ខ្ញុំទៅសាលាសំណាក់ ។ បងស្រីខ្ញុំមានអាយុប្រហែល១៨ឆ្នាំ ធ្វើការនៅមណ្ឌលកុមារកំព្រា ហើយបងប្រុសខ្ញុំមានអាយុប្រហែល៧ឆ្នាំស្នាក់នៅជាមួយម្តាយ ។

នៅក្នុងផ្ទះកាណាដា មានកុមារកំព្រាចំនួន៤០នាក់ និងបុគ្គលិកខ្មែរប្រហែល១០នាក់ឬ១៥នាក់មើលថែរក្សាកុមារទាំងនោះ ។ ក្រោយមក កុមារទាំងនោះត្រូវបានយកទៅចិញ្ចឹមនៅប្រទេសកាណាដា ។ ផ្ទះកាណាដានេះ រៀបចំឡើងដោយស្ត្រីជនជាតិកាណាដាជាច្រើននាក់ ។ លោក ស្រី ណាអូមិ ប្រុណស្តេន បានធ្វើដំណើរចុះឡើងពីកម្ពុជាទៅកាណាដាក្នុងការចាត់ចែងការទទួលយកក្មេងទៅចិញ្ចឹម ចំណែកលោកស្រី ដុល្លី ឆារ៉េត និង អាណា ឆារ៉េត ជាអ្នកមើលថែរក្សាកុមារកំព្រាទាំងនោះ ។

ទោះបីជាយើងខ្ញុំទាំងពីរនាក់ពុំមានព័ត៌មានលម្អិតច្រើនស្តីអំពីក្រុមគ្រួសាររបស់ខ្ញុំយ៉ាងណាក៏ដោយ ខ្ញុំសង្ឃឹមថា សារតាររបស់ខ្ញុំ និងផ្ទះកាណាដានេះ អាចផ្តល់ព័ត៌មានគ្រប់គ្រាន់សម្រាប់បងប្អូន ដែលបានដឹងដំណឹងអំពីបងប្រុស និងបងស្រីរបស់យើងទាំងពីរនាក់ ។ ខ្ញុំសូមថ្លែងអំណរគុណទុកជាមុនដល់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការជួយជ្រោមជ្រែងស្វែងរកព័ត៌មានបន្ថែមស្តីអំពីគ្រួសាររបស់យើងខ្ញុំទាំងពីរនាក់ និងអាចជួយធ្វើឲ្យយើងទាំងពីរនាក់ជួបជុំគ្រួសារវិញ ។

**ណាអូមិ ហាមម័រស្ទី**


បងស្រីរបស់ ណាអូមិ ហាមម័រស្ទី នៅផ្ទះកាណាដា




ឯកសារមួយនេះ និងឯកសារដែលនៅសេសសល់ដទៃទៀតបង្ហាញអំពីព័ត៌មានជាច្រើនអំពីរបបកម្ពុជាប្រជាធិបតេយ្យ ។ ឯកសារទាំងនេះ បានឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីរបៀបនិងមូលហេតុដែលប្រជាជនជាច្រើនបានស្លាប់បាត់បង់ជីវិត ។ នៅក្នុងន័យនេះ ឯកសារនីមួយៗតំណាងឲ្យជីវិតរបស់ប្រជាជនកម្ពុជាម្នាក់ដែលស្លាប់នៅក្នុងរបបខ្មែរក្រហម ។ មានឯកសាររបៀបនេះរាប់លានសន្លឹក ។

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 88, April 2007 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.